ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់

វិមជ្ឈការ និងវិសហមជ្ឈការ

# ផែនការសកម្មភាព និងថវិកា

# ឆ្នាំ ២០០៨

មេសា ២០០៨

## បុព្វកថា

ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ ២០០៨ របស់គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ (គ.ជ.វ.វ) ត្រូវបានរៀបចំបញ្ចប់ស្របពេលជាមួយនឹងការអនុម័តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដោយគណៈរដ្ឋមន្ត្រី ហើយត្រូវបានដាក់ជូនរដ្ឋសភា ដើម្បីធ្វើការពិនិត្យឡើងវិញ និងអនុម័ត ។ ការអនុម័តច្បាប់រៀបចំអង្គការ ដែលបានរៀបចំជាច្រើនឆ្នាំកន្លងមកនេះ តាមរយៈការជជែក និងពិភាក្សាយ៉ាងយកចិត្តទុកដាក់ នឹងបើកឡើងនូវទំព័រជាប្រវត្តិសាស្ត្រថ្មីមួយប្រកបដោយថាមពលនៃកិច្ចខិតខំប្រឹងប្រែងនានារបស់រាជរដ្ឋាភិបាល ក្នុងការពង្រឹងកិច្ចអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលទាមទារឱ្យមានការយកចិត្តទុកដាក់ពីសំណាក់គ្រប់មជ្ឈដ្ឋានក្នុងរាជរដ្ឋាភិបាលទាំងមូល ។

ដូច្នេះនៅក្នុងឆ្នាំ ២០០៨ គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ នឹងត្រូវបំពេញភារកិច្ចដ៏ធំធេងមួយ ដែលអាចបែងចែកជា ០៣ ផ្នែកសំខាន់ៗដូចខាងក្រោម :

### ១. ការរៀបចំតាក់តែងសេចក្តីណែនាំ និងលិខិតបទដ្ឋាននានាសម្រាប់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ

ច្បាប់រៀបចំអង្គការ នឹងតម្រូវឱ្យមានការបង្កើតគណៈកម្មាធិការជាតិមួយទទួលបន្ទុកកិច្ចអភិវឌ្ឍន៍បែបប្រជាធិបតេយ្យ ដែលមានភារកិច្ចសំខាន់ក្នុងការអភិវឌ្ឍន៍លិខិតបទដ្ឋានចាំបាច់នានានៅថ្នាក់ក្រោមជាតិសម្រាប់ការអនុវត្តច្បាប់រៀបចំអង្គការ ដោយរួមទាំងការរៀបចំតាក់តែងនូវគោលនយោបាយ និងប្រព័ន្ធនានាផងដែរ ។ ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិថ្មីទាំងឡាយនឹងត្រូវបង្កើតយ៉ាងយូរបំផុតក្នុងរយៈពេលមួយឆ្នាំ បន្ទាប់ពីច្បាប់រៀបចំអង្គការត្រូវបានចូលជាធរមាន ។ ដូច្នេះ នឹងមានការងារជាច្រើន សម្រាប់អនុវត្តនៅក្នុងឆ្នាំ ២០០៨ ដែលពាក់ព័ន្ធនឹងការរៀបចំលិខិតបទដ្ឋាន សេចក្តីណែនាំ និងកម្មវិធីបណ្តុះបណ្តាលនានា ដើម្បីឱ្យក្រុមប្រឹក្សាទាំងអស់អាចបំពេញមុខងារ និងការទទួលខុសត្រូវរបស់ខ្លួននៅក្នុងឆ្នាំ ២០០៩ ។

### ២. ការរៀបចំកម្មវិធីជាតិស្តីពីការអភិវឌ្ឍន៍បែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

ផ្អែកលើកិច្ចព្រមព្រៀងជាមួយដៃគូអភិវឌ្ឍន៍នានារបស់កម្ពុជា និងស្ថិតក្រោមសិទ្ធិអំណាចរបស់ គ.ជ.វ.វ ការរៀបចំកម្មវិធីជាតិមួយស្តីពីការអភិវឌ្ឍន៍បែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ នឹងត្រូវចាប់ផ្តើមនៅពាក់កណ្តាលឆ្នាំ ២០០៨ និងត្រូវបញ្ចប់នៅត្រីមាសទីមួយនៃឆ្នាំ ២០០៩ ។ ការរៀបចំកម្មវិធីជាតិនេះ នឹងរួមបញ្ចូលនូវយុទ្ធសាស្ត្រ និងកម្មវិធីអនុវត្តន៍មួយមានរយៈពេល ១០ ឆ្នាំ ដែលអាចឱ្យរាជរដ្ឋាភិបាលសម្រេចបាននូវវឌ្ឍនភាពសំខាន់ៗ ឈានឆ្ពោះទៅរកចក្ខុវិស័យជាយុទ្ធសាស្ត្រនៃវិមជ្ឈការ និងវិសហមជ្ឈការរបស់ខ្លួន ។ កម្មវិធីជាតិ គឺជាផែនការអនុវត្តន៍បែបអន្តរកម្មមួយ ដែលមានសារៈសំខាន់សម្រាប់ការប្រើ និងផ្តល់ផលប្រយោជន៍ដល់រាជរដ្ឋាភិបាល និងក្រសួង

ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិនានា ។ កម្មវិធីនេះ ក៏នឹងផ្តល់លទ្ធភាពដល់ដៃគូអភិវឌ្ឍន៍នានា ដែលរួមមានទីភ្នាក់ងារជាតិ និងអង្គការមិនមែនរដ្ឋាភិបាលទាំងឡាយ ក្នុងការឯកភាពលើយុទ្ធសាស្ត្ររួមនានា និងវិធីសាស្ត្រទាំងឡាយដែលមានលក្ខណៈសុខដុមនីយកម្ម ដើម្បីគាំទ្ររាជរដ្ឋាភិបាលក្នុងការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការផងដែរ ។

## ៣. ការអនុវត្តផែនការសកម្មភាព និងថវិកាឆ្នាំ ២០០៨ របស់ គ.ជ.វ.វ

ជាមួយនឹងការផ្តោតការយកចិត្តទុកដាក់លើការរៀបចំលិខិតបទដ្ឋានដំបូងនានា និងការរៀបចំកម្មវិធីជាតិ គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ក៏នឹងត្រូវផ្តោតការយកចិត្តទុកដាក់ផងដែរ លើការសម្របសម្រួលដល់ការអនុវត្តផែនការសកម្មភាព និងថវិកាឆ្នាំ ២០០៨ ដូចមានរៀបរាប់ក្នុង ឯកសារនេះ ។

នៅក្នុងឆ្នាំ ២០០៨ ធនធានសរុបដែលបានកៀរគរក្រោមក្របខ័ណ្ឌ គ.ជ.វ.វ មានចំនួនជិត ៧៨ លានដុល្លារ ដែលក្នុងនោះទឹកប្រាក់ចំនួនប្រមាណជាង ៧០.៥ លានដុល្លារ ត្រូវបានផ្ទេរមកគណនីរដ្ឋាភិបាល និងចំនួនប្រមាណ ៧.៤ លានដុល្លារ ត្រូវបានគ្រប់គ្រង ចាត់ចែងដោយដៃគូអភិវឌ្ឍន៍ផ្ទាល់ ដោយផ្តោតសំខាន់ទៅលើជំនួយបច្ចេកទេស ។ រាជរដ្ឋាភិបាលបានចូលរួមបដិភាគចំនួនជិត ២៣ លានដុល្លារ ស្មើនឹង ៣០%នៃធនធានសរុបចំណែកឯការចូលរួមរបស់ដៃគូអភិវឌ្ឍន៍ចំនួន ១៦ មានទឹកប្រាក់ប្រមាណជិត ៥៥ លាន ដុល្លារ ។ ផែនការសកម្មភាព និងថវិកាឆ្នាំ ២០០៨ របស់ គ.ជ.វ.វ បង្ហាញពីធនធានសរុបទាំងឡាយដែលទទួលបានពីប្រភពផ្តល់ជំនួយទាំងអស់ ការវិភាជន៍ដល់ស្ថាប័នអនុវត្តនានា និងផែនការប្រើប្រាស់នៃធនធានទាំងអស់ ដែលបានធ្វើកម្មវិធីនៅក្រោមក្របខ័ណ្ឌរបស់ គ.ជ.វ.វ ដើម្បីគាំទ្រវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ឃុំ សង្កាត់ ស្រុក ខណ្ឌ ខេត្ត ក្រុង និងថ្នាក់ជាតិនៅកម្ពុជា ។ ផែនការសកម្មភាព និងថវិកានេះ ជាលទ្ធផលនៃដំណើរការរៀបចំកម្មវិធី និងផែនការមានរយៈពេល ៥ ខែ ដែលបានអនុវត្តពីខែសីហាឆ្នាំ ២០០៧ ដល់ខែកុម្ភៈ ឆ្នាំ ២០០៨ ដោយមានការចូលរួមពិភាក្សា និងចរចាក្នុងក្រខ័ណ្ឌខ្សែបណ្តោយ និងខ្សែទទឹងរវាងក្រសួង ស្ថាប័នថ្នាក់ជាតិ រដ្ឋបាលថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ ក្រុមប្រឹក្សាឃុំ សង្កាត់ ដៃគូអភិវឌ្ឍន៍ និងទីភ្នាក់ងារនានា ដោយមានការគាំទ្រ និងសម្របសម្រួលពី គ.ជ.វ.វ និងលេខាធិការដ្ឋានរបស់ គ.ជ.វ.វ ។

ផែនការសកម្មភាព និងថវិកាឆ្នាំ ២០០៨ របស់ គ.ជ.វ.វ ឆ្លុះបញ្ចាំងឱ្យឃើញពីការសន្យាផ្តល់នូវធនធានមូលនិធិឃុំ សង្កាត់ទាំងឡាយឱ្យដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ដែលបានអនុម័តដោយ គ.ជ.វ.វ ការសន្យាធ្វើការវិភាជន៍បន្ថែមដល់ក្រុមប្រឹក្សាឃុំ សង្កាត់គោលដៅនានាដោយគម្រោងដៃគូអភិវឌ្ឍន៍មួយចំនួន ការសន្យាផ្តល់ធនធានសម្រាប់ស្រុក ខណ្ឌចំនួន ១៤០ ដោយគម្រោងដៃគូអភិវឌ្ឍន៍ផ្សេងៗ ការសន្យាផ្តល់ធនធានដល់រដ្ឋបាលខេត្ត ក្រុងចំនួន ២៤ ដើម្បីគាំទ្រការវិនិយោគ និងអភិបាលកិច្ច ការសន្យាផ្តល់ធនធានដល់ក្រសួង ស្ថាប័នថ្នាក់ជាតិចំនួន ១៤ សម្រាប់សកម្មភាពរៀបចំគោលនយោបាយ ការគ្រប់គ្រងរបស់ថ្នាក់ជាតិ និងការកសាងសមត្ថភាព ក៏ដូចជាការងារ

គ្រប់គ្រងគម្រោង ព្រមទាំងការសន្យាផ្តល់ធនធានសម្រាប់ គ.ជ.វ.វ លេខាធិការដ្ឋាន និងក្រុមគាំទ្រកម្មវិធី គ.ជ.វ.វ សម្រាប់ការគ្រប់គ្រងជាទូទៅនៃការអនុវត្តផែនការសកម្មភាព និងថវិកា ។ ផ្អែកលើមូលដ្ឋាននៃថវិកាវិភាជន៍ដែលបានអនុម័ត ធនធានទាំងអស់ត្រូវបានធ្វើការសន្យា និងអនុវត្តតាមរយៈការព្រមព្រៀងជាកិច្ចសន្យា ដែលរួមបញ្ចូលនូវផែនការសកម្មភាព និងថវិកាលំអិត ។ ហេតុដូច្នេះ ផែនការសកម្មភាព និងថវិកាឆ្នាំ ២០០៨ របស់គ.ជ.វ.វ នឹងបង្ហាញពីទិដ្ឋភាពទូទៅនៃធនធានសរុបដែលបានធ្វើកម្មវិធីក្នុងឆ្នាំ ២០០៨ ។ ដោយឡែកសកម្មភាព និងថវិកាលំអិតនឹងឆ្លុះបញ្ចាំង នៅក្នុងផែនការសកម្មភាព និងថវិកាចំនួន ២១ នៃគម្រោងរបស់ដៃគូអភិវឌ្ឍន៍នីមួយៗ កិច្ចសន្យាប្រចាំឆ្នាំចំនួន ២៤ ជាមួយក្រសួង ស្ថាប័នថ្នាក់ជាតិ ផែនការសកម្មភាព និងថវិកាចំនួន ៧៥ របស់ខេត្ត ក្រុងនីមួយៗ កិច្ចសន្យាប្រចាំចំនួន ៦០០ ជាមួយមន្ទីរជំនាញថ្នាក់ខេត្ត ក្រុង និងការិយាល័យស្រុក ខណ្ឌ ព្រមទាំងផែនការ និងថវិកាប្រចាំឆ្នាំចំនួន ១.៦២១ ដែលរៀបចំដោយក្រុមប្រឹក្សាឃុំ សង្កាត់នានា ។

អភិបាលកិច្ចល្អ គឺជាស្នូលរបស់យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ។ ស្របជាមួយនឹងយុទ្ធសាស្ត្រនេះ ក្នុងឆ្នាំ ២០០៨ មានធនធានសរុបចំនួនប្រហែល ១២ លានដុល្លារ ឬស្មើនឹង ១៦%នៃធនធានដែលមានក្នុងក្របខ័ណ្ឌរបស់ គ.ជ.វ.វ ត្រូវបានរៀបចំជាកម្មវិធីដើម្បីគាំទ្រការពង្រឹងអភិបាលកិច្ចល្អ ជាពិសេសនៅថ្នាក់ក្រោមជាតិ ។ ការវិភាជន៍ទាំងឡាយសម្រាប់ក្រសួង ស្ថាប័នថ្នាក់ជាតិចំនួន ១៤ រដ្ឋបាលខេត្ត ក្រុងចំនួន ២៤ និងកិច្ចសហប្រតិបត្តិការបច្ចេកទេសផ្តល់ឱ្យស្ថាប័នទាំងអស់នេះ នឹងគាំទ្រដល់សកម្មភាពទាំងឡាយដែលពាក់ព័ន្ធនឹងការពង្រឹងនូវបទប្បញ្ញត្តិប្រព័ន្ធ និងគោលនយោបាយ កម្មវិធីបណ្តុះបណ្តាលរបស់ថ្នាក់ជាតិដល់គ្រប់លំដាប់ថ្នាក់ទាំងអស់ ការពង្រឹងនូវប្រព័ន្ធព័ត៌មានស្តីពីការគ្រប់គ្រងនៃថ្នាក់ជាតិទាំងអស់ ការតាមដានត្រួតពិនិត្យ ការវាយតម្លៃ ការរៀបចំ របាយការណ៍ការគ្រប់គ្រង និងសវនកម្ម ព្រមទាំងការអភិវឌ្ឍន៍ភាពជាដៃគូនៅថ្នាក់ឃុំ សង្កាត់ ខេត្ត ក្រុង និងថ្នាក់ជាតិ ។

លើសពីនេះទៀត ក្នុងគោលបំណងផ្សាភ្ជាប់ជាមួយនឹងដំណើរការពង្រឹងអភិបាលកិច្ចមូលដ្ឋាន តម្រូវឱ្យមានការធានានូវធនធានវិនិយោគក្នុងកំរិតគ្រប់គ្រាន់មួយនៅថ្នាក់ឃុំ សង្កាត់ និងខេត្ត ក្រុង ដើម្បីធ្វើឱ្យគោលការណ៍ និងការអនុវត្តជាក់ស្តែងនៃអភិបាលកិច្ចផ្តល់នូវផលប្រយោជន៍ពិតប្រាកដដល់ប្រជាជន និងការកាត់បន្ថយភាពក្រីក្រ ។ នៅក្នុងឆ្នាំ ២០០៨ ៧៦% នៃធនធានសរុប ស្មើនឹង ៥៨ លានដុល្លារ ត្រូវបានរៀបចំជាកម្មវិធី ដើម្បីគាំទ្រការវិនិយោគ និងសេវាកម្មនានាដែលនឹងត្រូវអនុវត្តដោយក្រសួង ស្ថាប័នថ្នាក់ជាតិ មន្ទីរជំនាញថ្នាក់ខេត្ត ក្រុង ការិយាល័យថ្នាក់ស្រុក ខណ្ឌ ក្រុមប្រឹក្សាឃុំ សង្កាត់ និងអ្នកទទួលការវិស័យឯកជននានា ។ សកម្មភាពអភិវឌ្ឍន៍ទាំងនេះ ត្រូវបានរៀបចំឡើងដោយមានការពិភាក្សាយ៉ាងយកចិត្តទុកដាក់រវាងក្រុមប្រឹក្សាឃុំ សង្កាត់ មន្ទីរជំនាញថ្នាក់ខេត្ត ក្រុង ទីភ្នាក់ងារអភិវឌ្ឍន៍ជាតិ និងអន្តរជាតិ និងក្រសួង ស្ថាប័ននានា ផ្អែកលើយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ និងកិច្ចដំណើរការរៀបចំកម្មវិធី និងកសាងផែនការ ។

គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ មានគោលបំណងសំខាន់ក្នុងការពង្រឹង និងពង្រីកក្របខ័ណ្ឌនៃភាពជាដៃគូ ដែលបានអភិវឌ្ឍក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ដើម្បីគាំទ្រដល់

វិមជ្ឈការ និងវិសហមជ្ឈការទាំងនៅក្នុងរដ្ឋាភិបាល និងរវាងរដ្ឋាភិបាលជាមួយដៃគូអភិវឌ្ឍន៍របស់យើង ។ ក្របខ័ណ្ឌនៃភាពជាដៃគូដែលកើតឡើងក្នុងទម្រង់ទាំងពីរនេះ បានផុសចេញមក និងបានឈានឆ្ពោះទៅរកការិតជំសំខាន់មួយនៃសុខដុមនីយកម្មក្នុងការគ្រប់គ្រង ចាត់ចែងធនធានពីខាងក្រៅទាំងឡាយសមស្របតាមគោលការណ៍របស់អង្គការ ដើម្បីកិច្ចអភិវឌ្ឍន៍ និងសហប្រតិបត្តិការសេដ្ឋកិច្ច/គណៈកម្មាធិការជំនួយអភិវឌ្ឍន៍ (OEC/DAC) ។ ធនធានទាំងអស់ដែលបានរៀបរាប់ក្នុងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ ២០០៨ របស់ គ.ជ.វ.វ ត្រូវបានកៀរគរមកពីថវិកាជាតិ ធនាគារពិភពលោក ធនាគារ អភិវឌ្ឍន៍អាស៊ី និងមូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្ម សហគមន៍អឺរ៉ុប រដ្ឋាភិបាលស៊ុយអែដ ចក្រភពអង់គ្លេស ដាណឺម៉ាក ជប៉ុន កាណាដា អាល្លឺម៉ង់ និងអូស្ត្រាលី ប្រព័ន្ធអង្គការសហប្រជាជាតិរួមមាន UNDP, UNCEF, UNCDF និង UNFPA និងអង្គការមិនមែនរដ្ឋាភិបាលនានាជាច្រើនទៀត ។ លើសពីនេះទៀត ក៏មានធនធានបន្ថែមជាច្រើនលានដុល្លារផ្សេងទៀតដែលមិនបានរៀបរាប់ក្នុងឯកសារនេះ ដែលត្រូវបានរៀបចំកម្មវិធី ដើម្បីគាំទ្រដល់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងឆ្នាំ ២០០៨ ដោយមន្ទីរជំនាញថ្នាក់ខេត្ត ក្រុង អង្គការអន្តរជាតិអង្គការមិនមែនរដ្ឋាភិបាល តាមរយៈសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក ហើយដែលសកម្មភាពទាំងនោះ ត្រូវបានអនុវត្តផ្ទាល់ដោយស្ថាប័នទាំងអស់នោះក្នុងខេត្ត ក្រុងនីមួយៗ ក៏ដូចជាការចូលរួមបដិភាគពីសហគមន៍មូលដ្ឋាននានា ។

ក្នុងនាមរាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់សមាជិកទាំងអស់នៃ គ.ជ.វ.វ ក្រុមការងារលេខាធិការដ្ឋាន និងក្រុមគាំទ្រកម្មវិធីរបស់ គ.ជ.វ.វ អភិបាលខេត្ត ក្រុងទាំង ២៤ ដែលជាប្រធានគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត ក្រុង ទទួលខុសត្រូវក្នុងការគ្រប់គ្រងការអនុវត្តផែនការសកម្មភាព និងថវិកា គ.ជ.វ.វនៅថ្នាក់ខេត្ត ក្រុង មន្ត្រីរាជការទាំងអស់នៅថ្នាក់ខេត្ត ក្រុង និងស្រុក ខណ្ឌ ដែលទទួលខុសត្រូវក្នុងការអនុវត្ត និងគាំទ្រសកម្មភាពនានា ក្រុមប្រឹក្សាឃុំ សង្កាត់ទាំង១.៦២១ ដែលបានបំពេញការងារយ៉ាងសកម្មក្នុងការគ្រប់គ្រង និងអភិវឌ្ឍន៍មូលដ្ឋានរបស់ខ្លួន ដៃគូអភិវឌ្ឍន៍ទាំងអស់របស់យើង និងជាពិសេសចំពោះប្រជាពលរដ្ឋកម្ពុជាទាំងអស់នៅតំបន់ជនបទ ដែលបានបំពេញការងារយ៉ាងខ្លាំងក្លា និងជាមូលដ្ឋានគ្រឹះមួយដ៏រឹងមាំក្នុងការសម្រេចបាននូវគ្រប់សមិទ្ធផលទាំងអស់ ។

ភ្នំពេញ ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០០៨

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ប្រធាន គ.ជ.វ.វ**

**ស ខេង**

# មាតិកា


| | | |
|---|---|---|
| | បុព្វកថា | i |
| | មាតិកា | v |
| | បញ្ជីអក្សរកាត់ | vii |
| ១. | ថវិកានៃផែនការសកម្មភាព និងថវិកា គ.ជ.វ.វ | ១ |
| ១.១ | ឃុំ សង្កាត់ | ១ |
| ១.២ | ស្រុក ខណ្ឌ | ១ |
| ១.៣ | ខេត្ត ក្រុង | ២ |
| ១.៤ | ថ្នាក់ជាតិ | ២ |
| ២. | ធនធានឆ្នាំ ២០០៨ : ធនធានដែលមាន និងការរៀបចំជាកម្មវិធី | ៣ |
| ៣. | រាជរដ្ឋាភិបាលកម្ពុជា និងការចូលរួមបដិភាគរបស់ដៃគូអភិវឌ្ឍន៍ | ៨ |
| ៣.១ | រាជរដ្ឋាភិបាលកម្ពុជា | ៨ |
| ៣.២ | ធនាគារពិភពលោក | ៩ |
| ៣.៣ | ធនាគារអភិវឌ្ឍន៍អាស៊ី | ១២ |
| ៣.៤ | គម្រោង PSDD | ១៥ |
| ៣.៥ | មូលនិធិទ្រទ្រង់ជីវភាពរបស់ពហុដៃគូអភិវឌ្ឍន៍ MDLF | ១៨ |
| ៣.៦ | មូលនិធិអន្តរជាតិសម្រាប់ការអភិវឌ្ឍន៍កសិកម្ម | ២១ |
| ៣.៧ | សហគមន៍អឺរ៉ុប | ២៣ |
| ៣.៨ | អង្គការយូនីសេហ្វ/កម្មវិធីសិទ្ធិកុមារ | ២៦ |
| ៣.៩ | គម្រោង JICA របស់ប្រទេសជប៉ុន | ២៨ |
| ៣.១០ | រដ្ឋាភិបាលអាល្លឺម៉ង់ GTZ | ២៩ |
| ៣.១១ | រដ្ឋាភិបាលកាណាដា ADMAC | ៣១ |
| ៣.១២ | UNCDF : គម្រោង IDLD | ៣២ |
| ៣.១៣ | USAID/PACT_កម្មវិធីគាំទ្រកំណែទម្រង់រដ្ឋបាលមូលដ្ឋាន (គម្រោង LAAR) | ៣៤ |
| ៣.១៤ | អង្គការ GRET/PACEPAC | ៣៥ |
| ៣.១៥ | មូលនិធិរបស់អង្គការសហប្រជាជាតិដើម្បីសកម្មភាពប្រជាជន | ៣៦ |
| ៣.១៦ | គម្រោង CCJAP គាំទ្រដោយ AusAid | ៣៧ |
| ៣.១៧ | ភាពជាដៃគូផ្សេងទៀតជាមួយ NGOs | ៣៧ |

| | | |
|---|---|---|
| ៤. | កិច្ចព្រមព្រៀងហិរញ្ញវត្ថុ ការប្រតិបត្តិ និងលំហូរថវិកា | ៣៨ |
| ៥. | ការរៀបចំកម្មវិធីតាមរយៈសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក ខណ្ឌ | ៤២ |
| ៦. | ការរៀបចំកម្មវិធីថវិកាតាមខេត្ត ក្រុង ឆ្នាំ២០០៨ | ៤៦ |
| ៧. | ការវិភាគតាមផ្នែកថវិកា | ៥៦ |
| ៧.១ | មូលនិធិឃុំ សង្កាត់ | ៥៦ |
| ៧.២ | ឃុំ សង្កាត់គោលដៅរបស់គម្រោងនានា | ៥៨ |
| ៧.៣ | ថ្នាក់ស្រុក ខណ្ឌ | ៦២ |
| ៧.៤ | វិនិយោគខេត្ត ក្រុង | ៦៥ |
| ៧.៥ | ការគាំទ្រកម្មវិធីថ្នាក់ខេត្ត ក្រុង | ៦៩ |
| ៧.៦ | សេវាកម្មក្រសួង ស្ថាប័នថ្នាក់ជាតិ | ៧៥ |
| ៧.៧ | ការគាំទ្រកម្មវិធីនៅថ្នាក់ជាតិ | ៨២ |
| ៧.៨ | កិច្ចសហប្រតិបត្តិការបច្ចេកទេសពីខាងក្រៅ | ៨៤ |
| ៨. | សង្ខេបកិច្ចព្រមព្រៀងហិរញ្ញវត្ថុ និងផែនការសកម្មភាព/កិច្ចសន្យាឆ្នាំ ២០០៨ | ៨៧ |
| | ឧបសម្ព័ន្ធ | ៩០ |
| ១. | ផែនការសកម្មភាពសំខាន់ៗរបស់ គ.ជ.វ.វ /ប្រតិទិនការរៀបចំកម្មវិធីឆ្នាំ ២០០៨ | |
| ២. | ផែនការកសាងសមត្ថភាពរបស់ គ.ជ.វ.វ ឆ្នាំ ២០០៨ | |
| ៣. | ផែនការនៃការសិក្សាគ្រោងក្នុងឆ្នាំ ២០០៨អំពីវិមជ្ឈការ និងវិសហមជ្ឈការ | |
| ៤. | ការិភាជន៍នៃមូលនិធិឃុំ សង្កាត់ឆ្នាំ ២០០៨ | |

# បញ្ជីពាក្យកាត់

| | |
|---|---|
| ADMAC | អភិវឌ្ឍន៍កសិកម្មនៅក្នុងតំបន់រងគ្រោះដោយសារគ្រាប់មីននៃប្រទេសកម្ពុជា |
| AWPB | ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ |
| CAR | ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល |
| CAU | ផ្នែកគ្រប់គ្រងកិច្ចសន្យា (នៃគណៈកម្មាធិប្រតិបត្តិនៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត) |
| CCDP | គម្រោងអភិវឌ្ឍន៍របស់ក្រុមប្រឹក្សាឃុំ |
| CCJAP | គម្រោងជំនួយផ្នែកយុត្តិធម៌ឧក្រិដ្ឋជនកម្ពុជា |
| CIP | កម្មវិធីវិនិយោគឃុំ សង្កាត់ |
| CS | ឃុំ សង្កាត់ |
| DDLG | អភិបាលកិច្ចមូលដ្ឋាន និង អភិវឌ្ឍន៍លទ្ធិប្រជាធិបតេយ្យ |
| DfGG | តម្រូវការសម្រាប់អភិបាលកិច្ចល្អ |
| DIW | សិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក |
| DoLA | នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន |
| DOP | មន្ទីរផែនការ |
| DSP | កម្មវិធីវិសហមជ្ឈការតាមវិស័យ |
| ExCom | គណៈកម្មាធិការប្រតិបត្តិ (នៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត) |
| FU | ផ្នែកហិរញ្ញវត្ថុ (នៃគណៈកម្មាធិប្រតិបត្តិនៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត) |
| GTZ | ទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសអាឡឺម៉ង់ |
| IFAD | មូលនិធិអន្តរជាតិ ដើម្បីអភិវឌ្ឍន៍កសិកម្ម |
| LAU | ផ្នែករដ្ឋបាលមូលដ្ឋាន |
| M&E | តាមដានត្រួតពិនិត្យ និងវាយតំលៃ |
| MLMUPC | ក្រសួងរៀបចំដែនដី និងនគររូបនីយកម្ម |
| MoI | ក្រសួងមហាផ្ទៃ |
| MRD | ក្រសួងអភិវឌ្ឍន៍ជនបទ |
| NCDD | គណៈកម្មាធិការជាតិដឹកនាំការងារកំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការ (គ.ជ.វ.វ) |
| NCDDS | លេខាធិការដ្ឋានគណៈកម្មាធិការជាតិដឹកនាំការងារកំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការ |
| NCDD/PST | ក្រុមគាំទ្រកម្មវិធីនៃគណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| NREM | គម្រោងគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន |

| | |
|---|---|
| NRML | គម្រោងទ្រទ្រង់ជីវភាព និងគ្រប់គ្រងធនធានធម្មជាតិ |
| OWSO | ការិយាល័យច្រកចេញចូលតែមួយ |
| PIF | មូលនិធិវិនិយោគខេត្ត |
| PRDC | គណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត (គ.អ.ជ.ខ) |
| PSDD | គម្រោងអភិវឌ្ឍន៍លទ្ធិប្រជាធិបតេយ្យតាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ |
| PSU | អង្គភាពគាំទ្រគំរោង |
| RGC | ព្រះរាជាណាចក្រកម្ពុជា |
| RILG | គម្រោងអភិបាលកិច្ចមូលដ្ឋាន និងវិនិយោគជនបទ |
| RPRP | គម្រោងកាត់បន្ថយភាពក្រីក្រនៅជនបទ |
| RULIP | គម្រោងកែលំអជីវភាពនៅជនបទ |
| SIDA | ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិប្រទេសស៊ុយអែត |
| TSSL | គម្រោងទ្រទ្រង់ជីវភាពប្រជាជនបឹងទន្លេសាប |
| TSU | ផ្នែកគាំទ្របច្ចេកទេស |
| UNDP | កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ |
| UNCDF | មូលនិធិអង្គការសហប្រជាតិដើម្បីអភិវឌ្ឍន៍មូលធន៍ |
| UNFPA | មូលនិធិអង្គការសហប្រជាតិដើម្បីសកម្មភាពប្រជាជន |
| UNICEF | មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារ |

# ផែនការសកម្មភាព និងថវិការបស់ គ.ជ.វ.វ ឆ្នាំ ២០០៨

## ១. ថវិកានៃផែនការសកម្មភាព និងថវិការបស់ គ.ជ.វ.វ

ថវិការបស់ផែនការសកម្មភាព និងថវិការបស់ គ.ជ.វ.វ ឆ្នាំ ២០០៨ ដែលបានមកពីប្រភពផ្សេងៗត្រូវបានរៀបចំជាកម្មវិធី និងបែងចែកតាមប្រភេទដូចមានរៀបរាប់ខាងក្រោម :

### ១.១ ឃុំ សង្កាត់

**មូលនិធិឃុំ សង្កាត់ :** មូលនិធិឃុំ សង្កាត់ត្រូវបានបង្កើតឡើងដោយរាជរដ្ឋាភិបាល តាមរយៈអនុក្រឹត្យដែលបានរៀបចំឡើងនៅខែ កុម្ភៈ ២០០២ ។ មូលនិធិនេះបានមកពីថវិកាជាតិ និងការចូលរួមបដិភាគនានា ដែលបានវិភាជន៍ប្រចាំឆ្នាំតាមរយៈរូបមន្តមូលដែលមានតម្លាភាពហើយបានផ្ទេរទៅក្នុងគណនីរបស់ឃុំ សង្កាត់ ដែលបានបង្កើតនៅក្នុងរតនាគារខេត្ត ក្រុង ។ មូលនិធិឃុំ សង្កាត់ ត្រូវបានរៀបចំកម្មវិធីប្រើប្រាស់ដោយក្រុមប្រឹក្សាឃុំ សង្កាត់ ស្របតាមដំណើរការ និងបទប្បញ្ញត្តិនានាស្តីពីការកសាងផែនការ និងរៀបចំថវិកាឃុំ សង្កាត់ និងប្រតិបត្តិដោយក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីគាំទ្រការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងការងាររដ្ឋបាលរបស់ឃុំ សង្កាត់ ។ នៅថ្នាក់ជាតិ ការអនុវត្តមូលនិធិឃុំ សង្កាត់ ត្រូវបានគាំទ្រដោយនាយកដ្ឋានរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃ ក្រោមការគ្រប់គ្រងរបស់ គ.ជ.វ.វ ។

**ឃុំ សង្កាត់គោលដៅ :** នៅក្រោមក្របខ័ណ្ឌរបស់ គ.ជ.វ.វ ប្រភពថវិកាប្រភេទនេះរួមមានធនធានទាំងឡាយណាដែលបានវិភាជន៍ឱ្យក្រុមប្រឹក្សាឃុំ សង្កាត់គោលដៅ បន្ថែមលើមូលនិធិឃុំ សង្កាត់ ។ ការវិភាជន៍ទាំងនេះអាចជាការវិភាជន៍បន្ថែមសម្រាប់ប្រើប្រាស់ក្នុងគោលបំណងរួម ឬជាការវិភាជន៍សម្រាប់គោលបំណងអភិវឌ្ឍន៍ជាក់លាក់ណាមួយដែលបានកំណត់ដោយគម្រោងដៃគូអភិវឌ្ឍន៍ និងការកំណត់ដោយក្រុមប្រឹក្សាឃុំ សង្កាត់ ។

### ១.២ ស្រុក ខណ្ឌ

**កម្មវិធីសាកល្បងពង្រឹងតួនាទីថ្នាក់ស្រុក ខណ្ឌ :** អនុវត្តតាមសេចក្តីណែនាំដែលបានរៀបចំឡើងដោយក្រសួងមហាផ្ទៃនៅឆ្នាំ ២០០៦ ថវិការបស់ផ្នែកនេះរួមមានធនធាននានា ដែលបានវិភាជន៍ឱ្យគណៈកម្មាធិការអភិវឌ្ឍន៍ស្រុក ខណ្ឌ (គ.អ.ស) ដែលមានសមាជិកជាប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ តំណាងការិយាល័យជំនាញ និងចំណុះថ្នាក់ស្រុក ខណ្ឌ និងដឹកនាំដោយអភិបាលស្រុក ខណ្ឌ ។ ធនធានទាំងអស់ដែលបានរៀបចំជាកម្មវិធីដោយ គ.អ.ស ដើម្បីគាំទ្រវិនិយោគ និងសេវាកម្មអន្តរឃុំ សង្កាត់ជាអាទិភាពនានា ត្រូវបានកំណត់តាមរយៈដំណើរការកសាងផែនការមូលដ្ឋាន ហើយបានរៀបចំបញ្ចូលគ្នាជាផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ និងចុះហត្ថលេខាជាមួយ គ.អ.ជ.ខ ដើម្បីយកទៅអនុវត្ត តាមរយៈការរៀបចំជាកិច្ចសន្យាបន្តរវាងគណៈកម្មការអន្តរឃុំ សង្កាត់ ការិយាល័យជំនាញ អង្គការមិនមែនរដ្ឋាភិបាល ជាមួយវិស័យឯកជន ឬក៏ជាមួយមន្ទីរជំនាញក្នុងករណីស្រុក ខណ្ឌមិនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការអនុវត្ត ។

## ១.៣ ខេត្ត ក្រុង

**មូលនិធិវិនិយោគខេត្ត ក្រុង :** មូលនិធិវិនិយោគខេត្ត ក្រុង (PIF) រួមមានការវិភាជន៍ជាកញ្ចប់ប្រចាំឆ្នាំឱ្យដល់អាជ្ញាធរខេត្ត ក្រុង ដើម្បីរៀបចំជាកម្មវិធី និងប្រតិបត្តិដោយខេត្ត ក្រុង និងធ្វើកិច្ចសន្យាជាមួយមន្ទីរជំនាញនានា សម្រាប់អនុវត្តសេវាកម្ម និងការវិនិយោគ ដែលឆ្លើយតបទៅនឹងអាទិភាពទាំងឡាយដែលបានកំណត់ដោយក្រុមប្រឹក្សា ឃុំ សង្កាត់ និងមន្ទីរជំនាញខេត្ត ក្រុង និងមានលក្ខណៈសមស្របជាមួយនឹងគោលនយោបាយវិស័យ និងយុទ្ធសាស្ត្ររបស់ថ្នាក់ជាតិ ។

**កម្មវិធីវិសហមជ្ឈការវិស័យថ្នាក់ជាតិ :** ផ្នែកនេះរួមមានធនធាននានាដែលបានរៀបចំជាកម្មវិធី នៅក្រោមកិច្ចព្រមព្រៀងរវាងដៃគូអភិវឌ្ឍន៍ជាមួយនឹងក្រសួង ស្ថាប័ននានា ផ្អែកតាមវិស័យដែលបានកំណត់ និងយុទ្ធសាស្ត្រកម្មវិធីទាំងឡាយ ដែលពាក់ព័ន្ធនឹងការទទួលខុសត្រូវក្នុងការកសាងផែនការ និងការអនុវត្ត ដែលបានធ្វើប្រតិភូកម្មទៅឱ្យខេត្ត ក្រុង ក្រោមការសម្របសម្រួលរបស់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ។

**ការគាំទ្រកម្មវិធីថ្នាក់ខេត្ត ក្រុង :** ការគាំទ្រកម្មវិធីថ្នាក់ខេត្ត ក្រុង គឺជាធនធានទាំងឡាយដែលបានវិភាជន៍ទៅឱ្យខេត្ត ក្រុង ដើម្បីគ្រប់គ្រង និងប្រតិបត្តិប្រកបដោយប្រសិទ្ធភាពនូវផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំដោយអនុវត្តនូវមុខងារនានាដែលបានប្រគល់ឱ្យដោយថ្នាក់ជាតិ ក្នុងការគាំទ្រវិមជ្ឈការ និងវិសហមជ្ឈការដូចជា ការគាំទ្រ ការត្រួតពិនិត្យ និងការកសាងសមត្ថភាពក្រុមប្រឹក្សាឃុំ សង្កាត់ និងស្មៀន ការងាររដ្ឋបាល ការតាមដានត្រួតពិនិត្យ ការធ្វើរបាយការណ៍ និងការវាយតម្លៃកិច្ចសន្យានានា ដែលបានចុះហត្ថលេខារវាងអភិបាលខេត្ត ក្រុង និងភ្នាក់ងារអនុវត្តនានា ការគ្រប់គ្រងហិរញ្ញវត្ថុ និងការសម្របសម្រួលកិច្ចប្រតិបត្តិការនៅថ្នាក់ខេត្ត ក្រុង ។

**កិច្ចសហប្រតិបត្តិការបច្ចេកទេសថ្នាក់ខេត្ត ក្រុង :** ផ្នែកនេះរួមមានសេវាកម្មរបស់ទីប្រឹក្សាបច្ចេកទេស ដែលផ្តល់ឱ្យថ្នាក់ខេត្ត ក្រុង ដើម្បីគាំទ្រការអភិវឌ្ឍន៍សមត្ថភាពក្នុងការគ្រប់គ្រង និងអនុវត្តមុខងារទាំងឡាយដូចបានរៀបរាប់ខាងលើសំដៅពង្រឹងតម្លាភាព និងគណនេយ្យភាព និងអភិវឌ្ឍន៍បន្ថែមនូវក្របខ័ណ្ឌនៃភាពជាដៃគូក្នុងការគាំទ្រការងារអភិបាលកិច្ច និងកិច្ចអភិវឌ្ឍន៍ ។ ធនធានទាំងអស់ត្រូវបានបែងចែកជាទីប្រឹក្សាជាតិ និងអន្តរជាតិ ។

## ១.៤ ថ្នាក់ជាតិ

**សេវាកម្មក្រសួង ស្ថាប័នថ្នាក់ជាតិ :** ផ្នែកនេះរួមមានធនធាននានា ដែលបានវិភាជន៍ឱ្យក្រសួង ស្ថាប័នថ្នាក់ជាតិ ឬក៏អនុគណៈកម្មាធិការ គ.ជ.វ.វ ផ្អែកតាមផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ ដើម្បីគាំទ្រការរៀបចំ និងពង្រឹងគោលនយោបាយ លិខិតបទដ្ឋាន និងយុទ្ធសាស្ត្រទាំងឡាយ ការកសាងសមត្ថភាពដល់អាជ្ញាធរខេត្ត ក្រុង និងការត្រួតពិនិត្យរបស់ថ្នាក់ជាតិ ការសម្របសម្រួល ការតាមដានត្រួតពិនិត្យ ការវាយតម្លៃផ្ទៃក្នុង និងការងារសវនកម្ម ។

**ការគាំទ្រកម្មវិធីថ្នាក់ជាតិ :** ការគាំទ្រកម្មវិធីថ្នាក់ជាតិ គឺជាធនធានទាំងឡាយ ដែលបានផ្តល់ឱ្យ គ.ជ.វ.វ លេខាធិការដ្ឋាន និងក្រុមគាំទ្រកម្មវិធី គ.ជ.វ.វ សម្រាប់សម្របសម្រួលកម្មវិធីទាំងមូល ការតាមដានត្រួតពិនិត្យ ការវាយតម្លៃ និងធ្វើរបាយការណ៍ ការគ្រប់គ្រងហិរញ្ញវត្ថុ ការគាំទ្រកិច្ចប្រតិបត្តិការ និងការរៀបចំគោលនយោបាយ និងកម្មវិធី ។

**សេវាកម្មទីប្រឹក្សាបច្ចេកទេសថ្នាក់ជាតិ :** ផ្នែកនេះរួមមានសេវាកម្មទីប្រឹក្សាបច្ចេកទេសពីខាងក្រៅទាំងឡាយ ដែលបានផ្តល់ដល់ក្រសួង ស្ថាប័ននានា និងគ.ជ.វ.វ ក្នុងការគាំទ្រការងារអភិបាលកិច្ច កិច្ចអភិវឌ្ឍន៍ កិច្ចប្រតិបត្តិការកម្មវិធី ការរៀបចំគោលនយោបាយ និងការអភិវឌ្ឍន៍នូវភាពជាដៃគូនៅថ្នាក់ជាតិ ។ ធនធានទាំងអស់ក្នុងផ្នែកនេះ ត្រូវបានបែងចែកជាទីប្រឹក្សាបច្ចេកទេសជាតិ ទីប្រឹក្សាបច្ចេកទេសអន្តរជាតិ និងសេវាកម្មកុងស៊ុលតង់ ។

**ការសិក្សាថ្នាក់ជាតិ/ការវាយតម្លៃ/កុងស៊ុលតង់ :** ផ្នែកនេះរួមមានមូលនិធិទាំងឡាយ ដែលបានវិភាជន៍សម្រាប់ការសិក្សាជាក់លាក់នានា ការងាររៀបចំកម្មវិធី និងគោលនយោបាយ ការវាយតម្លៃ និងសវនកម្មពីខាងក្រៅ ដែលចុះកិច្ចសន្យាជាមួយកុងស៊ុលតង់រយៈពេលខ្លី ។

## ២. ធនធានឆ្នាំ ២០០៨ : ធនធានដែលមាន និងការរៀបចំជាកម្មវិធី

ធនធានសរុបទាំងអស់មានចំនួន ៧៧.៧ លានដុល្លារ រួមបញ្ចូលទាំងមូលនិធិឃុំ សង្កាត់ ត្រូវបានកៀរគរពីថវិកាជាតិ និងថវិការបស់ដៃគូអភិវឌ្ឍន៍នានា ដើម្បីរៀបចំជាកម្មវិធី និងបញ្ចូលទៅក្នុងផែនការសកម្មភាព និងថវិការបស់ គ.ជ.វ.វ ឆ្នាំ ២០០៨ ។ តារាងទី ១ : បង្ហាញពីធនធានទាំងឡាយរបស់ផែនការសកម្មភាព និងថវិកាឆ្នាំ ២០០៨ របស់ គ.ជ.វ.វ ត្រូវបានរៀបចំ និងបែងចែកតាមប្រភពធនធាន គិតជាដុល្លារអាមេរិក ក៏ដូចជាចំនួននៃខេត្ត ក្រុង ដែលទទួលបាននូវមូលនិធិទាំងនេះ ។

## តារាងទី១ ៖ ធនធាននានានៃផែនការសកម្មភាព និងថវិការបស់ គ.ជ.អ.ប ឆ្នាំ២០០៨

| ល.រ | ប្រភពធនធាន | ចំនួន | ភាគរយ | ខេត្តក្រុង |
|---|---|---|---|---|
| 1 | សរុបធនធានពីរាជរដ្ឋាភិបាលកម្ពុជា | **22,828,103** | **29.3%** | 24 |
| | WB/RILG | 13,168,442 | 16.9% | 23 |
| | WB/OWSO | 776,475 | 1.0% | 9 |
| | WB/LASED | 797,681 | 1.0% | 3 |
| 2 | សរុបធនធានពីធនាគារពិភពលោក | **14,742,598** | **18.9%** | **23** |
| | ADB/CCDP2 | 5,369,800 | 6.9% | 11 |
| | ADB/TSSL | 7,219,066 | 9.3% | 5 |
| 3 | សរុបធនធានពីធនាគារអភិវឌ្ឍន៍អាស៊ី | **12,588,866** | **16.2%** | **13** |
| 4 | សរុបធនធានពីគម្រោង **PSDD** | **11,398,595** | **14.6%** | **24** |
| | DAN-UK NRM D&D | 5,660,520 | 7.3% | 10 |
| | DAN-UK LAND | 1,613,442 | 2.1% | 10 |
| 5 | សរុបធនធានពីដានីដា-ចក្រភពអង់គ្លេស | **7,273,962** | **9.3%** | **10** |
| | IFAD/RPRP | 3,644,045 | 4.7% | 2 |
| | IFAD/RULIP | 1,880,905 | 2.4% | 3 |
| 6 | សរុបធនធានពី **IFAD** | **5,524,950** | **7.1%** | **5** |
| | EC/DDLG | 3,627,204 | 4.7% | 10 |
| | EC/EFMP | 1,377,319 | 1.8% | 1 |
| 7 | សរុបធនធានពីសហគមន៍អឺរ៉ុប | **5,004,523** | **6.4%** | **11** |
| 8 | សរុបធនធានពី **UNICEF** | **3,553,159** | **4.6%** | **6** |
| 9 | សរុបធនធានពី **Japan/JICA** | **1,500,000** | **1.9%** | 0 |
| 10 | សរុបធនធានពីប្រទេសកាណាដា | **1,130,000** | **1.4%** | 1 |
| 11 | សរុបធនធានពី **Germany/GTZ** | **966,226** | **1.2%** | 3 |
| 12 | សរុបធនធានពី **UNCDF** | **804,000** | **1.0%** | 2 |
| 13 | សរុបធនធានពី **USAID/LAAR** | **743,549** | **1.0%** | 8 |
| 14 | សរុបធនធានពី **GRET** | **146,890** | **0.2%** | 2 |
| 15 | សរុបធនធានពី **UNFPA** | **145,904** | **0.2%** | 8 |
| 16 | សរុបធនធានពី **AUSAID/CCJAP** | **95,000** | **0.1%** | 1 |
| សរុបរួម | | **$77,937,170** | **100%** | **24** |

ស្របគ្នាជាមួយនឹងថវិការបស់ គ.ជ.វ.វ ដែលបានរៀបរាប់នៅក្នុងផ្នែកទី ២ ខាងលើ តារាងទី២ : ការរៀបចំជាកម្មវិធីនៃធនធានឆ្នាំ ២០០៨ ដែលមានរៀបរាប់នៅទំព័របន្ទាប់ ឆ្លុះបញ្ចាំងពីធនធានទាំងឡាយដែលបានរៀបចំជាកម្មវិធី តាមឃុំ សង្កាត់ ស្រុក ខណ្ឌ ខេត្ត ក្រុងនីមួយៗ និងថ្នាក់ជាតិ និងតាមផ្នែកនៃថវិកា ។

**តារាងទី២ : ការរៀបចំធនធានតាមកម្មវិធីសម្រាប់ឆ្នាំ២០០៨**

| ប្រភេទថវិកា | ចំនួន | ភាគរយ |
|---|---|---|
| មូលនិធិឃុំ សង្កាត់ | 22,969,136 | 29% |
| មូលនិធិសម្រាប់ឃុំ សង្កាត់គោលដៅ | 14,401,368 | 18% |
| **សរុបថ្នាក់ឃុំ សង្កាត់** | **37,370,503** | **48%** |
| **សរុបថ្នាក់ស្រុក ខណ្ឌ** | **6,051,264** | **8%** |
| មូលនិធិវិនិយោគខេត្ត ក្រុង | 3,867,151 | 5% |
| កម្មវិធីវិស័យបែបវិសហមជ្ឈការ | 7,147,487 | 9% |
| ការគាំទ្រកម្មវិធីនៅថ្នាក់ខេត្ត ក្រុង | 4,769,217 | 6% |
| ជំនួយបច្ចេកទេសនៅថ្នាក់ខេត្ត ក្រុង | 2,696,275 | 3% |
| **សរុបថ្នាក់ខេត្ត ក្រុង** | **18,480,131** | **24%** |
| សេវាកម្មនានាតាមបណ្តាក្រសួង | 5,502,149 | 7% |
| ការគាំទ្រកម្មវិធីនៅថ្នាក់ជាតិ | 2,517,791 | 3% |
| ជំនួយបច្ចេកទេសនៅថ្នាក់ជាតិ | 4,795,230 | 6% |
| ការសិក្សា ឬការវាយតម្លៃ | 3,220,102 | 4% |
| **សរុបថ្នាក់ជាតិ** | **16,035,272** | **21%** |
| **សរុបរួម** | **77,937,170** | **100%** |

ការបង្ហាញក្នុងទម្រង់មួយទៀត គឺតារាងទី ៣ : ការរៀបចំជាកម្មវិធីនៃធនធានឆ្នាំ ២០០៨ ឆ្លុះបញ្ចាំងពីការរៀបចំធនធាននានាជា ការវិនិយោគ ការគាំទ្រកម្មវិធី និងកិច្ចសហប្រតិបត្តិការបច្ចេកទេស ។

ក្នុងការវិភាគថវិការបស់ផែនការសកម្មភាព និងថវិការបស់ គ.ជ.វ.វ ឆ្នាំ ២០០៧ ប្រៀបធៀបនឹងថវិការបស់ផែនការសកម្មភាព និងថវិកា គ.ជ.វ.វ ឆ្នាំ ២០០៧ បង្ហាញនូវចំណុចសំខាន់ៗមួយចំនួនដូចខាងក្រោម :

- **សរុបសង្ខេប** : ធនធានសរុបទាំងអស់នៅក្នុងផែនការសកម្មភាព និងថវិកាឆ្នាំ ២០០៨ គឺមានការកើនឡើងចំនួន ៣០% ស្មើនឹង ១៨.៥ លានដុល្លារ បើប្រៀបធៀបធនធានសរុបនៅក្នុងផែនការសកម្មភាព និងថវិការបស់ គ.ជ.វ.វ ឆ្នាំ ២០០៧ ។ ការកើនឡើងនេះបណ្តាលមកពីការកើនឡើងនូវចំនួនគម្រោងរបស់ដៃគូអភិវឌ្ឍន៍ ដែលបានប្រើប្រាស់ក្របខ័ណ្ឌវិមជ្ឈការ និងវិសហមជ្ឈការរបស់ គ.ជ.វ.វ សម្រាប់ការអនុវត្តគម្រោងរបស់ពួកគេ ។

## តារាងទី៣ : ការរៀបចំធនធានតាមកម្មវិធីសម្រាប់ឆ្នាំ២០០៨

| ផ្នែក | ចំនួន | ភាគរយ |
|---|---|---|
| មូលនិធិឃុំ សង្កាត់ | 22,969,136 | 29.5% |
| មូលនិធិសម្រាប់ឃុំ សង្កាត់គោលដៅ | 14,401,368 | 18.5% |
| វិនិយោគនៅថ្នាក់ស្រុក ខណ្ឌ | 6,051,264 | 7.8% |
| មូលនិធិវិនិយោគខេត្ត ក្រុង | 3,867,151 | 5.0% |
| កម្មវិធីវិស័យបែបវិសហមជ្ឈការ | 7,147,487 | 9.2% |
| សេវាកម្មនានាតាមបណ្តាក្រសួង | 5,502,149 | 7.1% |
| **សរុបការវិនិយោគ** | **59,938,555** | **76.9%** |
| ការគាំទ្រកម្មវិធីនៅថ្នាក់ខេត្ត ក្រុង | 4,769,217 | 6.1% |
| ការគាំទ្រកម្មវិធីនៅថ្នាក់ជាតិ | 2,517,791 | 3.2% |
| **សរុបការគាំទ្រកម្មវិធី** | **7,287,008** | **9.3%** |
| ជំនួយបច្ចេកទេសនៅថ្នាក់ខេត្ត ក្រុង | 2,696,275 | 3.5% |
| ជំនួយបច្ចេកទេសនៅថ្នាក់ជាតិ | 4,795,230 | 6.2% |
| ការសិក្សា ឬការវាយតម្លៃ | 3,220,102 | 4.1% |
| **សរុបជំនួយបច្ចេកទេស** | **10,711,607** | **13.7%** |
| **សរុបរួម** | **$77,937,170** | **100%** |

- **មូលនិធិឃុំ សង្កាត់ :** មូលនិធិឃុំ សង្កាត់ឆ្នាំ ២០០៨ បានកើនឡើងចំនួន ១.១ លានដុល្លារ ឬស្មើនឹង ៥% បើប្រៀបធៀបជាមួយឆ្នាំ ២០០៧ ។ ផ្អែកលើការសម្រេចចិត្តរបស់រដ្ឋាភិបាលក្នុងការវិភាជន៍មូលនិធិឃុំ សង្កាត់ឆ្នាំ ២០០៨-២០១០ នឹងត្រូវកំណត់ជាភាគរយនៃការវិភាជន៍ពីថវិកាជាតិ ដែលបានមកពីចំណូលក្នុងស្រុកប្រចាំឆ្នាំ ក៏ដូចជាការព្យាករណ៍សម្រាប់ចំណូលក្នុងឆ្នាំបន្ទាប់ ។ ដូច្នេះការកើនឡើងនៃមូលនិធិឃុំ សង្កាត់នេះ គឺបានមកពីការកើនឡើងនូវភាគរយនៃការវិភាជន៍ ។
- **ឃុំ សង្កាត់គោលដៅ :** ការវិភាជន៍បន្ថែមនានាដល់ឃុំ សង្កាត់គោលដៅដោយគម្រោងរបស់ដៃគូអភិវឌ្ឍន៍ជាក់លាក់ មានការកើនឡើងចំនួន ១២០% ស្មើនឹង ៨.២ លានដុល្លារ បើប្រៀបធៀបជាមួយធនធានឆ្នាំ ២០០៧ ដែលជាការកើនឡើងខ្ពស់ជាងគេ ។ ភាគច្រើននៃការកើនឡើងនេះ គឺបានមកពីការវិភាជន៍របស់គម្រោងគាំទ្រដោយធនាគារអភិវឌ្ឍន៍អាស៊ីចំនួន ២ គឺ CCDP2 ដែលផ្តោតលើសាងសង់ការិយាល័យសាលាឃុំ សង្កាត់ និងគម្រោងលើកកំពស់ជីវភាពរបស់ប្រជាពលរដ្ឋជុំវិញបឹងទន្លេសាប ដែលផ្តោតលើការផ្តល់ថវិកាដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីគាំទ្រសកម្មភាពលើកកំពស់ជីវភាពប្រជាពលរដ្ឋ ។

- **សរុបរបស់ឃុំ :** បើធ្វើការបូកសរុបនូវធនធានទាំងពីរប្រភេទខាងលើ ធនធានទាំងអស់ដែលបានវិភាជន៍ឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ មានការកើនឡើងចំនួន ៩.៤ លានដុល្លារ ឬស្មើនឹង ៣៤% បើប្រៀបធៀបនឹងឆ្នាំ ២០០៧ ។
- **ស្រុក ខណ្ឌ :** ក្នុងឆ្នាំ ២០០៨ ធនធានដែលបានវិភាជន៍ឱ្យស្រុក ខណ្ឌ ដើម្បីគាំទ្រគម្រោង/សកម្មភាពអន្តរឃុំ សង្កាត់ មានការកើនឡើងចំនួន ៥៩% ស្មើនឹង ២.២ លានដុល្លារ ។ ក្នុងឆ្នាំ ២០០៨ មានគម្រោងថ្មីចំនួន ៣ ដែលបានគាំទ្រដល់ថ្នាក់ស្រុក ខណ្ឌ គឺ គម្រោងការិយាល័យច្រកចេញចូលតែមួយ គម្រោងបែងចែកដីធ្លីសម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច ដែលគាំទ្រដោយធនាគារពិភពលោក និងគម្រោងគំនិតផ្តួចផ្តើមសម្រាប់វិមជ្ឈការ និងកិច្ចអភិវឌ្ឍន៍ដែលគាំទ្រដោយ UNCDF ។
- **ការវិនិយោគខេត្ត ក្រុង :** បូកសរុបប្រភេទធនធានទាំងពីរនៃមូលនិធិវិនិយោគខេត្ត ក្រុងជាមួយនឹងកម្មវិធីវិស័យវិសហមជ្ឈការ ចំនួនថវិកាសរុបមានការថយចុះចំនួន ៥០០.០០០ ដុល្លារ ឬស្មើនឹង ៥% តិចជាងឆ្នាំ ២០០៧ ។ ការថយចុះនេះ បណ្តាលមកពីមានការថយចុះធនធានមួយចំនួនរបស់គម្រោងដែលមានរយៈពេលវែង និងដោយមូលហេតុជាក់ស្តែងដែលគម្រោងថ្មីមួយចំនួនបានផ្តល់មូលនិធិវិនិយោគតិចតួចឱ្យខេត្ត ក្រុងមួយចំនួនឱ្យខេត្ត ក្រុងគ្រប់គ្រង ។
- **សេវាកម្មក្រសួង ស្ថាប័នថ្នាក់ជាតិ :** ថវិកាវិភាជន៍សម្រាប់ក្រសួង ស្ថាប័ននៅក្នុងក្របខ័ណ្ឌផែនការសកម្មភាព និងថវិការបស់ គ.ជ.វ.វ ឆ្នាំ ២០០៨ មានការកើនឡើងចំនួន ៤៨% គឺពី ៣.២ លានដុល្លារទៅ ៥.៣ លានដុល្លារ ។ មួយភាគធំនៃការកើនឡើងនេះ គឺបណ្តាលមកពីការវិភាជន៍ដល់គម្រោងជាក់លាក់របស់ PSU មានមូលនិធិបំរ៉ុងសម្រាប់ប្រើប្រាស់ក្នុងគោលបំណងផ្សេងៗមានចំនួនច្រើន ។
- **ការគាំទ្រកម្មវិធីថ្នាក់ខេត្ត ក្រុង :** ថវិកាវិភាជន៍សរុបដើម្បីគាំទ្រកិច្ចប្រតិបត្តិការរបស់គណៈកម្មាធិការប្រតិបត្តិខេត្ត ក្រុងមានការកើនឡើងតិចតួចគឺ ២% ។ ពិនិត្យជារួម ថវិកាសរុបដែលវិភាជន៍ឱ្យថ្នាក់ក្រោមជាតិមានការកើនឡើងចំនួន ៦ លានដុល្លារក្នុងឆ្នាំ ២០០៨ តែថវិកាប្រតិបត្តិការខេត្ត ក្រុងមានការថយចុះជាបន្តបន្ទាប់ គឺពី ១០% នៅឆ្នាំ ២០០៧ មក ៨% ក្នុងឆ្នាំ ២០០៨ ។
- **ការគាំទ្រកម្មវិធីថ្នាក់ជាតិ :** ថវិកាវិភាជន៍ឱ្យក្រុមគាំទ្រកម្មវិធីនៃលេខាធិការដ្ឋាន គ.ជ.វ.វ ក្នុងឆ្នាំ ២០០៨ មានចំនួន ២.៥ លានដុល្លារ ដែលស្មើនឹង ២.៥ ដងលើសឆ្នាំ ២០០៧ ។ ការកើនឡើងនេះបណ្តាលមកពីមានការកើនឡើងនូវចំនួនគម្រោង ដែលប្រើប្រាស់ក្រុមគាំទ្រកម្មវិធីនៃលេខាធិការដ្ឋាន គ.ជ.វ.វ សម្រាប់ប្រតិបត្តិគម្រោង និងការវិភាជន៍មួចំនួនធំគឺបានមកពីធនាគារពិភពលោក សម្រាប់ការងារលទ្ធកម្មឧបករណ៍ និងសំណង់ ។
- **កិច្ចសហប្រតិបត្តិការបច្ចេកទេស :** ថវិកាវិភាជន៍សរុបសម្រាប់ជំនួយបច្ចេកទេស ដើម្បីគាំទ្រសេវាកម្មទីប្រឹក្សាថ្នាក់ជាតិ និងខេត្ត ក្រុង ការសិក្សា និងការវាយតម្លៃនានាក្នុងឆ្នាំ ២០០៨ មានចំនួន ១០.៧

លានដុល្លារ ឬស្មើនឹង ៧០% កើនឡើងលើសឆ្នាំ ២០០៧ ។ ប៉ុន្តែថវិកាគាំទ្រសេវាកម្មទីប្រឹក្សានៅថ្នាក់ក្រោមជាតិមានចំនួនប្រហាក់ប្រហែលគ្នានឹងឆ្នាំ ២០០៧ ដែលស្មើនឹង ៤% នៃថវិកាសរុបដែលវិភាជន៍ឱ្យថ្នាក់ក្រោមជាតិ ។ ចំពោះថវិកាវិភាជន៍សម្រាប់ជំនួយបច្ចេកទេសនៅថ្នាក់ជាតិ គឺមានការកើនឡើងជាទ្វេដង ។ ការកើនឡើងនេះ ដោយសារមានគម្រោងជំនួយបច្ចេកទេសជាក់លាក់មួយចំនួនដូចជាគម្រោង JICA និង GTZ និងជំនួយបច្ចេកទេសផ្សេងទៀត ដែលពាក់ព័ន្ធជាក់លាក់ជាមួយនឹងអង្គភាពគាំទ្រគម្រោង ។ ពិនិត្យជារួមការវិភាជន៍ធនធានទាំងអស់សម្រាប់ការសិក្សា និងការវាយតម្លៃមានការកើនឡើងចំនួនទ្វេដងបើប្រៀបធៀបជាមួយឆ្នាំ ២០០៧ ដែលមានថវិកាចំនួន ៣.២ លានដុល្លារ ។ ផ្នែកដែលមានការ កើនឡើងខ្លាំងជាងគេ គឺការងាររៀបចំគម្រោងការ និងគោលនយោបាយដែលនឹងអនុវត្តនៅឆ្នាំ ២០០៨ បន្ទាប់ពីច្បាប់រៀបចំអង្គការត្រូវបានអនុម័ត ដែលពាក់ព័ន្ធនឹងការរៀបចំបទប្បញ្ញត្តិនានា និងការរៀបចំកម្មវិធីជាតិថ្មីមួយ ។

## ៣. រាជរដ្ឋាភិបាល អ្នកផ្តល់ជំនួយ និងដៃគូក្នុងឆ្នាំ ២០០៨

### ៣.១ រាជរដ្ឋាភិបាលកម្ពុជា

ដូចមានបង្ហាញនៅក្នុងតារាងទី ៤ ខាងក្រោម ធនធានសរុបពីរាជរដ្ឋាភិបាល បានដាក់បញ្ចូលក្នុងផែនការសកម្មភាព និងថវិកាឆ្នាំ ២០០៨ ដែលមានចំនួនស្មើនឹង ២២.៦ លានដុល្លារ ឬស្មើនឹង ៣១%នៃធនធានសរុបរបស់ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ ២០០៨ ។ មួយភាគធំនៃធនធានទាំងអស់ ជាធនធានដែលបានមកពីថវិកាជាតិផ្តល់ដល់មូលនិធិឃុំ សង្កាត់ ចំណែកឯសមគុល្យ ជាមូលនិធិដៃគូសម្រាប់ចូលរួមជាមួយគម្រោងគាំទ្រដោយ IFAD និងធនាគារពិភពលោក ។

**តារាងទី៤ : រាជរដ្ឋាភិបាលកម្ពុជា**

| ប្រភេទថវិកា | ចំនួន | ភាគរយ |
|---|---|---|
| **វិនិយោគ** | **22,716,485** | **99.5%** |
| មូលនិធិឃុំ សង្កាត់ | 22,469,136 | 98.4% |
| មូលនិធិសម្រាប់ឃុំ សង្កាត់គោលដៅ | 37,910 | 0.2% |
| វិនិយោគខេត្ត ក្រុង | 197,718 | 0.9% |
| សេវាកម្មនានាតាមបណ្តាក្រសួង | 11,722 | 0.1% |
| **ការគាំទ្រកម្មវិធី** | **69,321** | **0.3%** |
| ការគាំទ្រកម្មវិធីនៅថ្នាក់ខេត្ត ក្រុង | 16,476 | 0.1% |
| គ.ជ.វ.វ/ក្រុមគាំទ្រកម្មវិធី | 52,845 | 0.2% |
| **ការសិក្សា ឬការវាយតម្លៃ** | **42,297** | **0.2%** |
| **សរុបរួម** | **$22,828,103** | **100%** |

### ៣.១.១ រាជរដ្ឋាភិបាលកម្ពុជា : មូលនិធិឃុំ សង្កាត់

ផ្អែកលើអនុក្រឹត្យ ដែលបានអនុម័តនៅថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០៧ ការវិភាជន៍ថវិកាជាតិក្នុងឆ្នាំ ២០០៨ ដល់មូលនិធិឃុំ សង្កាត់ ត្រូវបានកំណត់មិនឱ្យតិចជាង ២.៧% នៃចំណូលក្នុងស្រុកសរុបក្នុងឆ្នាំ ២០០៧ ។ ផ្អែកលើមូលដ្ឋាននេះ មូលនិធិឃុំ សង្កាត់នៅឆ្នាំ ២០០៨ ត្រូវបានកំណត់ចំនួន ៨៧.៨០៩ កោដិរៀល ស្មើនឹង ២១.៦៨១.២៣៥ ដុល្លារ (អត្រា ៤.០៥០ រៀល=១ ដុល្លារ) ។ បន្ទាប់មកមានការអនុម័តនូវថវិកាចំនួន ៣.១៩១ កោដិរៀល (៧៨៧.៩០១ ដុល្លារ) សម្រាប់បង្កើនប្រាក់បៀវត្សរ៍ប្រចាំខែរបស់មេភូមិ និងអនុប្រធានភូមិ ដែលបានជ្រើសរើសដោយក្រុមប្រឹក្សាឃុំ សង្កាត់នៅពាក់កណ្តាលឆ្នាំ ២០០៦ ។ ដូច្នេះថវិកាបដិភាគសរុបរបស់រាជរដ្ឋាភិបាលដល់មូលនិធិឃុំ សង្កាត់មានចំនួន ៩១ កោដិរៀល ស្មើនឹង ២២.៤៦៩.១៣៦ ដុល្លារ និងមានការកើនឡើងចំនួន ៣.៤៥៧ កោដិរៀល (៨៥៨.០០០ ដុល្លារ) ឬស្មើនឹង ៣.៩% លើសការវិភាជន៍មូលនិធិឃុំ សង្កាត់ក្នុងឆ្នាំ ២០០៧ ។ ក្នុងឆ្នាំ ២០០៨ គម្រោង PSDD បានចូលរួមបដិភាគដល់មូលនិធិឃុំ សង្កាត់ចំនួន ៥០០.០០០ ដុល្លារ ស្មើនឹង ២.០២៥ កោដិរៀល ដូច្នេះចំនួនមូលនិធិឃុំ សង្កាត់ សរុបទាំងអស់ក្នុងឆ្នាំ ២០០៨ គឺ ៩៣.០២៥ កោដិរៀល ស្មើនឹង ២២.៩៦៩.១៣៦ ដុល្លារ (ការវិភាជន៍លំអិតនៃមូលនិធិឃុំ សង្កាត់មានរៀបរាប់ក្នុងផ្នែកទី ៧.១ ខាងក្រោម) ។

### ៣.១.២ រាជរដ្ឋាភិបាលកម្ពុជា : មូលនិធិដៃគូ

បន្ថែមលើមូលនិធិឃុំ សង្កាត់ រាជរដ្ឋាភិបាលកម្ពុជាបានចូលរួមបដិភាគជាសាច់ប្រាក់ជាមួយគម្រោង ២ ដែលគាំទ្រដោយ IFAD និងគម្រោង WB/RILG ដែលមានទឹកប្រាក់សរុបចំនួន ៣៨៧.២៤៦ ដុល្លារ ។ ដូចបានបង្ហាញនៅក្នុងតារាងខាងលើ នៅក្នុងប្រភេទវិនិយោគ មានការបដិភាគដល់ឃុំ សង្កាត់គោលដៅ វិនិយោគខេត្ត ក្រុង និងសេវាកម្មនានារបស់ក្រសួងស្ថាប័នថ្នាក់ជាតិ នៅក្នុងគម្រោងគាំទ្រដោយ IFAD និងប្រភេទថវិកាគាំទ្រកម្មវិធីដែលបានមកពីគម្រោងគាំទ្រដោយ IFAD និងធនាគារពិភពលោក ។ គួរកត់សម្គាល់ថា ការចូលរួមបដិភាគភាគច្រើនរបស់រាជរដ្ឋាភិបាល គឺសម្រាប់ថ្លៃប្រើប្រាស់ ប្រាក់បៀវត្សរ៍ ថ្លៃប្រតិបត្តិការធម្មតា និងថ្លៃពន្ធទាំងឡាយ ហើយថ្លៃទាំងនេះមិនបានបញ្ចូលក្នុងផែនការសកម្មភាព និងថវិការបស់ គ.ជ.វ.វ ទេ ។

## ៣.២ ធនាគារពិភពលោក

### ៣.២.១ គម្រោងវិនិយោគជនបទ និងអភិបាលកិច្ចមូលដ្ឋាន (RILGP)

គម្រោងវិនិយោគជនបទ និងអភិបាលកិច្ចមូលដ្ឋាន មានគោលបំណងចូលរួមចំណែកអភិវឌ្ឍជនបទ និងកាត់បន្ថយភាពក្រីក្រតាមរយៈការផ្តល់នូវទ្រព្យសម្បត្តិសាធារណៈដែលជាអាទិភាពនៅថ្នាក់ឃុំ សង្កាត់ ព្រមទាំងជំរុញអភិបាលកិច្ចល្អនៅថ្នាក់មូលដ្ឋានតាមរយៈការគាំទ្រប្រព័ន្ធអភិបាលកិច្ចមូលដ្ឋានដោយមានការចូលរួម និងតាមបែបវិមជ្ឈការ។ ក្នុងឆ្នាំ២០០៧ គម្រោងវិនិយោគជនបទ និងអភិបាលកិច្ចមូលដ្ឋាន បានអនុម័តផ្តល់មូលនិធិបន្ថែមចំនួន

៣៧ លានដុល្លារ សម្រាប់រយៈពេល៤ ឆ្នាំ ដោយគិតចាប់ពីឆ្នាំ២០០៧ ដល់ ២០១០។ គម្រោងនេះមានពីរសមាសភាគធំៗដូចខាងក្រោម :

### សមាសភាគទី១ : ការធ្វើផែនការ និងវិនិយោគមូលដ្ឋាន

គម្រោងផ្តល់ការគាំទ្រតាមរយៈមូលនិធិឃុំ សង្កាត់ និងដំណើរការកសាងផែនការបែបវិមជ្ឈការនៅថ្នាក់ឃុំ សង្កាត់។ ការចំណាយសម្រាប់គម្រោងមូលនិធិឃុំ សង្កាត់ ដែលអនុវត្តដោយរាជរដ្ឋាភិបាលកម្ពុជា នឹងត្រូវទូទាត់ចេញពីប្រាក់កម្ចី ហើយមូលនិធិដែលទទួលបានពីការទូទាត់នេះនឹងត្រូវប្រើប្រាស់ជាមូលនិធិឃុំ សង្កាត់បន្តទៀត។ លក្ខណៈវិនិច្ឆ័យនៃការចំណាយដែលអាចទូទាត់បានរួមមានដូចជា ទីតាំងស្ថិតនៅក្នុងខេត្តគោលដៅនៃគម្រោង (ខេត្ត ក្រុងគោលដៅនឹងត្រូវបានពង្រីកពី ១៤ ទៅ ២៣ ចាប់ពីឆ្នាំ ២០០៨ តទៅ) គម្រោងដែលមានលទ្ធផលវិជ្ជមាន និងមានអនុលោមភាពទៅនឹងបែបបទនីតិវិធីកន្លងមក។ ក្នុងឆ្នាំ២០០៨ មូលនិធិសរុបចំនួន ១០.៥លានដុល្លារ ត្រូវបានគ្រោងសម្រាប់ទូទាត់គម្រោងវិនិយោគដែលបានប្រើប្រាស់មូលនិធិឃុំ សង្កាត់។

**តារាងទី៥ : ការបែងចែកមូលនិធិរបស់ធនាគារពិភពលោកឆ្នាំ២០០៨**

| ប្រភេទថវិកា | RILG | DfGG-OWSO | LASED | សរុប | ភាគរយ |
|---|---|---|---|---|---|
| **វិនិយោគ** | **10,509,156** | **494,505** | **390,000** | **11,393,661** | **77%** |
| មូលនិធិឃុំ សង្កាត់ | 10,509,156 | | | 10,509,156 | 71% |
| មូលនិធិសម្រាប់ឃុំ សង្កាត់គោលដៅ | | | 300,000 | 300,000 | 2% |
| វិនិយោគនៅថ្នាក់ស្រុក ខណ្ឌ | | 494,505 | 40,000 | 534,505 | 4% |
| កម្មវិធីវិស័យបែបវិសហមជ្ឈការ | | | 50,000 | 50,000 | 0% |
| សេវាកម្មនានាតាមបណ្តាក្រសួង | | | | | 0% |
| **ការគាំទ្រកម្មវិធី** | **1,169,615** | **112,370** | **287,681** | **1,569,666** | **9%** |
| ការគាំទ្រកម្មវិធីនៅថ្នាក់ខេត្ត ក្រុង | | 38,160 | 50,000 | 88,160 | 1% |
| គ.ជ.វ.វ/ក្រុមគាំទ្រកម្មវិធី | 1,169,615 | 74,210 | 237,681 | 1,481,506 | 10% |
| **ជំនួយបច្ចេកទេស** | **1,489,671** | **169,600** | **120,000** | **1,779,271** | **11%** |
| ជំនួយបច្ចេកទេសនៅថ្នាក់ជាតិ | 403,730 | 99,600 | 120,000 | 623,330 | 4% |
| ការសិក្សា ឬការវាយតម្លៃ | 1,085,941 | 70,000 | | 1,155,941 | 8% |
| **សរុបរួម** | **$13,168,442** | **$776,475** | **$797,681** | **$14,742,598** | **100%** |

### សមាសភាគទី២ : គាំទ្រផ្នែកគោលនយោបាយ និងការគ្រប់គ្រងគម្រោង

គម្រោងផ្តល់ការគាំទ្រដល់ការកសាងសមត្ថភាព ការផ្តល់ជំនួយបច្ចេកទេស លទ្ធកម្មសាងសង់និងបរិក្ខារ និងចំណាយប្រតិបត្តិការនៅថ្នាក់ជាតិ ខេត្តក្រុង និងឃុំសង្កាត់ សម្រាប់អនុវត្តសមាសភាគទី១។ លើសពីនេះទៀត

គម្រោងក៏បានគាំទ្រថវិកាសម្រាប់សេវាពិគ្រោះយោបល់ ដែលមានបំណងសិក្សាជាយុទ្ធសាស្ត្រទាក់ទងនឹងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ការសិក្សាតាមដានអំពីសេដ្ឋកិច្ច-សង្គម ការវាយតម្លៃពាក់កណ្ដាលគម្រោង និងការវាយតម្លៃបញ្ចប់គម្រោង ព្រមទាំងចូលរួមចំណែកក្នុងការធ្វើសវនកម្មប្រចាំឆ្នាំ និងសវនកម្មពីខាងក្រៅ។ ក្នុងឆ្នាំ២០០៨ មូលនិធិសរុបចំនួន ២.៧លានដុល្លារ ត្រូវបានគ្រោងសម្រាប់សមាសភាគទី២ ដោយរួមបញ្ចូលទាំងការផ្ដល់មូលនិធិសម្រាប់ការរៀបចំបង្កើតកម្មវិធីថ្នាក់ជាតិថ្មី ទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធ និងវិមជ្ឈការសារពើពន្ធ ការសិក្សាទ្រង់ទ្រាយធំ និងការពិនិត្យឡើងវិញដែលបានឆ្លុះបញ្ចាំងនៅក្នុងឧបសម្ព័ន្ធទី៣ដូចជា ការសិក្សាអំពីវិមជ្ឈការ និងវិសហមជ្ឈការដែលបានគ្រោងសម្រាប់ឆ្នាំ២០០៨ លទ្ធកម្មអំពីការដឹកជញ្ជូន បរិក្ខារការិយាល័យ និងការសាងសង់អាគារចំនួនបួនសម្រាប់គណៈកម្មាធិការប្រតិបត្តិ និងចូលរួមចំណែកសម្រាប់ចំណាយប្រតិបត្តិការរបស់ គ.ជ.វ.វ/ក្រុមគាំទ្រកម្មវិធី។

### ៣.២.២ តម្រូវការសម្រាប់អភិបាលកិច្ចល្អ : សមាសភាគច្រកចេញចូលតែមួយ

ធនាគារពិភពលោកនឹងបញ្ចប់ការរៀបចំបង្កើត "គម្រោងតម្រូវការសម្រាប់អភិបាលកិច្ចល្អ" នាពេលខាងមុខ។ គម្រោងនេះបានបញ្ចូលសមាសភាពមួយគឺ ការពង្រឹង និងពង្រីកការិយាល័យច្រកចេញចូលតែមួយ ដោយផ្អែកតាមបទពិសោធន៍ល្អៗពីការអនុវត្តសាកល្បងនៅស្រុកមួយចំនួនក្នុងខេត្តបាត់ដំបង និងខេត្តសៀមរាបអស់រយៈពេលជាងបួនឆ្នាំកន្លងមក ដែលទទួលការគាំទ្រពី Asia Urbs និង Konrad Adenhauer។ គោលបំណងនៃការិយាល័យច្រកចេញចូលតែមួយគឺត្រូវផ្ដល់សេវារដ្ឋបាលបានពេញលេញ ប្រកបដោយប្រសិទ្ធភាព រហ័ស តម្លាភាព និងមានតម្លៃសមរម្យដល់ប្រជាពលរដ្ឋនៅក្នុងស្រុក ខណ្ឌគោលដៅ តាមរយៈ ក).បង្កើតការិយាល័យច្រកចេញចូលតែមួយដែលអនុវត្តមុខងារដ៏មានប្រសិទ្ធភាព ខ).ធ្វើប្រតិភូកម្មនូវរាល់សេវាកម្មសមស្របនានាដល់ការិយាល័យច្រកចេញចូលតែមួយ គ).បង្កើតឱ្យមានយន្តការនៃការចូលរួមរបស់ប្រជាពលរដ្ឋ និង ឃ).បង្កើតឱ្យមានការិយាល័យទទួលបណ្ដឹងដើម្បីផ្ដល់ឱកាសឱ្យប្រជាពលរដ្ឋបង្ហាញនូវកង្វល់របស់ពួកគេ ដាក់ពាក្យបណ្ដឹង និងស្នើសុំឱ្យមានការបញ្ជាក់ឡើងវិញជាដើម។

ការិយាល័យច្រកចេញចូលតែមួយ នឹងត្រូវប្រតិបត្តិដោយក្រុមគាំទ្រកម្មវិធីនៃ គ.ជ.វ.វ ដោយប្រើប្រាស់រចនាសម្ព័ន្ធ និងប្រព័ន្ធដែលមានស្រាប់នៅថ្នាក់ក្រោមជាតិ។ ខណៈដែលគម្រោង DDfG នឹងត្រូវបានអនុម័តនាចុងឆ្នាំ២០០៨ ការរៀបចំសកម្មភាពសម្រាប់ស្រុកសាកល្បងដែលមានស្រាប់ចំនួនពីរ និងស្រុក ខណ្ឌគោលដៅថ្មីចំនួន៧ដែលបានពង្រីកនឹងត្រូវអនុវត្តក្នុងឆ្នាំ២០០៨នេះ។

### ៣.២.៣ គម្រោងបែងចែកដីធ្លី និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម (LASED)

គម្រោងបែងចែកដីធ្លី និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ក៏ជាគម្រោងមួយដែលស្ថិតក្នុងការរៀបចំបង្កើតក្នុងឆ្នាំ២០០៨ ហើយរំពឹងថានឹងអនុម័តដោយក្រុមប្រឹក្សារបស់ធនាគារពិភពលោកនាពាក់កណ្ដាលឆ្នាំនេះ។ គម្រោងបែងចែកដីធ្លី និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម គឺជាគម្រោងមួយដែលផ្ដល់ការគាំទ្រដល់កម្មវិធីបែងចែកដីសម្បទាន

សង្គមកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការចែករំលែកដីដល់គ្រួសារគ្មានដីធ្លី និងគ្រួសារដែលមានដីតិចតួចតាមរយៈ ដីសម្បទានសង្គមកិច្ចដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅរបស់គ្រួសារក្រីក្រ និងគ្រួសារងាយរងគ្រោះ។ គម្រោងនេះមាន៤សមាសភាពផ្សេងៗគ្នា រួមមាន : ការធ្វើផែនការសម្បទានដីសង្គមកិច្ចនៅឃុំ សង្កាត់ និងការបែងចែកដីធ្លី ការផ្តល់សេវាកម្ម និងហេដ្ឋារចនាសម្ព័ន្ធជនបទក្នុងការគាំទ្រដល់សម្បទានដីសង្គមកិច្ច ការបង្កើតកម្មវិធីដីសម្បទានសង្គមកិច្ចប្រកបដោយតម្លាភាព និងនិរន្តរភាព ព្រមទាំងរដ្ឋបាល និងការគ្រប់គ្រងគម្រោង។

នៅក្រោមកិច្ចព្រមព្រៀងរវាងក្រសួងមហាផ្ទៃ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គម្រោងបែងចែកដីធ្លី និងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម នឹងត្រូវប្រតិបត្តិដោយក្រុមគាំទ្រកម្មវិធីនៃ គ.ជ.វ.វ ដោយប្រើប្រាស់ប្រព័ន្ធ និងរចនាសម្ព័ន្ធដែលមានស្រាប់នៅថ្នាក់ក្រោមជាតិសម្រាប់ការអនុវត្ត ដោយឡែកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នឹងត្រួតពិនិត្យលើការអនុវត្តសមាសភាពទីមួយ ដោយផ្តោតជាសំខាន់លើការធ្វើផែនការដីសម្បទានសង្គមកិច្ចនៅឃុំ សង្កាត់ និងការបែងចែកដីធ្លី ។ នៅក្នុងឆ្នាំដំបូង គម្រោងនឹងកំណត់យកឃុំចំនួន ៤ នៅក្នុងខេត្តកំពង់ចាម និងខេត្តក្រចេះ។

## ៣.៣ ធនាគារអភិវឌ្ឍន៍អាស៊ី

ធនាគារអភិវឌ្ឍន៍អាស៊ីមានគម្រោងពីរសម្រាប់គាំទ្រដល់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ គម្រោងទាំងពីរនោះរួមមាន គម្រោងអភិវឌ្ឍន៍ក្រុមប្រឹក្សាឃុំ សង្កាត់ជំហានទី២ និងគម្រោងទ្រទ្រង់ជីវភាពប្រជាជនបឹងទន្លេសាប ដែលគម្រោងទាំងពីរនេះចាប់ផ្តើមអនុវត្តក្នុងឆ្នាំ២០០៦/២០០៧។ ដោយធ្វើការឆ្លុះបញ្ចាំងទៅនឹងតារាងទី៦: ការវិភាជន៍មូលនិធិរបស់ធនាគារអភិវឌ្ឍន៍អាស៊ីសម្រាប់ឆ្នាំ២០០៨ ឃើញថាមានមូលនិធិសរុបចំនួន ១២,៦ លានដុល្លារ ត្រូវបានបញ្ចូលក្នុងផែនការថវិកាឆ្នាំ២០០៨ សម្រាប់គម្រោងទាំងពីរនេះ។

### ៣.៣.១ គម្រោងអភិវឌ្ឍន៍ក្រុមប្រឹក្សាឃុំ សង្កាត់ជំហានទី២

គម្រោងអភិវឌ្ឍន៍ក្រុមប្រឹក្សាឃុំ សង្កាត់ជំហានទី២ ត្រូវបានផ្តល់មូលនិធិដោយធនាគារអភិវឌ្ឍន៍អាស៊ីមានរយៈពេលពីរឆ្នាំ ដែលត្រូវអនុវត្តបន្តពីគម្រោងអភិវឌ្ឍន៍ក្រុមប្រឹក្សាឃុំ សង្កាត់ជំហានទី១ ។ គម្រោងអភិវឌ្ឍន៍ក្រុមប្រឹក្សាឃុំ សង្កាត់ជំហានទី២ មាន៣សមាសភាគដូចខាងក្រោម :

#### សមាសភាគទី១ : ផ្តល់មធ្យោបាយសម្រាប់ឃុំសង្កាត់

គម្រោងនឹងបន្តគាំទ្រក្នុងការផ្តល់មធ្យោបាយគ្រប់គ្រាន់សម្រាប់ការអនុវត្តការងារ និងការប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ព្រមទាំងការអនុវត្តការងារ និងការប្រជុំជាសាធារណៈ ដែលបង្ហាញអំពីតួនាទី និងភាពចាំបាច់នៃប្រជាធិបតេយ្យនៅមូលដ្ឋានក្នុងឃុំ សង្កាត់។ សាលាឃុំ សង្កាត់ចំនួន១៩០ ត្រូវបានគ្រោងសាងសង់បន្ថែមនៅក្នុងឆ្នាំ ២០០៨។

## សមាសភាគទី២ : ការបង្កើតប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន

គម្រោងនឹងបន្តពង្រឹងការរៀបចំ និងអនុវត្តប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋានក្នុងកុំព្យូទ័រប្រកបដោយនិរន្តរភាព ដោយរក្សាទុកនូវសៀវភៅអត្រានុកូលដ្ឋាន ព្រមទាំងមានទិន្នន័យមូលដ្ឋានសំខាន់ៗដែលមានវិសាលភាពធំធេង អាចស្រាវជ្រាវបាន និងអាចជាមជ្ឈមណ្ឌលទិន្នន័យផងដែរ ។

## សមាសភាគទី៣ : ការកសាងសមត្ថភាព

គម្រោងនឹងបន្តគាំទ្រមូលនិធិសម្រាប់ការបណ្តុះបណ្តាលក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀនឃុំ សង្កាត់ និងមន្ត្រីរដ្ឋាភិបាល ព្រមទាំងការផ្សព្វផ្សាយទ្រង់ទ្រាយធំ ដើម្បីឱ្យគោលបំណង និងដំណើរការនៃការអនុវត្តប្រជាធិបតេយ្យនៅមូលដ្ឋានមានលក្ខណៈស្របគ្នា ។

ក្នុងឆ្នាំ២០០៨ គម្រោងអភិវឌ្ឍន៍ក្រុមប្រឹក្សាឃុំសង្កាត់ជំហានទី២គ្រោងផ្តល់មូលនិធិចំនួន ៣.៩៩៣.០០០ ដុល្លារសម្រាប់សាងសង់សាលាឃុំសង្កាត់ចំនួន១៩០ ដែលសាលាឃុំ សង្កាត់នីមួយៗនឹងត្រូវចំណាយប្រមាណ ២១.០០០ ដុល្លារ ។ ការជ្រើសរើសឃុំ សង្កាត់សម្រាប់សាងសង់សាលាឃុំ ត្រូវផ្អែកលើលក្ខណៈវិនិច្ឆ័យដែលបានបង្កើតដោយក្រសួងមហាផ្ទៃ ហើយត្រូវអនុវត្តតាមគោលការណ៍ដែលបានកំណត់ដោយរួមបញ្ចូលទាំង ការធ្វើលទ្ធកម្មដែលមានការប្រកួតប្រជែង ការប្រើប្រាស់គណនីនៃធនាគារពាណិជ្ជសម្រាប់ទូទាត់ជាមួយអ្នកទទួលការជាដើម ។ ក្នុងសមាសភាពទី២ គម្រោងបានគ្រោងថវិកាចំនួន ៤២៤.៤០០ ដុល្លារសម្រាប់លទ្ធកម្មម៉ាស៊ីនកុំព្យូទ័រ ចំណាយពាក់ព័ន្ធនឹងការរៀបចំបង្កើតប្រព័ន្ធកុំព្យូទ័រ ការធ្វើតេស្តសាកល្បង ការបណ្តុះបណ្តាលមន្ត្រីប្រតិបត្តិការអំពីរបៀបប្រើប្រាស់ឧបករណ៍ និងការបញ្ចូលទិន្នន័យ ។

មូលនិធិចំនួន ៤៩៤.៤០០ដុល្លារ ត្រូវបានបែងចែកសម្រាប់សមាសភាពទី៣ ដែលក្នុងនោះ ៣០២.៤០០ដុល្លារគ្រោងសម្រាប់សកម្មភាពបណ្តុះបណ្តាលលើប្រធានបទជាអាទិភាព ដែលមាននៅក្នុងផែនការកសាងសមត្ថភាពរបស់ គ.ជ.វ.វ ឆ្នាំ២០០៨ និង ១៩២.០០០ ដុល្លារប្រើជាមូលនិធិសម្រាប់ផ្សព្វផ្សាយព័ត៌មាន ។ មូលនិធិផ្សព្វផ្សាយព័ត៌មាននឹងត្រូវបានប្រើប្រាស់សម្រាប់ការផលិត ការផ្សព្វផ្សាយ និងការវាយតម្លៃអំពីព័ត៌មានវិមជ្ឈការ និងប្រជាធិបតេយ្យនៅមូលដ្ឋាន ដោយប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានចម្រុះដូចជា វេទិកា ទូរទស្សន៍ វិទ្យុ ព្រឹត្តិប័ត្រជាដើម ដែលត្រូវធ្វើលទ្ធកម្មដោយមានការប្រកួតប្រជែង ។ ជាចុងក្រោយ មូលនិធិចំនួន ៣៧២.០០០ដុល្លារ ត្រូវបានបែងចែកសម្រាប់ជំនួយបច្ចេកទេស និងការសិក្សាវាយតម្លៃលើសមាសភាគទាំងបី ។

**តារាងទី៦ ៖ ការវិភាជន៍មូលនិធិរបស់ធនាគារអភិវឌ្ឍន៍អាស៊ី**

| ប្រភេទថវិកា | CCDP | TSSL | សរុប | ភាគរយ |
|---|---|---|---|---|
| **វិនិយោគ** | **3,993,000** | **5,693,000** | **9,686,000** | **0%** |
| មូលនិធិសម្រាប់ឃុំ សង្កាត់គោលដៅ | 3,993,000 | 5,693,000 | 9,686,000 | 77% |
| **ការគាំទ្រកម្មវិធី** | **1,004,800** | **526,000** | **1,530,800** | **12%** |
| ការគាំទ្រផ្នែកគាំទ្រគម្រោងនៅថ្នាក់ខេត្ត ក្រុង | | 40,000 | 40,000 | 0% |
| ការគាំទ្រផ្នែកគាំទ្រគម្រោងនៅថ្នាក់ជាតិ | 1,004,800 | 486,000 | 1,490,800 | 12% |
| **ជំនួយបច្ចេកទេស** | **372,000** | **1,000,066** | **1,372,066** | **11%** |
| ជំនួយបច្ចេកទេសនៅថ្នាក់ខេត្ត ក្រុង . | | 415,666 | 415,666 | 3% |
| ជំនួយបច្ចេកទេសនៅថ្នាក់ជាតិ | 152,000 | 271,800 | 423,800 | 3% |
| ជំនួយបច្ចេកទេសអន្តរជាតិ | 180,000 | | 180,000 | 1% |
| ការសិក្សា ឬការវាយតម្លៃ | 40,000 | 312,600 | 352,600 | 3% |
| **សរុបរួម** | **$5,369,800** | **$7,219,066** | **$12,588,866** | **100%** |

### ៣.៣.២ គម្រោងទ្រទ្រង់ជីវភាពប្រជាជនបឹងទន្លេសាប

គម្រោងទ្រទ្រង់ជីវភាពប្រជាជនបឹងទន្លេសាប មានមូលនិធិដែលជាជំនួយឥតសំណងចំនួន ១៥លានដុល្លារ ទទួលបានពីមូលនិធិពិសេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី និងមូលនិធិចំនួនចំនួន ៤.៧៤លានដុល្លារដែលជាជំនួយឥតសំណងរបស់រដ្ឋាភិបាលហ្វាំងឡង់សម្រាប់ចំណាយរដ្ឋបាលរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ហើយរាជរដ្ឋាភិបាលកម្ពុជាបានចូលរួមចំណែកចំនួន ០.៦០លានដុល្លារ ។ ការផ្ដល់ជំនួយចូលជាធរមានចាប់ពីថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០០៦ ហើយរយៈពេលនៃការប្រើប្រាស់នឹងត្រូវបញ្ចប់នៅថ្ងៃទី៣០ មិថុនា ឆ្នាំ២០១០ ដែលក្រសួងមហាផ្ទៃគឺជាភ្នាក់ងារប្រតិបត្តិ ។

បរិបទនៃគម្រោងគឺ កម្រងផ្តួចផ្តើមបឹងទន្លេសាប ភាពជាដៃគូនៃអង្គការនានា និងការធ្វើការរួមគ្នារបស់ប្រជាពលរដ្ឋដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមផ្នែកបរិស្ថាន និងភាពក្រីក្រ ដោយផ្អែកលើយុទ្ធសាស្ត្រអាងទន្លេសាបដែលលើកតម្កើង ជំរុញ និងសម្របសម្រួល (១).ផ្តោតលើអ្នកក្រីក្រ និរន្តរភាពនៃកំណើនសេដ្ឋកិច្ច (២).ការទទួលបាននូវធនធាន និង (៣).ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន។ គោលការណ៍នៃយុទ្ធសាស្ត្រអាងទន្លេសាបរួមមាន (១).និរន្តរភាពនៃជីវភាពរស់នៅ (២).ភាពយុត្តិធម៌នៅក្នុងសង្គម និង (៣).អនុវត្តសម្រាប់ផ្ទៃអាងបឹងទាំងមូល។ គម្រោងទ្រទ្រង់ជីវភាពប្រជាជនបឹងទន្លេសាប នឹងចូលរួមធ្វើឱ្យប្រសើរឡើងនូវជីវភាពដោយបង្កើនការទទួលបានធនធានដោយសហគមន៍នៅក្នុងខេត្ត ក្រុង ចំនួន៥ ដែលនៅជុំវិញបឹងទន្លេសាប។ តំបន់គោលដៅនៃគម្រោងព័ទ្ធជុំវិញតំបន់ទ្រនាប់ និងតំបន់ស្នូលនៃបរិមណ្ឌលជីវមណ្ឌលបឹងទន្លេសាប ។ ជាពិសេស គម្រោងគ្របដណ្តប់លើ

ឃុំគោលដៅ ចំនួន៣៧ ដែលមានភូមិចំនួន៣១៦ភូមិ ក្នុងនោះមានប្រជាជន ២៨៧.៤៣០នាក់ ស្មើនឹង ៥៤.៨៥៧ គ្រួសារ ។ គម្រោងមានសមាសភាគធំៗចំនួនបីដូចខាងក្រោម :

**សមាសភាគទី១ :** ការអភិវឌ្ឍន៍ដោយសហគមន៍ ត្រូវបានអនុវត្តដោយក្រសួងមហាផ្ទៃ ដែលរួមបញ្ចូលមូលនិធិទ្រទ្រង់ជីវភាពសហគមន៍មួយ (CLF) ដែលបានគ្រប់គ្រងដោយក្រុមប្រឹក្សាឃុំ ហើយផ្តល់ថវិកាជំនួយសំរាប់ហេដ្ឋារចនាសម្ព័ន្ធសង្គម ការទ្រទ្រង់ជីវភាពរស់នៅ សហគមន៍នេសាទ ក៏ដូចជាជំនួយសំរាប់រៀបចំ និងអនុវត្តកញ្ចប់មូលនិធិវិនិយោគទ្រទ្រង់ជីវភាពរស់នៅ ។

**សមាសភាគទី២ :** សុវត្ថិភាពតំបន់ស្នូល ត្រូវបានអនុវត្តដោយលេខាធិការដ្ឋានបឹងទន្លេសាប ដែលនឹងបង្កើតមូលដ្ឋានព័ត៌មានមួយ និងផ្តួចផ្តើមប្រព័ន្ធគ្រប់គ្រងមួយសំរាប់តំបន់ស្នូល និងរៀបចំបណ្តាញប្រសើរមួយនៃជំរកត្រី ។

**សមាសភាគទី៣ :** ការផ្តល់នូវជំនាញ និងការយល់ដឹងសំរាប់ការចិញ្ចឹមជីវិតរស់នៅប្រកបដោយនិរន្តភាព នឹង (១) គាំទ្រការសម្របសម្រួលល្អប្រសើរនៃកិច្ចអភិវឌ្ឍន៍ដោយសហគមន៍ ដែលមានក្រុមប្រឹក្សាអភិវឌ្ឍន៍កសិកម្ម និងជនបទ (CARD) ជាភ្នាក់ងារអភិវឌ្ឍន៍ (២) បង្កើនជំនាញជាមូលដ្ឋានសំរាប់ការអភិវឌ្ឍន៍ ដោយសហគមន៍ដែលមានក្រសួងមហាផ្ទៃជាភ្នាក់ងារអនុវត្ត និង (៣) អប់រំបរិស្ថានដើម្បីការពារធនធានធម្មជាតិ ដែលមានក្រសួងបរិស្ថានជាភ្នាក់ងារអនុវត្ត ។

ដូចបានបង្ហាញនៅក្នុងតារាងទី៦ខាងលើ ការទូទាត់គម្រោងក្នុងឆ្នាំ២០០៨ មានចំនួនរហូតដល់ ៧.២លានដុល្លាររួមបញ្ចូលថវិកាប៉ាន់ប្រមាណ ៥.៧លានដុល្លារនៃមូលនិធិជំនួយទ្រទ្រង់ជីវភាពសហគមន៍ដោយក្រុមប្រឹក្សាឃុំ ។

## ៣.៤ គម្រោងគាំទ្រការអភិវឌ្ឍន៍បែបប្រជាធិបតេយ្យតាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ (PSDD)

គម្រោងគាំទ្រការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យតាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ ជាគម្រោងមានរយៈពេល៣ឆ្នាំ ដែលមានថវិកាសរុប ៣៥លានដុល្លារ គាំទ្រមូលនិធិដោយ UK/DfID, Swedish/Sida និង UNDP ត្រូវបានអនុម័តដោយគណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅថ្ងៃទី ២៤ ខែមករា ឆ្នាំ២០០៧ និងចាប់ផ្តើមអនុវត្តនៅថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០០៧។ គម្រោង PSDD រួមមាន ៣សមាសភាគដូចខាងក្រោម :

**សមាសភាគទី១ :** គាំទ្រការរក្សា និងពង្រឹងប្រព័ន្ធ និងរចនាសម្ព័ន្ធរដ្ឋបាលមូលដ្ឋាននៅក្នុងរយៈពេលអន្តរកាល ដើម្បីអោយការវិនិយោគរបស់រាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍នៅថ្នាក់ក្រោមជាតិអាចរក្សាដំណើរការទៅមុខលើកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ។

**សមាសភាគទី២ :** គាំទ្រការកែលម្អគុណភាព ការទទួលបាន និងសមធម៌នៃការផ្តល់សេវានៅថ្នាក់ក្រោមជាតិ ។

**សមាសភាគទី៣ :** ការគាំទ្រក្របខ័ណ្ឌគោលនយោបាយ ច្បាប់ នយោបាយ ស្ថាប័ន និងរដ្ឋបាលដែលមានប្រសិទ្ធភាព ដែលផ្តល់ដល់ប្រជាពលរដ្ឋក្រីក្រនូវលទ្ធភាពប្រើប្រាស់ និងផលប្រយោជន៍កាន់តែច្រើនថែមទៀតពីសេវាកម្មមូលដ្ឋាន នៅពេលដែលច្បាប់អង្គការស្តីពីវិមជ្ឈការ និងវិសហមជ្ឈការត្រូវបានអនុម័ត។

ក្នុងការបន្តពីគម្រោងភាពជាដៃគូសម្រាប់អភិបាលកិច្ចមូលដ្ឋាន (PLG) ដែលមានរយៈពេល៦ឆ្នាំគម្រោង PSDD នឹងបន្តផ្តល់ការគាំទ្រហិរញ្ញប្បទាន និងបច្ចេកទេសស្នូលសំរាប់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ របស់រាជរដ្ឋាភិបាលកម្ពុជានៅក្រោមការទទួលខុសត្រូវរបស់គ.ជ.វ.វ តាមរយៈបែបបទប្រតិបត្តិជាតិ។ ការអនុវត្ត គម្រោង PSDD គឺស្ថិតក្រោមការទទួលខុសត្រូវផ្ទាល់របស់ក្រុមគាំទ្រកម្មវិធី គ.ជ.វ.វ។

**តារាងទី៧ : ធនធាននានាសម្រាប់គម្រោង PSDD ឆ្នាំ២០០៨**

| ម្ចាស់ជំនួយ | ចំនួន | ភាគរយ |
|---|---|---|
| ចក្រភពអង់គ្លេស/DfID | 5,200,000 | 44% |
| ប្រទេសស៊ុយអែត/SIDA | 4,600,000 | 39% |
| កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) | 1,200,000 | 10% |
| សល់ពីឆ្នាំ២០០៧ | 700,000 | 6% |
| **សរុប** | **$11,700,000** | **100%** |

ដូចបង្ហាញនៅក្នុងតារាងទី៧ : ធនធានគម្រោង PSDD ឆ្នាំ២០០៨ ខាងលើ ថវិកាសរុបចំនួន ១១.៧លាន ដុល្លា មានក្នុងឆ្នាំ២០០៨ ហើយបានដាក់បញ្ចូលទៅក្នុងផែនការសកម្មភាពនិងថវិកាឆ្នាំ២០០៨ ដែលបានអនុម័តដោយ គ.ជ.វ.វ។ ធនធាន PSDD សរុបបានផ្តល់សំរាប់កម្មវិធីនៅក្នុងផែនការសកម្មភាព និងថវិកាគ.ជ.វ.វមានចំនួន ១១.៤លានដុល្លារ ដូចបានបង្ហាញនៅក្នុងតារាងទី៨ : ការវិភាជន៍របស់គម្រោង PSDDឆ្នាំ២០០៨ ខាងក្រោម។ ធនធានគម្រោង PSDD ត្រូវបានរៀបចំដោយក្រុមគាំទ្រកម្មវិធី គ.ជ.វ.វ នៅរវាងខែសីហា និងធ្នូ តាមរយៈដំណើរ ការពិគ្រោះយោបល់ ដែលដឹកនាំដោយរដ្ឋាភិបាលមួយនៅគ្រប់ថ្នាក់ស្របតាមរូបមន្ត និងលក្ខណៈវិនិច្ឆ័យដែលបាន កំណត់។ ការវិភាជន៍មូលនិធិវិនិយោគថ្នាក់ក្រោមជាតិ រួមមាន វិភាគទាន៥០០.០០០ដុល្លារ ដល់មូលនិធិឃុំសង្កាត់ មូលនិធិជំនួយតាមវិស័យ ២៤០.០០០ដុល្លារ សំរាប់ស្ត្រី និងកុមារឃុំនៅក្នុង១៨ខេត្ត ថវិកា ៤០៨.០០០ដុល្លារត្រូវបាន វិភាជន៍ដល់ ២៨ស្រុកនៅក្នុង ១៤ខេត្ត សំរាប់កម្មវិធីសាកល្បងពង្រឹងតួនាទីស្រុក ខណ្ឌ និងវិភាគទានប្រហែល ២លានដុល្លា សំរាប់មូលនិធិវិនិយោគខេត្ត ក្រុង ក្នុង២៤ខេត្ត ក្រុង។ ការវិភាជន៍សំរាប់ការគាំទ្រកម្មវិធីនៅថ្នាក់ក្រោម ជាតិដល់គណៈកម្មាធិការប្រតិបត្តិ ក្នុងឆ្នាំ២០០៨ មានចំនួនរហូតដល់ ៣.៧លានដុល្លារ ដើម្បីផ្តល់ហិរញ្ញប្បទានសំរាប់ មុខងារផ្សេងៗទាក់ទងទៅនឹង ការគ្រប់គ្រង ការសម្របសម្រួល ការផ្តល់សេវាហិរញ្ញវត្ថុ និងបច្ចេកទេស ការតាមដាន ការវាយតម្លៃ និងការធ្វើរបាយការណ៍ និងការកសាងសមត្ថភាព។ សេវាកម្មទាំងនេះ ផ្តល់ផលប្រយោជន៍ដល់អ្នកផ្តល់ ជំនួយទាំងអស់ដែលនៅក្រោមក្របខ័ណ្ឌផែនការសកម្មភាព និងថវិការបស់គ.ជ.វ.វ។ ការវិភាជន៍ទាំងអស់នេះ ត្រូវ

បានរៀបចំដោយអ្នកទទួលខុសត្រូវថ្នាក់ក្រោមជាតិនៅក្នុងទម្រង់ជាកិច្ចសន្យាប្រចាំឆ្នាំ ដែលកំណត់លទ្ធផលរំពឹងទុក សកម្មភាព និងថវិកាគ្រោងជាក់លាក់ ហើយដែលត្រូវបានវាយតំលៃ និងអនុម័តដោយអ្នកទទួលខុសត្រូវពាក់ព័ន្ធ។ ព័ត៌មានកិច្ចសន្យាលំអិតត្រូវបានរក្សាទុកនៅក្នុងពត៌មានទិន្នន័យនានាដោយក្រុមគាំទ្រកម្មវិធី គ.ជ.វ.វ ដែលត្រូវបានប្រើប្រាស់សំរាប់ការវាយការណ៍វឌ្ឍនភាព។

**តារាងទី៨ : ការបែងចែកមូលនិធិគម្រោង PSDD ឆ្នាំ២០០៨**

| ប្រភេទថវិកា | ចំនួន | ភាគរយ |
|---|---:|---:|
| **វិនិយោគ** | **3,644,963** | **32.0%** |
| មូលនិធិឃុំ សង្កាត់ | 500,000 | 4.4% |
| មូលនិធិសម្រាប់ឃុំ សង្កាត់គោលដៅ | 239,800 | 2.1% |
| វិនិយោគនៅថ្នាក់ស្រុក ខណ្ឌ | 408,282 | 3.6% |
| មូលនិធិវិនិយោគខេត្ត ក្រុង | 1,996,881 | 17.5% |
| សេវាកម្មនានាតាមបណ្ដាក្រសួង | 500,000 | 4.4% |
| **ការគាំទ្រកម្មវិធី** | **4,347,023** | **38.1%** |
| ការគាំទ្រកម្មវិធីនៅថ្នាក់ខេត្ត ក្រុង | 3,697,023 | 32.4% |
| គ.ជ.វ.វ/ក្រុមគាំទ្រកម្មវិធី | 650,000 | 5.7% |
| **ជំនួយបច្ចេកទេស** | **3,406,609** | **29.9%** |
| ជំនួយបច្ចេកទេសនៅថ្នាក់ខេត្ត ក្រុង | 1,816,609 | 15.9% |
| ជំនួយបច្ចេកទេសនៅថ្នាក់ជាតិ | 1,030,000 | 9.0% |
| ការសិក្សា ឬការវាយតម្លៃ | 560,000 | 4.9% |
| **សរុបរួម** | **$11,398,595** | **100%** |

នៅថ្នាក់ជាតិ ការវិភាជន៍របស់គម្រោង PSDD ឆ្នាំ២០០៨ មានចំនួន ២០០.០០០ដុល្លារ បានវិភាជន៍ដល់ ៥ អនុគណៈកម្មការនៃ គ.ជ.វ.វ និង ៣០០.០០០ដុល្លារ ដល់១២ ក្រសួង ស្ថាប័នថ្នាក់ជាតិសំរាប់សកម្មភាពទាក់ទងនឹងការបង្កើតគោលនយោបាយ និងយុទ្ធសាស្ត្រស្តីពីវិមជ្ឈការ និងវិសហមជ្ឈការ ការគ្រប់គ្រង ការតាមដាន និងការបង្កើនសមត្ថភាពដល់អ្នកទទួលខុសត្រូវថ្នាក់ក្រោមជាតិ និងការងារវិស័យដែលទាក់ទងទៅនឹងអណត្តិជាក់លាក់ ។ ថវិកាចំនួន ៦៥០.០០០ដុល្លារ ក៏ត្រូវបានវិភាជន៍ផងដែរដល់ក្រុមគាំទ្រកម្មវិធី គ.ជ.វ.វ ដើម្បីគាំទ្រដល់ការគ្រប់គ្រង ការសម្របសម្រួល និងការធ្វើសុខដុមនីយកម្មទូទៅនៅក្នុងការអនុវត្ត ការតាមដាន និងការវាយតម្លៃ ផែនការសកម្មភាព និងថវិកាឆ្នាំ២០០៨ របស់ គ.ជ.វ.វ។

កិច្ចសហប្រតិបត្តិការនៅក្រោមគម្រោង PSDD ក្នុងឆ្នាំ២០០៨ រួមមាន : ក្រុមទីប្រឹក្សាថ្នាក់ខេត្ត ២៤ខេត្ត ក្រុង សរុបមានទីប្រឹក្សាចំនួន ១៤៤ នាក់ (ជាមធ្យម ៦នាក់ក្នុងមួយខេត្ត) ដែលគាំទ្រអភិបាលខេត្ត គណៈកម្មាធិការប្រតិបត្តិ និងមន្ទីរជំនាញពាក់ព័ន្ធថ្នាក់ខេត្ត នៅក្នុងការការគ្រប់គ្រង ការអនុវត្ត ការតាមដានធនធានកម្មវិធីទាំងអស់ដែលស្ថិតនៅក្រោមផែនការសកម្មភាព និងថវិការបស់ គ.ជ.វ.វ ក្រុមទីប្រឹក្សាថ្នាក់ជាតិមួយគាំទ្រដល់លេខាធិការដ្ឋាន និងក្រុមគាំទ្រកម្មវិធី ដែលរួមមាន ទីប្រឹក្សាជាតិ ១២នាក់ និងទីប្រឹក្សាបរទេស ៥នាក់ និងក្រុមទីប្រឹក្សានៅក្នុងនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃចំនួន៦នាក់ និងក្រុមទីប្រឹក្សាមួយនៅក្នុងក្រសួងកសិកម្ម ដែលមានទីប្រឹក្សាជាតិ ៣នាក់ និងបរទេស ១នាក់។ ដោយផ្តល់នូវកិរិតហិរញ្ញប្រទានខាងក្រៅខ្ពស់ ក្រុមទាំងនេះក៏ធ្វើអោយប្រាកដផងដែរថា ការតាមដានប្រកបដោយប្រសិទ្ធភាព ការវាយតំលៃ និងគណនេយ្យភាព ត្រូវបានធានាសំរាប់ផែនការសកម្មភាព និងថវិកាទាំងមូល។ សង្ខេបមក ធនធានគម្រោង PSDDសរុប ត្រូវបានវិភាជន៍សំរាប់កិច្ចសហប្រតិបត្តិការបច្ចេកទេសនៅក្នុងឆ្នាំ២០០៨ មានចំនួន ២,៨៧លានដុល្លារ ។ ជាចុងក្រោយ ថវិកាចំនួន ៥៦០.០០០ ដុល្លារ ត្រូវបានវិភាជន៍សំរាប់ការសិក្សានានា និងសេវាទីប្រឹក្សារយៈពេលខ្លី ដែលបានកំណត់នៅក្នុងឧបសម្ព័ន្ធទី៣ : ផែនការសិក្សានានាឆ្នាំ២០០៨ ស្តីពីវិមជ្ឈការ និងវិសហមជ្ឈការ។

## ៣.៥ មូលនិធិទ្រទ្រង់ជីវភាពរស់របស់ពហុដៃគូអភិវឌ្ឍន៍ សម្រាប់ការគ្រប់គ្រងធនធានធម្មជាតិ និងការទ្រទ្រង់ជីវភាពរស់នៅ (MDLF)

ការគ្រប់គ្រងធនធានធម្មជាតិ និងទ្រទ្រង់ជីវភាពរស់នៅ គឺជាកម្មវិធីរយៈពេលបួនឆ្នាំមួយ ដែលគាំទ្រថវិកាដោយរដ្ឋាភិបាលដាណឺម៉ាក និងចក្រភពអង់គ្លេស នៅក្រោមមូលនិធិទ្រទ្រង់ជីវភាពរស់នៅរបស់ពហុដៃគូអភិវឌ្ឍន៍ (MDLF)។ កម្មវិធី NRM&L មានសមាសភាគ៣ដែលមានទំនាក់ទំនងគ្នាទៅវិញទៅមក ផ្តោតលើ ការគ្រប់គ្រងធនធានធម្មជាតិតាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ សង្គមស៊ីវិលនិងទីផ្សារអ្នកក្រីក្រ និងការអភិវឌ្ឍន៍គោលនយោបាយ វិស័យសំរាប់ ការរៀបចំដែនដី ព្រៃឈើ និងជលផល។ សំរាប់គោលបំណងនៃផែនការសកម្មភាព និងថវិកាឆ្នាំ២០០៨ របស់ គ.ជ.វ.វ សមាសភាគគ្រប់គ្រងធនធានធម្មជាតិតាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ និងអនុសមាសភាគរៀបចំដែនដីត្រូវបានដាក់បញ្ចូល ដោយសារសមាសភាគទាំងនេះផ្ទេរធនធានទៅថ្នាក់ក្រោមជាតិ ហើយប្រើប្រាស់ប្រព័ន្ធ និងរចនាសម្ព័ន្ធគ្រប់គ្រងវិមជ្ឈការ និងវិសហមជ្ឈការដែលមានស្រាប់។

### ៣.៥.១ សមាសភាគគ្រប់គ្រងធនធានធម្មជាតិ តាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ

គោលបំណងអភិវឌ្ឍន៍សមាសភាគនេះ គឺកាត់បន្ថយភាពងាយរងគ្រោះរបស់អ្នកក្រីក្រនៅជនបទ ដែលជីវភាពរបស់ពួកគេពឹងផ្អែកតែទៅលើធនធានធម្មជាតិ ។ គោលបំណងបន្ទាន់ គឺការធ្វើឱ្យប្រសើរឡើងនូវដំណើរការអភិបាលកិច្ចមូលដ្ឋាន ដើម្បីឱ្យការគ្រប់គ្រងធនធានធម្មជាតិមាននិរន្តរភាពសំរាប់បំរើផលប្រយោជន៍ឱ្យអ្នកក្រីក្រ ។ លទ្ធផលគ្រោងរួមមាន : ភាពស៊ីចង្វាក់គ្នារវាងគោលនយោបាយគ្រប់គ្រងធនធានធម្មជាតិនៅក្នុងបរិបទវិមជ្ឈការ

និងវិសហមជ្ឈការត្រូវបានធ្វើឱ្យកាន់តែប្រសើរឡើង ច្បាប់ និងក្របខ័ណ្ឌការងារច្បាប់សំរាប់បញ្ជាបការគ្រប់គ្រងធនធានធម្មជាតិទៅក្នុងការធ្វើផែនការវិមជ្ឈការ និងវិសហមជ្ឈការត្រូវបានរៀបចំឡើង ទុនវិនិយោគសំរាប់គម្រោងគ្រប់គ្រងធនធានធម្មជាតិ និងជីវភាពរស់នៅត្រូវបានគាំទ្រទៅដល់ថ្នាក់ឃុំ តាមរយៈការចូលរួមរបស់សង្គមស៊ីវិល និងការធ្វើសេចក្តីសំរេចចិត្តនៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ឃុំ ដំណើរការកសាងផែនការអភិវឌ្ឍន៍ និងវិនិយោគនៅថ្នាក់ខេត្ត ដែលរួមបញ្ចូលនូវ សកម្មភាពគ្រប់គ្រងធនធានធម្មជាតិ និងជីវភាពរស់នៅត្រូវបានពង្រឹង និងការឆ្លើយតបរបស់ថ្នាក់ស្រុក ទៅនឹងតំរូវការរបស់អន្តរឃុំ ដើម្បីទទួលបាននូវទុនវិនិយោគសំរាប់សកម្មភាពគ្រប់គ្រងធនធានធម្មជាតិ និងជីវភាពរស់នៅ ត្រូវបានកែលំអឱ្យប្រសើរឡើង ។

ដូចបានបង្ហាញនៅក្នុងតារាងទី៩ : ការវិភាជន៍របស់មូលនិធិ MDLF ខាងក្រោម នៅក្នុងឆ្នាំ២០០៨ ថវិកាដែលបានសន្យាគាំទ្រសរុបពីសមាសភាគគ្រប់គ្រងធនធានធម្មជាតិ ដោយរួមបញ្ចូលផងដែរថវិកាសល់ពីឆ្នាំចាស់ មានចំនួនសរុប ៥,៧លានដុល្លារ ។ ធនធានវិនិយោគសរុបមានចំនួន ៥,២លានដុល្លារ រួមមានការវិភាជន៍ដល់ឃុំ សង្កាត់គោលដៅចំនួន ៤៩៩ឃុំ សង្កាត់ (ជាមធ្យម ៤.០០០ ដុល្លាក្នុងមួយឃុំ) ការវិភាជន៍ដល់កម្មវិធីសាកល្បងពង្រឹងតួនាទីថ្នាក់ស្រុករបស់ក្រសួងមហាផ្ទៃ ចំនួន ៦៦ស្រុក ខណ្ឌ (ជាមធ្យម ៣០.០០០ដុល្លារក្នុងមួយស្រុក) និងការវិភាជន៍ដល់ខេត្ត ក្រុងគោលដៅចំនួន ១០ សំរាប់សកម្មភាពគ្រប់គ្រងធនធានធម្មជាតិ និងទ្រទ្រង់ជីវភាពរស់នៅ ដែលអនុវត្តដោយមន្ទីរពាក់ព័ន្ធថ្នាក់ខេត្ត ក្រុង (ជាមធ្យម ៤០.០០០ដុល្លារក្នុងមួយខេត្ត) ។ ថវិកាសរុប ១០០.០០០ដុល្លារត្រូវបានវិភាជន៍ដល់ខេត្ត ក្រុងគោលដៅ សំរាប់គាំទ្រសកម្មភាពបណ្តុះបណ្តាល និងការសម្របសម្រួលដែលទាក់ទងនឹងការអនុវត្តមូលនិធិវិនិយោគ NRM នៅថ្នាក់ក្រោមជាតិ (ជាមធ្យម ១០.០០០ដុល្លារ ក្នុងមួយខេត្ត) ។

នៅថ្នាក់ជាតិ ថវិកាសរុប ៣៥០.០០០ដុល្លារ ត្រូវបានវិភាជន៍ចេញពី MDLF សំរាប់ជួលសេវាទីប្រឹក្សារយៈពេលខ្លីជាក់លាក់ ដែលនឹងរួមចំណែកទាំងការបង្កើតយុទ្ធសាស្ត្រសមាសភាគគ្រប់គ្រងធនធានធម្មជាតិ និងកម្មវិធីជាតិទូទៅពាក់ព័ន្ធដែលនៅសេសសល់ដទៃទៀត ។ ផែនការសេវាទីប្រឹក្សារយៈពេលខ្លី មានរួមបញ្ចូលនៅក្នុងឧបសម្ព័ន្ធ៣ : ផែនការសិក្សានានាឆ្នាំ២០០៨ ស្តីពីវិមជ្ឈការ និងវិសហមជ្ឈការ ។

សមាសភាគគ្រប់គ្រងធនធានធម្មជាតិ តាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ នឹងទទួលផលប្រយោជន៍ពីការគាំទ្រកម្មវិធី និងជំនួយបច្ចេកទេសដែលបានផ្តល់តាមរយៈក្រុមគាំទ្រកម្មវិធី គ.ជ.វ.វ និងគម្រោង PSDD ។ ឯកសារចម្លងស្តីពីផែនការសកម្មភាព និងថវិកាឆ្នាំ ២០០៨ របស់សមាសភាគគ្រប់គ្រងធនធានធម្មជាតិតាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ អាចរកបាននៅលេខាធិការដ្ឋាន គ.ជ.វ.វ ។

**តារាងទី៩ : ការវិភាជន៍មូលនិធិគម្រោង MDLF ឆ្នាំ២០០៨**

| ប្រភេទថវិកា | NRM in D&D | NRM in Land | សរុប | ភាគរយ |
|---|---|---|---|---|
| **វិនិយោគ** | **5,190,320** | **1,303,442** | **6,493,762** | **89%** |
| មូលនិធិសម្រាប់ឃុំ សង្កាត់គោលដៅ | 1,996,000 | | 1,996,000 | 27% |
| វិនិយោគនៅថ្នាក់ស្រុក ខណ្ឌ | 2,772,268 | | 2,772,268 | 38% |
| មូលនិធិវិនិយោគខេត្ត ក្រុង | 422,053 | | 422,053 | 6% |
| កម្មវិធីវិស័យបែបបរិស្ថានមជ្ឈការ | | 613,442 | 613,442 | 8% |
| សេវាកម្មនានាតាមបណ្តាក្រសួង | | 690,000 | 690,000 | 9% |
| **ការគាំទ្រកម្មវិធី** | **120,000** | **0** | **120,000** | **2%** |
| ការគាំទ្រកម្មវិធីនៅថ្នាក់ខេត្ត ក្រុង | 100,000 | | 100,000 | 1% |
| គ.ជ.វ.វ/ក្រុមគាំទ្រកម្មវិធី | 20,000 | | 20,000 | 0% |
| **ជំនួយបច្ចេកទេស** | **350,200** | **310,000** | **660,200** | **6%** |
| ជំនួយបច្ចេកទេសនៅថ្នាក់ខេត្ត ក្រុង | | 100,000 | 100,000 | 1% |
| ជំនួយបច្ចេកទេសនៅថ្នាក់ជាតិ | | 60,000 | 60,000 | 1% |
| ការសិក្សា ឬការវាយតម្លៃ | 350,200 | 150,000 | 500,200 | 7% |
| **សរុបរួម** | **$5,660,520** | **$1,613,442** | **$7,273,962** | **100%** |

### ៣.៥.២ សមាសភាគគ្រប់គ្រងដីធ្លី

គោលបំណងអភិវឌ្ឍន៍របស់សមាសភាគគ្រប់គ្រងដីធ្លី គឺដើម្បីកាត់បន្ថយភាពងាយរងគ្រោះរបស់ប្រជាពលរដ្ឋក្រីក្រជនបទ ដែលមានជីវភាពរស់នៅពឹងផ្អែកលើធនធានធម្មជាតិ ។ គោលបំណងបន្ទាន់គឺកម្មសិទ្ធិដីធ្លី និងសិទ្ធិនៅក្នុងការប្រើប្រាស់ដីធ្លី និងធនធានធម្មជាតិត្រូវបានធានា ។ លទ្ធផលរំពឹងទុករួមមាន : ក). គោលនយោបាយវិស័យ និងអន្តរវិស័យមានភាពទាក់ទងគ្នាដើម្បីជម្រុញដល់ការគ្រប់គ្រងដីធ្លី ខ). ក្របខ័ណ្ឌគតិយុត្តិ និងបទប្បញ្ញត្តិសម្រាប់ការរៀបចំផែនការប្រើប្រាស់ និងគ្រប់គ្រងដីត្រូវបានរៀបចំ គ). សមត្ថភាពស្ថាប័ននៃអគ្គនាយកដ្ឋានគ្រប់គ្រងដីធ្លី និងផែនការទីប្រជុំជនត្រូវបានរៀបចំ ឃ). សេចក្តីណែនាំស្តីពីការរៀបចំផែនការប្រើប្រាស់ដី ការចុះបញ្ជីដីធ្លីដាច់ដោយដុំ និងការគ្រប់គ្រងធនធានធម្មជាតិ ឧបករណ៍ និងគំរូនានាសម្រាប់ការផ្តល់សេវាកម្ម ត្រូវបានអនុវត្ត ង). ការមានលទ្ធភាពទទួលបានព័ត៌មានស្តីពីការគ្រប់គ្រងដី ដោយសង្គមស៊ីវិលត្រូវបានកែលម្អ ច). ផ្តល់ការគាំទ្រទុនវិនិយោគ ដើម្បីអនុវត្តការរៀបចំផែនការប្រើប្រាស់ និងការគ្រប់គ្រងដីធ្លី ជាផ្នែកមួយនៃកម្មវិធីនាពេលអនាគតនៅក្នុងវិស័យដីធ្លី ។

ដូចដែលបានឆ្លុះបញ្ចាំងនៅក្នុងតារាងទី៩ខាងលើ នៅក្នុងឆ្នាំ២០០៨នេះ ថវិកាសរុបដែលបានអនុម័តនៅក្នុងសមាសភាគគ្រប់គ្រងដីធ្លី សម្រាប់សកម្មភាពនានានៅថ្នាក់ក្រោមជាតិ មានចំនួនសរុប ៦១៥,០០០ដុល្លារ ។

ថវិកានេះ បានគ្រោងដើម្បីគាំទ្រដល់ : ក). ការកសាងសមត្ថភាពនៃការិយាល័យគ្រប់គ្រងដីធ្លីខេត្ត និងស្រុក ខ). ការបង្កើត និងការអនុវត្តកន្សោមអាទិភាព សម្រាប់ការរៀបចំផែនការប្រើប្រាស់ដីធ្លី និងផែនទី គ). ការផ្តល់ទុនវិនិយោគគាំទ្រដល់ ការរៀបចំផែនការប្រើប្រាស់ដីឃុំ សង្កាត់ ជាផ្នែកមួយនៃការដាក់បញ្ចូលក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍន៍/វិនិយោគឃុំ សង្កាត់ ឃ). គាំទ្រដល់សកម្មភាពរៀបចំផែនទី និងការកំណត់ព្រំប្រទល់ឃុំ សង្កាត់ ការកំណត់ និងការរៀបចំផែនទីដីរដ្ឋ ការចុះបញ្ជីដីសហគមន៍ និងការដោះស្រាយវិវាទដីធ្លី ។

សមាសភាគគ្រប់គ្រងដីធ្លី នឹងអនុវត្តដោយអគ្គនាយកដ្ឋានគ្រប់គ្រងដី នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។ សមាសភាគនេះ នឹងទទួលផលពីជំនួយផ្នែកបច្ចេកទេសដ៏ទូលំទូលាយទាំងនៅថ្នាក់ជាតិ និងខេត្ត ។ ឯកសារស្តីពីផែនការសកម្មភាព និងថវិកានៃសមាសភាគគ្រប់គ្រងដីធ្លី សម្រាប់ឆ្នាំ២០០៨ មាននៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

## ៣.៦ មូលនិធិអន្តរជាតិសម្រាប់ការអភិវឌ្ឍន៍កសិកម្ម (IFAD)

នៅក្នុងឆ្នាំ២០០៨ គម្រោង IFAD ចំនួនពីរបានប្រតិបត្តិនៅក្រោមក្របខ័ណ្ឌផែនការសកម្មភាព និងថវិកា គ.ជ.វ.វ ដែលរួមមាន គម្រោងកាត់បន្ថយភាពក្រីក្រជនបទ (RPRP) នៅខេត្តព្រៃវែង និងស្វាយរៀង និងគម្រោងកែលម្អជីវភាព (RULIP) នៅខេត្តក្រចេះ ព្រះវិហារ និងរតនគិរី ។ ដូចដែលបានបង្ហាញនៅក្នុងតារាងទី ១០ : ការបែងចែកថវិកា IFAD ឆ្នាំ ២០០៨ ថវិការួមគ្នាសរុប ៥.៥លានដុល្លារនៃធនធានរបស់ IFAD បានគ្រោងគាំទ្រទៅដល់គម្រោងទាំងពីរនៅក្នុង ឆ្នាំ២០០៨ ។ ការចូលរួមចំណែកពីរាជរដ្ឋាភិបាលកម្ពុជា សម្រាប់គាំទ្រដល់គម្រោងទាំងពីរមានបង្ហាញនៅក្នុងផ្នែកទី៣.១ ខាងលើ ។ គម្រោងទាំងពីរនេះ ប្រើប្រាស់រចនាសម្ព័ន្ធ និងប្រព័ន្ធសម្រាប់ប្រតិបត្តិការនៅថ្នាក់ក្រោមជាតិ ហើយទទួលផល ពីការគាំទ្រទាំងផ្នែកបច្ចេកទេស និងថវិកាពី PSDD ។

**តារាងទី១០ : ការបែងចែកមូលនិធិ IFAD ឆ្នាំ២០០៨**

| ប្រភេទថវិកា | RPRP | RULIP | សរុប | ភាគរយ |
|---|---|---|---|---|
| **វិនិយោគ** | **3,225,025** | **1,631,657** | **4,856,682** | **88%** |
| មូលនិធិសម្រាប់ឃុំ សង្កាត់គោលដៅ | 720,313 | | 720,313 | 13% |
| កម្មវិធីវិស័យបែបវិសហមជ្ឈការ | 2,504,712 | 1,631,657 | 4,136,369 | 75% |
| **ការគាំទ្រកម្មវិធី** | **419,020** | **249,248** | **668,268** | **11%** |
| ការគាំទ្រកម្មវិធីនៅថ្នាក់ខេត្ត ក្រុង | 241,122 | 19,068 | 260,190 | 5% |
| ការគាំទ្រផ្នែកគាំទ្រគម្រោងនៅថ្នាក់ជាតិ | 150,858 | 230,180 | 381,038 | 7% |
| គ.ជ.វ.វ/ក្រុមគាំទ្រកម្មវិធី | 27,040 | | 27,040 | 0% |
| **សរុបរួម** | **$3,644,045** | **$1,880,905** | **$5,524,950** | **100%** |

### ៣.៦.១ គម្រោងកាត់បន្ថយភាពក្រីក្រនៅជនបទ (RPRP)

គម្រោង RPRP ជាគម្រោងកម្ចីដែលមានថវិកាសរុប ១៩.៦លានដុល្លារ សម្រាប់រយៈពេល៧ឆ្នាំ គ្របដណ្តប់ខេត្តព្រៃវែង និងស្វាយរៀងកំពុងស្ថិតនៅក្នុងឆ្នាំទី៥នៃការអនុវត្តគិតត្រឹមឆ្នាំ២០០៨ ។ គោលដៅរបស់គម្រោងនេះគឺសំដៅកាត់បន្ថយភាពក្រីក្រ១២០.៦០០គ្រួសារ តាមរយៈការកែលម្អជីវភាព ការពង្រឹងសមត្ថភាព ការរៀបចំប្រព័ន្ធកសិកម្ម និងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព ការអភិវឌ្ឍន៍ និងការស្តារហេដ្ឋារចនាសម្ព័ន្ធ ព្រមទាំងបង្កើនលទ្ធភាពប្រើប្រាស់បច្ចេកវិទ្យា សេវាកម្ម និងទីផ្សារ សម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម ។ គម្រោងនេះមានសមាសភាគ សំខាន់៣ : ក). វិនិយោគកសិកម្ម ខ). អភិវឌ្ឍន៍មូលដ្ឋាន និង គ). គាំទ្រស្ថាប័ន ។

ក្រសួងកសិកម្ម ទទួលខុសត្រូវរួមនៅក្នុងការសម្របសម្រួលចាប់តាំងពីដើមឆ្នាំ២០០៧ ហើយក្រុមគាំទ្រកម្មវិធី គ.ជ.វ.វ សម្របសម្រួលផ្នែកអភិវឌ្ឍន៍មូលដ្ឋាន ។ ជាមួយនឹងការរំពឹងលើការអនុម័តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នៅដើមឆ្នាំ២០០៨នេះ បានផ្តល់នូវឱកាសថ្មីនានាសម្រាប់ការពិគ្រោះគោលនយោបាយ ផ្អែកលើមេរៀន បទពិសោធន៍ដែលទទួលបានពី IFAD/PST ទាក់ទងទៅនឹងការផ្តោតការយកចិត្តទុកដាក់ចំពោះជនក្រីក្រ ការកាត់បន្ថយភាពក្រីក្រ និងវិមជ្ឈការ និងវិសហមជ្ឈការនៅក្នុងការអភិវឌ្ឍន៍កសិកម្ម និងការកាត់បន្ថយភាពក្រីក្រនៅជនបទ ។

នៅក្នុងឆ្នាំ២០០៨ នៅក្រោមសមាសភាគកសិកម្ម ថវិកាសរុប២.៩លានដុល្លា ត្រូវបានបែងចែកគាំទ្រដល់ការផ្តល់សេវាកម្ម និងសម្ភារៈកសិកម្មនានា ដល់កសិករក្រីក្រចូលរួមក្នុងកម្មវិធី ៤០.០០០នាក់ ។ សមាសភាគកសិកម្មនេះ សម្រេចបានការគ្របដណ្តប់ពីគម្រោងពេញលេញលើ៧៧ឃុំនៅក្នុង១៣ស្រុក (៥០ឃុំ ៨ស្រុកនៅក្នុងខេត្តព្រៃវែង និង ២៧ឃុំ ៥ស្រុក នៅក្នុងខេត្តស្វាយរៀង) តាំងពីឆ្នាំ២០០៧ ។ អ្នកផ្សព្វផ្សាយកសិកម្មឃុំ (CEW) សរុប១៦៨នាក់ បានចុះកិច្ចសន្យាជាមួយមន្ទីរកសិកម្មខេត្តទាំងពីរ ដើម្បីបន្តផ្តល់សេវាផ្សព្វផ្សាយកសិកម្មទៅដល់ក្រុមជួយខ្លួនឯងចំនួន ១.៦០០ នាក់ (៩៤៤ក្រុម នៅក្នុងខេត្តព្រៃវែង និង៦៥៦ក្រុម នៅក្នុងខេត្តស្វាយរៀង) ហើយនឹងអ្នកទទួលផលផ្ទាល់ចំនួន៤០.០០០គ្រួសារ ។ អ្នកផ្សព្វផ្សាយភូមិចំនួន៥០០ នាក់ បានបន្តទទួលនូវការបណ្តុះបណ្តាលលើជំនាញផ្សព្វផ្សាយកសិកម្ម និងមូលដ្ឋានបច្ចេកវិទ្យានានា ដើម្បីបំពេញភារកិច្ចជាបណ្តើរៗពី CEW នាពេលអនាគត ។

នៅក្នុងឆ្នាំ២០០៨ នៅក្រោមសមាសភាគអភិវឌ្ឍន៍មូលដ្ឋាន ថវិកាសរុបចំនួន ៧២០.០០០ដុល្លារ បានគ្រោងនៅក្រោមមូលនិធិអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធឃុំ (CIDF) រួមបញ្ចូលទាំងថវិកានៅសល់ពីឆ្នាំ២០០៧ ។ ធនធាននេះប្រើប្រាស់សម្រាប់ហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច ដែលបានលើកផែនការ និងចាត់អាទិភាពដោយឃុំ និងប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់ ។

ជាចុងក្រោយ សមាសភាគស្ថាប័នរួមមានកម្មវិធីគាំទ្រដល់ក្រសួងកសិកម្ម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងកិច្ចការនារី និងក្រុមគាំទ្រកម្មវិធី គ.ជ.វ.វ នៅថ្នាក់ជាតិ និងគណៈកម្មាធិការប្រតិបត្តិនៅក្នុងខេត្តទាំងពីរ

ដើម្បីធានាថា កម្មវិធីនេះបានគ្រប់គ្រង និងប្រតិបត្តិប្រកបដោយប្រសិទ្ធភាពស្របជាមួយយុទ្ធសាស្ត្រវិមជ្ឈការ និងវិសហមជ្ឈការ ហើយយេនឌ័រ ត្រូវបានបញ្ជ្រាបយ៉ាងពេញលេញតាមរយៈកម្មវិធី ។

### ៣.៦.២ គម្រោងលើកកំពស់ជីវភាពជនបទ (RULIP)

គម្រោង RULIP ថ្មីដែលមានរយៈពេល៧ឆ្នាំ មានថវិកាសរុប៩.២១លានដុល្លារ ប្រតិបត្តិដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ផ្តល់ថវិការរួមគ្នាពី UNDP បានចាប់ផ្តើមដំណើរការនាពាក់កណ្តាលឆ្នាំ២០០៧ ហើយនឹងចាប់ផ្តើមដំណើរការពេញលេញនៅក្នុងឆ្នាំ២០០៨ ។ នៅក្រោមផែនការសកម្មភាព និងថវិកាឆ្នាំ២០០៨ ថវិកាបែងចែកពី IFAD មានចំនួនសរុប ១.៩ ដុល្លារ ។ គម្រោងផ្តោតការយកចិត្តទុកដាក់លើការអភិវឌ្ឍន៍កសិកម្មតំបន់ខ្ពង់រាបនៅភាគឦសានក្នុងខេត្តក្រចេះ ព្រះវិហារ និងរតនគិរី ដែលរួមមាន២សមាសភាគ : ១). ការកែលម្អជីវភាព និង ២). គាំទ្រដល់វិមជ្ឈការ និងវិសហមជ្ឈការនៅក្នុងវិស័យកសិកម្ម ។

នៅក្រោមសមាសភាគកែលម្អជីវភាព គម្រោងនឹងផ្តោតការយកចិត្តទុកដាក់ដល់ការកែលម្អសុវត្ថិភាពស្បៀងដល់ពលរដ្ឋក្រីក្រ និងលើកកម្ពស់ប្រពលវប្បកម្មកសិកម្ម និងការអភិវឌ្ឍន៍ទីផ្សារសម្រាប់ផលិតផលកសិកម្ម ។ សមាសភាគនេះ ផ្អែកលើមូលដ្ឋានបទពិសោធវិជ្ជមានទទួលបានពី RPRP រួមមាន : ក្រុមជួយខ្លួនឯងជាមួយនឹងព័ត៌មានស្តីពីការកែលម្អជីវភាពរស់នៅ និងប្រព័ន្ធកសិកម្ម ការធ្វើផែនការមូលដ្ឋានដោយប្រើប្រាស់វិធីសាស្ត្រវិភាគប្រព័ន្ធកសិត្រ-បរិស្ថាន ការកសាងសមត្ថភាព និងគាំទ្រដល់អ្នកផ្តល់សេវាកម្មផ្សព្វផ្សាយ ។ កម្មវិធីផ្តល់ការគាំទ្របំពេញបន្ថែមដែលមានលក្ខណៈសមស្របនៅក្នុងសហគមន៍រួមមាន : (១). គាំទ្រដល់ការរៀបចំផែនការថ្នាក់ឃុំ និងការតាមដាន (២). គាំទ្រដល់អ្នកផ្សព្វ ផ្សាយភូមិ ភ្នាក់ងារពេទ្យសត្វ និងជលផលភូមិ (៣). ការបញ្ជ្រាបយេនឌ័រ (៤).គាំទ្រដល់ការចាប់ផ្តើមទីផ្សារ (៥). ការបង្ហាញប្រព័ន្ធកសិកម្មចម្រុះ (៦). ការគាំទ្រដល់វិស័យឯកជន (៧). ពិពណ៌ពាណិជ្ជកម្មស្រុក និង (៨).ការបង្កើតឡើងនូវ ក្លឹបយុវជន ។ ការគាំទ្រដល់សមាសភាគវិមជ្ឈការ និងវិសហមជ្ឈការនៅក្នុងវិស័យកសិកម្មរួមមាន៣សមាសភាគរង : (១). គាំទ្រដល់កម្មវិធីវិនិយោគកសិកម្មថ្នាក់ខេត្ត (២). គាំទ្រដល់ការបញ្ជ្រាបយេនឌ័រនៅក្នុងវិស័យកសិកម្ម និង(៣). ការរៀនសូត្រសហគមន៍ ។

## ៣.៧ សហគមន៍អឺរ៉ុប (EC)

សហគមន៍អឺរ៉ុបផ្តល់ហិរញ្ញវត្ថុគាំទ្រដល់គម្រោង២នៅក្នុងឆ្នាំ២០០៨ នៅក្រោមក្របខ័ណ្ឌរួមនៃគ.ជ.វ.វ ដែលគម្រោងទាំងពីរមានការចូលរួមផ្តល់ថវិកាគាំទ្រពី UNDP ។ ដូចដែលបានបង្ហាញនៅក្នុងតារាងទី១១ : ថវិកាផ្តល់រួមគ្នាដោយ EC-UNDP នៅក្នុងឆ្នាំ២០០៨ នៅក្រោមគម្រោងទាំង២មានចំនួនប្រមាណ ៥លានដុល្លារ រួមទាំងថវិកានៅសល់ពី ឆ្នាំ២០០៧ ។

## តារាងទី១១ ៖ ការចំណាយថវិកាមូលនិធិ EC-UNDP ឆ្នាំ២០០៨

| ប្រភេទថវិកា | DDLG | EFMP | សរុប | ភាគរយ |
|---|---|---|---|---|
| **វិនិយោគ** | **2,216,210** | **1,254,321** | **3,470,531** | **69%** |
| វិនិយោគថ្នាក់ស្រុក ខណ្ឌ/ICC | 2,216,210 | | 2,216,210 | 44% |
| កម្មវិធីវិស័យទាក់ទងនឹងវិសហមជ្ឈការ | | 1,254,321 | 1,254,321 | 25% |
| សេវាកម្មនានាតាមបណ្តាក្រសួង | | | 0 | 0% |
| **ការគាំទ្រកម្មវិធី** | **542,495** | **49,934** | **592,429** | **12%** |
| ការគាំទ្រកម្មវិធីនៅថ្នាក់ខេត្ត ក្រុង | 154,585 | 49,934 | 204,519 | 4% |
| ការគាំទ្រផ្នែកគាំទ្រគម្រោងនៅថ្នាក់ជាតិ | 387,910 | | 387,910 | 8% |
| **ជំនួយបច្ចេកទេស** | **868,500** | **73,064** | **941,564** | **19%** |
| ជំនួយបច្ចេកទេសនៅថ្នាក់ខេត្ត ក្រុង | | 29,000 | 29,000 | 1% |
| ជំនួយបច្ចេកទេសនៅថ្នាក់ជាតិ | 663,500 | | 663,500 | 13% |
| ការសិក្សា ឬការវាយតម្លៃ | 205,000 | 44,064 | 249,064 | 5% |
| **សរុបរួម** | **$3,627,204** | **$1,377,319** | **$5,004,523** | **100%** |

### ៣.៧.១ គម្រោងពង្រឹងប្រជាធិបតេយ្យ និងអភិបាលកិច្ចវិមជ្ឈការ

គម្រោង DDLG ដែលមានរយៈពេល៥ឆ្នាំ ថវិកាសរុប១០.៥លានអឺរ៉ូ ដែលមានការចូលរួមផ្តល់ថវិកាដោយ UNDP បានចាប់ផ្តើមអនុវត្តឆ្នាំទីពាររបស់ខ្លួននៅឆ្នាំ២០០៨នេះ ។ តាមរយៈការប្រើប្រាស់ក្រុមប្រឹក្សាឃុំ សង្កាត់ ជាចំនុចចាប់ផ្តើម គម្រោងនេះមានសមាសភាគចំនួន ៣ ដូចខាងក្រោម ៖

- ការបង្កើតអោយមានយន្តការបញ្ចេញមតិ និងទទួលខុសត្រូវដើម្បីកែលម្អការពិគ្រោះយោបល់លើកទឹកចិត្តភាពជាដៃគូ និងគណនេយ្យភាព ព្រមទាំងសម្របសម្រួលការកសាងសមត្ថភាព
- ការបង្កើតឡើងនូវបណ្តាញក្រុមប្រឹក្សាឃុំ សង្កាត់នៅថ្នាក់ខេត្ត និងជាតិ ជាភ្នាក់ងារពង្រឹងតួនាទីក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងដំណើរការវិមជ្ឈការ និង
- ផ្តោតការគាំទ្រដល់ជនក្រីក្រ គម្រោងអន្តរឃុំ សង្កាត់ ឬការអនុវត្តរួមគ្នាដើម្បីរួមចំណែកដល់ការអភិវឌ្ឍន៍មូលដ្ឋាន

ការគាំទ្រសម្ព័ន្ធភាពជាតិក្រុមប្រឹក្សាឃុំ សង្កាត់ គណៈកម្មការគម្រោងចម្រុះ បានឯកភាពបង្កើតនូវសមាគមខេត្ត ក្រុងនៃក្រុមប្រឹក្សាឃុំ សង្កាត់ (P/M ACS) នៅក្នុងខេត្ត ក្រុង ដែលនៅសល់ទាំង៨នៅចុង ឆ្នាំ២០០៨ ។ ការផ្តល់ការគាំទ្រដល់ P/M ACS នៅក្នុងការបំពេញតួនាទីរបស់ខ្លួនអោយក្លាយ ជាសម្របសម្រួល ពាំនាំព័ត៌មាន និងគាំពារមតិពីតម្រូវការ និងចំណាប់អារម្មណ៍របស់ក្រុមប្រឹក្សាឃុំ សង្កាត់ នៅក្នុងក្របខ័ណ្ឌដំណើរការកំណែទម្រង់ ។ នៅក្នុង

សមាសភាគ ICC ខេត្ត ក្រុងគោលដៅបច្ចុប្បន្នទាំង១០ នឹងនៅបន្តទទួលបានការគាំទ្រពីគម្រោង ដើម្បីធានាថា សមត្ថភាពបន្ថែមទៀតត្រូវបានកសាង តាមរយៈបទពិសោធន៍ និងការអនុវត្តដោយផ្ទាល់ ព្រមទាំងទទួលបាន ឥទ្ធិពលអតិបរមា ។

នៅក្នុងឆ្នាំ២០០៨នេះ គម្រោងកិច្ចសហប្រតិបត្តិការអន្តរឃុំ សង្កាត់នឹងមានថវិកាចំនួន ២,២លានដុល្លារ ហើយថវិកានេះបូករួមទាំងថវិកា ដែលនៅសល់ពីឆ្នាំ២០០៧ផងដែរ ត្រូវបានគ្រោងដើម្បីគាំទ្រដល់ការវិនិយោគ នឹងការរៀបចំសេវាកម្មនានា តាមរយៈការពិគ្រោះយោបល់ និងការធ្វើផែនការអន្តរឃុំ សង្កាត់ នៅក្នុងស្រុកគោលដៅ ប្រហែលជា៤៥ស្រុក ខណ្ឌ ១០ ខេត្ត ក្រុង ។ ការផ្តល់ថវិកាគាំទ្របន្ថែម ដែលមានចំនួនប្រហែលជា ១៦០.០០០ដុល្លារ នឹងត្រូវបានផ្តល់ទៅដល់គណៈកម្មាធិការប្រតិបត្តិខេត្ត ក្រុង ដើម្បីសម្របសម្រួល តាមដាន និងរាយការណ៍ពី សកម្មភាពនានានៅក្នុងការគាំទ្រដល់គម្រោងអន្តរឃុំ សង្កាត់ ។ នៅក្នុងឆ្នាំ២០០៨ សមាសភាគនេះ នឹងសាកល្បង កិច្ចសហប្រតិបត្តិការរវាងឃុំ សង្កាត់ដែលស្ថិតនៅជាប់នឹងស្រុក ខណ្ឌផងដែរ ។

### ៣.៧.២ មូលនិធិសហគមន៍អឺរ៉ុបសម្រាប់គម្រោងមីក្រូ (EFMP)

ផ្អែកកិច្ចព្រមព្រៀងហិរញ្ញវត្ថុរបស់ UNDP និងសហគមន៍អឺរ៉ុប គម្រោង EFMP រយៈពេល ២ ឆ្នាំ ដែល មានទឹកប្រាក់ចំនួន ១,៧ លានអឺរ៉ូ ត្រូវបានចុះហត្ថលេខាដោយផ្ទាល់រវាង UNDP និងអភិបាលខេត្តបាត់ដំបង និងជា ប្រធាន គ.អ.ជ.ខ។ គោលបំណងរួមរបស់គម្រោងនេះ គឺកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេសកម្ពុជា តាមរយៈការ គាំទ្រការកែលំអស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ចជាមូលដ្ឋាននៅក្នុងស្រុកគោលដៅចំនួន ៤ ក្នុងខេត្តបាត់ដំបង ។ គម្រោងនេះមានឃុំគោលដៅចំនួន២៤ នៅក្នុងស្រុកដែលបានជ្រើសរើសទាំងបួន ដែលពាក់ព័ន្ធនឹងការផ្តល់សេវាកម្ម និងទ្រព្យសម្បត្តិសាធារណៈជាមូលដ្ឋាន។ គំរោងនេះមានលទ្ធផលរំពឹងទុកយ៉ាងច្បាស់លាស់ដូចខាងក្រោម :

- ធ្វើអោយប្រសើរឡើងសំរាប់ថ្នាក់ភូមិអាចទំនាក់ទំនងបានជាមួយនឹងឃុំ និងឃុំជាមួយនឹងស្រុក និងអាច ចូលទៅ ដល់ទីផ្សារ និងការស្តារបនាឡើងវិញនូវផ្លូវថ្នល់ក្នុងខេត្ត ជាមួយនឹងប្រពន្ធ័បង្ហូរទឹកខ្វែងខ្វាត់។
- សាងសង់នូវសាលាបឋមសិក្សា និងវិទ្យាល័យ ដោយផ្តោតយកចិត្តទុកដាក់លើឃុំទាំងឡាយណាដែលសេវា ទាំងនោះមិនមាន ឬនៅឆ្ងាយពីភូមិរបស់ប្រជាពលរដ្ឋរស់នៅ ដែលរួមមានគ្រឿងសង្ហិមសម្រាប់ ថ្នាក់រៀន ទឹកស្អាត និងអនាម័យ។
- ការផ្តល់នូវការផ្គត់ផ្គង់ទឹកស្អាតសម្រាប់ប្រើប្រាស់ តាមរយៈការសាងសង់នូវប្រព័ន្ធចែកចាយទឹកដូចជា អណ្តូងលូ អណ្តូងស្នប់ និងសេវាមូលដ្ឋានអនាម័យ ។
- ជួយស្ត្រីក្រីក្រ និងងាយរងគ្រោះ ដើម្បីធ្វើឱ្យល្អប្រសើរនូវល័ក្ខខ័ណ្ឌនៃការរស់នៅសំរាប់ពួកគេ និងក្រុម គ្រួសារ ដោយអោយពួកគេចូលរៀនពីជំនាញទីផ្សារ នៅមជ្ឈមណ្ឌលបណ្តុះបណ្តាលថ្មីពីរនៅថ្នាក់ស្រុក។

នៅឆ្នាំ២០០៨ ថវិកាប្រហែល ១.៤ លានដុល្លារត្រូវបានរៀបចំ និងផ្ទេរដោយផ្ទាល់ពីអង្គការយូអិនឌីភីទៅគណ:កម្មាធិការប្រតិបត្តិនៃគណ:កម្មាធិការអភិវឌ្ឍន៍ជនបទខេត្តបាត់ដំបង។ គំរោង PSDD នឹងផ្តល់នូវការគាំទ្រលើផ្នែកបច្ចេកទេស។

## ៣.៨ អង្គការយូនីសេហ្វ/កម្មវិធីសិទ្ធិកុមារ

កម្មវិធីអង្គការយូនីសេហ្វ/សិទ្ធិកុមារ (សកម្មភាពសហគមន៍សំរាប់សិទ្ធិកុមារ) ត្រូវបានបញ្ចូលទៅក្នុងកម្មវិធីរបស់អង្គការយូនីសេហ្វប្រចាំប្រទេសសម្រាប់ឆ្នាំ ២០០៦-២០១០ ដែលបានចុះហត្ថលេខាជាមួយក្រសួងផែនការ ។ ចាប់តាំងពីឆ្នាំ ២០០៤ មក តាមរយ:អនុស្សារណ:នៃការយល់ដឹងជាមួយនឹងកម្មវិធីសិលា អង្គការយូនីសេហ្វបានប្រើប្រាស់រចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងថ្នាក់ខេត្ត សម្រាប់អនុវត្តផែនការការងារ និងថវិកាប្រចាំឆ្នាំរបស់កម្មវិធីសិទ្ធិកុមារ ដោយមានជំនួយបច្ចេកទេសពីគម្រោង PSDD ។ សេចក្តីណែនាំថ្មីរវាងអង្គការយូនីសេហ្វជាមួយគណ:កម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ (គ.ជ.វ.វ) ត្រូវបានរៀបចំដើម្បីបន្តនូវការចាត់ចែងលើភាពជាដៃគូក្នុងការគាំទ្រដល់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាលកម្ពុជា។

**កម្មវិធីសិទ្ធិកុមារ** ផ្តោតយកចិត្តទុកដាក់លើ : ក) គាំទ្រដល់កិច្ចសហប្រតិបត្តិការក្នុងចំណោមក្រសួងវិស័យរដ្ឋបាលថ្នាក់ក្រោមជាតិ (ខេត្ត ស្រុក) ក្រុមប្រឹក្សាឃុំ និងអ្នកផ្តល់សេវាសង្គមជួរមុខ ដើម្បីជំរុញការផ្តល់សេវាកម្មនៅថ្នាក់មូលដ្ឋាន និង ខ) ចូលរួមដល់ការកាត់បន្ថយអត្រាមរណ:ភាពរបស់កុមារ និងកែលំអការទទួលបាននូវការអប់រំថ្នាក់បឋមសិក្សានៅក្នុងប្រទេសកម្ពុជា ដោយជំរុញឱ្យទទួលបាននូវទឹកស្អាតសំរាប់បរិភោគ និងបរិស្ថានមានអនាម័យទាំងនៅតាមសហគមន៍ និងសាលាបឋមសិក្សា។

**កម្មវិធីសិទ្ធិកុមារ** មានគោលបំណងដើម្បីធ្វើការបញ្ជាក់ និងពង្រឹងទំនាក់ទំនងរវាងអ្នកអនុវត្តដទៃទៀតនៅក្នុងស្ថាប័នរាជរដ្ឋាភិបាល និងសង្គមស៊ីវិល ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការធ្វើផែនការ ការផ្តល់និងការទទួលបាននូវសេវានៅថ្នាក់មូលដ្ឋាន ដ៏ដូចជាការលើកកម្ពស់សេវាមូលដ្ឋានរបស់សហគមន៍ និងការការពារកុមារពីការបោះបង់ ការប្រកាន់ ពណ៌សម្បុរពូជសាសន៍ ការរំលោភ និងពីអំពើហិង្សា។

**កម្មវិធីសិទ្ធកុមារ** ផ្សំឡើងដោយគម្រោងចំនួន ២ គឺ :

### I. អភិបាលកិច្ចមូលដ្ឋានដើម្បីសិទ្ធិកុមារ

គោលបំណងនៃគម្រោងនេះ គឺលើកកំពស់សមត្ថភាពរបស់សមាជិកទាំងឡាយនៃរដ្ឋបាលថ្នាក់ក្រោមជាតិ និងអាជ្ញាធរមូលដ្ឋាននៅថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដើម្បី :

- វាយតម្លៃ និងវិភាគអតីតភាព និងបញ្ហាសំខាន់ៗ ដែលពាក់ព័ន្ធនឹងសិទ្ធិកុមារ និងស្ត្រី
- រៀបចំដំណោះស្រាយដែលមានលក្ខណ:សមស្រប អាចវាស់វែងបាន និងសាមញ្ញ ដើម្បីដោះស្រាយបញ្ហា និងអាទិភាពទាំងនោះ និង

▪ ធ្វើការតាមដាន និងត្រួតពិនិត្យលទ្ធផលក្នុងលក្ខណៈជាប្រព័ន្ធ

ការផ្តោតយកចិត្តទុកដាក់ជាសំខាន់របស់គម្រោង គឺការពង្រឹងកិច្ចសហប្រតិបត្តិការរវាងរដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងអ្នកផ្គត់ផ្គង់សេវាកម្មមូលដ្ឋាននានា ដើម្បីលើកកំពស់ទទួលបាន និងការផ្គត់ផ្គង់សេវាកម្ម ។ កម្មវិធីផ្តោតគោលដៅនៃការផ្តល់សេវាកម្មដូចជា សុខាភិបាល អប់រំ ការការពារ ទឹកស្អាត និងអនាម័យ និងការយកចិត្តទុកដាក់លើការទទួលបាន និងការប្រើប្រាស់នូវសេវាកម្មទាំងនេះ ។ គម្រោងក៏មានគោលបំណងលើកទឹកចិត្ត និងជំរុញការបញ្ចូលនៃសេវាកម្មទាំងនេះនៅក្នុងដំណើរការនៃការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ។

## II. អនាម័យបរិស្ថាន និងទឹក

គម្រោងមានគោលបំណងក្នុងការលើកកំពស់ការទទួលបាន និងប្រើប្រាស់ទឹកបរិភោគដែលមានសុវត្ថិភាព និងអនាម័យបរិស្ថានទាំងនៅតាមគេហដ្ឋាន និងសាលារៀន ។ គម្រោងក៏មានគោលបំណងក្នុងការពង្រឹងសមត្ថភាពរបស់ទីភ្នាក់ងារសំខាន់ៗរបស់រដ្ឋាភិបាលផងដែរ នៅថ្នាក់រដ្ឋបាលផ្សេងៗ ដើម្បីបំពេញតួនាទីរបស់ពួកគេក្នុងការផ្តល់សេវាកម្មអនាម័យ និងផ្គត់ផ្គង់ទឹកជនបទដែលមានគុណភាពល្អ ។

នៅថ្នាក់ខេត្ត សកម្មភាពទាំងអស់ដែលគាំទ្រថវិកាដោយកម្មវិធីសិទ្ធិកុមារ ត្រូវបានគ្រប់គ្រង និងសម្របសម្រួលដោយគណៈកម្មាធិការប្រតិបត្តិនៃ គ.អ.ជ.ខ និងអនុវត្តដោយមន្ទីរជំនាញនានា ស្របតាមអាណត្តិរបស់ពួកគេ ឬក៏អនុវត្តផ្ទាល់ដោយឃុំ សង្កាត់ ។

**តារាងទី១២ : ការវិភាជន៍មូលនិធិ UNICEF ឆ្នាំ២០០៨**

| ប្រភេទថវិកា | ចំនួន | ភាគរយ |
|---|---|---|
| **វិនិយោគ** | **2,978,612** | **84%** |
| មូលនិធិសម្រាប់ឃុំ សង្កាត់គោលដៅ | 347,886 | 10% |
| មូលនិធិវិនិយោគខេត្ត ក្រុង | 1,448,218 | 41% |
| សេវាកម្មនានាតាមបណ្តាក្រសួង | 1,182,508 | 33% |
| **ការគាំទ្រកម្មវិធី** | **274,547** | **8%** |
| ការគាំទ្រកម្មវិធីនៅថ្នាក់ខេត្ត ក្រុង | 274,547 | 8% |
| **ជំនួយបច្ចេកទេស** | **300,000** | **8%** |
| ជំនួយបច្ចេកទេសនៅថ្នាក់ខេត្ត ក្រុង | 150,000 | 4% |
| ជំនួយបច្ចេកទេសនៅថ្នាក់ជាតិ | 150,000 | 4% |
| **សរុប** | **$3,553,159** | **100%** |

នៅថ្នាក់ជាតិ កម្មវិធីសិទ្ធិកុមារ នឹងសហការដោយផ្ទាល់ជាមួយក្រសួងចំនួន ៤ ដែលជាសមាជិក គ.ជ.វ.វ : ក្រសួងមហាផ្ទៃ (នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន) ក្រសួងកិច្ចការនារី ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងផែនការ ។

ដូចមានបង្ហាញនៅក្នុងតារាងទី ១២ ខាងលើស្តីពី ការវិភាជន៍ថវិការបស់ UNICEF ឆ្នាំ ២០០៨. អង្គការ UNICEF បានរៀបចំជាកម្មវិធីដែលមានទឹកប្រាក់ចំនួន ៣.៥ លានដុល្លារ ។ នៅក្នុងឆ្នាំ ២០០៨ កម្មវិធីសិទ្ធិកុមារ នឹងបង្កើនឃុំគោលដៅពីចំនួន ៣១៧ ឃុំ ទៅ ៤២២ ឃុំ នៅក្នុងខេត្តគោលដៅទាំង ៦ ដែលខេត្តនីមួយៗនឹងទទួល បាននូវការវិភាជន៍បន្ថែម ដើម្បីគាំទ្រសកម្មភាពទាំងឡាយដែលពាក់ព័ន្ធនឹងការងារស្ត្រី និងកុមារ ។ ជារួម មានថវិកា ប្រហែល ១.៤៥ លានដុល្លារ ដែលបានរៀបចំជាកម្មវិធី ដើម្បីគាំទ្រសកម្មភាពវិស័យនានា ដែលអនុវត្តដោយមន្ទីរ ជំនាញដោយសាហការជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ និងថវិកាចំនួន ១.២លានដុល្លារ ត្រូវបានវិភាជន៍ឱ្យក្រសួងដែល ជាសមាជិក គ.ជ.វ.វ ចំនួន ៤ ដែលពាក់ព័ន្ធនឹងកម្មវិធីសិទ្ធិកុមារ ។ លើសពីនេះទៀត អង្គការ UNICEF បានចូលរួម បដិភាគចំនួន ២៧៥.០០០ ដុល្លារ ដើម្បីគាំទ្រកម្មវិធីខេត្ត ដែលក្នុងនោះថវិកាចំនួនប្រមាណ ៧៥.០០០ ដុល្លារសម្រាប់ ការគាំទ្រផ្នែកស្នូលនៃប្រតិបត្តិការរបស់ គ.ប្រ និងថវិកាចំនួន ២០០.០០០ ដុល្លារ សម្រាប់គាំទ្រអង្គភាពរដ្ឋបាលមូល ដ្ឋាននៃខេត្តគោលដៅទាំង ៦ ដើម្បីធ្វើការសម្របសម្រួល និងគាំទ្រដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ពាក់ព័ន្ធនឹងការងារស្ត្រី និងកុមារ ។

## ៣.៩ គម្រោង JICA របស់ប្រទេសជប៉ុន

រាជរដ្ឋាភិបាលជប៉ុនតាមរយៈទីភ្នាក់ងារ JICA បានគាំទ្រនូវការអនុវត្តគម្រោងមួយ ដែលមានឈ្មោះថា គម្រោងកែលម្អរដ្ឋបាលមូលដ្ឋាននៅកម្ពុជា (PILAC) ដែលនឹងចាប់ផ្តើមដំណាក់កាលលើកទីពីររបស់ខ្លួននៅក្នុងឆ្នាំ ២០០៨។ គោលដៅរួមរបស់គម្រោង PILAC នេះគឺការអភិវឌ្ឍធនធានមនុស្សលើផ្នែករដ្ឋបាលមូលដ្ឋាន តាមរយៈ ការបណ្តុះបណ្តាល និងពង្រឹងសមត្ថភាព ។ ចំពោះទិសដៅរបស់គម្រោង គឺកែលម្អសមត្ថភាពផ្នែកជំនាញគ្រប់គ្រង លើការងាររដ្ឋបាលមូលដ្ឋានរបស់មន្ត្រីនៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាននៅថ្នាក់កណ្តាល និងខេត្ត ក្រុង។

នៅក្នុងឆ្នាំ ២០០៨ ផែនការបណ្តុះបណ្តាលចំនួន ៤ វគ្គ ដែលគ្រោងនឹងផ្តល់ជូនដល់មន្ត្រីជាង ១.០០០ នាក់ រួមមានដូចខាងក្រោម:

ក). **វគ្គគ្រប់គ្រងការបណ្តុះបណ្តាល** : មន្ត្រីអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន នឹងអាចកែលម្អជំនាញគ្រប់គ្រងការ បណ្តុះបណ្តាល ព្រមទាំងទទួលបានចំណេះដឹងតាមរយៈការអនុវត្តការងារក្នុងតួនាទីជាអ្នកដឹកនាំ។

ខ). **ការបណ្តុះបណ្តាលលើគ្រូឧទ្ទេសថ្នាក់ជាតិ និងគ្រូតាមតំបន់** : មន្ត្រីដែលចូលរួមការបណ្តុះបណ្តាលគ្រូឧទ្ទេសថ្នាក់ ជាតិ និងតាមតំបន់ បង្កើនចំណេះដឹង និងជំនាញបច្ចេកទេសក្នុងការបណ្តុះបណ្តាល ព្រមទាំងទទួលបទពិសោធន៍ ការងារតាមរយៈធ្វើជាអ្នកសម្របសម្រួលវគ្គបណ្តុះបណ្តាល ។

**គ). វគ្គបណ្តុះបណ្តាលផ្នែក គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនិងរដ្ឋបាលមូលដ្ឋាន :** មន្ត្រីថ្នាក់កណ្តាល និងមន្ត្រីមកពីបណ្តាខេត្ត ក្រុង និងស្រុកគោលដៅ នឹងទទួលបានជំនាញនិងចំណេះដឹងលើផ្នែកគោលនយោបាយ វិមជ្ឈការ និងវិសហមជ្ឈការ និងផ្នែករដ្ឋបាលមូលដ្ឋានផងដែរ ។

**ឃ). វគ្គបណ្តុះបណ្តាលផ្នែករដ្ឋបាលមូលដ្ឋាននៅប្រទេសជប៉ុន:** មន្ត្រីថ្នាក់កណ្តាល និងខេត្ត ក្រុង ដែលត្រូវជ្រើសរើស ក្នុងការចូលរួមវគ្គបណ្តុះបណ្តាលនៅប្រទេសជប៉ុន ដើម្បីសិក្សាមុខជំនាញផ្នែករដ្ឋបាលមូលដ្ឋាន និងប្រព័ន្ធហិរញ្ញវត្ថុ និងប្រើប្រាស់ចំណេះដឹងទាំងនោះក្នុងការកែលម្អការអនុវត្តការងារនៅក្នុងប្រទេសកម្ពុជាឱ្យកាន់តែល្អប្រសើរ ។

ដូចមានបង្ហាញនៅក្នុងតារាងទី ១៣ ស្តីពីកាវិភាជន៍ឆ្នាំ ២០០៨ របស់ប្រទេសជប៉ុន គម្រោង PILAC នៅក្នុងឆ្នាំ ២០០៨ គ្រោងថវិកាចំនួន ១.៥ លានដុល្លារ ដើម្បីគាំទ្រអ្នកឯកទេសជំនាញរបស់គម្រោង និងគាំទ្រ សកម្មភាពបណ្តុះបណ្តាលដែលបានរៀបរាប់ដូចខាងលើ ។

**តារាងទី១៣ : ការវិភាជន៍មូលនិធិរបស់ជប៉ុនឆ្នាំ២០០៨**

| **ប្រភេទថវិកា** | **ចំនួន** | **ភាគរយ** |
|---|---:|:---:|
| វិនិយោគ | **0** | **0.0%** |
| ការគាំទ្រកម្មវិធី | **500,000** | **33.3%** |
| អង្គភាពការគាំទ្រគម្រោងថ្នាក់ជាតិ | 500,000 | 33.3% |
| **ជំនួយបច្ចេកទេស** | **1,000,000** | **66.7%** |
| ទីប្រឹក្សាបច្ចេកទេសជាតិ | 1,000,000 | 66.7% |
| សរុប | **$1,500,000** | **100%** |

## ៣.១០ រដ្ឋាភិបាលអាល្លឺម៉ង់ (GTZ)

រាជរដ្ឋាភិបាលអាល្លឺម៉ង់ ផ្តល់ការគាំទ្រលើការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅប្រទេស កម្ពុជាតាមរយៈការអនុវត្តគម្រោងសំខាន់ៗចំនួន២រួមមាន : កំណែទម្រង់រដ្ឋបាលនិងកម្មវិធីវិមជ្ឈការ (ARDP) ដែលគាំទ្រនៅថ្នាក់កណ្តាល និងកម្មវិធីអភិវឌ្ឍសេដ្ឋកិច្ចតំបន់ (RED) នៅក្នុងខេត្តសៀមរាប ។

### ៣.១០.១ កម្មវិធីកំណែទម្រង់រដ្ឋបាលនិងវិមជ្ឈការ (ARDP)

កម្មវិធីកំណែទម្រង់រដ្ឋបាល និងវិមជ្ឈការ (២០០៨-២០១១) បានអនុវត្តដំណាក់កាលទី៣ នាខែមករា ឆ្នាំ ២០០៨ ។ ដោយបន្តលើការអនុវត្តនាដំណាក់កន្លងមក កម្មវិធីនេះមានគោលដៅ " ស្ថាប័នថ្នាក់កណ្តាល អាជ្ញាធរ

ថ្នាក់ក្រោមជាតិ និងអង្គការសង្គមស៊ីវិលអនុវត្តកំណែទម្រង់រដ្ឋបាល និងវិមជ្ឈការឱ្យមានប្រសិទ្ធភាពខ្ពស់ "។ ក្នុងឆ្នាំ ២០០៨ កម្មវិធីផ្តោតលើសមាសភាគដូចខាងក្រោម :

- **អំណាច និងមុខងារ :** ធ្វើបច្ចុប្បន្នភាពប្រព័ន្ធទិន្នន័យអំពីអំណាច និងមុខងារ ការគាំទ្រដើម្បីឱ្យមានភាពច្បាស់លាស់ចំពោះមុខងារ និងសមត្ថកិច្ច និងតម្រូវការធនធាន និងការគាំទ្រលើដំណើរការធ្វើសេចក្តីសម្រេចចិត្តរវាងស្ថាប័នពាក់ព័ន្ធ។
- **ការអភិវឌ្ឍន៍សមត្ថភាព និងការបណ្តុះបណ្តាល :** ការអភិវឌ្ឍសមត្ថភាពដល់មន្ត្រីរាជការស៊ីវិល និងសង្គមស៊ីវិល ដើម្បីបង្កើនសមត្ថភាពគ្រប់គ្រងស្ថាប័នរដ្ឋ និងមិនមែនរដ្ឋក្នុងការចូលរួម និងរួមចំណែកលើការអនុវត្តកំណែទម្រង់ថ្នាក់ក្រោមជាតិ។
- **ការពង្រឹងសង្គមស៊ីវិល និងថ្នាក់ក្រោមជាតិ :** តាមរយៈការធ្វើការរួមគ្នារវាងរដ្ឋាភិបាល និងសង្គមស៊ីវិល ដោយមានគម្រោងផ្តួចផ្តើមក្នុងស្រុកជាមួយក្រសួងមហាផ្ទៃ និងការចូលរួមរបស់ក្រុមការងារដៃគូវិមជ្ឈការ (WGPD)។
- **ការបញ្ជ្រាបយេនឌ័រ :** គាំទ្រលើការពង្រឹងយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័ររបស់នាយកដ្ឋានរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃ ដូចជា វេទិកាស្ត្រីក្រុមប្រឹក្សាឃុំ សង្កាត់ និងការបង្កើតបណ្តាញអង្គការសង្គមស៊ីវិលដែលមាន ឈ្មោះថា " គណៈកម្មាធិការជំរុញការចូលរួមនយោបាយរបស់ស្ត្រី "

ដូចដែលបានបង្ហាញជូននៅក្នុងតារាងទី ១៤ ការគាំទ្រថវិការបស់រាជរដ្ឋាភិបាលអាល្លឺម៉ង់មានទឹកប្រាក់ ចំនួន ៨៥៥.០០០ ដុល្លារ សម្រាប់អនុវត្តគម្រោងសកម្មភាពឆ្នាំ ២០០៨ ក្នុងនោះរួមមាន ការគាំទ្រជំនួយបច្ចេកទេស ជាតិ និងអន្តរជាតិ ការសិក្សា និងសិក្ខាសាលា និងការបណ្តុះបណ្តាល។

**តារាងទី១៤ : ការវិភាគទានមូលនិធិ Germany/GTZ ឆ្នាំ២០០៨**

| ប្រភេទថវិកា | ARDP | RED | សរុប |
|---|---|---|---|
| ជំនួយបច្ចេកទេសនៅថ្នាក់ខេត្ត ក្រុង | 0 | 185,000 | 185,000 |
| ជំនួយបច្ចេកទេសនៅថ្នាក់ជាតិ | 450,000 | | 450,000 |
| ការសិក្សា | 240,000 | 30,000 | 270,000 |
| សិក្ខាសាលា/បណ្តុះបណ្តាល | 195,000 | 30,000 | 225,000 |
| **សរុបរួម** | **885,000** | **245,000** | **$1,130,000** |

### ៣.១០.២ កម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ចតំបន់ក្នុងខេត្តសៀមរាប (RED)

កម្មវិធី RED គាំទ្រការអនុវត្តយុទ្ធសាស្ត្រ " ខ្សែក្រវ៉ាត់ពណ៌បៃតង " របស់រាជរដ្ឋាភិបាលនៅក្នុងខេត្តសៀមរាប ដែលបានចាប់ផ្តើមដំណាក់កាលលើកដំបូងតាំងពី ខែកញ្ញា ឆ្នាំ ២០០៧ និងបន្តការអនុវត្តពេញលេញចាប់ពីខែ មេសា ឆ្នាំ ២០០៨។ ផ្អែកលើបទពិសោធន៍ដែលទទួលបានពីការ អនុវត្តគម្រោងអភិវឌ្ឍជនបទ (RDP) នៅខេត្ត

កំពង់ធំ និងកំពត ទិសដៅរបស់គម្រោង RED រួមមាន " រដ្ឋាភិបាលមូលដ្ឋាន ប្រជាពលរដ្ឋ និងមន្ទីរវិស័យពាក់ព័ន្ធ វិមជ្ឈការអនុវត្តដំណើរការប្រកបដោយប្រសិទ្ធភាព និងតម្លាភាព និងបង្កើតឡើងយន្តការសហការក្នុងការអនុវត្ត ផែនការ គ្រប់គ្រងហិរញ្ញវត្ថុ និងអនុវត្តគម្រោង "។

នៅក្នុងឆ្នាំ ២០០៨ សកម្មភាពអាទិភាពដែលគ្រោងនឹងអនុវត្តរួមមាន :

**ក). ថ្នាក់សហគមន៍ :** គាំទ្រដល់អង្គការសហគមន៍មូលដ្ឋាន ដើម្បីចូលរួមជាមួយក្រុមប្រឹក្សាឃុំ សង្កាត់។

**ខ). ថ្នាក់ឃុំ :** ពង្រឹងសមត្ថភាពដល់ក្រុមប្រឹក្សាឃុំ ដើម្បីបង្កើនការចូលរួមឱ្យសកម្មជាមួយអង្គការសង្គមស៊ីវិលក្នុងការចរចាជាមួយស្ថាប័នថ្នាក់លើ និងសម្របសម្រួលការអនុវត្តសកម្មភាព ដើម្បីបង្កើនប្រាក់ចំណូល។

**គ). ថ្នាក់ស្រុក :** ធ្វើការកែលម្អលើការផ្តល់សេវាកម្ម ។

**ឃ). ថ្នាក់ខេត្ត :** គាំទ្រការផ្សារភ្ជាប់ទំនាក់ទំនងប្រកបដោយប្រសិទ្ធភាពរវាង រដ្ឋបាលថ្នាក់ខេត្ត មន្ទីរវិស័យ PACC រដ្ឋបាលស្រុក និងឃុំទាំងអស់។

ដូចដែលបានបង្ហាញនៅក្នុងតារាងទី១៣ ទឹកប្រាក់សរុបសម្រាប់ឆ្នាំ ២០០៨ រួមមាន ២៤៥.០០០ ដុល្លារ សម្រាប់ជាជំនួយបច្ចេកទេសទីប្រឹក្សា ការសិក្សា និងការបោះពុម្ព។

## ៣.១១ រដ្ឋាភិបាលកាណាដា : ការអភិវឌ្ឍន៍កសិកម្មក្នុងតំបន់រងគ្រោះដោយសារគ្រាប់មីន នៅកម្ពុជា (ADMAC)

ក្រសួងកសិកម្ម ក្រោមកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរមីនកម្ពុជា (CMAA) បានប្រតិបត្តិគម្រោង ADMAC ពីឆ្នាំ ២០០៦ ដែលមានរយៈពេល៤ឆ្នាំ មានទឹកប្រាក់សរុបចំនួន ៣,៧៣ លានដុល្លារ ដែលផ្តល់ហិរញ្ញប្បទានដោយ CIDA ប្រទេសកាណាដា។ ADMAC មានគោលដៅកាត់បន្ថយភាពក្រីក្រក្នុងចំណោមកសិករជាបុរស និងស្ត្រីគ្មានទីពឹង ដោយបង្កើនសុវត្ថិភាពស្បៀង និងប្រាក់ចំណូលក្នុងស្រុកចំនួន៦ ដែលរងគ្រោះដោយសារគ្រាប់មីនក្នុងខេត្តក្រុងចំនួន៣ នៅភូមិភាគពាយ័ព្យ គឺខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង និងក្រុងប៉ៃលិន។

គម្រោង ADMAC មានសមាសភាគពីរគឺ : (១). ការផ្សព្វផ្សាយកសិកម្មក្នុងកម្មវិធីចំនួន៤ រួមមាន (កម្មវិធីផលិតកម្មកសិកម្មថ្មី (PSP)) កម្មវិធីកែលំអកសិកម្ម (AIP) កសិកម្មមីក្រូហិរញ្ញវត្ថុ (AMF) និងការបញ្ជ្រាបយេនឌ័រ និង (២). សកម្មភាពកំចាត់មីន ។ ក្នុងឆ្នាំ២០០៨ សមាសភាគផ្សព្វផ្សាយកសិកម្ម នឹងតាមដានព្រមទាំងផ្តល់វគ្គរំលឹកឡើងវិញដល់កសិករ PSP និង AIP ចំនួន ១២.៣៦៩ គ្រួសារ (៦.២២៥ ស្ត្រីជាមេគ្រួសារ) ក្នុងគោលបំណងបង្កើនប្រាក់ចំណូល និងសុវត្ថិភាពស្បៀង ។ កសិករ PSP និង AIP ចំនួនប្រមាណ ១៥០នាក់ នឹងត្រូវជ្រើសរើស ជាអ្នកផ្សព្វផ្សាយភូមិក្នុងនោះ៥០% ជាស្ត្រី ។ កម្មវិធីមីក្រូហិរញ្ញវត្ថុ នឹងបន្តតាមដានក្រុមឥណទាន

និងសន្សំប្រាក់ឃុំ (CSCGs) ដែលមានស្រាប់ និងបង្កើតបន្ថែម CSCGs ចំនួន៨ ថែមទៀត ។ ពួកគាត់ទាំងអស់ នឹងទទួលបានប្រាក់កម្ចីកម្រិតតូចព្រមទាំងវិញ្ញាបនប័ត្រ ជាសមាគមកសិករ ។

**តារាងទី១៥ : ការវិភាជន៍មូលនិធិប្រទេសកាណាដាឆ្នាំ២០០៨**

| ប្រភេទថវិកា | ចំនួន | ភាគរយ |
|---|---|---|
| **វិនិយោគ** | **895,637** | **93%** |
| កម្មវិធីវិស័យបែបវិសហមជ្ឈការ | 895,637 | 93% |
| **ការគាំទ្រកម្មវិធី** | **70,589** | **7%** |
| ការគាំទ្រកម្មវិធីនៅថ្នាក់ខេត្ត ក្រុង | 26,882 | 3% |
| ការគាំទ្រ **CMAA** | 5,000 | 1% |
| ការគាំទ្រផ្នែកគាំទ្រគម្រោងនៅថ្នាក់ជាតិ | 38,707 | 4% |
| **សរុប** | **$966,226** | **100%** |

សមាសភាគសកម្មភាពមីនគាំទ្រដល់ផ្នែកកសាងផែនការសកម្មភាពមីន (MAPU) ដល់ខេត្តគោលដៅទាំងបី។ ដោយ PSP/AIPs ស្ថិតនៅក្នុងតំបន់ដែលរងគ្រោះដោយសារមីន MAPU ដើរតួយ៉ាងសំខាន់ក្នុងការរៀបចំផែនការ និងសម្របសម្រួល ដើម្បីឆ្លើយតបទៅនឹងស្ថានភាពប្រើប្រាស់ដីធ្លីនានាដែលជួបប្រទះ។ ការនេះរាប់បញ្ចូលទាំងការរាយការណ៍អំពីតំបន់ដែលសង្ស័យមានមីន (SMAs) ជាជំនួយក្នុងការនាំកសិករ PSP និង AIP ទៅធ្វើផលិតកម្មកសិកម្មលើដីដែលបានសំអាតមីនរួច ក៏ដូចជាដីដែលសង្ស័យនៅមានមីន (SMAs) ពោលគឺដីដែលបានសំអាតមីនរួចហើយ តែនៅបារម្ភចំពោះសុវត្ថិភាពពួកគាត់ ។ វិញ្ញាបនប័ត្រដីធ្លីបណ្តោះអាសន្ននឹងផ្តល់ដល់កសិករ ដែលកំពុងរស់នៅលើដីដែលសំអាតមីនរួច។

ដូចបង្ហាញក្នុង**តារាងទី១៥** : ការវិភាជន៍ថវិកាពីប្រទេសកាណាដាឆ្នាំ២០០៨ សរុបចំនួន ៩៥០.០០០ដុល្លារ ជាដំបូងគឺធ្វើហិរញ្ញប្បទានដល់សកម្មភាពរបស់មន្ទីរកសិកម្មខេត្ត និង MAPUs ក្នុងខេត្តក្រុងទាំងបី ។ ការបញ្ជ្រាបយេនឌ័រក្នុងវិស័យកសិកម្មផ្អែកលើយុទ្ធសាស្ត្របង្កើតឡើងដោយ ក្រសួងកសិកម្ម សម្រាប់កម្មវិធី IFAD/RPRP ក៏ត្រូវបានយកចិត្តទុកដាក់យ៉ាងជាក់លាក់ផងដែរ។ ការបញ្ជ្រាបយេនឌ័រក្នុងសកម្មភាពមីន នឹងបន្តការគាំទ្រដោយភ្នាក់ងារអភិវឌ្ឍន៍ស្ត្រីអន្តរជាតិ (IWDA) ។

## ៣.១២ UNCDF : មូលនិធិអភិវឌ្ឍន៍សម្រាប់វិមជ្ឈការ និងកិច្ចអភិវឌ្ឍន៍មូលដ្ឋាន (IDLD)

គម្រោងគាំទ្រវិមជ្ឈការ និងអភិវឌ្ឍន៍មូលដ្ឋាន (IDLD) ត្រូវបានអនុម័តនៅដើមឆ្នាំ២០០៨ និងប្រតិបត្តិដោយក្រុមគាំទ្រកម្មវិធី/លេខាធិការដ្ឋាន គ.ជ.វ.វ។ គោលបំណងរបស់គម្រោង (IDLD) គឺសំដៅលើការអភិវឌ្ឍន៍មូលដ្ឋានសម្រាប់អ្នកក្រីក្រ រាប់បញ្ចូលការពង្រីក និងកែលំអគុណភាព ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន និងសេវាកម្មបង្កើនការគ្រប់គ្រងធនធានធម្មជាតិនៅថ្នាក់មូលដ្ឋានល្អប្រសើរ និងអភិវឌ្ឍន៍សេដ្ឋកិច្ចមូលដ្ឋានបានទូលំទូលាយ។

លទ្ធផលគម្រោងនេះចែកចេញជាបីប្រភេទធំៗ (១) ការពង្រឹងស្ថាប័នថ្នាក់ក្រោមជាតិរបស់រាជរដ្ឋាភិបាល (២) បង្កើនវិនិយោគក្នុងការអភិវឌ្ឍន៍មូលដ្ឋាន និង(៣) បង្កើតគោលនយោបាយ ច្បាប់ដ៏មានប្រសិទ្ធភាពក្រោមក្របខ័ណ្ឌច្បាប់ រៀបចំអង្គការ ។ ម្ចាស់ជំនួយផ្សេងទៀត បានផ្តល់ហិរញ្ញប្បទានដល់សកម្មភាពអភិវឌ្ឍន៍មូលដ្ឋានដ៏ច្រើន ចំណែកឯគម្រោង IDLD នឹងផ្តោតជាសំខាន់លើលទ្ធផលដែលជាការបង្កើតនិងឆ្លុះបញ្ចាំងគោលនយោបាយ ដែលត្រូវការទុនជាមូលដ្ឋានតិចតួច សម្រាប់ធ្វើការសាកល្បងគោលនយោបាយ និងការកែប្រែដែលស្មើឡើង។ គម្រោងសំដៅប្រតិបត្តិឱ្យបាន ដំណើរការកំណែទម្រង់វិមជ្ឈការ និងកសាងផ្អែកលើបទពិសោធន៍ UNCDF ដែលមានកន្លងមក។ សមាសភាគបីរបស់គម្រោងគឺ ក) ជំរុញនវានុវត្តន៍មូលដ្ឋាននៅថ្នាក់ស្រុកដោយគាំទ្រ ការរៀបចំ ប្រព័ន្ធអាជ្ញាធរមូលដ្ឋានពីរថ្នាក់ ខ) ធ្វើបុរេប្រទានដំណើរការកំណែទម្រង់វិមជ្ឈការ គ) គាំទ្រផ្នែកគ្រប់គ្រង លេខាធិការដ្ឋាន គ.ជ.វ.វ និងក្រុមគាំទ្រកម្មវិធី ។

**តារាងទី១៦ : ការវិភាជន៍មូលនិធិ UNCDF ឆ្នាំ២០០៨**

| ប្រភេទថវិកា | ចំនួន | ភាគរយ |
|---|---|---|
| **វិនិយោគ** | **207,000** | **26%** |
| វិនិយោគនៅថ្នាក់ស្រុក ខណ្ឌ | 120,000 | 15% |
| សេវាកម្មនានាតាមបណ្តាក្រសួង | 87,000 | 11% |
| **ការគាំទ្រកម្មវិធី** | **292,400** | **36%** |
| ការគាំទ្រកម្មវិធីនៅថ្នាក់ខេត្ត ក្រុង | 6,000 | 1% |
| គ.ជ.វ.វ/ក្រុមគាំទ្រកម្មវិធី | 286,400 | 36% |
| **ជំនួយបច្ចេកទេស** | **304,600** | **38%** |
| ជំនួយបច្ចេកទេសនៅថ្នាក់ជាតិ | 214,600 | 27% |
| ការសិក្សា/ការប្រឹក្សាយោបល់ | 90,000 | 11% |
| **សរុប** | **$804,000** | **100%** |

ដូចបង្ហាញក្នុង**តារាងទី១៦ :** ការវិភាជន៍ថវិកា **UNCDF** ឆ្នាំ២០០៨ សរុបចំនួន ៨០០.០០០ដុល្លារ សម្រាប់អនុវត្តន៍សកម្មភាពឆ្នាំ២០០៨។ ក្រោមសមាសភាគទី១ គម្រោង IDLD នឹងមានដៃគូជាមួយ IFAD, UNICEF និង PSDD នៅក្នុងស្រុកចំនួន៤ នៃខេត្តព្រៃវែង និងស្វាយរៀង ដើម្បីសាកល្បងវិធីសាស្រ្តនវានុវត្តន៍ដល់ស្រុកជាមូលដ្ឋានរៀបចំការផ្តល់សេវាកម្មអន្តរឃុំក្រោមប្រព័ន្ធអាជ្ញាធរមូលដ្ឋានពីរថ្នាក់។ ក្រោមសមាសភាគទី២ គម្រោង IDLD នឹងផ្តល់ការគាំទ្រដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីរៀបចំកំណែទម្រង់វិមជ្ឈការសារពើពន្ធ។ ក្រោមសមាសភាគទី៣ គម្រោងនឹងផ្តល់ការគាំទ្រដល់លេខាធិការដ្ឋាន គ.ជ.វ.វ និងក្រុមគាំទ្រកម្មវិធីលើប្រធានបទជាក់លាក់ទាក់ទងនឹងគោលនយោបាយ ការងារគ្រប់គ្រង និងការតាមដានត្រួតពិនិត្យ និងវាយតម្លៃកម្មវិធី ។

## ៣.១៣ USAID/PACT: កម្មវិធីគាំទ្រកំណែទម្រង់រដ្ឋបាលមូលដ្ឋាន (គម្រោង LAAR)

ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិរបស់សហរដ្ឋអាមេរិក (USAID) បានផ្តល់ជំនួយឥតសំណងចំនួន ១៤,៤លានដុល្លារឱ្យដល់អង្គការ PACT កម្ពុជា ដើម្បីអនុវត្តគម្រោងរយៈពេល៥ឆ្នាំ ក្នុងគោលបំណងបង្កើនការចូលរួមរបស់ក្រុមប្រឹក្សាឃុំ និងប្រជាពលរដ្ឋ ក្នុងដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅប្រទេសកម្ពុជា។ បច្ចុប្បន្ននេះ ស្ថិតក្នុងដំណាក់កាលឆ្នាំទី៣ កម្មវិធី LAAR កំពុងអនុវត្តនៅក្នុង ៣៦៥ ឃុំ នៃខេត្តចំនួន ៨ ។ គោលបំណងនៃការអនុវត្តកម្មវិធីនេះរួមមាន : (១) បង្កើនការចូលរួម និងលទ្ធិប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (២) កសាងទំនាក់ទំនងខ្សែបណ្តោយ និងខ្សែទទឹងរវាងរដ្ឋាភិបាលមូលដ្ឋាន រដ្ឋាភិបាលថ្នាក់ជាតិ និងសង្គមស៊ីវិល (៣) បង្កើនការចូលរួមរបស់ប្រជាជនក្នុងដំណើរការកសាងកម្មវិធីវិនិយោគឃុំ (CIP) និងដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។ ដោយកម្មវិធី LAAR ជាគម្រោងពហុវិស័យ គម្រោងនេះត្រូវបានរៀបចំឡើងដោយផ្អែកលើកម្មវិធីនានា ដែលកំពុងអនុវត្តក្នុងក្របខ័ណ្ឌវិមជ្ឈការ ដោយយកចិត្តទុកដាក់លើអភិបាលកិច្ចល្អ ក្រុមប្រជាពលរដ្ឋដែលមានតំណាងតិច និងការគ្រប់គ្រងធនធានធម្មជាតិ (NRM)។ គម្រោងនេះ នឹងលើកកម្ពស់អភិបាលកិច្ចល្អ តាមរយៈការអនុវត្តគោលការណ៍សំខាន់ទាំង៤ ដូចជា ការចូលរួម ភាពជាដៃគូ តម្លាភាព និងគណនេយ្យភាព ។ កម្មវិធី LAAR អនុវត្តផ្ទាល់ដោយអង្គការ PACT កម្ពុជា ផ្អែកលើអនុស្សារណៈនៃការយោគយល់ ដែលបានចុះហត្ថលេខាដោយ USAID និងក្រសួងមហាផ្ទៃ និងបានកំណត់យ៉ាងច្បាស់នូវកិច្ចសហប្រតិបត្តិការរវាងរដ្ឋាភិបាលទាំងពីរ ។ បន្ថែមលើនេះ អង្គការ PACT កម្ពុជាក៏បានពិភាក្សា និងរៀបចំអនុសារណៈនៃការយោគយល់ជាមួយរដ្ឋាភិបាលថ្នាក់ខេត្ត ដែលត្រូវអនុវត្តគម្រោងផងដែរ។ កម្មវិធី LAAR មានសមាសភាគសំខាន់ៗមួយចំនួនដូចខាងក្រោម :

១. **ការគាំទ្រ និងកសាងសមត្ថភាព :** ជាអាទិភាព ការគាំទ្រ និងកសាងសមត្ថភាព ត្រូវបានផ្តល់ទៅឱ្យអង្គការមិនមែនរដ្ឋាភិបាលជាដៃគូចំនួន ១៤ ជាអ្នកអនុវត្តនី ។ កម្មវិធី LAAR ផ្តល់ការកសាងសមត្ថភាពទាំងអង្គការសង្គមស៊ីវិល និងក្រុមប្រឹក្សាឃុំដោយផ្តោតលើ : ១) ការបង្កើនការចូលរបស់សាធារណៈ និងតម្លាភាពនៃការធ្វើសេចក្តីសម្រេចចិត្តក្នុងការងាររបស់ក្រុមប្រឹក្សា និង ២) ការកែលំអការគ្រប់គ្រងមូលនិធិឃុំ សង្កាត់ឱ្យកាន់តែមានតម្លាភាព និងគណនេយ្យភាព និង ៣) ការកំណត់ រៀបចំ និងអនុវត្តគម្រោងសេវាកម្មខ្នាតតូចទាំងឡាយដោយផ្តោតលើការអភិវឌ្ឍន៍សង្គម (អប់រំ សុខាភិបាល យេនឌ័រ យុវជន ឬជាការគ្រប់គ្រងធនធានធម្មជាតិសហគមន៍មូលដ្ឋាន) ។

២. **មូលនិធិអភិវឌ្ឍន៍សង្គម :** គម្រោង LAAR បានផ្តល់នូវថវិកាជាជំនួយឥតសំណងជាជំហានៗទៅឱ្យក្រុមប្រឹក្សាឃុំ : ១) ថវិកាសម្រាប់ចាប់ផ្តើមដំណើរការ " Outreach Grant " ដែលគាំទ្រការទំនាក់ទំនងរបស់ក្រុមប្រឹក្សាជាមួយសហគមន៍នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន (ជាមធ្យម ១.៣៦០ ដុល្លារក្នុងមួយឃុំ) និង ២) ថវិកាសំរាប់គម្រោងអភិវឌ្ឍន៍សង្គម (SDP) ដែលកំណត់ជាអាទិភាពដោយសហគមន៍មូលដ្ឋាន (មិនលើសពី ៦.០០០ដុល្លារ ក្នុងមួយឃុំ

សំរាប់រយៈពេលពីរឆ្នាំ) ។ ដូច្នេះ ឃុំគោលដៅនីមួយៗ នឹងទទួលបានថវិកាប្រហែលជា ៧.៣៦០ដុល្លារសំរាប់ប្រើប្រាស់រយៈពេលពាឆ្នាំជាប់គ្នា។ ដើម្បីបង្កើនភាពជាម្ចាស់ និងនិរន្តរភាពនៃគម្រោង ការផ្តល់មូលនិធិអភិវឌ្ឍន៏សង្គមរបស់ LAAR តម្រូវអោយមានទុនចូលរួមបដិភាគរបស់ឃុំ ។ គម្រោង LAAR នឹងផ្តល់ថវិកាមិនលើសពី ៦០% នៃថវិកាសរុបរបស់គំរោងស្នើសុំនិមួយៗ ដែលមានតំលៃខ្ពស់បំផុតត្រឹម ៦.០០០ ដុល្លារ ។

ធនធានប៉ាន់ស្មានវិភាជន៏ដោយកម្មវិធី LAAR ក្នុងឆ្នាំ២០០៨ មានថវិកាចំនួន ៧៤៣.៩៥០ ដុល្លារ ដែលត្រូវផ្តល់ឱ្យក្រុមប្រឹក្សាឃុំផ្ទាល់ ។ ក្រៅពីនេះ នៅមានថវិកាបន្ថែមចំនួន ១.១៩៧.៣៨៣ ដុល្លារទៀត នឹងត្រូវបានផ្តល់ឱ្យអង្គការមិនមែនរដ្ឋាភិបាល សំរាប់ផ្តល់ជំនួយបច្ចេកទេសដល់ក្រុមប្រឹក្សាឃុំ ។ នៅក្នុងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០០៨របស់ គ.ជ.វ.វ និងប្រភេទថវិកាដែលបានអនុម័ត មានតែថវិកាមួយចំនួនតូចប៉ុណ្ណោះដែលផ្តល់ឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ដែលត្រូវបានរំលេចនៅក្នុងតារាងថវិកា ។

### ៣.១៤ អង្គការ GRET/PACEPAC

នៅក្នុងកម្មវិធីថ្មីមួយដែលមានឈ្មោះថា PACEPAC អង្គការមិនមែនរដ្ឋាភិបាល GRET នឹងបន្តការងារនវានុវត្តន៏របស់ខ្លួនក្នុងការកែលំអអនាម័យ និងលទ្ធភាពប្រើប្រាស់ទឹកស្អាតនៅតំបន់គោលដៅ ជាពិសេសការបង្កើតប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតនៅតំបន់ទីប្រជុំជន ដែលអ្នកពាក់ព័ន្ធរួមមាន វិស័យឯកជន និងសហគមន៏អ្នកប្រើប្រាស់ទឹក ។ វិធីសាស្ត្រស្រដៀងគ្នាត្រូវបានបង្កើតឡើងក្នុងការសាកល្បងប្រមូលទឹកស្អុយ និងការចម្រោះទឹកស្អុយ ។ យោងតាមអនុស្សារណៈនៃការយោគយល់ដែលបានចុះកិច្ចព្រមព្រៀងជាមួយ គ.ប្រ/គ.អ.ជ.ខ នៃខេត្តតាកែវ និង កណ្តាល ឃុំចំនួន ៧ ត្រូវបានជ្រើសរើសនៅក្នុងខេត្តទាំងពីរ ដោយផ្អែកទៅលើឆន្ទៈរបស់ពួកគេក្នុងការអនុវត្តផែនការអនាម័យ និងទឹកស្អាតជាមួយសហគមន៏។ ថវិកាប្រមាណ ៣៥.០០០ដុល្លារ នឹងត្រូវផ្តល់ជូនដល់ខេត្តគោលដៅនីមួយៗ ក្នុងការគាំទ្រសកម្មភាពដែលបានផ្តួចផ្តើមនេះ ក្នុងនោះថវិកាចំនួន ៤.៥០០ដុល្លារ សម្រាប់គាំទ្រការបណ្តុះបណ្តាល កិច្ចសម្របសម្រួល និងការគ្រប់គ្រង និងទឹកប្រាក់ចំនួន ៣០.០០០ដុល្លារ សម្រាប់ចំណាយលើការវិនិយោគ ។ នៅក្នុងកិច្ចព្រមព្រៀងបានចែងថា គ.អ.ជ.ខ ជាអ្នកគ្រប់គ្រងការរៀបចំកិច្ចសន្យា និងអនុវត្តស្របបព័ន្ធនានានៅថ្នាក់ខេត្តដែលបានបង្កើត។

**តារាងទី១៧ : ការវិភាជន៏មូលនិធិ GRET**

| ប្រភេទថវិកា | ចំនួន | ភាគរយ |
|---|---|---|
| **វិនិយោគ** | **139,410** | **95%** |
| មូលនិធិសម្រាប់ឃុំ សង្កាត់គោលដៅ | 139,410 | 95% |
| **ការគាំទ្រកម្មវិធី** | **7,480** | **5%** |
| ការគាំទ្រកម្មវិធីនៅថ្នាក់ខេត្ត ក្រុង | 7,480 | 5% |
| **សរុប** | **$146,890** | **100%** |

## ៣.១៥ ការគាំទ្ររបស់មូលនិធិអង្គការសហប្រជាជាតិដើម្បីសកម្មភាពប្រជាជន (UNFPA) ដល់ទិវង្គការ និងវិសហមង្គការ

មូលនិធិអង្គការសហប្រជាជាតិដើម្បីសកម្មភាពប្រជាជន បានចុះហត្ថលេខាព្រមព្រៀងលើផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ ជាមួយនាយកដ្ឋានរដ្ឋបាលមូលដ្ឋានរបស់ក្រសួងមហាផ្ទៃ ដើម្បីគាំទ្រទៅលើការកសាងសមត្ថភាព និងការយល់ដឹងទៅលើបញ្ហាធំៗមួយចំនួនរបស់ប្រជាជន ទៅដល់អ្នកធ្វើផែនការវិមជ្ឈការ ក្រុមប្រឹក្សាឃុំ សង្កាត់ មន្ត្រីបង្គោលទទួលបន្ទុកការងារស្ត្រី និងកុមារ និងសមាជិកសហគមន៍ទាំងឡាយ នៅក្នុងខេត្ត និងឃុំមួយចំនួន ។ លទ្ធផលរំពឹងទុកពីការព្រមព្រៀងនេះមាន : (១) គោលនយោបាយថ្នាក់ជាតិ និងផែនការវិមជ្ឈការដែលយកចិត្តទុកដាក់លើបញ្ហាទំនាក់ទំនងរវាងប្រជាជន និងភាពក្រីក្រ ជាមួយនឹងការអភិវឌ្ឍន៍, (២) យន្តការក្នុងស្ថាប័ន និងការប្រតិបត្តិក្នុងសង្គម និងវប្បធម៌ដែលលើកតំកើង និងការពារសិទ្ធិរបស់ស្ត្រី និងកុមារី ដើម្បីធ្វើឱ្យសមធម៌យេនឌ័រ កាន់តែមានការវិវឌ្ឍទៅមុខ និង (៣) ធ្វើឱ្យប្រសើរឡើងនូវការយល់ដឹង និងអោយអំណាច ជាពិសេសទៅដល់ស្ត្រី និងយុវជនអំពីសិទ្ធិបន្តពូជរួមទាំងសេវាសុខភាពបន្តពូជផងដែរ ។

នៅឆ្នាំ ២០០៨ ការហ្វឹកហ្វឺនជាច្រើន និងសកម្មភាពលើកកំពស់ការយល់ដឹង ដែលទាក់ទងទៅនឹងសុខភាពសហគមន៍ សេវាបន្តពូជ និងសមធម៌យេនឌ័រ នឹងត្រូវអនុវត្តនៅក្នុងឃុំចំនួន ២០១ ក្នុងខេត្តចំនួន ៨ ដែលពាក់ព័ន្ធនឹងការកែសម្រួលឡើងវិញនូវដំណើរការរៀបចំផែនការវិនិយោគឃុំ សង្កាត់ ដើម្បីលើកកំពស់សកម្មភាពមូលដ្ឋាន ដើម្បីដោះស្រាយបញ្ហាប្រជាជន។

ដូចបង្ហាញក្នុងតារាងទី១៨ ខាងក្រោម ឃុំចំនួន២០១ នឹងទទួលបាននូវមូលនិធិចំនួន ៥០០ដុល្លារក្នុងមួយឃុំ ដើម្បីគាំទ្រសកម្មភាពទាំងអស់ខាងលើ។ សរុបទាំងអស់ ថវិកាដែលនឹងទទួលបានទូទាំង ២០១ឃុំនោះគឺ ១០០.៥០០ ដុល្លារ ។ ថវិកាចំនួន ១៣.០០០ដុល្លារបន្ថែមទៀត នឹងត្រូវវិភាជទៅឱ្យអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត និងចំនួនជាង ៣២.០០០ដុល្លារទៀត ទៅនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ដើម្បីគាំទ្រទៅដល់ការរៀបចំវេទិកា សិក្ខាសាលា វគ្គបណ្តុះបណ្តាលគ្រូបង្គោល និងសកម្មភាពតាមដានត្រួតពិនិត្យផ្សេងៗ។

**តារាងទី១៨ : ការវិភាជន៍មូលនិធិ UNFPA**

| ប្រភេទថវិកា | ចំនួន | ភាគរយ |
|---|---|---|
| **វិនិយោគ** | **132,964** | **91%** |
| មូលនិធិសម្រាប់ឃុំ សង្កាត់គោលដៅ | 100,500 | 69% |
| សេវាកម្មនានាតាមបណ្តាក្រសួង | 32,464 | 22% |
| **ការគាំទ្រកម្មវិធី** | **12,940** | **9%** |
| ការគាំទ្រកម្មវិធីនៅថ្នាក់ខេត្ត ក្រុង | 12,940 | 9% |
| **សរុប** | **$145,904** | **100%** |

## ៣.១៦ គម្រោងជំនួយផ្នែកយុត្តិធម៌ដល់ឧក្រិដ្ឋជននៅកម្ពុជា (CCJAP) គាំទ្រដោយ AusAid

ដំណាក់កាលទី៣នៃគម្រោងជំនួយផ្នែកយុត្តិធម៌ដល់ឧក្រិដ្ឋជននៅកម្ពុជា គាំទ្រដោយ (CCJAP III) គឺជាគម្រោងទ្វេភាគីរវាងរដ្ឋាភិបាលអូស្ត្រាលី និងរដ្ឋាភិបាលកម្ពុជា ដែលផ្តល់ការគាំទ្រមូលនិធិដោយជំនួយអូស្ត្រាលីសំរាប់ការអភិវឌ្ឍន៍អន្តរជាតិ (AusAid) ដោយផ្តោតការយកចិត្តទុកដាក់ជាក់លាក់ទៅលើ លទ្ធភាពទទួលបាននូវយុត្តិធម៌ ការប្រឆាំងអំពើពុករលួយ និងតម្រូវការរបស់យុវជន និងក្រុមងាយរងគ្រោះដទៃទៀត។ នៅឆ្នាំ ២០០៧ នៅខេត្តកណ្តាល ការងារទប់ស្កាត់បទល្មើស និងសកម្មភាពសុវត្ថិភាពជាច្រើន ត្រូវបានដាក់បញ្ចូលតាមរយៈដំណើរការធ្វើផែនការវិនិយោគឃុំ នៅក្នុងស្រុកចំនួន៤ ហើយជាលទ្ធផលគឺទទួលបានការយល់ព្រមជាមួយឃុំចំនួន ៤២ សម្រាប់គម្រោងជាក់លាក់ខ្នាតតូចចំនួន៦៥ គម្រោង ។ លទ្ធផលសង្ឃឹមទុកនៃការគាំទ្ររបស់គម្រោង CCJAP រួមមាន : ក) ជួយបង្កើតការទប់ស្កាត់បទល្មើសប្រកបដោយនិរន្តរភាព និងសហប្រតិបត្តិការ សុវត្ថិភាពសហគមន៍ និងគំនិតផ្តួចផ្តើមដើម្បីភាពយុត្តិធម៌សហគមន៍, ខ) ជួយរៀបចំសេចក្តីណែនាំសំរាប់ការគាំទ្រនាពេលអនាគតនៅក្នុងខេត្តផ្សេងៗទៀត និង គ) ផ្តល់ព័ត៌មានអំពីការបង្កើតវិធីសាស្ត្រជាតិក្នុងការទប់ស្កាត់បទល្មើស និងសុវត្ថិភាពសហគមន៍នៅកម្ពុជា ។ នៅក្នុងអនុស្សរណៈយោគយល់ ដែលបានចុះហត្ថលេខារវាង CCJAP III និងគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្តកណ្តាល ថវិកាសរុបចំនួន ៩៥.០០០ ដុល្លារ ត្រូវបានវិភាជសម្រាប់គាំទ្រគំនិតផ្តួចផ្តើមថ្នាក់ឃុំចំនួន ៩០.០០០ដុល្លារ និង ៥.០០០ដុល្លារទៀត ដើម្បីគាំទ្រគណៈកម្មាធិការប្រតិបត្តិខេត្តកណ្តាល ក្នុងការគាំទ្រការអនុវត្ត និងកិច្ចប្រតិបត្តិការផ្សេងៗ ។

**តារាងទី ១៩ : ការវិភាជន៍ថវិកា AusAid**

| ប្រភេទថវិកា | ចំនួន | ភាគរយ |
|---|---|---|
| **វិនិយោគ** | **90,000** | **95%** |
| មូលនិធិសម្រាប់ឃុំ សង្កាត់គោលដៅ | 90,000 | 95% |
| **ការគាំទ្រកម្មវិធី** | **5,000** | **5%** |
| ការគាំទ្រកម្មវិធីនៅថ្នាក់ខេត្ត ក្រុង | 5,000 | 5% |
| **សរុប** | **$95,000** | **100%** |

## ៣.១៧ ភាពជាដៃគូផ្សេងទៀតជាមួយ NGOs

ក្រៅពីភាពជាដៃគូដោយផ្ទាល់ជាមួយអង្គការមិនមែនរដ្ឋាភិបាលដែលបានគូសបញ្ជាក់ពីខាងលើ នៅមានភាពជាដៃគូមិនផ្ទាល់ជាច្រើនទៀត ជាមួយអង្គការមិនមែនរដ្ឋាភិបាលទូទាំងប្រទេស រួមមានការសន្ទនា និងការសហការជុំវិញបញ្ហាអភិបាលកិច្ចមូលដ្ឋាន និងកិច្ចអភិវឌ្ឍន៍ ។ ដូចបានបានបង្ហាញតាមរយៈសូចនាករនៃបណ្តាញការងារ និងសុខដុមនីយកម្មដែលបានបង្កើតឡើង តាមរយៈដំណើរការសមាហរណកម្មផែនការថ្នាក់ស្រុកក្នុងឆ្នាំ២០០៧ អង្គការ

មិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិចំនួនជិត ៣០០ បានសន្យាជួយគាំទ្រការវិនិយោគឃុំ និងសេវាកម្ម តាមរយៈកិច្ចព្រមព្រៀងចំនួន ១៤.០០០ ដែលបានចុះហត្ថលេខាជាមួយក្រុមប្រឹក្សាឃុំ សង្កាត់។ នៅក្នុងការតាមដានត្រួតពិនិត្យ និងការអនុវត្តនៃសកម្មភាពទាំងនេះ មានការសន្ទនា និងការសម្របសម្រួលយ៉ាងច្រើននៅ គ្រប់លំដាប់ថ្នាក់ដែលបានរៀបចំឡើង។ ស្ទើរគ្រប់ខេត្ត ក្រុង ការរៀបចំវេទិកាអភិវឌ្ឍន៍មូលដ្ឋាន ដែលមានការចូលរួមពីអាជ្ញាធរខេត្ត ក្រុង អង្គការមិនមែនរដ្ឋាភិបាល និងអង្គការអន្តរជាតិ បានបន្តរៀបចំ ដើម្បីធ្វើការផ្លាស់ប្តូរព័ត៌មាន ការពិភាក្សាពីបញ្ហាសំខាន់ៗ ដែលជាការព្រួយបារម្ភរបស់ភាគីទាំងអស់ និងដើម្បីពង្រឹងកិច្ចសហការឱ្យកាន់តែរឹងមាំ។

## ៤. កិច្ចព្រមព្រៀងហិរញ្ញវត្ថុ លំហូរមូលនិធិ ការប្រតិបត្តិការ និងការរៀបចំកិច្ចសន្យា

ធនធានទាំងអស់ដូចបានរៀបរាប់ខាងលើ ត្រូវបានអនុម័តក្រោមកិច្ចព្រមព្រៀងហិរញ្ញវត្ថុដោយឡែកៗពីគ្នារវាងភ្នាក់ងារម្ចាស់ជំនួយជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា។ ទំនាក់ទំនងនៃធនធានទាំងនោះជាមួយនឹងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ គ.ជ.វ.វ ត្រូវបានពិពណ៌នានៅក្នុងកិច្ចព្រមព្រៀងហិរញ្ញវត្ថុនៃធនធានទាំងនោះ និងក៏ត្រូវបានពិពណ៌នានៅក្នុងកិច្ចព្រមព្រៀងជាក់លាក់ ឬអនុស្សរណៈនៃកិច្ចព្រមព្រៀង និងព្រមទាំងបានដាក់បញ្ចូលក្នុងកិច្ចព្រមព្រៀងជាក់លាក់ជាមួយអាជ្ញាធរខេត្ត ក្រុង ឬក៏ត្រូវបានបញ្ជាក់បំភ្លឺតាមរយៈការរៀបចំសម្រាប់ការអនុវត្តផ្សេងៗទៀត។ ចំពោះជំនួយពីស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ (IFI) ធនធានហិរញ្ញវត្ថុនឹងត្រូវបានផ្ទេរតាមរយៈគណនីពិសេសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទៅក្នុងគណនីរបស់ភ្នាក់ងារអនុវត្តនៅថ្នាក់ជាតិ និងថ្នាក់ខេត្តក្រុង ឬទៅក្នុងគណនីឃុំ សង្កាត់គោលដៅតាមរយៈរតនាគារជាតិ ឬតាមធនាគារពាណិជ្ជកម្ម។ ចំពោះជំនួយទ្វេភាគី និងពហុភាគី ធនធានហិរញ្ញវត្ថុនឹងត្រូវផ្ទេរទៅក្នុងគណនីរបស់គម្រោងដែលគ្រប់គ្រងដោយភ្នាក់ងារប្រតិបត្តិការគម្រោង និងបន្ទាប់មកធនធានទាំងនោះ នឹងត្រូវផ្ទេរពីគណនីគម្រោងនេះ ទៅអាជ្ញាធរពាក់ព័ន្ធនានានៅថ្នាក់ក្រោមជាតិ។

បន្ទាប់ពីបានទទួលធនធាននៅក្នុងគណនីនៅថ្នាក់ខេត្ត ក្រុងហើយ ធនធានប្រមាណ៩០% ត្រូវបានអនុវត្តទៅតាមនីតិវិធីនៃការរៀបចំកិច្ចសន្យា ការគ្រប់គ្រងហិរញ្ញវត្ថុ ការទូទាត់ ការចុះបញ្ជីការគណនេយ្យ និងរបាយការណ៍ ដែលបានកំណត់នៅក្នុងប្រព័ន្ធ និងសៀវភៅណែនាំ ដែលបានអនុម័តដោយ គ.ជ.វ.វ។

ក្នុងការសម្របសម្រួលភាពផ្សេងៗគ្នា នៃកិច្ចព្រមព្រៀងហិរញ្ញវត្ថុ និងលំហូរមូលនិធិពីថ្នាក់ជាតិទៅថ្នាក់ខេត្ត ក្រុង ក្របខ័ណ្ឌផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ គ.ជ.វ.វ នឹងធានាលើចំណុចសំខាន់ៗ ដែលធ្វើឱ្យមានភាពស្របគ្នាក្នុងការរៀបចំ និងគ្រប់គ្រងកម្មវិធី និងកិច្ចសន្យា ដែលត្រូវអនុវត្តតាម តាមរយៈប្រព័ន្ធផែនការនៅថ្នាក់ឃុំ សង្កាត់ ថ្នាក់ខេត្ត ក្រុង និងថ្នាក់ជាតិ។ ភាគច្រើននៃធនធានហិរញ្ញវត្ថុដែលត្រូវផ្តល់ និងអនុវត្តនៅថ្នាក់ភូមិ ឬឃុំ សង្កាត់ នឹងត្រូវអនុវត្តតាមក្របខ័ណ្ឌច្បាប់ និងលិខិតបទដ្ឋាននៃមូលនិធិឃុំ សង្កាត់។ ដោយឡែក ធនធានហិរញ្ញវត្ថុមួយចំនួន ដែលត្រូវផ្តល់ទៅថ្នាក់ភូមិ ឬឃុំ សង្កាត់ នឹងត្រូវបានចចារជាមួយថ្នាក់មូលដ្ឋាននោះផ្ទាល់ ដោយមានការចូលរួមរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងត្រូវបានអនុវត្តតាមរយៈកិច្ចព្រមព្រៀងរវាងអាជ្ញាធរខេត្ត ក្រុង

ជាមួយនឹងក្រុមប្រឹក្សាឃុំ សង្កាត់ លើការទូទាត់ដែលត្រូវធ្វើឡើងដោយផ្ទាល់ពី គ.ប្រ ឬពីគណនីធនាគាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់។ ធនធានហិរញ្ញវត្ថុដែលត្រូវផ្តល់ និងអនុវត្តនៅថ្នាក់ខេត្ត ក្រុង និងថ្នាក់ជាតិភាគច្រើន ត្រូវអនុវត្តតាមប្រព័ន្ធកិច្ចសន្យារបស់ គ.ជ.វ.វ ដោយមានគណនីដាក់លាក់នីមួយៗដោយឡែកៗ ពីគ្នាទៅតាមប្រភពធនធាននីមួយៗ ប៉ុន្តែត្រូវបានដាក់បញ្ចូលគ្នានៅក្នុងផែនការសកម្មភាព និងថវិការួមមួយ សម្រាប់មន្ទីរ ឬខេត្តក្រុងពាក់ព័ន្ធទាំងនោះ។

នៅក្នុងទំព័រខាងក្រោម នឹងមានដ្យាក្រាមស្តីពីលំហូរមូលនិធិនៃផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ គ.ជ.វ.វ ដែលបង្ហាញអំពីរបៀបលំហូរថវិកាផ្សេងៗគ្នា ដែលត្រូវបានប្រើប្រាស់ដោយគម្រោងជំនួយផ្សេងៗគ្នា។ ក្នុងចំណោមធនធានហិរញ្ញវត្ថុសរុបចំនួន៥៨លានដុល្លារ ដែលត្រូវផ្ទេរឱ្យទៅអាជ្ញាធរថ្នាក់ក្រោមជាតិ ក្រោមក្របខ័ណ្ឌនៃផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ គ.ជ.វ.វ ធនធានហិរញ្ញវត្ថុចំនួន៤៨ លានដុល្លារ (៨១%) នឹងត្រូវគ្រប់គ្រងដោយ គ.ប្រ នៃ គ.អ.ជ ខ ដោយត្រូវអនុវត្តតាមប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រោមក្របខ័ណ្ឌ គ.ជ.វ.វ និងធនធានហិរញ្ញវត្ថុចំនួន១០លានដុល្លារ (១៧%) នឹងត្រូវបានគ្រប់គ្រងតាមការរៀបចំដោយឡែក ក្រៅពីរចនាសម្ព័ន្ធរបស់ គ.ប្រ។

## ផែនការសកម្មភាព និងថវិកាឆ្នាំ២០០៨ : ការព្រមព្រៀងទៅលើលំហូរមូលនិធិ



ធនធានទាំងអស់ដែលស្ថិតក្រោមក្របខ័ណ្ឌនៃផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០០៨របស់ គ.ជ.វ.វ ត្រូវផ្ទេរឱ្យទៅក្រសួង ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ត្រូវបានដាក់បញ្ចូលទៅក្នុងកិច្ចព្រមព្រៀងអនុវត្តកិច្ចសន្យា និងថវិកា ដោយមានភ្ជាប់ជាមួយនូវផែនការសកម្មភាពលម្អិត។ តារាងទី ២០ ស្តីពីចំនួនកិច្ចសន្យាប៉ាន់ស្មាននឹងបង្ហាញឱ្យឃើញថានឹងមានកិច្ចសន្យាចំនួនប្រមាណ ៥.៥០០ កិច្ចសន្យា ដែលនឹងត្រូវអនុវត្ត និងគ្រប់គ្រងនៅក្នុងឆ្នាំ ២០០៨ ក្រោមក្របខ័ណ្ឌនៃផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ គ.ជ.វ.វ។

**តារាងទី២០ : កិច្ចសន្យាប៉ាន់ស្មានឆ្នាំ២០០៨**

| ប្រភេទថវិកា | ចំនួន | តម្លៃ |
|---|---:|---:|
| ថ្នាក់ឃុំ សង្កាត់ | | |
| កិច្ចសន្យាឃុំ សង្កាត់ | 4,300 | 29,134,885 |
| ថ្នាក់ស្រុក ខណ្ឌ | | |
| កិច្ចសន្យាស្រុក ខណ្ឌ | 300 | 5,748,701 |
| ថ្នាក់ខេត្ត ក្រុង | | |
| គ.អ.ជ.ខ : ស្រុក ខណ្ឌ | 160 | 6,051,264 |
| គ.អ.ជ.ខ : មន្ទីរជំនាញខេត្ត ក្រុង | 335 | 11,014,638 |
| គ.អ.ជ.ខ : គ.ប្រ | 245 | 4,769,217 |
| ថ្នាក់ជាតិ | | |
| គ.ជ.វ.វ : ខេត្ត ក្រុង | 125 | 21,835,120 |
| ម្ចាស់អំណោយ/គ.ជ.វ.វ : ក្រសួង | 30 | 8,019,940 |
| រាជរដ្ឋាភិបាលកម្ពុជា : ម្ចាស់អំណោយ | 21 | 63,009,067 |
| **សរុបរួម** | **5,516** | |

ចំនួនភាគច្រើននៃកិច្ចសន្យាទាំងនេះ ត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងកិច្ចសន្យា ជាភាសាខ្មែរ និងអង់គ្លេស ដែលបានរៀបចំជាពិសេសសម្រាប់ ការកត់ត្រាតាមដានត្រួតពិនិត្យមើលការរីកចម្រើននៃការអនុវត្តកិច្ចសន្យា ប្រៀបធៀបទៅនឹងផែនការសកម្មភាព លទ្ធផលរំពឹងទុក និងការចំណាយនានានៅក្នុងឆ្នាំនៃការអនុវត្ត។ ចំពោះព័ត៌មានកិច្ចសន្យាអនុវត្តគម្រោង ដែលធ្វើឡើងរវាងឃុំ សង្កាត់ជាមួយអ្នកទទួលការឯកជន ត្រូវបានកត់ត្រារក្សាទុកនៅក្នុងប្រព័ន្ធទិន្នន័យគ្រប់គ្រងព័ត៌មានគម្រោង ដែលត្រូវបានគ្រប់គ្រងនៅថ្នាក់ខេត្ត ក្រុង ដោយផ្នែករដ្ឋបាលមូលដ្ឋាន និងនៅថ្នាក់ជាតិដោយនាយកដ្ឋានរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃ។ ចំពោះព័ត៌មាននៃកិច្ចសន្យារវាងខេត្ត ក្រុង ជាមួយនឹងភ្នាក់ងារអនុវត្តគម្រោងនានា នឹងត្រូវកត់ត្រាចូលក្នុងប្រព័ន្ធទិន្នន័យគ្រប់គ្រងកិច្ចសន្យារបស់ គ.ជ.វ.វ ដែលត្រូវបានគ្រប់គ្រងនៅថ្នាក់ខេត្ត ក្រុង ដោយផ្នែកគ្រប់គ្រងកិច្ចសន្យានៃ គ.ប្រ និងនៅថ្នាក់ជាតិដោយ

ផ្នែកគាំទ្រកម្មវិធីរបស់ គ.ជ.វ.វ។ ប្រមាណជា១៥%នៃកិច្ចព្រមព្រៀងថវិកាសរុប ត្រូវបានចុះហត្ថលេខាដោយផ្ទាល់រវាងម្ចាស់ជំនួយជាមួយភ្នាក់ងារអនុវត្តគម្រោង ហើយត្រូវបានកត់ត្រាសម្រាប់ការតាមដាន នៅក្រៅប្រព័ន្ធទិន្នន័យរបស់ គ.ជ.វ.វ។

## ៥. ការរៀបចំកម្មវិធីតាមរយៈសមាហរណកម្មផែនការថ្នាក់ស្រុក ខណ្ឌ

ការជួយគាំទ្រនឹងត្រូវបន្តផ្តល់ដល់ការរៀបចំ និងដំណើរការសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ ស្រុក ខណ្ឌ ដើម្បីជម្រុញភាពជាដៃគូរវាងក្រុមប្រឹក្សាឃុំ សង្កាត់ ជាមួយមន្ទីរជំនាញនៅតាមខេត្ត ក្រុង ភ្នាក់ងារអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលនានាដើម្បីកិច្ចអភិវឌ្ឍន៍មូលដ្ឋាន។ នៅក្នុងឆ្នាំ២០០៧ មានការផ្តោតយកចិត្តទុកដាក់ក្នុងការកែលម្អប្រសិទ្ធភាពនៃការរៀបចំសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក ខណ្ឌ។ ការយកចិត្តទុកដាក់នោះ គឺពាក់ព័ន្ធទៅនឹងការវិភាគយ៉ាងស៊ីជម្រៅទៅលើតារាងម៉ាទ្រិចនៃគម្រោងអាទិភាព ដែលត្រូវយកទៅបង្ហាញនៅក្នុងសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក ខណ្ឌ មុននឹងធ្វើការវិភាជន៍មូលនិធិវិនិយោគខេត្ត ក្រុងឱ្យទៅមន្ទីរវិស័យជំនាញ ការរៀបចំឱ្យមានការពិភាក្សាយ៉ាងទូលំទូលាយនៅតាមមន្ទីរជំនាញនានា ទៅលើសកម្មភាពតាមវិស័យ ដែលបានស្នើឡើងសម្រាប់ការផ្តល់មូលនិធិវិនិយោគខេត្ត ក្រុង និងការពិភាក្សាយ៉ាងលម្អិតទៅលើសំណើសុំមូលនិធិវិនិយោគខេត្ត ក្រុងរវាងមន្ទីរជំនាញនានា មន្ទីរផែនការ និងមន្ទីរកិច្ចការនារីខេត្ត ក្រុង។ គោលបំណងនៃការពិភាក្សាទាំងនេះ គឺដើម្បីបង្កើនការឆ្លើយតបរបស់មន្ទីរជំនាញ និងអង្គការមិនមែនរដ្ឋាភិបាលទៅលើសំណើអាទិភាពនានារបស់ឃុំ សង្កាត់។ ក្នុងឆ្នាំ២០០៧ គណៈកម្មាធិការជាតិគាំទ្រឃុំសង្កាត់ បានស្នើឱ្យក្រុមប្រឹក្សាឃុំសង្កាត់បញ្ចប់ជំហានទី៧នៃដំណើរការកសាងផែនការឃុំ សង្កាត់ ដែលជាដំណាក់កាលរៀបចំបញ្ជីគម្រោងអាទិភាពរបស់ឃុំសង្កាត់ នៅពាក់កណ្តាលខែកញ្ញា។ ការធ្វើបែបនេះ គឺដើម្បីផ្តល់ពេលវេលាឱ្យបានគ្រប់គ្រាន់ដល់មន្ទីរផែនការខេត្ត ក្រុង ក្នុងការរៀបចំបញ្ចូលបញ្ជីសំណើសកម្មភាព ឬគម្រោងអាទិភាពទាំងនោះ ដាក់ទៅក្នុងប្រព័ន្ធទិន្នន័យផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងដើម្បីរៀបចំឱ្យមានតារាងម៉ាទ្រិចនៃគម្រោងអាទិភាពរបស់ស្រុក ខណ្ឌ ដើម្បីផ្សព្វផ្សាយជូនអង្គភាពពាក់ព័ន្ធក្នុងរយៈពេលពី២ទៅ៣សប្តាហ៍ មុនពេលរៀបចំដំណើរការសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក ខណ្ឌ។

សិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក ត្រូវបានរៀបចំឡើងនៅក្នុងចន្លោះពីចុងខែតុលា ដល់ដើមខែធ្នូ ឆ្នាំ២០០៧ ដោយមានចូលរួមពីតំណាងមកពីមន្ទីរជំនាញជាច្រើន និងពីតំណាងភ្នាក់ងារដែលបំពេញការងារនៅក្នុងស្រុក ខណ្ឌ។ សំណើគម្រោងអាទិភាពរបស់ឃុំ សង្កាត់ត្រូវបានបង្ហាញ និងដាក់ឱ្យពិភាក្សាពិនិត្យមើលឡើងវិញ ដោយក្រុមប្រឹក្សាឃុំ សង្កាត់។ ព្រមជាមួយគ្នានោះ ការបង្ហាញរបស់មន្ទីរជំនាញ និងភ្នាក់ងារនានា ក៏បានធ្វើឡើងដែរ ដើម្បីបញ្ជាក់អំពីសេវាកម្ម និងការវិនិយោគដែលមន្ទីរជំនាញ និងភ្នាក់ងារទាំងនោះ មានបំណងផ្តល់ឱ្យនៅក្នុងឆ្នាំ២០០៨ តាមរយៈការឆ្លើយតបដោយផ្ទាល់ទៅនឹងសំណើគម្រោងអាទិភាព ឬក៏ផ្តល់គម្រោងបន្ថែមទៅលើគម្រោងអាទិភាព

របស់ថ្នាក់មូលដ្ឋាន។ កិច្ចព្រមព្រៀងបណ្តោះអាសន្ន ត្រូវបានរៀបចំឡើងរវាងមន្ទីរជំនាញ/ភ្នាក់ងារដែលផ្តល់ការគាំទ្រជាមួយក្រុមប្រឹក្សាឃុំ សង្កាត់។ ការអនុវត្តកិច្ចព្រមព្រៀងនេះ នឹងត្រូវបានតាមដានតាមរយៈអាជ្ញាធរស្រុក ខណ្ឌ ហើយក៏មានការពិភាក្សាទ្វេភាគី ដើម្បីបញ្ជាក់កំណត់អំពីថវិកា លទ្ធផល និងផែនការសកម្មភាពសម្រាប់ការអនុវត្តកិច្ចព្រមព្រៀងទាំងនេះ។ កិច្ចព្រមព្រៀងបណ្តោះអាសន្នទាំងអស់ ត្រូវបានកត់ត្រាបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យផែនការអភិវឌ្ឍន៍ឃុំ ហើយការវិភាគទៅលើកម្រិត ប្រភេទ និងរបាយតាមភូមិសាស្ត្រនៃការឆ្លើយតបទៅនឹងអាទិភាពដែលបានកំណត់ដោយមូលដ្ឋាន នឹងត្រូវបញ្ចប់នៅពាក់កណ្តាលឆ្នាំ២០០៨។

តារាងទី ២១ : ស្តីពីការសង្ខេបលទ្ធផលនៃសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក ខណ្ឌ ដែលមាននៅក្នុងទំព័រខាងក្រោយនេះ នឹងបង្ហាញអំពីព័ត៌មានសង្ខេបស្តីពីលទ្ធផលនៃសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក ខណ្ឌ នៃស្រុក ខណ្ឌចំនួន១៨៥ នៅក្នុងខេត្ត ក្រុងទាំង២៤ ដែលមានការចូលរួមដោយក្រុមប្រឹក្សាឃុំ សង្កាត់ទាំង ១៦២១ឃុំ សង្កាត់។ តារាងនេះ នឹងសង្ខេបអំពីចំនួនសរុបនៃគម្រោងអាទិភាពដែលបានស្នើឡើងដោយក្រុមប្រឹក្សាឃុំ សង្កាត់ ដែលមាននៅក្នុងផ្នែកទាំងប្រាំនៃផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ចំនួននៃកិច្ចព្រមព្រៀងបណ្តោះអាសន្នដែលបានចុះហត្ថលេខាជាមួយមន្ទីរជំនាញ អង្គការមិនមែនរដ្ឋាភិបាល អ្នកផ្តល់ជំនួយឯកជន ដែលបានគាំទ្រគម្រោងដែលមាននៅក្នុងតារាងម៉ាទ្រិច នៃគម្រោងអាទិភាពនៅក្នុងស្រុក ខណ្ឌ និងទាំងការគាំទ្រគម្រោងដែលមិនមាននៅក្នុងតារាងម៉ាទ្រិច និងភាគរយនៃកិច្ចព្រមព្រៀងដែលបានចុះហត្ថលេខា ក្នុងការឆ្លើយតបដោយផ្ទាល់ទៅលើគម្រោងអាទិភាពដែលបានកំណត់ដោយថ្នាក់មូលដ្ឋាន។ ព័ត៌មានសង្ខេបនៃលទ្ធផលសិក្ខាសាលាសមាហរណកម្មមានដូចខាងក្រោម៖

គម្រោងអាទិភាពសរុបចំនួន ៦២.៥០០គម្រោងត្រូវបានលើកឡើងដោយ ១.៦២១ឃុំ សង្កាត់ (ជាមធ្យម គឺ ៣៨ គម្រោងក្នុងមួយឃុំ សង្កាត់)។ គម្រោងទាំងនេះមានចំនួនច្រើនជាងគម្រោង ដែលបានលើកឡើងក្នុងឆ្នាំ២០០៦ ចំនួន៣៥%។ ប្រមាណមួយភាគបីនៃគម្រោងអាទិភាព គឺជាគម្រោងក្នុងផ្នែកសេដ្ឋកិច្ច មួយភាគបី គឺជាគម្រោងផ្នែកសង្គមកិច្ច និងមួយភាគបី គឺជាគម្រោងនៃផ្នែកធនធានធម្មជាតិ និងបរិស្ថាន យេនឌ័រ និងផ្នែកសេវារដ្ឋបាល និងសន្តិសុខ។ ទាំងនេះជាភស្តុតាង ដែលអាចបញ្ជាក់បានថា គំនិតដែលយល់ឃើញថាក្រុមប្រឹក្សាឃុំ សង្កាត់ បានលើកដាក់ក្នុងផែនការតែគម្រោងហេដ្ឋារចនាសម្ព័ន្ធនោះ គឺជាការមិនពិតឡើយ។

កិច្ចព្រមព្រៀងបណ្តោះអាសន្នសរុបចំនួន៦២.៥០០ ត្រូវបានចុះហត្ថលេខា (គិតជាជាមធ្យម គឺមាន ២១ កិច្ចព្រមព្រៀង ក្នុងមួយឃុំសង្កាត់) ដែលចំនួនកិច្ចព្រមព្រៀងបណ្តោះអាសន្ននេះ តិចជាងចំនួនកិច្ចព្រមព្រៀងក្នុងឆ្នាំ ២០០៦។ ក្នុងចំណោមកិច្ចព្រមព្រៀងបណ្តោះអាសន្នក្នុងឆ្នាំ២០០៧ មានកិច្ចព្រមព្រៀងចំនួន៦០% ត្រូវបានចុះហត្ថលេខារវាងក្រុមប្រឹក្សាឃុំ សង្កាត់ជាមួយមន្ទីរជំនាញ ចំនួន៤០%ត្រូវបានចុះហត្ថលេខារវាងក្រុមប្រឹក្សាឃុំ សង្កាត់ជាមួយអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ។ ក្នុងចំណោមកិច្ចព្រមព្រៀងបណ្តោះអាសន្ន ដែលបានចុះហត្ថលេខា មានកិច្ចព្រមព្រៀងចំនួន ៤០% គឺជាការឆ្លើយផ្ទាល់ទៅលើគម្រោងអាទិភាព ដែលបានលើកឡើងដោយឃុំ

សង្កាត់ ដែលចំនួននេះមានការកើនឡើង១០% បើប្រៀបធៀបទៅនឹងឆ្នាំ២០០៦។ ភាគរយនៃកិច្ចព្រមព្រៀងបណ្តោះនៃការឆ្លើយតបផ្ទាល់ទៅលើគម្រោង ដែលបានលើកឡើងដោយឃុំ សង្កាត់ មានកម្រិតខុសៗគ្នារវាងខេត្ត ក្រុងមួយ ទៅខេត្ត ក្រុងមួយទៀត។ ខេត្ត ក្រុងដែលមានភាគរយខ្ពស់ជាងគេ គឺខេត្តបាត់ដំបង ដែលមានរហូតដល់៧០% និងខេត្ត ក្រុងដែលមានភាគរយទាបជាងគេ គឺក្រុងប៉ៃលិន មាន២០%។ ភាគរយជាមធ្យម គឺប្រមាណ២៤%។ ការវិភាគមួយចំនួនទៀត នឹងត្រូវធ្វើនៅក្នុងឆ្នាំ២០០៨ ដើម្បីរិះរកកត្តាជាក់លាក់មួយចំនួន ដែលពាក់ព័ន្ធនឹងការកំណត់កម្រិតនៃការឆ្លើយតបពីថ្នាក់ខេត្ត ក្រុង ទៅលើគម្រោងអាទិភាពឃុំ សង្កាត់។

## តារាងទី២១ : សង្ខេបលទ្ធផលសិក្ខាសាលាផែនការសមាហរណកម្មផែនការថ្នាក់ស្រុក ខណ្ឌឆ្នាំ២០០៨ : គ្រប់ខេត្ត ក្រុង

| កូដ GIS | ខេត្ត ក្រុង | ចំនួន ឃុំ សង្កាត់ | ចំនួនគម្រោងអាទិភាពឃុំ សង្កាត់ឆ្នាំ២០០៨តាមផ្នែក | | | | | | កិច្ចព្រមព្រៀងបណ្ដោះអាសន្នដែលបានចុះហត្ថលេខានៅក្នុងឆ្នាំ២០០៧ | | | | | | | | សរុបរួម |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | មន្ទីរ វិស័យ | | NGO/IO | | វិស័យឯកជននិងផ្សេងទៀត | | សរុប | | |
| | | | សេដ្ឋកិច្ច | សង្គមកិច្ច | NREM | ខ | យេនឌ័រ | សរុប | ក្នុង DPAM | ក្រៅ DPAM | ក្នុង DPAM | ក្រៅ DPAM | ក្នុង DPAM | ក្រៅ DPAM | ក្នុង DPAM | ក្រៅ DPAM | |
| (1) | (2) | (3) | (4) | (5) | (6) | (7) | (8) | (9) | (10) | (11) | (12) | (13) | (14) | (15) | (16) | (17) | (18) |
| 1 | បន្ទាយមានជ័យ | 64 | 822 | 950 | 242 | 327 | 260 | 2,601 | 277 | 242 | 487 | 1,133 | | | 764 | 1,375 | 2,139 |
| 2 | បាត់ដំបង | 96 | 1,505 | 1,726 | 625 | 740 | 651 | 5,247 | 703 | 176 | 1,318 | 697 | | | 2,021 | 873 | 2,894 |
| 3 | កំពង់ចាម | 173 | 2,172 | 1,610 | 628 | 710 | 521 | 5,641 | 1,044 | 1,073 | 147 | 369 | 0 | 3 | 1,191 | 1,445 | 2,636 |
| 4 | កំពង់ឆ្នាំង | 69 | 761 | 696 | 231 | 336 | 261 | 2,285 | 187 | 167 | 223 | 1,254 | 0 | 0 | 410 | 1,421 | 1,831 |
| 5 | កំពង់ស្ពឺ | 87 | 1,310 | 1,308 | 457 | 509 | 364 | 3,948 | 459 | 1,088 | 44 | 209 | 0 | 0 | 503 | 1,297 | 1,800 |
| 6 | កំពង់ធំ | 81 | 896 | 875 | 313 | 463 | 501 | 3,048 | 263 | 194 | 45 | 309 | 9 | 9 | 317 | 512 | 829 |
| 7 | កំពត | 92 | 1,269 | 1,018 | 328 | 548 | 372 | 3,535 | 390 | 822 | 67 | 169 | | | 457 | 991 | 1,448 |
| 8 | កណ្ដាល | 147 | 1,027 | 1,066 | 433 | 595 | 438 | 3,559 | 392 | 615 | 128 | 190 | 3 | 1 | 523 | 806 | 1,329 |
| 9 | កោះកុង | 33 | 240 | 175 | 120 | 115 | 89 | 739 | 58 | 117 | 24 | 84 | | | 82 | 201 | 283 |
| 10 | ក្រចេះ | 46 | 778 | 749 | 377 | 430 | 216 | 2,550 | 98 | 268 | 128 | 448 | 0 | 0 | 226 | 716 | 942 |
| 11 | មណ្ឌលគិរី | 21 | 264 | 222 | 77 | 80 | 74 | 717 | 92 | 178 | 106 | 169 | | | 198 | 347 | 545 |
| 12 | ភ្នំពេញ | 76 | 246 | 817 | 378 | 796 | 392 | 2,629 | 1,367 | 1,170 | 134 | 210 | 6 | 1 | 1,507 | 1,381 | 2,888 |
| 13 | ព្រះវិហារ | 49 | 499 | 426 | 118 | 138 | 102 | 1,283 | 123 | 82 | 73 | 222 | 0 | 0 | 196 | 304 | 500 |
| 14 | ព្រៃវែង | 116 | 1,838 | 1,756 | 308 | 552 | 391 | 4,845 | 880 | 593 | 771 | 812 | 0 | 0 | 1,651 | 1,405 | 3,056 |
| 15 | ពោធិ៍សាត់ | 49 | 1,049 | 939 | 466 | 600 | 393 | 3,447 | 204 | 261 | 198 | 326 | 0 | 0 | 402 | 587 | 989 |
| 16 | រតនគិរី | 49 | 556 | 499 | 207 | 215 | 176 | 1,653 | 164 | 183 | 29 | 372 | 0 | 0 | 193 | 555 | 748 |
| 17 | សៀមរាប | 100 | 1,310 | 1,060 | 442 | 489 | 380 | 3,681 | 458 | 311 | 206 | 377 | 2 | 4 | 666 | 692 | 1,358 |
| 18 | ក្រុងព្រះសីហនុ | 22 | 302 | 308 | 174 | 188 | 132 | 1,104 | 600 | 382 | 77 | 134 | 0 | 0 | 677 | 516 | 1,193 |
| 19 | ស្ទឹងត្រែង | 34 | 314 | 386 | 146 | 125 | 144 | 1,115 | 197 | 510 | 34 | 215 | 0 | 0 | 231 | 725 | 956 |
| 20 | ស្វាយរៀង | 80 | 1,240 | 1,442 | 334 | 522 | 640 | 4,178 | 731 | 1,782 | 307 | 243 | 6 | 51 | 1,044 | 2,076 | 3,120 |
| 21 | តាកែវ | 100 | 943 | 666 | 269 | 268 | 247 | 2,393 | 393 | 422 | 223 | 606 | 0 | 0 | 616 | 1,028 | 1,644 |
| 22 | ឧត្តរមានជ័យ | 24 | 702 | 625 | 88 | 157 | 118 | 1,690 | 89 | 350 | 85 | 132 | 0 | 0 | 174 | 482 | 656 |
| 23 | ក្រុងកែប | 5 | 105 | 95 | 66 | 45 | 34 | 345 | 110 | 60 | 19 | 10 | 0 | 0 | 129 | 70 | 199 |
| 24 | ក្រុងប៉ៃលិន | 8 | 86 | 81 | 20 | 35 | 25 | 247 | 36 | 161 | 66 | 263 | 0 | 0 | 102 | 424 | 526 |
| | សរុប | 1,621 | 20,234 | 19,495 | 6,847 | 8,983 | 6,921 | 62,480 | 9,315 | 11,207 | 4,939 | 8,953 | 26 | 69 | 14,280 | 20,229 | 34,509 |
| | ភាគរយ | | 32% | 31% | 11% | 14% | 11% | 100% | 27% | 32% | 14% | 26% | 0% | 0% | 41% | 59% | 100% |

កំណត់សម្គាល់ :

ក). "នៅ DPAM" សំដៅទៅលើសកម្មភាពនានាដែលបានស្នើឡើងដោយឃុំសង្កាត់ ហើយបានបញ្ចូលក្នុងតារាងម៉ាទ្រិចនៃសកម្មភាពអាទិភាពតាមស្រុកខណ្ឌ ដែលរៀបចំដោយមន្ទីរផែនការ សម្រាប់សិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក

ខ). "ក្រៅ DPAM" សំដៅទៅលើសកម្មភាពនានាដែលបានស្នើឡើងដោយមន្ទីរ ឬអង្គការមិនមែនរដ្ឋាភិបាល ដែលឃុំសង្កាត់មិនស្នើឡើង ហើយមិនបានបញ្ចូលក្នុងតារាងម៉ាទ្រិចនៃសកម្មភាពអាទិភាពតាមស្រុកខណ្ឌ ។

គ). ភាគរយគាំទ្រគម្រោងឃុំ សង្កាត់ "ធៀបកូឡោនទី១៤". "សរុបក្នុង DPAM" ជាមួយកូឡោនទី៩ "គម្រោងអាទិភាពឃុំ សង្កាត់ឆ្នាំ២០០៨សរុប" ។

## ៦. ការរៀបចំកម្មវិធីថវិកាតាមខេត្ត ក្រុង ឆ្នាំ ២០០៨

បន្ទាប់ពីសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក ខណ្ឌ ក្រុមប្រឹក្សាឃុំ សង្កាត់បានបញ្ចប់ការរៀបចំកម្មវិធីវិនិយោគ និងថវិកាប្រចាំឆ្នាំ២០០៨របស់ខ្លួន រួមជាមួយនឹងការដឹងអំពីសេវាកម្ម និងការវិនិយោគ ដែលនឹងត្រូវផ្តល់ដោយមន្ទីរជំនាញ និងភ្នាក់ងារនានា។ ក្នុងពេលនោះដែរ គណៈកម្មាធិការអភិវឌ្ឍន៍ស្រុក ខណ្ឌ ដែលមានការពាក់ព័ន្ធជាមួយនឹងកម្មវិធីពង្រឹងតួនាទីថ្នាក់ស្រុក ខណ្ឌ ជាមួយនឹងមន្ទីរជំនាញ និងភ្នាក់ងារអនុវត្តនានា ក៏ត្រូវបញ្ចប់ការរៀបចំផែនការសកម្មភាព និងថវិកា ដែលឆ្លុះបញ្ចាំងពីកិច្ចព្រមព្រៀងនៃការគាំទ្រដល់គម្រោងអាទិភាពរបស់មូលដ្ឋាន សកម្មភាពពាក់ព័ន្ធទៅនឹងការកែលម្អការផ្តល់សេវាកម្ម និងចំណាយប្រតិបត្តិការ។ នៅគ្រប់ថ្នាក់ទាំងអស់ការរៀបចំថវិកា នឹងត្រូវបញ្ចប់នៅចុងឆ្នាំ២០០៧ ហើយធនធាននានានឹងត្រូវបានរៀបចំជាកិច្ចសន្យាសម្រាប់កាអនុវត្តសម្រាប់ឆ្នាំ២០០៨។

នៅក្នុង៧ទំព័រខាងក្រោមនេះ គឺជាតារាងទី ២២ សង្ខេបថវិកាប្រចាំឆ្នាំ២០០៨របស់ គ.ជ.វ.វ តាមខេត្ត ក្រុងនីមួយៗ ដែលឆ្លុះបញ្ចាំងឱ្យឃើញអំពីធនធានថវិកាសរុប ដែលបានដាក់ក្នុងផែនការ/កម្មវិធី និងដែលនឹងត្រូវផ្តល់នៅក្នុងឆ្នាំ២០០៨ ក្រោមក្របខ័ណ្ឌផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ គ.ជ.វ.វ តាមប្រភេទនៃថវិកានិមួយៗ។ ថវិកាវិភាជន៍នៃមូលនិធិឃុំ សង្កាត់សរុបតាមខេត្ត ក្រុងនីមួយៗ នឹងបង្ហាញពីថវិកាវិភាជន៍សរុបសម្រាប់ផ្នែករដ្ឋបាល និងផ្នែកវិនិយោគរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់នៅក្នុងខេត្ត ក្រុងនីមួយៗនោះ។ តារាងថវិកាវិភាជន៍សរុបសម្រាប់ឃុំ សង្កាត់ទាំងអស់ នឹងមានបង្ហាញនៅក្នុងឧបសម្ព័ន្ធទី IV ស្តីពីមូលនិធិឃុំ សង្កាត់ឆ្នាំ២០០៨។

## តារាងទី២២ : សង្ខេបថវិកាឆ្នាំ២០០៨ តាមខេត្ត ក្រុង

| កូដ GIS | 01 | 02 | 03 | 04 | 05 | 06 | 07 | 08 | 09 | 10 | 11 | 12 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ខេត្ត ក្រុង | បន្ទាយមានជ័យ | បាត់ដំបង | កំពង់ចាម | កំពង់ឆ្នាំង | កំពង់ស្ពឺ | កំពង់ធំ | កំពត | កណ្ដាល | កោះកុង | ក្រចេះ | មណ្ឌលគិរី | ភ្នំពេញ |
| **I. ទុនវិនិយោគ** | | | | | | | | | | | | |
| **១.១. ការវិភាជន៍មូលនិធិឃុំ សង្កាត់ (ដុល្លារ)** | **1,009,188** | **1,435,083** | **2,695,069** | **899,371** | **1,385,839** | **1,153,046** | **1,112,465** | **2,022,097** | **352,958** | **561,539** | **210,473** | **1,252,812** |
| មូលនិធិផ្នែកអភិវឌ្ឍន៍ (រៀល) | 2,670,383,400 | 3,898,898,600 | 7,007,424,000 | 2,416,020,000 | 3,236,902,000 | 3,020,506,000 | 3,186,723,000 | 5,468,552,000 | 1,017,342,000 | 1,593,504,000 | 597,698,000 | 3,366,542,000 |
| មូលនិធិផ្នែករដ្ឋបាល (រៀល) | 1,467,288,000 | 1,984,940,200 | 4,042,358,200 | 1,271,400,700 | 2,445,037,900 | 1,706,983,200 | 1,374,382,200 | 2,822,047,700 | 429,785,900 | 708,805,000 | 265,242,500 | 1,769,986,200 |
| **១.២. ឃុំ សង្កាត់ គោលដៅ** | **297,241** | **1,427,823** | **850,006** | **283,800** | **782,241** | **501,034** | **414,093** | **814,684** | **117,100** | **366,200** | **236,926** | **15,200** |
| ADB/TSSL | 0 | 757,500 | 0 | 270,000 | 0 | 380,000 | 0 | 0 | 0 | 0 | 0 | 0 |
| ADB/CCDP2 | 273,941 | 395,693 | 0 | 0 | 365,255 | 0 | 395,693 | 608,758 | 0 | 0 | 138,226 | 0 |
| MDLF NRM in D&D | 0 | 0 | 572,000 | 0 | 328,000 | 0 | 0 | 0 | 104,000 | 184,000 | 84,000 | 0 |
| USAID-PACT/LAAR | 0 | 238,430 | 86,406 | 0 | 0 | 63,791 | 0 | 41,526 | 0 | 0 | 0 | 0 |
| UNICEF/Seth Koma | 0 | 0 | 0 | 0 | 88,986 | 57,243 | 0 | 0 | 0 | 0 | 0 | 0 |
| WB/LASED | 0 | 0 | 150,000 | 0 | 0 | 0 | 0 | 0 | 0 | 150,000 | 0 | 0 |
| PSDD/CCWC | 12,800 | 19,200 | 34,600 | 13,800 | 0 | 0 | 18,400 | 29,400 | 6,600 | 9,200 | 4,200 | 15,200 |
| GRET/PACEPAC | 0 | 0 | 0 | 0 | 0 | 0 | 0 | 45,000 | 0 | 0 | 0 | 0 |
| IFAD/RPRP - CIDF | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| UNFPA | 10,500 | 17,000 | 7,000 | 0 | 0 | 0 | 0 | 0 | 6,500 | 23,000 | 10,500 | 0 |
| AusAid/CCJAP | | | | | | | | 90,000 | | | | |
| **១. សរុបថ្នាក់ឃុំ សង្កាត់ (ដុល្លារ)** | **1,306,429** | **2,862,905** | **3,545,075** | **1,183,171** | **2,168,080** | **1,654,080** | **1,526,557** | **2,836,781** | **470,058** | **927,739** | **447,399** | **1,268,012** |
| **២. កម្មវិធីសាកល្បងថ្នាក់ស្រុក ខណ្ឌ** | **89,104** | **58,595** | **849,435** | **375,214** | **261,055** | **86,045** | **28,129** | **405,588** | **376,875** | **309,718** | **189,662** | **115,000** |
| MDLF/NRM In D&D | 0 | 0 | 588,390 | 0 | 261,055 | 0 | 0 | 0 | 286,875 | 228,673 | 189,662 | 0 |
| EC-UNDP/DDLG-ICC | 0 | 0 | 180,000 | 334,818 | 0 | 0 | 0 | 319,543 | 90,000 | 0 | 0 | 90,000 |
| WB/DFGG-OWSO | 61,045 | 33,595 | 61,045 | 0 | 0 | 61,045 | 0 | 61,045 | 0 | 61,045 | 0 | 0 |
| PSDD | 28,059 | 25,000 | 0 | 40,396 | 0 | 25,000 | 28,129 | 25,000 | 0 | 0 | 0 | 25,000 |
| UNCDF/IDLD | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| WB/LASED | 0 | 0 | 20,000 | 0 | 0 | 0 | 0 | 0 | 0 | 20,000 | 0 | 0 |
| **៣. វិនិយោគថ្នាក់ខេត្ត ក្រុង** | | | | | | | | | | | | |
| **កសិកម្ម** | **105,550** | **360,210** | **35,400** | **18,500** | **25,400** | **6,500** | **12,800** | **20,475** | **15,250** | **483,343** | **15,496** | **17,700** |
| កម្មវិធីកម្ចី IFAD | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 483,343 | 0 | 0 |
| មូលនិធិចូលរួមពីរាជរដ្ឋាភិបាលកម្ពុជាដល់គម្រោង IFAD | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| PSDD/PIF គាំទ្រដល់សេវាកម្មផ្សព្វផ្សាយ | 10,000 | 11,000 | 0 | 18,500 | 0 | 6,500 | 12,800 | 20,475 | 15,250 | 0 | 0 | 17,700 |
| MDLF/NRML គាំទ្រដល់សេវាកម្មផ្សព្វផ្សាយ | 0 | 0 | 35,400 | 0 | 25,400 | 0 | 0 | 0 | 0 | 0 | 15,496 | 0 |
| Canada/ADMAC | 95,550 | 349,210 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| **វប្បធម៌** | **0** | **4,500** | **0** | **4,000** | **13,300** | **2,500** | **3,200** | **0** | **4,000** | **3,500** | **0** | **0** |
| PSDD/PIF គាំទ្រដល់សកម្មភាពវប្បធម៌ | 0 | 4,500 | 0 | 4,000 | 0 | 2,500 | 3,200 | 0 | 0 | 0 | 0 | 0 |
| MDLF/NRML គាំទ្រដល់វប្បធម៌ | 0 | 0 | 0 | 0 | 13,300 | 0 | 0 | 0 | 4,000 | 3,500 | 0 | 0 |

## តារាងទី២២ : សង្ខេបថវិកាឆ្នាំ២០០៨ តាមខេត្ត ក្រុង

| កូដ GIS<br>ខេត្ត ក្រុង | 01<br>បន្ទាយមានជ័យ | 02<br>បាត់ដំបង | 03<br>កំពង់ចាម | 04<br>កំពង់ឆ្នាំង | 05<br>កំពង់ស្ពឺ | 06<br>កំពង់ធំ | 07<br>កំពត | 08<br>កណ្ដាល | 09<br>កោះកុង | 10<br>ក្រចេះ | 11<br>មណ្ឌលគិរី | 12<br>ភ្នំពេញ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ៣. វិនិយោគថ្នាក់ខេត្ត ក្រុង (ត) | | | | | | | | | | | | |
| **អប់រំ** | **2,500** | **94,591** | **0** | **0** | **22,500** | **8,944** | **0** | **5,000** | **5,505** | **2,500** | **11,634** | **0** |
| PSDD/PIF គាំទ្រដល់សាលារៀន-អប់រំក្រៅប្រព័ន្ធ | 2,500 | 5,000 | 0 | 0 | 14,000 | 0 | 0 | 5,000 | 5,505 | 2,500 | 11,634 | 0 |
| EC-UNDP/EFMP គាំទ្រដល់សាលារៀន | 0 | 89,591 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| UNICEF/SK គាំទ្រដល់សាលារៀន-អប់រំក្រៅប្រព័ន្ធ | 0 | 0 | 0 | 0 | 8,580 | 8,944 | 0 | 0 | 0 | 0 | 0 | 0 |
| **បរិស្ថាន** | **6,922** | **7,000** | **0** | **5,000** | **11,800** | **4,500** | **4,700** | **5,300** | **5,000** | **4,150** | **14,656** | **8,000** |
| PSDD/PIF គាំទ្រដល់សកម្មភាពបរិស្ថាន | 6,922 | 7,000 | 0 | 5,000 | 0 | 4,500 | 4,700 | 5,300 | 5,000 | 0 | 0 | 8,000 |
| MDLF/NRML គាំទ្រដល់បរិស្ថាន | 0 | 0 | 0 | 0 | 11,800 | 0 | 0 | 0 | 0 | 4,150 | 14,656 | 0 |
| **ផលផល (MDLF)** | | | | | | | | | | **6,000** | | |
| **រុក្ខាប្រមាញ់ព្រៃឈើ** | **0** | **6,000** | **4,000** | **0** | **0** | **0** | **0** | **0** | **0** | **7,000** | **0** | **0** |
| Danida-DfID/NRML គាំទ្រដល់ព្រៃឈើ | 0 | 0 | 4,000 | 0 | 0 | 0 | 0 | 0 | 0 | 7,000 | 0 | 0 |
| PSDD/PIF | 0 | 6,000 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| **សុខាភិបាល (PSDD PHC/HIV-AIDS)** | **5,000** | **8,000** | **28,193** | **0** | **0** | **6,000** | **0** | **24,530** | **0** | **20,740** | **0** | **45,750** |
| **ព័ត៌មាន (PSDD/PIF)** | **0** | **0** | **3,000** | **0** | **0** | **0** | **0** | **2,000** | **0** | **0** | **0** | **0** |
| **ការគ្រប់គ្រងដីធ្លី** | **2,500** | **8,000** | **80,000** | **2,850** | **56,692** | **4,000** | **0** | **4,000** | **60,000** | **82,855** | **77,000** | **0** |
| PSDD/PIF គាំទ្រដល់ការគ្រប់គ្រងដីធ្លី | 2,500 | 8,000 | 0 | 2,850 | 0 | 4,000 | 0 | 4,000 | 0 | 0 | 0 | 0 |
| MDLF/NRML គាំទ្រដល់ផ្នែកដីធ្លី | 0 | 0 | 80,000 | 0 | 56,692 | 0 | 0 | 0 | 60,000 | 82,855 | 77,000 | 0 |
| **ការងារ/ការបណ្ដុះបណ្ដាលវិជ្ជាជីវៈ** | **0** | **5,000** | **6,000** | **0** | **0** | **4,000** | **0** | **0** | **0** | **3,000** | **0** | **0** |
| PSDD/PIF | 0 | 5,000 | 6,000 | 0 | 0 | 4,000 | 0 | 0 | 0 | 0 | 0 | 0 |
| MDLF/NRML | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 3,000 | 0 | 0 |
| **អង្គភាពដែនការដោះមីន (MAPU)** | **17,801** | **31,923** | **0** | **0** | **0** | **0** | **0** | **0** | **0** | **0** | **0** | **0** |
| PSDD/PIF | 0 | 8,000 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| Canada/ADMAC | 17,801 | 23,923 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| **ផែនការខេត្ត ក្រុង** | **8,500** | **11,800** | **17,375** | **7,975** | **15,500** | **12,800** | **8,700** | **11,850** | **6,725** | **6,500** | **8,325** | **8,300** |
| PSDD/PIF | 8,500 | 11,800 | 17,375 | 7,975 | 10,000 | 7,300 | 8,700 | 11,850 | 6,725 | 6,500 | 8,325 | 8,300 |
| UNICEF/SK | 0 | 0 | 0 | 0 | 5,500 | 5,500 | 0 | 0 | 0 | 0 | 0 | 0 |
| **សាធារណការ (PSDD/PIF)** | **0** | **0** | **0** | **0** | **0** | **0** | **0** | **5,000** | **0** | **0** | **0** | **0** |
| **កិច្ចការសាសនា (PSDD/PIF)** | **4,800** | **0** | **0** | **0** | **0** | **0** | **0** | **0** | **0** | **0** | **0** | **0** |
| **ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ជនបទ** | **16,797** | **1,099,230** | **104,507** | **12,012** | **0** | **11,081** | **5,792** | **25,300** | **0** | **8,596** | **10,636** | **0** |
| EC-UNDP/EFMP គាំទ្រដល់ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ជនបទ | 0 | 1,085,230 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| PSDD/PIF គាំទ្រដល់ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ | 16,797 | 14,000 | 104,507 | 12,012 | 0 | 11,081 | 5,792 | 25,300 | 0 | 8,596 | 10,636 | 0 |

## តារាងទី២២ : សង្ខេបថវិកាឆ្នាំ២០០៨ តាមខេត្ត ក្រុង

| កូដ GIS / ខេត្ត ក្រុង | 01 បន្ទាយមានជ័យ | 02 បាត់ដំបង | 03 កំពង់ចាម | 04 កំពង់ឆ្នាំង | 05 កំពង់ស្ពឺ | 06 កំពង់ធំ | 07 កំពត | 08 កណ្ដាល | 09 កោះកុង | 10 ក្រចេះ | 11 មណ្ឌលគិរី | 12 ភ្នំពេញ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ៣. វិនិយោគថ្នាក់ខេត្ត ក្រុង (ត) | | | | | | | | | | | | |
| **ទឹកស្អាតជនបទ/អនាម័យ** | 7,425 | 11,125 | 0 | 5,000 | 245,002 | 255,760 | 8,300 | 0 | 7,000 | 4,500 | 0 | 20,000 |
| PSDD/PIF គាំទ្រដល់ទឹកស្អាតជនបទ-អនាម័យ | 7,425 | 4,625 | 0 | 5,000 | 20,600 | 0 | 8,300 | 0 | 7,000 | 4,500 | 0 | 20,000 |
| UNICEF/SK គាំទ្រដល់ទឹកស្អាតជនបទ-អនាម័យ | 0 | 0 | 0 | 0 | 224,402 | 255,760 | 0 | 0 | 0 | 0 | 0 | 0 |
| EC-UNDP/EFMP គាំទ្រដល់ផ្គត់ផ្គង់ទឹកស្អាតជនបទ | 0 | 6,500 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| **សង្គមកិច្ច (PSDD/PIF)** | 4,400 | 4,700 | 5,000 | 2,500 | 0 | 3,500 | 0 | 0 | 0 | 0 | 0 | 0 |
| **ទេសចរណ៍** | 0 | 0 | 0 | 2,000 | 0 | 0 | 1,400 | 0 | 0 | 7,726 | 0 | 0 |
| PSDD/PIF | 0 | 0 | 0 | 2,000 | 0 | 0 | 1,400 | 0 | 0 | 0 | 0 | 0 |
| MDLF/NRML គាំទ្រដល់ទេសចរណ៍នៅមូលដ្ឋាន | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 7,726 | 0 | 0 |
| **ធនធានទឹក** | 11,105 | 7,000 | 68,310 | 3,000 | 35,167 | 32,435 | 39,458 | 37,080 | 27,250 | 28,050 | 0 | 22,150 |
| PSDD/PIF គាំទ្រដល់ធារាសាស្ត្រខ្នាតតូច-ការសិក្សា | 11,105 | 7,000 | 0 | 3,000 | 35,167 | 32,435 | 39,458 | 37,080 | 0 | 28,050 | 0 | 22,150 |
| IFAD គាំទ្រដល់ប្រព័ន្ធធារាសាស្ត្រខ្នាតមធ្យម | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| មូលនិធិចូលរួមពីរាជរដ្ឋាភិបាលកម្ពុជាដល់គម្រោង IFAD | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| MDLF/NRML គាំទ្រដល់ធារាសាស្ត្រ/WUG | 0 | 0 | 68,310 | 0 | 0 | 0 | 0 | 0 | 27,250 | 0 | 0 | 0 |
| **កិច្ចការនារី** | 8,500 | 85,000 | 21,825 | 8,750 | 32,850 | 41,873 | 15,800 | 13,250 | 7,670 | 6,500 | 8,620 | 9,700 |
| PSDD/PIF គាំទ្រដល់ការបញ្ជ្រាបយេនឌ័រ | 8,500 | 12,000 | 21,825 | 8,750 | 0 | 1,000 | 15,800 | 13,250 | 7,670 | 6,500 | 8,620 | 9,700 |
| UNICEF/SK គាំទ្រដល់ការបញ្ជ្រាបយេនឌ័រ | 0 | 0 | 0 | 0 | 9,348 | 9,600 | 0 | 0 | 0 | 0 | 0 | 0 |
| UNICEF/SK គាំទ្រដល់ស្ត្រី/កុមារ | 0 | 0 | 0 | 0 | 23,502 | 31,273 | 0 | 0 | 0 | 0 | 0 | 0 |
| កម្មវិធីកម្ចី IFAD | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| មូលនិធិចូលរួមពីរាជរដ្ឋាភិបាលកម្ពុជាដល់គម្រោង IFAD | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| EC-UNDP/EFMP គាំទ្រដល់ការបណ្តុះបណ្តាលជំនាញនានា | 0 | 73,000 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| **៣. សរុបវិនិយោគថ្នាក់ខេត្ត ក្រុង** | 201,800 | 1,744,079 | 373,610 | 71,587 | 458,211 | 393,893 | 100,150 | 153,785 | 138,400 | 674,960 | 146,367 | 131,600 |
| **II. ការគាំទ្រកម្មវិធីខេត្ត ក្រុង** | | | | | | | | | | | | |
| **៤.១. សេវាកម្មប្រតិបត្តិការនានា** | 136,294 | 228,394 | 301,193 | 138,035 | 224,073 | 223,165 | 179,343 | 238,801 | 143,144 | 119,775 | 97,130 | 139,017 |
| រដ្ឋបាលមូលដ្ឋានរបស់ គ.ប្រ | 46,996 | 106,035 | 146,025 | 62,178 | 119,907 | 124,322 | 77,316 | 113,734 | 70,078 | 50,942 | 42,780 | 63,433 |
| រដ្ឋបាល និងកិច្ចសន្យារបស់ គ.ប្រ | 55,538 | 70,067 | 86,901 | 41,562 | 57,092 | 53,709 | 65,683 | 63,358 | 37,653 | 44,105 | 30,707 | 36,581 |
| សេវាកម្មហិរញ្ញវត្ថុរបស់ គ.ប្រ | 17,228 | 23,170 | 33,015 | 17,846 | 25,260 | 19,770 | 14,468 | 33,764 | 13,338 | 13,131 | 10,706 | 20,934 |
| សេវាកម្មបច្ចេកទេសរបស់ គ.ប្រ | 16,532 | 29,122 | 35,252 | 16,449 | 21,814 | 25,364 | 21,876 | 27,945 | 22,075 | 11,597 | 12,937 | 18,069 |
| **៤.២. ប្រតិបត្តិការរបស់ PSDD** | 22,325 | 40,400 | 25,530 | 19,595 | 19,930 | 23,250 | 20,795 | 20,620 | 22,450 | 21,645 | 16,780 | 19,595 |
| **៤. សរុបការគាំទ្រកម្មវិធីខេត្ត ក្រុង** | 158,619 | 268,794 | 326,723 | 157,630 | 244,003 | 246,415 | 200,138 | 259,421 | 165,594 | 141,420 | 113,910 | 158,612 |

## តារាងទី២២ : សង្ខេបថវិកាឆ្នាំ២០០៨ តាមខេត្ត ក្រុង

| កូដ GIS<br>ខេត្ត ក្រុង | 01<br>បន្ទាយមានជ័យ | 02<br>បាត់ដំបង | 03<br>កំពង់ចាម | 04<br>កំពង់ឆ្នាំង | 05<br>កំពង់ស្ពឺ | 06<br>កំពង់ធំ | 07<br>កំពត | 08<br>កណ្ដាល | 09<br>កោះកុង | 10<br>ក្រចេះ | 11<br>មណ្ឌលគិរី | 12<br>ភ្នំពេញ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| **III. កិច្ចសហប្រតិបត្តិការបច្ចេកទេសក្រៅ** | | | | | | | | | | | | |
| ៥. សរុបកិច្ចសហប្រតិបត្តិការបច្ចេកទេស | **74,497** | **164,571** | **119,371** | **112,072** | **121,922** | **124,988** | **66,848** | **89,797** | **84,673** | **95,722** | **84,123** | **76,522** |
| ជាតិ | 74,497 | 139,571 | 119,371 | 87,072 | 121,922 | 99,988 | 66,848 | 89,797 | 84,673 | 95,722 | 84,123 | 76,522 |
| អន្តរជាតិ | 0 | 25,000 | 0 | 25,000 | 0 | 25,000 | 0 | 0 | 0 | 0 | 0 | 0 |
| ៦. សរុបរួមជាសង្ខេបនៅថ្នាក់ខេត្ត ក្រុង | | | | | | | | | | | | |
| មូលនិធិឃុំ សង្កាត់ | 1,009,188 | 1,435,083 | 2,695,069 | 899,371 | 1,385,839 | 1,153,046 | 1,112,465 | 2,022,097 | 352,958 | 561,539 | 210,473 | 1,252,812 |
| មូលនិធិសម្រាប់ឃុំ សង្កាត់គោលដៅ | 297,241 | 1,427,823 | 850,006 | 283,800 | 782,241 | 501,034 | 414,093 | 814,684 | 117,100 | 366,200 | 236,926 | 15,200 |
| កម្មវិធីសាកល្បងថ្នាក់ស្រុក ខណ្ឌ | 89,104 | 58,595 | 849,435 | 375,214 | 261,055 | 86,045 | 28,129 | 405,588 | 376,875 | 309,718 | 189,662 | 115,000 |
| វិនិយោគខេត្ត ក្រុង | 201,800 | 1,744,079 | 373,610 | 71,587 | 458,211 | 393,893 | 100,150 | 153,785 | 138,400 | 674,960 | 146,367 | 131,600 |
| ការគាំទ្រកម្មវិធី | 158,619 | 268,794 | 326,723 | 157,630 | 244,003 | 246,415 | 200,138 | 259,421 | 165,594 | 141,420 | 113,910 | 158,612 |
| កិច្ចសហប្រតិបត្តិការបច្ចេកទេសខាងក្រៅ | 74,497 | 164,571 | 119,371 | 112,072 | 121,922 | 124,988 | 66,848 | 89,797 | 84,673 | 95,722 | 84,123 | 76,522 |
| **សរុបរួម** | **$1,830,449** | **$5,098,944** | **$5,214,213** | **$1,899,674** | **$3,253,271** | **$2,505,420** | **$1,921,822** | **$3,745,372** | **$1,235,599** | **$2,149,559** | **$981,461** | **$1,749,746** |

## តារាងទី២២ : សង្ខេបថវិកាឆ្នាំ២០០៨ តាមខេត្ត ក្រុង

| កូដ GIS | 13 | 14 | 15 | 16 | 17 | 18 | 19 | 20 | 21 | 22 | 23 | 24 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ខេត្ត ក្រុង | ព្រះវិហារ | ព្រៃវែង | ពោធិ៍សាត់ | រតនគិរី | សៀមរាប | ក្រុងព្រះសីហនុ | ស្ទឹងត្រែង | ស្វាយរៀង | តាកែវ | ឧត្តរមានជ័យ | ក្រុងកែប | ក្រុងប៉ៃលិន |
| **I. វិនិយោគ** | | | | | | | | | | | | |
| **១.១. ការវិភាជន៍មូលនិធិឃុំ សង្កាត់ (ដុល្លារ)** | **528,893** | **1,771,669** | **727,314** | **517,895** | **1,418,744** | **275,781** | **346,950** | **1,074,746** | **1,540,464** | **330,935** | **58,962** | **112,893** |
| មូលនិធិផ្ទេរអភិវឌ្ឍន៍ (រៀល) | 1,434,499,000 | 4,535,468,000 | 1,851,358,000 | 1,438,069,000 | 3,732,918,000 | 796,255,000 | 993,231,000 | 2,776,494,000 | 3,844,764,000 | 843,215,000 | 174,689,000 | 287,325,000 |
| មូលនិធិផ្ទេររដ្ឋបាល (រៀល) | 707,517,000 | 2,639,793,000 | 1,094,263,700 | 659,405,200 | 2,012,995,000 | 320,658,100 | 411,916,700 | 1,576,227,900 | 2,394,114,800 | 497,072,400 | 64,105,500 | 169,893,000 |
| **១.២. ឃុំ សង្កាត់ គោលដៅ** | **9,800** | **873,564** | **2,949,238** | **510,179** | **2,339,568** | **92,400** | **186,189** | **160,862** | **617,284** | **164,081** | **142,752** | **249,103** |
| ADB/TSSL | 0 | 0 | 2,720,500 | 0 | 1,565,000 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| ADB/CCDP2 | 0 | 0 | 0 | 304,379 | 456,568 | 0 | 152,189 | 0 | 395,693 | 141,350 | 121,752 | 243,503 |
| MDLF NRM in D&D | 0 | 0 | 144,000 | 196,000 | 276,000 | 88,000 | 0 | 0 | 0 | 0 | 20,000 | 0 |
| USAID-PACT/LAAR | 0 | 73,429 | 74,938 | 0 | 0 | 0 | 0 | 57,848 | 107,181 | 0 | 0 | 0 |
| UNICEF/Seth Koma | 0 | 82,712 | 0 | 0 | 0 | 0 | 34,000 | 62,214 | 0 | 22,731 | 0 | 0 |
| WB/LASED | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| PSDD/CCWC | 9,800 | 0 | 9,800 | 9,800 | 20,000 | 4,400 | 0 | 0 | 20,000 | 0 | 1,000 | 1,600 |
| GRET/PACEPAC | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 94,410 | 0 | 0 | 0 |
| IFAD/RPRP - CIDF | 0 | 717,423 | 0 | 0 | 0 | 0 | 0 | 40,800 | 0 | 0 | 0 | 0 |
| UNFPA | 0 | 0 | 0 | 0 | 22,000 | 0 | 0 | 0 | 0 | 0 | 0 | 4,000 |
| AusAid/CCJAP | | | | | | | | | | | | |
| **១. សរុបថ្នាក់ឃុំ សង្កាត់ (ដុល្លារ)** | **538,693** | **2,645,233** | **3,676,552** | **1,028,074** | **3,758,312** | **368,181** | **533,140** | **1,235,608** | **2,157,748** | **495,017** | **201,713** | **361,997** |
| **២. កម្មវិធីសាកល្បងថ្នាក់ស្រុក ខណ្ឌ** | **25,000** | **334,902** | **249,327** | **461,262** | **430,627** | **377,147** | **28,208** | **324,147** | **301,727** | **31,221** | **81,306** | **34,380** |
| MDLF/NRM In D&D | 0 | 0 | 249,327 | 371,262 | 397,032 | 118,687 | 0 | 0 | 0 | 0 | 81,306 | 0 |
| EC-UNDP/DDLG-ICC | 0 | 180,000 | 0 | 90,000 | 0 | 197,416 | 0 | 236,115 | 270,727 | 0 | 0 | 0 |
| WB/DFGG-OWSO | 0 | 61,045 | 0 | 0 | 33,595 | 61,045 | 0 | 0 | 0 | 0 | 0 | 0 |
| PSDD | 25,000 | 33,857 | 0 | 0 | 0 | 0 | 28,208 | 28,032 | 31,001 | 31,221 | 0 | 34,380 |
| UNCDF/IDLD | 0 | 60,000 | 0 | 0 | 0 | 0 | 0 | 60,000 | 0 | 0 | 0 | 0 |
| WB/LASED | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| **៣. វិនិយោគថ្នាក់ខេត្ត ក្រុង** | | | | | | | | | | | | |
| **កសិកម្ម** | **649,707** | **1,543,747** | **22,750** | **559,056** | **17,630** | **15,000** | **12,764** | **923,430** | **16,000** | **5,140** | **5,000** | **122,577** |
| កម្មវិធីកម្ចី IFAD | 576,418 | 1,521,009 | 0 | 477,593 | 0 | 0 | 0 | 907,868 | 0 | 0 | 0 | 0 |
| មូលនិធិចូលរួមពីរាជរដ្ឋាភិបាលកម្ពុជាដល់គម្រោង IFAD | 73,289 | 22,738 | 0 | 64,663 | 0 | 0 | 0 | 15,562 | 0 | 0 | 0 | 0 |
| PSDD/PIF គាំទ្រដល់សេវាកម្មផ្សព្វផ្សាយ | 0 | 0 | 0 | 0 | 0 | 0 | 12,764 | 0 | 16,000 | 5,140 | 0 | 0 |
| MDLF/NRML គាំទ្រដល់សេវាកម្មផ្សព្វផ្សាយ | 0 | 0 | 22,750 | 16,800 | 17,630 | 15,000 | 0 | 0 | 0 | 0 | 5,000 | 0 |
| Canada/ADMAC | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 122,577 |
| **វប្បធម៌** | **0** | **0** | **0** | **0** | **4,200** | **0** | **3,300** | **0** | **3,000** | **0** | **0** | **1,550** |
| PSDD/PIF គាំទ្រដល់សកម្មភាពវប្បធម៌ | 0 | 0 | 0 | 0 | 4,200 | 0 | 3,300 | 0 | 3,000 | 0 | 0 | 1,550 |
| MDLF/NRML គាំទ្រដល់វប្បធម៌ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |

## តារាងទី២២ : សង្ខេបថវិកាឆ្នាំ២០០៨ តាមខេត្ត ក្រុង

| កូដ GIS | 13 | 14 | 15 | 16 | 17 | 18 | 19 | 20 | 21 | 22 | 23 | 24 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ខេត្ត ក្រុង | ព្រះវិហារ | ព្រៃវែង | ពោធិ៍សាត់ | រតនគិរី | សៀមរាប | ក្រុងព្រះសីហនុ | ស្ទឹងត្រែង | ស្វាយរៀង | តាកែវ | ឧត្តរមានជ័យ | ក្រុងកែប | ក្រុងប៉ៃលិន |
| ៣. វិនិយោគថ្នាក់ខេត្ត ក្រុង (ត) | | | | | | | | | | | | |
| **អប់រំ** | **7,000** | **58,017** | **10,000** | **7,600** | **18,434** | **4,000** | **7,000** | **42,186** | **16,523** | **7,861** | **6,000** | **9,000** |
| PSDD/PIF គាំទ្រដល់សាលារៀន-អប់រំក្រៅប្រព័ន្ធ | 7,000 | 47,916 | 10,000 | 7,600 | 18,434 | 4,000 | 0 | 27,059 | 16,523 | 0 | 6,000 | 9,000 |
| EC-UNDP/EFMP គាំទ្រដល់សាលារៀន | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| UNICEF/SK គាំទ្រដល់សាលារៀន-អប់រំក្រៅប្រព័ន្ធ | 0 | 10,102 | 0 | 0 | 0 | 0 | 7,000 | 15,127 | 0 | 7,861 | 0 | 0 |
| **បរិស្ថាន** | **1,800** | **4,000** | **4,900** | **7,400** | **7,950** | **4,150** | **3,000** | **3,700** | **4,000** | **0** | **2,000** | **2,510** |
| PSDD/PIF គាំទ្រដល់សកម្មភាពបរិស្ថាន | 1,800 | 4,000 | 0 | 0 | 0 | 0 | 3,000 | 3,700 | 4,000 | 0 | 0 | 2,510 |
| MDLF/NRML គាំទ្រដល់បរិស្ថាន | 0 | 0 | 4,900 | 7,400 | 7,950 | 4,150 | 0 | 0 | 0 | 0 | 2,000 | 0 |
| **ផលផល (MDLF)** | | | | **5,600** | | | | | | | | |
| **រុក្ខាប្រមាញ់ព្រៃឈើ** | **0** | **0** | **0** | **0** | **8,000** | **5,000** | **0** | **0** | **0** | **0** | **0** | **0** |
| Danida-DfID/NRML គាំទ្រដល់ព្រៃឈើ | 0 | 0 | 0 | 0 | 8,000 | 5,000 | 0 | 0 | 0 | 0 | 0 | 0 |
| PSDD/PIF | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| **សុខាភិបាល (PSDD PHC/HIV-AIDS)** | **0** | **0** | **5,750** | **0** | **4,300** | **0** | **0** | **6,000** | **6,500** | **0** | **5,000** | **0** |
| **ពត៌មាន (PSDD/PIF)** | **0** | **0** | **0** | **3,825** | **3,950** | **5,000** | **3,000** | **2,500** | **3,000** | **0** | **0** | **0** |
| **ការគ្រប់គ្រងដីធ្លី** | **0** | **0** | **63,399** | **73,000** | **55,051** | **46,431** | **0** | **3,000** | **5,500** | **0** | **19,014** | **0** |
| PSDD/PIF គាំទ្រដល់ការគ្រប់គ្រងដីធ្លី | 0 | 0 | 0 | 0 | 0 | 0 | 0 | 3,000 | 5,500 | 0 | 0 | 0 |
| MDLF/NRML គាំទ្រដល់ផ្នែកដីធ្លី | 0 | 0 | 63,399 | 73,000 | 55,051 | 46,431 | 0 | 0 | 0 | 0 | 19,014 | 0 |
| **ការងារ/ការបណ្តុះបណ្តាលវិជ្ជាជីវៈ** | **0** | **5,000** | **7,600** | **4,000** | **5,400** | **0** | **0** | **3,000** | **0** | **0** | **0** | **0** |
| PSDD/PIF | 0 | 5,000 | 7,600 | 4,000 | 5,400 | 0 | 0 | 3,000 | 0 | 0 | 0 | 0 |
| MDLF/NRML | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| **អង្គភាពដែនការដោះមីន (MAPU)** | **8,560** | **0** | **0** | **0** | **0** | **0** | **0** | **0** | **0** | **5,760** | **0** | **16,577** |
| PSDD/PIF | 8,560 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 5,760 | 0 | 0 |
| Canada/ADMAC | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 16,577 |
| **ផែនការខេត្ត ក្រុង** | **6,350** | **15,423** | **7,100** | **8,000** | **11,910** | **5,400** | **12,064** | **13,425** | **9,550** | **8,900** | **4,325** | **4,400** |
| PSDD/PIF | 6,350 | 9,423 | 7,100 | 8,000 | 11,910 | 5,400 | 8,064 | 7,925 | 9,550 | 5,400 | 4,325 | 4,400 |
| UNICEF/SK | 0 | 6,000 | 0 | 0 | 0 | 0 | 4,000 | 5,500 | 0 | 3,500 | 0 | 0 |
| **សាធារណការ (PSDD/PIF)** | **0** | **0** | **0** | **0** | **0** | **0** | **0** | **0** | **0** | **0** | **0** | **0** |
| **កិច្ចការសាសនា (PSDD/PIF)** | **0** | **0** | **2,900** | **0** | **5,500** | **0** | **0** | **0** | **0** | **0** | **0** | **0** |
| **ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ជនបទ** | **17,747** | **31,103** | **8,200** | **0** | **33,871** | **1,000** | **7,342** | **12,102** | **18,055** | **2,000** | **3,900** | **6,226** |
| EC-UNDP/EFMP គាំទ្រដល់ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ជនបទ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| PSDD/PIF គាំទ្រដល់ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ | 17,747 | 31,103 | 8,200 | 0 | 33,871 | 1,000 | 7,342 | 12,102 | 18,055 | 2,000 | 3,900 | 6,226 |

## តារាងទី២២ : សង្ខេបថវិកាឆ្នាំ២០០៨ តាមខេត្ត ក្រុង

| កូដ GIS / ខេត្ត ក្រុង | 13 ព្រះវិហារ | 14 ព្រៃវែង | 15 ពោធិ៍សាត់ | 16 រតនគិរី | 17 សៀមរាប | 18 ក្រុងព្រះសីហនុ | 19 ស្ទឹងត្រែង | 20 ស្វាយរៀង | 21 តាកែវ | 22 ឧត្តរមានជ័យ | 23 ក្រុងកែប | 24 ក្រុងប៉ៃលិន |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ៣. វិនិយោគថ្នាក់ខេត្ត ក្រុង (ត) | | | | | | | | | | | | |
| ទឹកស្អាតជនបទ/អនាម័យ | 0 | 230,792 | 3,300 | 9,750 | 6,090 | 14,658 | 86,205 | 219,323 | 0 | 120,000 | 6,342 | 3,240 |
| PSDD/PIF គាំទ្រដល់ទឹកស្អាតជនបទ-អនាម័យ | 0 | 0 | 3,300 | 9,750 | 6,090 | 14,658 | 0 | 0 | 0 | 0 | 6,342 | 3,240 |
| UNICEF/SK គាំទ្រដល់ទឹកស្អាតជនបទ-អនាម័យ | 0 | 230,792 | 0 | 0 | 0 | 0 | 86,205 | 219,323 | 0 | 120,000 | 0 | 0 |
| EC-UNDP/EFMP គាំទ្រដល់ផ្គត់ផ្គង់ទឹកស្អាតជនបទ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| សង្គមកិច្ច (PSDD/PIF) | 0 | 4,000 | 3,000 | 5,000 | 2,723 | 3,000 | 0 | 3,000 | 3,000 | 0 | 0 | 0 |
| ទេសចរណ៍ | 0 | 5,000 | 8,365 | 8,700 | 0 | 0 | 0 | 1,200 | 0 | 1,100 | 5,487 | 0 |
| PSDD/PIF | 0 | 5,000 | 0 | 0 | 0 | 0 | 0 | 1,200 | 0 | 1,100 | 5,487 | 0 |
| MDLF/NRML គាំទ្រដល់ទេសចរណ៍នៅមូលដ្ឋាន | 0 | 0 | 8,365 | 8,700 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| ធនធានទឹក | 0 | 64,650 | 8,800 | 0 | 28,570 | 8,000 | 0 | 18,683 | 10,000 | 20,895 | 10,000 | 5,469 |
| PSDD/PIF គាំទ្រដល់ធារាសាស្ត្រខ្នាតតូច-ការសិក្សា | 0 | 56,250 | 8,800 | 0 | 6,750 | 8,000 | 0 | 8,683 | 10,000 | 20,895 | 0 | 5,469 |
| IFAD គាំទ្រដល់ប្រព័ន្ធធារាសាស្ត្រខ្នាតមធ្យម | 0 | 8,400 | 0 | 0 | 0 | 0 | 0 | 9,759 | 0 | 0 | 0 | 0 |
| មូលនិធិចូលរួមពីរាជរដ្ឋាភិបាលកម្ពុជាដល់គម្រោង IFAD | 0 | 0 | 0 | 0 | 0 | 0 | 0 | 241 | 0 | 0 | 0 | 0 |
| MDLF/NRML គាំទ្រដល់ធារាសាស្ត្រ/WUG | 0 | 0 | 0 | 0 | 21,820 | 0 | 0 | 0 | 0 | 0 | 10,000 | 0 |
| កិច្ចការនារី | 66,694 | 90,576 | 7,850 | 62,290 | 11,000 | 6,025 | 28,000 | 68,728 | 10,675 | 26,513 | 5,488 | 4,625 |
| PSDD/PIF គាំទ្រដល់ការបញ្ជ្រាបយេនឌ័រ | 7,616 | 0 | 7,850 | 8,500 | 11,000 | 6,025 | 0 | 3,000 | 10,675 | 0 | 5,488 | 4,625 |
| UNICEF/SK គាំទ្រដល់ការបញ្ជ្រាបយេនឌ័រ | 0 | 12,000 | 0 | 0 | 0 | 0 | 6,500 | 9,100 | 0 | 6,000 | 0 | 0 |
| UNICEF/SK គាំទ្រដល់ស្ត្រី/កុមារ | 0 | 41,000 | 0 | 0 | 0 | 0 | 21,500 | 33,868 | 0 | 20,513 | 0 | 0 |
| កម្មវិធីកម្ចី IFAD | 49,773 | 36,246 | 0 | 44,530 | 0 | 0 | 0 | 21,430 | 0 | 0 | 0 | 0 |
| មូលនិធិចូលរួមពីរាជរដ្ឋាភិបាលកម្ពុជាដល់គម្រោង IFAD | 9,305 | 1,330 | 0 | 9,260 | 0 | 0 | 0 | 1,330 | 0 | 0 | 0 | 0 |
| EC-UNDP/EFMP គាំទ្រដល់ការបណ្តុះបណ្តាលជំនាញនានា | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| ៣. សរុបវិនិយោគថ្នាក់ខេត្ត ក្រុង | 757,857 | 2,052,308 | 163,913 | 754,221 | 224,579 | 117,664 | 162,675 | 1,320,278 | 105,803 | 198,169 | 72,557 | 176,173 |
| II. ការគាំទ្រកម្មវិធីខេត្ត ក្រុង | | | | | | | | | | | | |
| ៤.១. សេវាកម្មប្រតិបត្តិការនានា | 127,504 | 380,559 | 120,491 | 167,737 | 197,830 | 102,362 | 133,684 | 295,950 | 187,706 | 117,620 | 71,844 | 58,898 |
| រដ្ឋបាលមូលដ្ឋានរបស់ គ.ប្រ | 49,855 | 209,157 | 46,447 | 73,494 | 106,307 | 45,092 | 56,177 | 149,750 | 86,252 | 44,025 | 37,773 | 15,878 |
| រដ្ឋបាល និងកិច្ចសន្យារបស់ គ.ប្រ | 40,069 | 108,946 | 43,240 | 63,197 | 45,537 | 32,891 | 43,057 | 72,597 | 51,879 | 50,090 | 22,890 | 27,765 |
| សេវាកម្មហិរញ្ញវត្ថុរបស់ គ.ប្រ | 18,805 | 22,584 | 16,861 | 12,911 | 22,185 | 12,963 | 19,450 | 29,812 | 25,806 | 11,252 | 5,870 | 9,414 |
| សេវាកម្មបច្ចេកទេសរបស់ គ.ប្រ | 18,775 | 39,872 | 13,943 | 18,135 | 23,801 | 11,416 | 15,000 | 43,791 | 23,769 | 12,253 | 5,311 | 5,842 |
| ៤.២. ប្រតិបត្តិការរបស់ PSDD | 25,650 | 27,130 | 19,395 | 24,780 | 25,590 | 16,990 | 19,260 | 21,645 | 20,965 | 19,410 | 13,444 | 13,495 |
| ៤. សរុបការគាំទ្រកម្មវិធីខេត្ត ក្រុង | 153,154 | 407,689 | 139,886 | 192,517 | 223,420 | 119,352 | 152,944 | 317,595 | 208,671 | 137,030 | 85,288 | 72,393 |

## តារាងទី២២ : សង្ខេបថវិកាឆ្នាំ២០០៨ តាមខេត្ត ក្រុង

| កូដ GIS | 13 | 14 | 15 | 16 | 17 | 18 | 19 | 20 | 21 | 22 | 23 | 24 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ខេត្ត ក្រុង | ព្រះវិហារ | ព្រៃវែង | ពោធិ៍សាត់ | រតនគិរី | សៀមរាប | ក្រុងព្រះសីហនុ | ស្ទឹងត្រែង | ស្វាយរៀង | តាកែវ | ឧត្តរមានជ័យ | ក្រុងកែប | ក្រុងប៉ៃលិន |
| **III. កិច្ចសហប្រតិបត្តិការបច្ចេកទេសក្រៅ** | | | | | | | | | | | | |
| ៥. សរុបកិច្ចសហប្រតិបត្តិការបច្ចេកទេស | **96,971** | **134,971** | **291,164** | **116,171** | **390,462** | **83,923** | **88,723** | **120,046** | **77,647** | **89,423** | **53,449** | **35,724** |
| ជាតិ | 96,971 | 134,971 | 146,164 | 116,171 | 195,462 | 83,923 | 88,723 | 120,046 | 77,647 | 89,423 | 53,449 | 35,724 |
| អន្តរជាតិ | 0 | 0 | 145,000 | 0 | 195,000 | 0 | 0 | 0 | 0 | 0 | 0 | 0 |
| ៦. សរុបរួមជាសង្ខេបនៅថ្នាក់ខេត្ត ក្រុង | | | | | | | | | | | | |
| មូលនិធិឃុំ សង្កាត់ | 528,893 | 1,771,669 | 727,314 | 517,895 | 1,418,744 | 275,781 | 346,950 | 1,074,746 | 1,540,464 | 330,935 | 58,962 | 112,893 |
| មូលនិធិសម្រាប់ឃុំ សង្កាត់គោលដៅ | 9,800 | 873,564 | 2,949,238 | 510,179 | 2,339,568 | 92,400 | 186,189 | 160,862 | 617,284 | 164,081 | 142,752 | 249,103 |
| កម្មវិធីសាកល្បងថ្នាក់ស្រុក ខណ្ឌ | 25,000 | 334,902 | 249,327 | 461,262 | 430,627 | 377,147 | 28,208 | 324,147 | 301,727 | 31,221 | 81,306 | 34,380 |
| វិនិយោគខេត្ត ក្រុង | 757,857 | 2,052,308 | 163,913 | 754,221 | 224,579 | 117,664 | 162,675 | 1,320,278 | 105,803 | 198,169 | 72,557 | 176,173 |
| ការគាំទ្រកម្មវិធី | 153,154 | 407,689 | 139,886 | 192,517 | 223,420 | 119,352 | 152,944 | 317,595 | 208,671 | 137,030 | 85,288 | 72,393 |
| កិច្ចសហប្រតិបត្តិការបច្ចេកទេសខាងក្រៅ | 96,971 | 134,971 | 291,164 | 116,171 | 390,462 | 83,923 | 88,723 | 120,046 | 77,647 | 89,423 | 53,449 | 35,724 |
| **សរុបរួម** | **$1,571,675** | **$5,575,102** | **$4,520,841** | **$2,552,245** | **$5,027,400** | **$1,066,267** | **$965,689** | **$3,317,674** | **$2,851,596** | **$950,859** | **$494,313** | **$680,666** |

## តារាងទី២២ : សង្ខេបថវិកាឆ្នាំ២០០៨ តាមខេត្ត ក្រុង

| ខេត្ត ក្រុង | 1 | | 2 | 3 | 4 | 5 | | 6 | |
|---|---|---|---|---|---|---|---|---|---|
| | មូលនិធិ ឃុំ សង្កាត់ | មូលនិធិសម្រាប់ ឃុំសង្កាត់គោលដៅ | ស្រុក ខណ្ឌ | វិនិយោគ ខេត្ត ក្រុង | សរុបវិនិយោគ ខេត្ត ក្រុង | គាំទ្រកម្មវិធី ខេត្ត ក្រុង | សរុប | ជំនួយ បច្ចេកទេស | សរុបរួម |
| បន្ទាយមានជ័យ | 1,021,647 | 297,241 | 89,104 | 201,800 | **1,609,792** | 158,619 | **1,768,411** | 74,497 | **1,842,908** |
| បាត់ដំបង | 1,452,800 | 1,427,823 | 58,595 | 1,744,079 | **4,683,296** | 268,794 | **4,952,090** | 164,571 | **5,116,661** |
| កំពង់ចាម | 2,728,341 | 850,006 | 849,435 | 373,610 | **4,801,392** | 326,723 | **5,128,114** | 119,371 | **5,247,485** |
| កំពង់ឆ្នាំង | 910,474 | 283,800 | 375,214 | 71,587 | **1,641,076** | 157,630 | **1,798,706** | 112,072 | **1,910,778** |
| កំពង់ស្ពឺ | 1,402,948 | 782,241 | 261,055 | 458,211 | **2,904,455** | 244,003 | **3,148,459** | 121,922 | **3,270,381** |
| កំពង់ធំ | 1,167,281 | 501,034 | 86,045 | 393,893 | **2,148,253** | 246,415 | **2,394,668** | 124,988 | **2,519,655** |
| កំពត | 1,126,199 | 414,093 | 28,129 | 100,150 | **1,668,570** | 200,138 | **1,868,708** | 66,848 | **1,935,556** |
| កណ្ដាល | 2,047,062 | 814,684 | 405,588 | 153,785 | **3,421,119** | 259,421 | **3,680,540** | 89,797 | **3,770,336** |
| កោះកុង | 357,316 | 117,100 | 376,875 | 138,400 | **989,690** | 165,594 | **1,155,284** | 84,673 | **1,239,957** |
| ក្រចេះ | 568,471 | 366,200 | 309,718 | 674,960 | **1,919,349** | 141,420 | **2,060,769** | 95,722 | **2,156,491** |
| មណ្ឌលគិរី | 213,072 | 236,926 | 189,662 | 146,367 | **786,027** | 113,910 | **899,937** | 84,123 | **984,059** |
| ភ្នំពេញ | 1,268,279 | 15,200 | 115,000 | 131,600 | **1,530,079** | 158,612 | **1,688,691** | 76,522 | **1,765,213** |
| ព្រះវិហារ | 528,893 | 9,800 | 25,000 | 757,857 | **1,321,550** | 153,154 | **1,474,704** | 96,971 | **1,571,675** |
| ព្រៃវែង | 1,771,669 | 873,564 | 334,902 | 2,052,308 | **5,032,443** | 407,689 | **5,440,132** | 134,971 | **5,575,102** |
| ពោធិ៍សាត់ | 727,314 | 2,949,238 | 249,327 | 163,913 | **4,089,792** | 139,886 | **4,229,677** | 291,164 | **4,520,841** |
| រតនគិរី | 517,895 | 510,179 | 461,262 | 754,221 | **2,243,557** | 192,517 | **2,436,074** | 116,171 | **2,552,245** |
| សៀមរាប | 1,418,744 | 2,339,568 | 430,627 | 224,579 | **4,413,518** | 223,420 | **4,636,938** | 390,462 | **5,027,400** |
| ក្រុងព្រះសីហនុ | 275,781 | 92,400 | 377,147 | 117,664 | **862,992** | 119,352 | **982,344** | 83,923 | **1,066,267** |
| ស្ទឹងត្រែង | 346,950 | 186,189 | 28,208 | 162,675 | **724,023** | 152,944 | **876,967** | 88,723 | **965,689** |
| ស្វាយរៀង | 1,074,746 | 160,862 | 324,147 | 1,320,278 | **2,880,033** | 317,595 | **3,197,628** | 120,046 | **3,317,674** |
| តាកែវ | 1,540,464 | 617,284 | 301,727 | 105,803 | **2,565,278** | 208,671 | **2,773,949** | 77,647 | **2,851,596** |
| ឧត្ដរមានជ័យ | 330,935 | 164,081 | 31,221 | 198,169 | **724,406** | 137,030 | **861,436** | 89,423 | **950,859** |
| ក្រុងកែប | 58,962 | 142,752 | 81,306 | 72,557 | **355,576** | 85,288 | **440,864** | 53,449 | **494,313** |
| ក្រុងប៉ៃលិន | 112,893 | 249,103 | 34,380 | 176,173 | **572,549** | 72,393 | **644,942** | 35,724 | **680,666** |
| **សរុបរួម** | **$22,969,136** | **$14,401,368** | **$5,823,673** | **$10,694,638** | **$53,888,815** | **$4,651,217** | **$58,540,032** | **$2,793,775** | **$61,333,807** |
| | **$37,370,503** | | | | | | | | |

# ៧. ការវិភាគថវិកាតាមផ្នែកនីមួយៗ

## ៧.១ មូលនិធិឃុំ សង្កាត់

### ៧.១.១ ធនធានដែលអាចមាន

ក្នុងឆ្នាំ២០០៨ ធនធានដែលត្រូវបានវិភាជន៍ឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ បានមកពី ៣ ប្រភពដូចខាងក្រោម៖

- **រាជរដ្ឋាភិបាល :** យោងតាមអនុក្រឹត្យលេខ១០៩ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៧ ភាគរយនៃចំណូលចរន្តដែលត្រូវធ្វើការវិភាជន៍ឱ្យទៅមូលនិធិឃុំ សង្កាត់សម្រាប់ឆ្នាំ២០០៨ គឺស្មើនឹង ២,៧%នៃចំណូលចរន្តឆ្នាំ២០០៧ ដែលស្មើនឹង៨៧,៨ កោដិរៀល (២១,៧លានដុល្លារ) និងមានថវិកាវិភាជន៍បន្ថែមចំនួន៣,២ កោដិរៀល (៧៨៨.០០០ដុល្លារ) សម្រាប់បង្គ្រប់លើការកើនឡើងនៃប្រាក់ឧបត្ថម្ភមេភូមិ អនុប្រធានភូមិ និងជំនួយការភូមិ ដែលបានអនុម័តជាបន្តបន្ទាប់។ ដូច្នេះ ថវិកាវិភាជន៍សរុបសម្រាប់ មូលនិធិឃុំ សង្កាត់ ឆ្នាំ២០០៨ គឺមាន ៩១ កោដិរៀល (២២,៥ លានដុល្លារ)។
- **គម្រោងគាំទ្រវិមជ្ឈការ និងវិសហមជ្ឈការ** (PSDD)**:** នៅខែតុលា គម្រោង PSDD បានប្រកាសជូនដំណឹងស្តីពីការផ្តល់ថវិកាជំនួយចំនួន ៥.០០០.០០០ ដុល្លារ (២,០២៥ កោដិរៀល) សម្រាប់ធ្វើការវិភាជន៍ឱ្យទៅមូលនិធិឃុំ សង្កាត់ឆ្នាំ២០០៨។
- **គម្រោងវិនិយោគជនបទ និងអភិបាលកិច្ចមូលដ្ឋានរបស់ធនាគារពិភពលោក** (WB/RILG) **:** ក្រោមក្របខ័ណ្ឌផែនការសកម្មភាព និងថវិកាឆ្នាំ២០០៨នៃគម្រោងវិនិយោគជនបទ និងអភិបាលកិច្ចមូលដ្ឋានរបស់ធនាគារពិភពលោក មានថវិកាសរុបចំនួន៧,៩លានដុល្លារ សម្រាប់គាំទ្រដល់ការវិនិយោគគម្រោងមូលនិធិឃុំ សង្កាត់ក្នុងខេត្ត ក្រុងគោលដៅចំនួន២៣ខេត្ត ក្រុង តាមរបៀបនៃការទូទាត់សងពីធនាគារពិភពលោកតាមក្រោយ បន្ទាប់ពីការអនុវត្តគម្រោងមូលនិធិឃុំសង្កាត់ទាំងឡាយណាដែលមានលក្ខណៈសមស្របត្រូវបានបញ្ចប់។ តារាងខាងក្រោម នឹងបង្ហាញអំពីថវិកាវិភាជន៍សរុបសម្រាប់មូលនិធិឃុំ សង្កាត់ឆ្នាំ២០០៨ និងចំនួនសមាមាត្រប៉ាន់ស្មាននៃមូលនិធិដែលត្រូវទទួលបានការទូទាត់ដោយធនាគារពិភពលោក។

**តារាងទី២៣ : មូលនិធិឃុំ សង្កាត់ឆ្នាំ២០០៨ និងសមាមាត្រដែលបានកែតម្រូវរួច**

| ប្រភព | ជាប្រាក់រៀល | ជាប្រាក់ដុល្លារ | សមាមាត្រដែលបានកែតម្រូវរួច | | |
|---|---|---|---|---|---|
| | | | រៀល | ដុល្លារ | ភាគរយ |
| រាជរដ្ឋាភិបាលកម្ពុជា | 91,000,000,000 | 22,469,136 | 48,437,918,200 | 11,959,980 | 52% |
| ធនាគារពិភពលោក/RILGP | | | 42,562,081,800 | 10,509,156 | 46% |
| គម្រោង PSDD | 2,025,000,000 | 500,000 | 2,025,000,000 | 500,000 | 2% |
| **សរុប** | **93,025,000,000** | **22,969,136** | **93,025,000,000** | **22,969,136** | **100%** |

## ៧.១.២ ការរៀបចំកម្មវិធីសម្រាប់ការប្រើប្រាស់មូលនិធិឃុំ សង្កាត់

ការរៀបចំកម្មវិធីសម្រាប់ការប្រើប្រាស់មូលនិធិឃុំ សង្កាត់ឆ្នាំ២០០៨ គឺអនុវត្តតាមបទប្បញ្ញត្តិ ដែលមាននៅក្នុងអនុក្រឹត្យលេខ១០៩ ដែលបានបញ្ជាក់ថាមូលនិធិមិនលើសពី ៣៣% នឹងត្រូវប្រើប្រាស់សម្រាប់ការចំណាយផ្នែករដ្ឋបាល និងមូលនិធិមិនតិចជាង ៦៧% នឹងត្រូវធ្វើការវិភាជន៍សម្រាប់ការចំណាយលើផ្នែកអភិវឌ្ឍន៍។ ដូច្នេះ មូលនិធិឃុំសង្កាត់សរុប ដែលបានមកពីចំណែកនៃចំណូលចរន្តរបស់រាជរដ្ឋាភិបាលកម្ពុជា និងបានមកពីគម្រោង PSDD និងត្រូវយកមករៀបចំកម្មវិធីសម្រាប់ការប្រើប្រាស់ស្របតាមបទប្បញ្ញត្តិនេះ។ ផ្អែកតាមការពិនិត្យមើលឡើងវិញជាបន្តបន្ទាប់ទៅលើតម្រូវការថវិកាបន្ថែមបានកត់សម្គាល់ឃើញថា ដោយសារតែការកើនឡើងនៃប្រាក់ឧបត្ថម្ភមេភូមិ អនុប្រធានភូមិ និងជំនួយការភូមិ នឹងនាំឱ្យមានការថយចុះនៃថវិកាសម្រាប់ចំណាយផ្នែករដ្ឋបាលមួយចំនួន។ ដូច្នេះ រាជរដ្ឋាភិបាលកម្ពុជា បានយល់ព្រមផ្តល់ថវិកាបន្ថែមសម្រាប់បង្គ្រប់ទៅលើខ្ទង់ប្រាក់ឧបត្ថម្ភមេភូមិ អនុប្រធានភូមិ និងជំនួយការភូមិ ដើម្បីរក្សាសមាមាត្ររវាងថវិកាផ្នែករដ្ឋបាល និងផ្នែកអភិវឌ្ឍន៍ ។ តារាងទី២៤ខាងក្រោម នឹងបង្ហាញអំពីមូលនិធិឃុំ សង្កាត់ ដែលធ្វើការបែងចែកតាមផ្នែករដ្ឋបាល និងផ្នែកអភិវឌ្ឍន៍។

**តារាងទី២៤ : ការវិភាជន៍មូលនិធិឃុំ សង្កាត់តាមសមាសភាគ**

| សមាសភាគមូលនិធិឃុំ សង្កាត់ | ចំនួនវិភាជន៍ | ភាគរយ | មធ្យម/ឃុំ សង្កាត់ | |
|---|---|---|---|---|
| | | | រៀល | ដុល្លារ |
| រដ្ឋបាលទូទៅ | 29,645,220,000 | 32% | 18,288,229 | 4,516 |
| ប្រាក់ឧបត្ថម្ភសម្រាប់ថ្នាក់ដឹកនាំភូមិ | 3,191,000,000 | 3% | 1,968,538 | 486 |
| សរុបរដ្ឋបាល | **32,836,220,000** | **35%** | **20,256,767** | **5,002** |
| អភិវឌ្ឍន៍មូលដ្ឋាន | 60,188,780,000 | 65% | 37,130,648 | 9,168 |
| **សរុបរួម** | **93,025,000,000** | **100%** | **57,387,415** | **$14,170** |

**មូលនិធិផ្នែករដ្ឋបាល:** ថវិកាផ្នែករដ្ឋបាលគឺត្រូវបានវិភាជន៍ដោយផ្អែកលើចំនួននៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដែលត្រូវបានកំណត់ដោយផ្អែកទៅលើកត្តានៃចំនួនប្រជាពលរដ្ឋ។ ប្រាក់ឧបត្ថម្ភសម្រាប់មេភូមិ អនុប្រធានភូមិ និងជំនួយការភូមិ ត្រូវបានដាក់បញ្ចូលទៅក្នុងថវិកាផ្នែករដ្ឋបាលនៃមូលនិធិឃុំ សង្កាត់ ដើម្បីបង្កើនគណនេយ្យភាពរបស់មេភូមិ អនុប្រធានភូមិ និងជំនួយការភូមិ ចំពោះមុខក្រុមប្រឹក្សាឃុំ សង្កាត់ ដែលត្រូវបានជ្រើសរើសដោយការបោះឆ្នោតនៅថ្នាក់មូលដ្ឋាន។ តារាងទី២៥ខាងក្រោមនេះ បង្ហាញពីចំនួនថវិកាសរុបនៃប្រាក់ឧបត្ថម្ភប្រចាំខែរបស់សមាជិកក្រុមប្រឹក្សា មេភូមិ អនុប្រធានភូមិ និងជំនួយការភូមិសម្រាប់ឆ្នាំ២០០៨ គឺស្មើនឹង៨០% នៃថវិកាវិភាជន៍ផ្នែករដ្ឋបាលសរុប។ នៅក្នុងឆ្នាំ២០០៨ ថវិកាវិភាជន៍ជាមធ្យមសម្រាប់ចំណាយផ្នែករដ្ឋបាល ដោយមិនគិតពីប្រាក់ឧបត្ថម្ភប្រចាំខែ គឺមានចំនួនប្រមាណ ៨៨៥ដុល្លារ ក្នុង ១ ឃុំ សង្កាត់ ដែលមានចំនួន ៤០%តិចជាងថវិកាវិភាជន៍ក្នុងឆ្នាំ២០០៦ ។ ការបែងចែកថវិកាវិភាជន៍ផ្នែករដ្ឋបាល តាមប្រភេទថវិកា និងចំនួនប៉ាន់ប្រមាណជាមធ្យមតាមឃុំ សង្កាត់ នឹងមានបង្ហាញនៅក្នុងតារាងខាងក្រោម ។

**តារាងទី២៥ : ការវិភាជន៍មូលនិធិឃុំ សង្កាត់សមាភាគរដ្ឋបាលឆ្នាំ២០០៨**

| ប្រភេទថវិកា | ការវិភាជន៍សរុប | | ភាគរយ | មធ្យម/ឃុំ សង្កាត់ | |
|---|---|---|---|---|---|
| | រៀល | ដុល្លារ | | រៀល | ដុល្លារ |
| ប្រាក់ឧបត្ថម្ភក្រុមប្រឹក្សាឃុំ សង្កាត់ | 10,509,120,000 | 2,594,844 | 32% | 6,483,109 | 1,601 |
| ប្រាក់ឧបត្ថម្ភថ្នាក់ដឹកនាំភូមិ | 16,516,800,000 | 4,078,222 | 50% | 10,189,266 | 2,516 |
| រដ្ឋបាល | 5,810,300,000 | 1,434,642 | 18% | 3,584,392 | 885 |
| សរុប | **32,836,220,000** | **$8,107,709** | **100%** | **20,256,767** | **$5,002** |

**មូលនិធិផ្នែកអភិវឌ្ឍន៍ :** ដូចបានបង្ហាញនៅក្នុងតារាងទី២៤ ថវិកាសរុបចំនួន៦០.២កោដិរៀល ត្រូវបានវិភាជន៍សម្រាប់ផ្នែកអភិវឌ្ឍន៍នេះ ដែលជាមធ្យមគឺមានចំនួនប្រមាណ៩.១៦៨ដុល្លារ ក្នុងមួយឃុំ សង្កាត់។ នេះបង្ហាញឱ្យឃើញពីការកើនឡើងប្រមាណ៩០០ ដុល្លារ ក្នុងមួយឃុំ សង្កាត់ បើប្រៀបធៀបទៅនឹងថវិកាឆ្នាំ២០០៧។

ថវិកាវិភាជន៍នៃមូលនិធិឃុំ សង្កាត់សរុប ទាំងផ្នែករដ្ឋបាល និងផ្នែកអភិវឌ្ឍន៍តាមខេត្ត ក្រុងនីមួយៗ នឹងមានបង្ហាញនៅក្នុងតារាងទី២២ និងថវិកាវិភាជន៍តាមឃុំ សង្កាត់នីមួយៗនឹងមានបង្ហាញនៅក្នុងឧបសម្ព័ន្ធ ៤ ។

## ៧.២ ឃុំ សង្កាត់គោលដៅរបស់គម្រោងនានា

ដូចមានបង្ហាញនៅក្នុងតារាងទី២៦ខាងក្រោម នៅក្នុងឆ្នាំ២០០៨នេះ មានថវិកាសរុបចំនួន១៤.៣លានដុល្លារ ត្រូវបានរៀបចំនៅក្នុងកម្មវិធីគាំទ្រដល់ក្រុមប្រឹក្សាឃុំ សង្កាត់គោលដៅ ក្រោមប្រកខ័ណ្ឌនៃគម្រោងចំនួន១១ ផ្សេងៗគ្នា។ ថវិកាវិភាជន៍របស់គម្រោងទាំងនោះ ដែលផ្តល់ឱ្យឃុំ សង្កាត់គោលដៅ គឺជាធនធានវិនិយោគបន្ថែមទៅលើមូលនិធិឃុំ សង្កាត់នៃឃុំ សង្កាត់ទាំងនោះ។ ថវិកាវិភាជន៍ទាំងនេះ នឹងមានរៀបរាប់ដោយសង្ខេបដូចខាងក្រោម:

**តារាងទី២៦ ៖ ការវិភាជន៍មូលនិធិសម្រាប់ឃុំ សង្កាត់គោលដៅឆ្នាំ២០០៨**

| ល.រ | គម្រោង | ឃុំ សង្កាត់គោលដៅ | ការវិភាជន៍សរុប | ការវិភាជន៍/ឃុំ សង្កាត់ |
|---|---|---|---|---|
| 1 | ADB/TSSL | 37 | 5,693,000 | 153,865 |
| 2 | ADB/CCDP2 | 190 | 3,993,000 | 21,016 |
| 3 | MDLF NRM in D&D | 499 | 1,996,000 | 4,000 |
| 4 | USAID-PACT/LAAR | 356 | 743,549 | 2,089 |
| 5 | UNICEF/Seth Koma | 422 | 347,886 | 824 |
| 6 | WB/LASED | 10 | 300,000 | 30,000 |
| 7 | PSDD/CCWC | 1,199 | 239,800 | 200 |
| 8 | GRET/PACEPAC | 7 | 139,410 | 19,916 |
| 9 | IFAD/RPRP - CIDF | 148 | 720,313 | 4,867 |
| 10 | UNFPA | 201 | 100,500 | 500 |
| 11 | AusAid/CCJAP | 42 | 90,000 | 2,143 |
| 12 | RGC/RPRP-CIDF | 148 | 37,910 | 256 |
| សរុប | | | **$14,273,458** | |

**គម្រោងទ្រទ្រង់ជីវភាពប្រជាជនបឹងទន្លេសាបរបស់ធនាគារអភិវឌ្ឍន៍អាស៊ី** (ADB/TSSLP)៖ ក្រោមក្របខ័ណ្ឌនៃគម្រោងនេះ មានថវិកាប្រមាណ១២លានដុល្លារ នឹងត្រូវបានវិភាជន៍ឱ្យទៅក្រុមប្រឹក្សាឃុំគោលដៅចំនួន ៣៧ ឃុំ ក្នុងខេត្តគោលដៅចំនួន៥ ដែលស្ថិតនៅជុំវិញបឹងទន្លេសាប សម្រាប់រយៈពេល២ឆ្នាំ។ ជាមធ្យមថវិកាវិភាជន៍សម្រាប់ឃុំគោលដៅនីមួយៗ មានចំនួនប្រមាណ៣២០.០០០ដុល្លារ។ ក្នុងឆ្នាំ២០០៨នេះ ថវិកាវិភាជន៍ជាមធ្យមសម្រាប់ឃុំគោលដៅនីមួយៗ មានចំនួនប្រមាណ ១៥៤.០០០ដុល្លារ ។ ថវិកាវិភាជន៍នេះ នឹងត្រូវផ្ទេរទៅគណនីរបស់ឃុំ ដែលបើកនៅធនាគារពាណិជ្ជកម្ម។

**គម្រោងគាំទ្រកិច្ចអភិវឌ្ឍន៍ឃុំ សង្កាត់របស់ធនាគារអភិវឌ្ឍន៍អាស៊ី** (ADB/CCDP2)៖ ក្រោមក្របខ័ណ្ឌនៃគម្រោងនេះ មានថវិកាប្រមាណ៤លានដុល្លារ ត្រូវបានដាក់បញ្ចូលនៅក្នុងផែនការថវិកាឆ្នាំ២០០៨ សម្រាប់ការសាងសង់សាលាឃុំ សង្កាត់ចំនួន១៩០ ដែលមានតម្លៃប្រមាណ២១.០០០ ដុល្លារសម្រាប់សាលាឃុំនីមួយៗ គិតបញ្ចូលទាំងតម្លៃឧបករណ៍ និងគ្រឿងសង្ហារិមសម្រាប់បំពាក់ផងដែរ។ ការជ្រើសរើសឃុំ សង្កាត់ សម្រាប់ផ្តល់ការសាងសង់សាលាឃុំ សង្កាត់ទាំងនេះ គឺត្រូវកំណត់តាមលក្ខណៈវិនិច្ឆ័យ និងកិច្ចដំណើរការវាយតម្លៃនានា។ ថវិកាវិភាជន៍នេះ នឹងត្រូវផ្ទេរទៅគណនីរបស់ឃុំ សង្កាត់ ដែលបើកនៅធនាគារពាណិជ្ជកម្ម។

**គម្រោងគ្រប់គ្រងធនធានធម្មជាតិក្នុងក្របខ័ណ្ឌវិមជ្ឈការ និងវិសហមជ្ឈការ** (NRM in D&D)៖ ក្រោមក្របខ័ណ្ឌនៃគម្រោងនេះ ក្នុងឆ្នាំ២០០៨ មានឃុំគោលដៅសរុបចំនួន៤៩៩ឃុំ នៅក្នុង១០ខេត្ត ក្រុងគោលដៅ នឹងត្រូវទទួលបានថវិកាវិភាជន៍ជាមធ្យមចំនួន៤.០០០ដុល្លារ បន្ថែមទៅលើមូលនិធិវិនិយោគឃុំ សង្កាត់ ដើម្បីយកទៅ

គាំទ្រលើការអនុវត្តគម្រោងពាក់ព័ន្ធនឹងការគ្រប់គ្រងធនធានធម្មជាតិ ដែលបានកំណត់នៅក្នុងកម្មវិធីវិនិយោគឃុំ។ ថវិកាសរុបសម្រាប់វិភាជន៍ឱ្យឃុំគោលដៅរបស់គម្រោងនេះ មានចំនួនប្រមាណ២លានដុល្លារ។ ក្នុងឆ្នាំ២០០៨នេះ ឃុំគោលដៅចំនួន១៨ត្រូវបានកាត់បន្ថយពីក្របខ័ណ្ឌនៃគម្រោងនេះ ដោយសារឃុំគោលដៅទាំងនេះត្រូវបានទទួលថវិកាគាំទ្រដោយគម្រោង ADB/TSSLP ដែលមានលទ្ធភាពផ្តល់ថវិកាវិភាជន៍យ៉ាងច្រើនដល់ឃុំទាំងនេះ។

**គម្រោង USAID/PACT-LAAR** :ក្រោមក្របខ័ណ្ឌនៃផែនការសកម្មភាព និងថវិការបស់គម្រោងនេះ មានថវិកាសរុបប្រមាណ៧៤៥.០០០ដុល្លារ នឹងត្រូវវិភាជន៍ក្នុងលក្ខណៈជាជំនួយ ឱ្យទៅក្រុមប្រឹក្សាឃុំគោលដៅចំនួន ៣៥៦ឃុំ នៅក្នុងខេត្ត ក្រុងគោលដៅចំនួន៨។ ជំនួយទាំងនេះរួមមាន ថវិកាសម្រាប់គាំទ្រក្រុមប្រឹក្សា ឃុំគោលដៅក្នុងការបង្កើនសកម្មភាពនៃរៀបចំការងារជាមួយសហគមន៍នានានៅក្នុងមូលដ្ឋានរបស់ខ្លួន (ជាមធ្យម១.៣៦០ដុល្លារក្នុងមួយឃុំ) និងជំនួយថវិកាសម្រាប់គម្រោងកិច្ចអភិវឌ្ឍន៍សង្គម ដែលឆ្លើយតបទៅនឹងអាទិភាពដែលបានកំណត់ដោយសហគមន៍មូលដ្ឋាន (មិនលើសពី៦.០០០ដុល្លារ ក្នុងមួយឃុំ សម្រាប់រយៈពេល២ឆ្នាំ)។ ជំនួយនេះ នឹងប្រើប្រាស់ដើម្បីគាំទ្រសកម្មភាពគម្រោងអភិវឌ្ឍន៍សង្គម ហើយលំហូរនៃមូលនិធិជំនួយនេះ នឹងត្រូវផ្ទេរទៅគណនីរបស់ឃុំដែលបើកនៅធនាគារពាណិជ្ជកម្ម។

**កម្មវិធីសិទ្ធិកុមារគាំទ្រដោយ** UNICEF (UNICEF/Seth Koma): តាមរយៈកិច្ចសហប្រតិបត្តិការរវាង UNICEFជាមួយនឹងគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ ចាប់ពីឆ្នាំ២០០៤ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ត្រូវបានរៀបចំបង្កើនឡើង នៅក្នុងគ្រប់ឃុំគោលដៅរបស់កម្មវិធីសិទ្ធិកុមារ។ នៅក្នុងឆ្នាំ២០០៨នេះ UNICEF នឹងពង្រីកឃុំគោលដៅរបស់ខ្លួនពីចំនួន៣១៨ឃុំ ទៅដល់ ៤២២ឃុំគោលដៅ នៅក្នុងខេត្តគោលដៅចំនួន៦។ ថវិកាវិភាជន៍សរុបមានចំនួនប្រមាណ ៣៤៧.៨៨៦ ដុល្លារ ដែលឃុំគោលដៅនីមួយៗ នឹងទទួលបានថវិកាជាមធ្យមចំនួន៨២៥ដុល្លារ ដើម្បីគាំទ្រដល់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ការផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្តដល់អ្នកទទួលបន្ទុកកិច្ចការស្ត្រី និងកុមារ ដែលមិនមែនជាសមាជិកក្រុមប្រឹក្សាឃុំ ការផ្តល់ប្រាក់ឧបត្ថម្ភដល់គ្រូដែលត្រូវបានជ្រើសរើសសម្រាប់បង្រៀនថ្នាក់មត្តេយ្យសហគមន៍នៅតាមភូមិ និងសម្រាប់ការចំណាយនានាពាក់ព័ន្ធនិងការអនុវត្តសកម្មភាពរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការស្ត្រី និងកុមារ។

**គម្រោងការបែងចែកដីធ្លីសម្រាប់អភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ចគាំទ្រដោយធនាគារពិភពលោក (WB/LASED)**: គម្រោងនេះ នឹងត្រូវអនុម័ត និងចាប់ផ្តើមអនុវត្តនៅឆ្នាំ២០០៨។ ក្រោមក្របខ័ណ្ឌនៃគម្រោងនេះ មានថវិកាវិភាជន៍ចំនួន៣០.០០០ដុល្លារក្នុងមួយឃុំ នឹងត្រូវផ្តល់ឱ្យឃុំគោលដៅចំនួន១០ នៅក្នុងខេត្តគោលដៅចំនួន២ ដើម្បីគាំទ្រដល់ការរៀបចំគម្រោងហេដ្ឋារចនាសម្ព័ន្ធ ដែលបានកំណត់ជាអាទិភាពដោយថ្នាក់មូលដ្ឋាន ក្នុងការជួយគាំទ្រដល់ការរៀបចំលំនៅស្ថានរបស់ប្រជាជនក្រីក្រនៅក្នុងតំបន់ដីសម្បទានសង្គមកិច្ច។

**គម្រោងគាំទ្រកិច្ចអភិវឌ្ឍន៍បែបប្រជាធិតេយ្យថ្នាក់ក្រោមជាតិតាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ** (PSDD): ផ្អែកលើបទពិសោធន៍ជាវិជ្ជមានជាមួយនឹងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ នៅក្នុងខេត្ត

ទាំង៦ដែលគាំទ្រដោយ UNICEF និងការសម្រេចចិត្តរបស់គ.ជ.វ.វ ក្នុងការពង្រីកយន្តការនេះ ឱ្យគ្របដណ្តប់ទូទាំងប្រទេស ក្នុងឆ្នាំ២០០៨នេះ គម្រោង PSDD យល់ព្រមផ្តល់ការគាំទ្រដល់ឃុំ សង្កាត់ចំនួន១.១៩៩ នៅក្នុង១៨ខេត្ត ក្រុង។ ឯកសារព្រមព្រៀងសម្រាប់ការផ្តល់ជំនួយគាំទ្រនេះ កំពុងត្រូវបានរៀបចំបញ្ចប់ ហើយបានកំណត់ការគាំទ្រថវិកាដល់ឃុំ សង្កាត់ទាំង១.១៩៩ ចំនួន២០០ដុល្លារ ក្នុងមួយឃុំ សង្កាត់ សម្រាប់យកទៅគាំទ្រលើដំណើរការប្រតិបត្តិការរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ។ ថវិកាវិភាជន៍សរុប មានចំនួន២៣៩.៨០០ដុល្លារ។ ក្រៅពីថវិកានេះ គម្រោងនេះក៏គាំទ្រផងដែរ ក្នុងការផ្តល់ការសម្របសម្រួលលើការងារបណ្តុះបណ្តាល។

**គម្រោង GRET:** ផ្អែកលើបទពិសោធន៍ជាច្រើនឆ្នាំលើគម្រោងផ្គត់ផ្គង់ទឹកស្អាតជនបទ និងការបង្កើតប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត តាមរយៈភាពជាដៃគូសហប្រតិបត្តិការរវាងឯកជន និងរដ្ឋ អង្គការ GRET បានចុះហត្ថលេខាលើអនុស្សារណៈនៃកិច្ចព្រមព្រៀងជាមួយ គ.អ.ជ.ខ នៃខេត្តកណ្តាល និងខេត្តតាកែវ ដើម្បីពង្រីកការគាំទ្រដល់ឆ្នាំ២០០៩។ ក្នុងឆ្នាំ២០០៨ មានឃុំសរុបចំនួន៧ នៅក្នុងខេត្តទាំងពីរ នឹងទទួលបានការគាំទ្រពីគម្រោងនេះ ដែលមានថវិកាជាមធ្យមចំនួន២០.០០០ដុល្លារ ជាមួយនឹងថវិកាបង្គ្រប់បន្ថែមដោយផ្នែកឯកជន និងការចូលរួមសហគមន៍មូលដ្ឋាន។

**គម្រោងកាត់បន្ថយភាពក្រីក្រនៅជនបទ គាំទ្រដោយមូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្ម IFAD :** ក្រោមក្របខ័ណ្ឌនៃគម្រោងនេះ បានគាំទ្រលើការអនុវត្តផ្នែកមូលនិធិអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធឃុំ នៅខេត្តព្រៃវែង និងស្វាយរៀងចាប់តាំងពីឆ្នាំ២០០៤ តាមរយៈការផ្តល់ថវិកាវិភាជន៍បន្ថែមដល់ឃុំក្រីក្រចំនួន ១៤៨ឃុំ ។ ក្រោមក្របខ័ណ្ឌនៃគម្រោងនេះ មានថវិកាវិភាជន៍យ៉ាងច្រើនត្រូវបានផ្តល់ និងអនុវត្តក្នុងរយៈពេល៧ឆ្នាំកន្លងមក។ ក្រោមក្របខ័ណ្ឌនៃផែនការសកម្មភាព និងថវិកាឆ្នាំ២០០៨ នឹងមានថវិកាសរុបចំនួន៧៨០.០០០ដុល្លារ ត្រូវបានដាក់នៅក្នុងកម្មវិធីសម្រាប់អនុវត្ត (៣៧.៩០០ដុល្លារ ជាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា)។ ធនធានទាំងនេះ នឹងត្រូវផ្ទេរតាមរតនាគារជាតិ ទៅគណនីរបស់ឃុំ នៅរតនាគារខេត្ត និងត្រូវអនុវត្តតាមប្រព័ន្ធមូលនិធិឃុំ សង្កាត់។

**កម្មវិធីគាំទ្រពី UNFPA :** តាមរយៈអនុស្សរណៈនៃកិច្ចព្រមព្រៀងជាមួយនឹងនាយកដ្ឋានរដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃ UNFPA នឹងផ្តល់ថវិកាសរុបចំនួន ១០០.៥០០ ដុល្លារ ដល់ក្រុមប្រឹក្សាឃុំ សង្កាត់ចំនួន២០១ឃុំ សង្កាត់ នៅក្នុងខេត្ត ក្រុងចំនួន៧ ដើម្បីគាំទ្រលើការរៀបចំ និងអនុវត្តសកម្មភាពនានា ដែលពាក់ព័ន្ធនឹងបញ្ហាប្រជាជន និងភាពក្រីក្រ និងកិច្ចអភិវឌ្ឍន៍មូលដ្ឋាន ដែលមានបញ្ចូលទាំងសិទ្ធិនារី សិទ្ធកុមារ សមធិមយេនឌ័រ និងការអប់រំផ្នែកសុខភាពបន្តពូជ។

**គម្រោង AusAid/CCJAP:** គម្រោងគាំទ្រជំនួយផ្នែកយុត្តិធម៌ (CCJAP) ផ្តោតជាសំខាន់លើការរកបានយុត្តិធម៌ ការប្រឆាំងអំពើពុករលួយ និងសេចក្តីត្រូវការរបស់យុវជន និងក្រុមជនងាយរងគ្រោះ។ នៅដើមឆ្នាំ២០០៧ គម្រោងនេះបានផ្តល់ការគាំទ្រលើការរៀបចំដាក់បញ្ចូលអំពីសុវត្ថិភាពសហគមន៍ និងការការពារកុំឱ្យមានបទល្មើសឧក្រិដ្ឋ ទៅក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍន៍ឃុំ នៅក្នុងស្រុកចំនួន៦ស្រុកនៃខេត្តកណ្តាល។ ដើម្បីឆ្លើយតបទៅ

នឹងតម្រូវការដែលបានកំណត់ក្នុងអនុស្សរណៈនៃកិច្ចព្រមព្រៀងជាមួយ គ.ប្រ នៃ គ.អ.ជ.ខ គម្រោងនេះបានផ្តល់ថវិកាវិភាជន៍ចំនួន៩៥.០០០ដុល្លារ ក្នុងការគាំទ្រគម្រោងចំនួន ៦៥គម្រោងនៅក្នុងឃុំចំនួន៤២ឃុំ។

**សង្ខេបការវិនិយោគនៅថ្នាក់ឃុំ សង្កាត់:**

សរុបមូលនិធិឃុំ សង្កាត់ផ្នែកអភិវឌ្ឍន៍ រួមជាមួយនឹងមូលនិធិវិភាជន៍បន្ថែមសម្រាប់ឃុំ សង្កាត់គោលដៅរបស់គម្រោងផ្សេងៗទៀត មានចំនួនប្រមាណជិត ២៧.៦លានដុល្លារ សម្រាប់ការវិនិយោគនៅថ្នាក់ឃុំ សង្កាត់ឆ្នាំ ២០០៨។ តារាងទី២៧ ខាងក្រោមនេះ នឹងផ្តល់ព័ត៌មានធនធានវិនិយោគ ដែលអាចមានតាមឃុំ សង្កាត់ ទាំងអស់នៅទូទាំងប្រទេសក្នុងឆ្នាំ២០០៨នេះ។ ឃុំ សង្កាត់ប្រមាណ១៧% មានថវិកាវិភាជន៍ផ្នែកអភិវឌ្ឍន៍លើសពី២០.០០០ដុល្លារ ឃុំ សង្កាត់ប្រមាណ៤០% មានថវិកាវិភាជន៍ផ្នែកអភិវឌ្ឍន៍ចន្លោះពី១០.០០០-២០.០០០ដុល្លារ និងឃុំ សង្កាត់ប្រមាណ ៣៨% មានថវិកាវិភាជន៍ផ្នែកអភិវឌ្ឍន៍ចន្លោះពី ៦.៥០០-១០.០០០ដុល្លារ ។

**តារាងទី២៧ : ការវិភាជន៍មូលនិធិអភិវឌ្ឍន៍ឃុំ សង្កាត់ឆ្នាំ២០០៨**

| ប្រភព | ចំនួន |
|---|---|
| មូលនិធិឃុំ សង្កាត់ផ្នែកអភិវឌ្ឍន៍ | 14,861,427 |
| ការវិភាជន៍មូលនិធិសម្រាប់ឃុំ សង្កាត់គោលដៅ | 14,273,458 |
| **សរុបមូលនិធិដែលមាន** | **29,134,885** |
| **ការវិភាជន៍មូលនិធិជាមធ្យមសម្រាប់ឃុំ សង្កាត់នីមួយៗ** | **17,973** |
| ទំហំនៃការវិភាជន៍ | ចំនួនឃុំ សង្កាត់ |
| > $ 100,000 | 37 |
| $ 20,000 - $ 60,000 | 240 |
| $ 10,000 - $ 20,000 | 734 |
| $ 6,500 - $ 10,000 | 610 |

ការកើនឡើងនៃការផ្តល់មូលនិធិក្នុងគម្រោងអភិវឌ្ឍន៍ឱ្យទៅឃុំគោលដៅ គឺជាចំណុចវិជ្ជមានមួយ ។ ទោះជាយ៉ាងណាក្តី ក៏មានការសង្ឃឹមថា មូលនិធិឃុំ សង្កាត់របស់រាជរដ្ឋាភិបាលកម្ពុជា ដែលត្រូវធ្វើការវិភាជន៍តាមរូបមន្តដែលពាក់ព័ន្ធនឹងកត្តាចំនួនប្រជាជន និងកម្រិតនៃភាពក្រីក្រ នឹងបន្តការកើនឡើងផងដែរ។ លើសពីនេះទៀត ក្នុងឆ្នាំ ២០០៨ ក្រុមប្រឹក្សាឃុំ សង្កាត់មួយចំនួន នឹងទទួលបាននូវការគាំទ្រមូលនិធិពី ៤-៥ ប្រភព ។ ដូច្នេះ កិច្ចការសំខាន់គឺការបន្តអនុវត្តសុខដុមនីយកម្មនៃនីតិវិធីផ្សេងៗ ដើម្បីកាត់បន្ថយភាពសាំញ៉ាំសម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

## ៧.៣ ថ្នាក់ស្រុក ខណ្ឌ

នៅឆ្នាំ២០០៨ មានគម្រោង/កម្មវិធីចំនួន៦ដែលធ្វើការគាំទ្រដល់សកម្មភាពផ្សេងៗគ្នានៅថ្នាក់ស្រុក ខណ្ឌ ដើម្បីបង្កើតបទពិសោធន៍សំខាន់ៗនានា សម្រាប់កំណែទម្រង់ថ្នាក់ស្រុក ខណ្ឌនាពេលអនាគត។ ស្រុក ខណ្ឌសរុបចំនួន

១៤៣ស្រុក ខណ្ឌ ស្មើនឹង៧៥% នៃស្រុក ខណ្ឌចំនួន១៨៥ នៅក្នុងប្រទេស ត្រូវបានគាំទ្រដោយយ៉ាងតិចពី គម្រោង/កម្មវិធីចំនួន១ ក្នុងចំណោមគម្រោង/កម្មវិធីទាំង៦។ តារាងទី២៨ ខាងក្រោមបង្ហាញឱ្យឃើញថា មានថវិកាសរុបចំនួន៦លានដុល្លារ ត្រូវបានធ្វើការវិភាជន៍ ក្រោមក្របខ័ណ្ឌគម្រោង/កម្មវិធីទាំង៦នេះ ដោយរាប់បញ្ចូលទាំងថវិកាដែលសល់មកពីឆ្នាំ ២០០៧ ។

**តារាងទី២៨ : ការវិភាជន៍មូលនិធិសម្រាប់ថ្នាក់ស្រុក ខណ្ឌឆ្នាំ២០០៨**

| គម្រោង | ស្រុក ខណ្ឌគោលដៅ | ចំនួនវិភាជន៍សរុប | ចំនួនវិភាជន៍/ស្រុកខណ្ឌ |
|---|---|---|---|
| MDLF/NRM In D&D | 66 | 2,772,268 | 42,004 |
| EC-UNDP/DDLG-ICC | 44 | 2,216,210 | 50,368 |
| WB/DFGG-OWSO | 9 | 494,505 | 54,945 |
| PSDD | 28 | 408,282 | 14,582 |
| UNCDF/IDLD | 4 | 120,000 | 30,000 |
| WB/LASED | 2 | 40,000 | 20,000 |
| សរុបរួម | **153** | **$6,051,264** | **39,551** |

ការពិពណ៌នាអំពីគម្រោង/កម្មវិធីនិមួយៗ មានរៀបរាប់ដូចខាងក្រោម:

**កម្មវិធីពង្រឹងតួនាទីថ្នាក់ស្រុក ខណ្ឌ :**

កម្មវិធីពង្រឹងតួនាទីពង្រឹងថ្នាក់ស្រុក ខណ្ឌ របស់ក្រសួងមហាផ្ទៃ បានរួមបញ្ចូលនូវគោលបំណង និងធនធានរបស់គម្រោងចំនួន៣ គឺគម្រោងគ្រប់គ្រងធនធានធម្មជាតិក្នុងក្របខ័ណ្ឌវិមជ្ឈការ និងវិសហមជ្ឈការ (NRM in D&D) គម្រោងអន្តរឃុំ សង្កាត់ (EC-UNDP/DDLG) និងគម្រោងគាំទ្រវិមជ្ឈការ និងវិសហមជ្ឈការ តាមរយៈកិច្ចអភិវឌ្ឍន៍បែបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ ( PSDD)។ គម្រោងនីមួយៗនេះ មានគោលបំណងដោយឡែកៗពីគ្នា ប៉ុន្តែគម្រោងទាំងអស់នោះ ត្រូវបានអនុវត្តតាមគោលការណ៍ណែនាំ ដែលបានរៀបចំបង្កើតឡើងដោយក្រសួងមហាផ្ទៃ និងដែលបានកែសម្រួលប្រចាំឆ្នាំ ពាក់ព័ន្ធនឹងការរៀបចំផែនការ ការជ្រើសរើស និងចាត់អាទិភាពគម្រោងតាមរយៈការសម្របសម្រួលពិភាក្សាជាលក្ខណៈអន្តរឃុំ សង្កាត់ នៅថ្នាក់ស្រុក ខណ្ឌ។ នៅក្នុងឆ្នាំ២០០៨ កម្មវិធីពង្រឹងតួនាទីថ្នាក់ស្រុក ខណ្ឌ នឹងបន្តអនុវត្តសាកល្បងលើគំរូថ្មីនានា ដើម្បីរៀបចំកម្មវិធីផ្តល់សេវាកម្ម និងការវិនិយោគនៅថ្នាក់ស្រុក ខណ្ឌ ប្រកបដោយការចូលរួម ដើម្បីរៀបចំបង្កើតក្របខ័ណ្ឌគណនេយ្យភាពថ្មីសម្រាប់ការផ្តល់សេវាកម្មនៅមូលដ្ឋាន រៀបចំបង្កើតកិច្ចសហប្រតិបត្តិការអន្តរឃុំ សង្កាត់ និងដើម្បីប្រមូលផ្តុំមេរៀនបទពិសោធន៍ សម្រាប់ចូលរួមចំណែកក្នុងការរៀបចំក្របខ័ណ្ឌនៃលិខិតបទដ្ឋាននានា បម្រើឱ្យការអនុវត្តនៅថ្នាក់ស្រុក ខណ្ឌ ក្រោមក្របខ័ណ្ឌនៃច្បាប់គ្រប់គ្រងអង្គការ ។

**គម្រោងគ្រប់គ្រងធនធានធម្មជាតិក្នុងក្របខ័ណ្ឌវិមជ្ឈការ និងវិសហមជ្ឈការ** (NRM ក្នុង D&D)៖

គម្រោង នេះនឹងផ្តល់ឱ្យស្រុក ខណ្ឌគោលដៅនូវកញ្ចប់ថវិកា ដើម្បីរៀបចំផែនការកម្មវិធីប្រចាំឆ្នាំសម្រាប់គាំទ្រដល់គម្រោងសកម្មភាពពាក់ព័ន្ធទៅនឹងការលើកកម្ពស់ជីវភាពរស់នៅ តាមរយៈការកែលម្អការគ្រប់គ្រងធនធានធម្មជាតិ ដែលមានលក្ខណៈជាអន្តរឃុំ សង្កាត់ នឹងស្រមតាមលក្ខណៈវិនិច្ឆ័យដែលបានកំណត់។ ក្រោមក្របខ័ណ្ឌគ្រប់គ្រងរបស់គណៈកម្មាធិការអភិវឌ្ឍន៍ស្រុក កិច្ចសន្យាអនុវត្តសកម្មភាពគម្រោងនានា ត្រូវបានចុះហត្ថលេខាជាមួយភ្នាក់ងារអនុវត្តទាំងឡាយ ដែលក្នុងនោះរួមមានមន្ទីរជំនាញ ឬការិយាល័យជំនាញនៅថ្នាក់ស្រុក ខណ្ឌ អង្គការមិនមែនរដ្ឋាភិបាល អ្នកទទួលការ ឬអ្នកផ្តល់សេវាកម្មផ្នែកឯកជន និងគណៈកម្មការអន្តរឃុំ សង្កាត់។

**គម្រោងអន្តរឃុំ សង្កាត់** (EC-UNDP/DDLG) ៖

គម្រោងនេះ ផ្តល់នូវតួលេខថវិកាសម្រាប់រៀបចំផែនការ ដើម្បីគាំទ្រលើការអនុវត្ត ជ្រើសរើសគម្រោងអន្តរឃុំ សង្កាត់ នៅក្នុងស្រុក ខណ្ឌ ដែលបានទទួលការឯកភាពគ្នាក្នុងការជ្រើសរើសថាជាគម្រោងអាទិភាព។ ក្រោមក្របខ័ណ្ឌនៃការគ្រប់គ្រងរបស់គណៈកម្មការអន្តឃុំ ដែលបានបង្កើតឡើងសម្រាប់ការគ្រប់គ្រងការអនុវត្តគម្រោងនីមួយៗ កិច្ចសន្យាអនុវត្តគម្រោងត្រូវបានរៀបចំឡើង និងចុះហត្ថលេខាជាមួយភ្នាក់ងារអនុវត្តគម្រោង។ ភ្នាក់ងារអនុវត្តគម្រោងភាគច្រើន គឺជាអ្នកទទួលការផ្នែកឯកជន។

**គម្រោង** PSDD ៖

គម្រោងនេះ ផ្តល់កញ្ចប់ថវិកាឱ្យគណៈកម្មាធិការអភិវឌ្ឍន៍ស្រុក ខណ្ឌគោលដៅ ដោយកំណត់ភាគរយជាក់លាក់សម្រាប់ប្រើប្រាស់លើគម្រោងហេដ្ឋារចនាសម្ព័ន្ធ និងគម្រោងផ្តល់សេវាកម្ម ដែលត្រូវបានរៀបចំដាក់ក្នុងផែនការ និងកម្មវិធីប្រចាំឆ្នាំ ដើម្បីគាំទ្រកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម ដែលមានលក្ខណៈជាគម្រោងអន្តរឃុំ សង្កាត់។ ដូចកញ្ចប់ថវិកាដែលផ្តល់ដោយគម្រោង NRM in D&D ដែរ កិច្ចសន្យាអនុវត្តសកម្មភាពគម្រោង នឹងត្រូវចុះហត្ថលេខាជាមួយភ្នាក់ងារអនុវត្តន៍នានា រួមមានមន្ទីរជំនាញ ឬការិយាល័យជំនាញនៅថ្នាក់ស្រុក ខណ្ឌ អង្គការមិនមែនរដ្ឋាភិបាល អ្នកទទួលការ ឬអ្នកផ្តល់សេវាកម្មផ្នែកឯកជន និងគណៈកម្មការអន្តរឃុំ សង្កាត់។ ក្រៅពីនេះ គម្រោងនេះ ក៏បានកំណត់ភាគរយនៃថវិកាមួយចំនួនទៀត សម្រាប់ការពង្រឹងសមត្ថភាពរបស់គណៈកម្មាធិការអភិវឌ្ឍន៍ស្រុក ខណ្ឌ ដើម្បីបង្កើត និងពង្រឹងជំនាញក្នុងការគ្រប់គ្រងកិច្ចសន្យា គ្រប់គ្រងហិរញ្ញវត្ថុ ការតាមដានត្រួតពិនិត្យ និងការរៀបចំរបាយការណ៍។

**គម្រោងគាំទ្រការិយាល័យច្រកចេញចូលតែមួយគាំទ្រដោយធនាគារពិភពលោក** (**World Bank/ DfGG-OWSO**) ៖ ផ្អែកលើបទពិសោធន៍ជាវិជ្ជមាន ដែលបានអនុវត្តក្រោមក្របខ័ណ្ឌគាំទ្ររបស់ Asia Urbs/ Konrad Adenhauer ក្នុងការអនុវត្តសាកល្បងនូវការិយាល័យច្រកចេញចូលតែមួយ ក្នុងស្រុកពីរក្នុងខេត្តសៀមរាប និងបាត់ដំបង គម្រោងអភិបាលកិច្ចល្អ (DfGG)របស់ធនាគារពិភពលោក ត្រូវបានរៀបចំឡើងក្រោមកិច្ចសហការ

ជាមួយក្រសួងមហាផ្ទៃ ដោយបានបញ្ចូលនូវផ្នែកមួយ ដែលជាការពង្រីកការបង្កើតការិយាល័យច្រកចេញចូលតែមួយទៅស្រុកគោលដៅចំនួន៧ទៀតនៅដើមឆ្នាំ២០០៨នេះ។ ផ្នែកនេះ នឹងត្រូវអនុវត្តដោយក្រុមគាំទ្រកម្មវិធីនៃគ.ជ.វ.វ និងមានការរៀបចំផ្តល់នូវមុខងារជាក់លាក់នានា ពាក់ព័ន្ធនឹងការផ្តល់សេវាកម្មជូនប្រជាពលរដ្ឋ ឱ្យទៅថ្នាក់ស្រុក ខណ្ឌគោលដៅ ។

**គម្រោងការបែងចែកដី ដើម្បីសង្គមកិច្ច និងអភិវឌ្ឍន៍សេដ្ឋកិច្ច គាំទ្រដោយធនាគារពិភពលោក (WB/LASED)** : នៅដើមឆ្នាំ២០០៨ គម្រោងនេះនឹងត្រូវអនុវត្តនៅក្នុងខេត្តគោលដៅចំនួនបី ដើម្បីគាំទ្រទៅលើការបែងចែកដីធ្លីឱ្យទៅគ្រួសារក្រីក្រ តាមរយៈកម្មវិធីសម្បទានដីសង្គមកិច្ច រួមជាមួយនឹងកម្មវិធីគាំទ្រដល់ការដោះស្រាយ និងរៀបចំលំនៅស្ថាន ដែលរួមមានការគាំទ្រដល់សកម្មភាពពាក់ព័ន្ធនឹងការប្រកបមុខរបរ ដើម្បីជីវភាពរបស់នៅ និងការរៀបចំហេដ្ឋារចនាសម្ព័ន្ធនានា។ នៅក្នុងតំបន់គោលដៅរបស់គម្រោង ថ្នាក់ស្រុកនឹងត្រូវដើរ តួសំខាន់ជាអ្នកទំនាក់ទំនងរវាងឃុំពាក់ព័ន្ធជាមួយទីភ្នាក់ងាររដ្ឋ និងដើរតួក្នុងការផ្តល់សេវាកម្មក្នុងតំបន់ ដែលត្រូវការដោះស្រាយ និងរៀបចំលំនៅស្ថាន។

**គម្រោងនវានុវត្តន៍សម្រាប់វិមជ្ឈការ និងកិច្ចអភិវឌ្ឍន៍មូលដ្ឋានគាំទ្រដោយមូលនិធិសហប្រជាជាតិដើម្បីអភិវឌ្ឍន៍មូលធន (UNCDF/IDLD)**: នៅក្នុងឆ្នាំ២០០៨ គម្រោងថ្មីនេះ នឹងអនុវត្តនៅក្នុងខេត្តគោលដៅចំនួន២ ដោយផ្តោតទៅលើចំនុចជាយុទ្ធសាស្ត្រសំខាន់ៗចំនួន២នៅថ្នាក់ស្រុក ខណ្ឌ គឺការរៀបចំឱ្យមានយន្តការទំនាក់ទំនងនៃអាជ្ញាធរមូលដ្ឋានពីរថ្នាក់ " two-tier " ដើម្បីបញ្ជាក់ឱ្យបានច្បាស់អំពីអន្តរមុខងារ ដែលត្រូវអនុវត្តដោយស្រុក ខណ្ឌ និងក្រុមប្រឹក្សាប្រឹក្សាឃុំ សង្កាត់នៅក្នុងស្រុកខណ្ឌ និងការសម្របសម្រួលជាមួយអង្គការ UNICEF និង IFAD ក្នុងការសាកល្បងរៀបចំឡើងវិញនូវមុខងារដែលពាក់ព័ន្ធនឹងកិច្ចអភិវឌ្ឍន៍សង្គម និងកសិកម្ម ដើម្បីផ្តល់ឱ្យស្រុក ខណ្ឌគោលដៅអនុវត្ត។

## ៧.៤ វិនិយោគខេត្ត ក្រុង

នៅក្នុងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០០៨របស់ គ.ជ.វ.វ តារាងថវិកា និងតារាងវិភាគលើការវិនិយោគខេត្ត ក្រុង បានដាក់បញ្ចូលធនធានផ្នែកអភិវឌ្ឍន៍ ដែលបានរៀបចំដាក់ក្នុងកម្មវិធីអនុវត្តតាមរយៈមូលនិធិវិនិយោគខេត្ត ក្រុង រួមជាមួយនឹងធនធានផ្នែកអភិវឌ្ឍន៍ ដែលបានរៀបចំដាក់ក្នុងកម្មវិធីអនុវត្តក្រោមក្របខ័ណ្ឌវិសហមជ្ឈការតាមវិស័យ ។ក្រោមក្របខ័ណ្ឌគោលនយោបាយ វាមានសារៈសំខាន់ណាស់ ចំពោះយុទ្ធសាស្ត្រផ្សេងៗគ្នានៃឧបករណ៍ប្រើប្រាស់សម្រាប់ការផ្តល់មូលនិធិទាំងនេះ។ មូលនិធិវិនិយោខេត្ត ក្រុង គឺជាកញ្ចប់មូលនិធិ ដែលត្រូវផ្តល់ឱ្យទៅខេត្ត ក្រុង ហើយបន្ទាប់មក ខេត្ត ក្រុងនីមួយៗ ធ្វើការបែងចែកមូលនិធិនេះ និងចាត់ចែងតាមកម្មវិធីសម្រាប់ការអនុវត្តការវិនិយោគ និងការផ្តល់សេវាកម្មជាអាទិភាព ដែលមាននៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងកម្មវិធីវិនិយោគឃុំសង្កាត់។ ដូចនេះ មូលនិធិវិនិយោគខេត្ត ក្រុង គឺរៀបចំបង្កើតឡើង ដើម្បីពង្រឹងប្រព័ន្ធគ្រប់គ្រង

និងនីតិវិធីសម្រាប់ការរៀបចំកម្មវិធីអនុវត្ត ដែលនឹងត្រូវយកទៅប្រើប្រាស់នាពេលអនាគត់ ក្នុងការផ្តល់កញ្ចប់មូលនិធិឆន្ទានុសិទ្ធិទៅតាមខេត្តក្រុង ដើម្បីគាំទ្រកិច្ចអភិវឌ្ឍន៍ជាអាទិភាពនានា ដែលបានកំណត់តាមរយៈដំណើរការសមាហរណកម្មផែនការ។ កម្មវិធីវិសហមជ្ឈការតាមវិស័យ គឺពាក់ព័ន្ធទៅនឹងការផ្តល់ថវិកាវិភាជន៍ឱ្យទៅវិស័យគោលដៅនានា ដែលមានក្នុងកម្មវិធីជាក់លាក់របស់គម្រោងម្ចាស់ជំនួយដែលបានរៀបចំឡើង ដោយមានការពិភាក្សា និង ចរចារជាមួយក្រសួងនានា។ ដូច្នេះ ធនធាននេះ គឺដើម្បីការរៀបចំបង្កើតប្រព័ន្ធ នីតិវិធី និងមេរៀន ដែលអាចយកទៅអនុវត្តនាពេលអនាគត់ ក្នុងការរៀបចំវិសហមជ្ឈការថវិការបស់ក្រសួងឱ្យទៅថ្នាក់ខេត្ត ក្រុង។ ទោះជាវិធីសាស្ត្រទាំងពីរនេះ មានសារៈសំខាន់បែបផ្សេងៗគ្នាក៏ដោយ ក៏វិធីសាស្ត្រផ្តល់មូលនិធិទាំង២នេះ បានតម្រូវឱ្យមានការរៀបចំផែនការ ថវិកា និងការអនុវត្តនៅថ្នាក់ខេត្ត ក្រុង ក្រោមការគ្រប់គ្រងរបស់អភិបាលខេត្ត ដែលជាអ្នកចុះហត្ថលេខាអនុវត្តគម្រោងជាមួយមន្ទីរជំនាញ និងផ្នែកឯកជន។ ករណីទាំងពីរនេះ គឺមានសារៈសំខាន់ក្នុងការពង្រឹងគណនេយ្យភាពតាមខ្សែទទឹងនៅថ្នាក់ខេត្ត ក្រុង។ បទពិសោធន៍គួរឱ្យកត់សម្គាល់ ដែលត្រូវបង្កើតឡើងនៅទូទាំងប្រទេស ក្នុងការគ្រប់គ្រងយន្តការទាំងពីរបែបនៃការផ្តល់មូលនិធិ ត្រូវបានពិចារណាថាមានការពាក់ព័ន្ធយ៉ាងខ្លាំងទៅនឹងការរៀបចំបង្កើតសមាហរណកម្មថវិកានៅថ្នាក់ខេត្ត ក្រុង ដូចដែលបានគិតគូនៅក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល។ ដូចបានបង្ហាញនៅក្នុងតារាង២៩ ខាងក្រោម ក្នុងឆ្នាំ២០០៨ នេះ មានមូលនិធិប្រមាណ១១លានដុល្លារ ដែលនឹងត្រូវបានផ្តល់ឱ្យដាក់ក្នុងកម្មវិធីសម្រាប់ការវិនិយោគខេត្ត ក្រុង ដែលនៅក្នុងនោះ ៣.៩%លានដុល្លារត្រូវផ្តល់តាមរយៈមូលនិធិវិនិយោគខេត្ត ក្រុង និង៧.១លានដុល្លា ផ្តល់តាមរយៈកម្មវិធីវិសហមជ្ឈការតាមវិស័យ។ មូលនិធិនេះ ជាមធ្យមមានចំនួន ៤៦០.០០០ ដុល្លារក្នុងមួយខេត្ត ក្រុង។ មូលនិធិដែលផ្តល់ចំនួនច្រើនជាងគេ គឺ២.០៥លានដុល្លារនៅខេត្តព្រៃវែង និងតិចជាងគេគឺ ៧១.៦០០ ដុល្លារនៅខេត្តកំពង់ឆ្នាំង។

**តារាងទី២៩ : ការវិភាជន៍មូលនិធិវិនិយោគខេត្ត ក្រុងឆ្នាំ២០០៨**

| ល.រ | ប្រភព | មូលនិធិវិនិយោគខេត្ត ក្រុង | | កម្មវិធីវិស័យទាក់ទងនឹងវិសហមជ្ឈការ | | សរុប | |
|---|---|---|---|---|---|---|---|
| | | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| 1 | PSDD | 1,996,881 | 52% | | | **1,996,881** | 18% |
| 2 | UNICEF | 1,448,218 | 37% | | | **1,448,218** | 13% |
| 3 | MDLF/NRM in D&D | 422,053 | 11% | | | **422,053** | 4% |
| 4 | IFAD/RPRP | | | 2,504,712 | 35% | **2,504,712** | 23% |
| 5 | IFAD/RULIP | | | 1,631,657 | 23% | **1,631,657** | 15% |
| 6 | EC-UNDP/EFMP | | | 1,254,321 | 18% | **1,254,321** | 11% |
| 7 | MDLF/NRM in Land | | | 613,442 | 9% | **613,442** | 6% |
| 8 | Canada/ADMAC | | | 895,637 | 13% | **895,637** | 8% |
| 9 | Royal Government | | | 197,718 | 3% | **197,718** | 2% |
| 10 | World Bank/LASED | | | 50,000 | 1% | **50,000** | 0% |
| សរុបរួម | | **$3,867,151** | **100%** | **$7,147,487** | **100%** | **$11,014,638** | **100%** |

### ៧.៤.១ មូលនិធិវិនិយោគខេត្ត ក្រុង

យោគទៅតាមវដ្តនៃការរៀបចំថវិកា និងកម្មវិធី ធនធានមូលនិធិវិនិយោគខេត្ត ក្រុង សម្រាប់ឆ្នាំ២០០៨ ភាគច្រើនត្រូវបានវិភាជន៍ឱ្យទៅខេត្ត ក្រុងទាំង២៤ នៅខែតុលា ឆ្នាំ២០០៧។ ផ្អែកលើគោលការណ៍ណែនាំស្តីការរៀបចំកម្មវិធី និងតាមរយៈកិច្ចដំណើរការនៃការពិគ្រោះពិភាក្សាគ្នារវាងអាជ្ញាធរខេត្ត ក្រុង ជាមួយមន្ទីរជំនាញ និងក្រុមប្រឹក្សាឃុំ សង្កាត់តាមរយៈសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក ខណ្ឌមូលនិធិវិនិយោគខេត្ត ក្រុង នឹងត្រូវបានធ្វើការវិភាជន៍ជាបន្តបន្ទាប់ សម្រាប់គាំទ្រដល់សកម្មភាពជាក់លាក់ ដែលមានលក្ខណៈស្របទៅនឹងយុទ្ធសាស្ត្ររបស់វិស័យ និងអាទិភាពរបស់មូលដ្ឋាន។

### ៧.៤.២ កម្មវិធីវិសហមជ្ឈការតាមវិស័យ

មូលនិធិសម្រាប់កម្មវិធីវិសហមជ្ឈការតាមវិស័យ នឹងត្រូវធ្វើវិនិយោគ តាមរយៈកម្មវិធីដែលមានរយៈពីមធ្យមទៅរយៈពេលវែង ដែលបានរៀបចំផែនការជាមុន ដោយម្ចាស់ជំនួយ និងអាជ្ញាធរជាតិ ដែលពាក់ព័ន្ធទៅនឹងវិស័យដែលបានកំណត់។ ការរៀបចំកម្មវិធីសម្រាប់មូលនិធិនេះ មានការពាក់ព័ន្ធ និងចូលរួមកាន់តែច្រើនឡើងរវាងអាជ្ញាធរខេត្ត ក្រុង ជាមួយនឹងមន្ទីរជំនាញ រួមទាំងក្រុមប្រឹក្សាឃុំ សង្កាត់ផងដែរ តាមរយៈការផ្សព្វផ្សាយបង្ហាញអំពីសកម្មភាពវិនិយោគ នៅក្នុងសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក ខណ្ឌ។

តារាងទី៣០ ស្តីពីការវិភាជន៍មូលនិធិវិនិយោគខេត្ត ក្រុង តាមវិស័យ/អនុវិស័យ នឹងផ្តល់ព័ត៌មានលម្អិតអំពីមូលនិធិវិនិយោគខេត្តក្រុង ដែលបានបែងចែកទៅតាមវិស័យ និងអនុវិស័យ ដែលឆ្លុះបញ្ចាំងឱ្យឃើញអំពីធនធានសរុប ភាគរយ ចំនួនខេត្ត ក្រុង ដែលទទួលបានមូលនិធិវិភាជន៍ ចំនួនមូលនិធិជាមធ្យមដែលត្រូវវិភាជន៍តាមវិស័យ។

**តារាងទី៣០ : ការវិភាជន៍មូលនិធិវិនិយោគខេត្ត ក្រុងឆ្នាំ២០០៨ តាមវិស័យ/អនុវិស័យ**

| ល.រ | វិស័យ/អនុវិស័យ | ចំនួនសរុប | ភាគរយ | ខេត្ត ក្រុង | ភាគរយ | មធ្យម/ ខេត្ត ក្រុង | ចន្លោះ | |
|---|---|---|---|---|---|---|---|---|
| | | | | | | | ពី | ដល់ |
| 1 | កសិកម្ម | 5,118,238 | 46.5% | 24 | 100% | 213,260 | 1,543,747 | 5,000 |
| 2 | វប្បធម៌ | 51,850 | 0.5% | 12 | 50% | 4,321 | 13,300 | 1,550 |
| 3 | អប់រំ | 338,935 | 3.1% | 19 | 79% | 17,839 | 94,591 | 2,500 |
| 4 | បរិស្ថាន | 122,438 | 1.1% | 22 | 92% | 5,565 | 14,656 | 1,800 |
| 5 | ជលផល | 11,600 | 0.1% | 2 | 8% | 5,800 | 6,000 | 5,600 |
| 6 | ព្រៃឈើ | 30,000 | 0.3% | 5 | 21% | 6,000 | 8,000 | 4,000 |
| 7 | សុខាភិបាល | 160,763 | 1.5% | 11 | 46% | 14,615 | 45,750 | 4,300 |
| 8 | ព័ត៌មាន | 26,275 | 0.2% | 8 | 33% | 3,284 | 5,000 | 2,000 |
| 9 | ការគ្រប់គ្រងដីធ្លី | 623,437 | 5.7% | 16 | 67% | 38,965 | 82,855 | 2,500 |
| 10 | ការងារ/ការបណ្ដុះបណ្ដាលវិជ្ជាជីវៈ | 43,000 | 0.4% | 9 | 38% | 4,778 | 7,600 | 3,000 |
| 11 | មីក្រូហិរញ្ញវត្ថុ | 270,000 | 2.5% | 3 | 13% | 90,000 | 160,000 | 50,000 |
| 12 | សកម្មភាពដោះមីន | 80,620 | 0.7% | 5 | 21% | 16,124 | 31,923 | 5,760 |
| 13 | ផែនការ | 231,197 | 2.1% | 24 | 100% | 9,633 | 15,500 | 4,325 |
| 14 | សាធារណការ | 5,000 | 0.0% | 1 | 4% | 5,000 | 5,000 | 5,000 |
| 15 | កិច្ចការសាសនា | 8,400 | 0.1% | 2 | 8% | 4,200 | 5,500 | 2,900 |
| 16 | គមនាគមន៍ជនបទ | 1,424,619 | 12.9% | 23 | 96% | 61,940 | 1,099,230 | 1,000 |
| 17 | ទឹកស្អាតជនបទ/អនាម័យ | 1,263,632 | 11.5% | 19 | 79% | 66,507 | 255,760 | 3,240 |
| 18 | សង្គមកិច្ច | 43,823 | 0.4% | 12 | 50% | 3,652 | 5,000 | 2,500 |
| 19 | ទេសចរណ៍ | 40,978 | 0.4% | 9 | 38% | 4,553 | 8,365 | 1,100 |
| 20 | ធនធានទឹក | 470,923 | 4.3% | 19 | 79% | 24,785 | 68,310 | 3,000 |
| 21 | កិច្ចការនារី | 648,912 | 5.9% | 24 | 100% | 27,038 | 90,576 | 4,625 |
| | សរុបរួម | **11,014,638** | **100%** | | **100%** | **458,943** | **2,043,908** | **53,542** |

ដូចបានបញ្ជាក់នៅក្នុងតារាងនេះ មូលនិធិវិនិយោគនៅក្នុងកិច្ចអភិវឌ្ឍន៍វិស័យកសិកម្ម មានចំនួនប្រមាណពាក់កណ្ដាលនៃមូលនិធិសរុប។ មូលនិធិសម្រាប់វិស័យគមនាគមន៍ជនបទ និងផ្គត់ផ្គង់ទឹកស្អាត មានប្រមាណ២៥%។ ជាមធ្យម នៅក្នុងខេត្ត ក្រុងនីមួយៗ មានវិស័យចំនួនប្រមាណ១០ បានទទួលមូលនិធិវិភាជន៍។ មកទល់ពេលនៃការរៀបចំបញ្ចប់ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ២០០៨របស់ គ.ជ.វ.វ នៅមិនទាន់ទទួលបានព័ត៌មានលម្អិតអំពីមូលនិធិវិនិយោគខេត្ត ក្រុងប្រមាណ ៥០០០០ ដុល្លារ។

តារាងនេះ ក៏បានឆ្លុះបញ្ចាំងផងដែរអំពីកម្រិតលំដាប់លំដោយនៃមូលនិធិ ដែលបានវិភាជន៍ទៅតាមខេត្ត ក្រុង។ ខេត្ត ក្រុងដែលទទួលបានថវិកាទាប គឺជាទូទៅអាស្រ័យដោយខេត្តនោះមានចំនួនប្រជាជនតិច ដូចជាក្រុងកែប និងក្រុង ប៉ៃលិន ទទួលបានមូលនិធិតិចជាងគេ។ ទំហំនៃមូលនិធិវិភាជន៍នេះ ក៏អាស្រ័យផងដែរទៅលើការផ្ដល់ការ

វិនិយោគទៅលើវិស័យគោលដៅ នៅក្នុងខេត្តគោលដៅរបស់គម្រោងគាំទ្រដោយ IFAD និង UNICEF ដែលក្នុងនោះខេត្ត ដែលទទួលបានមូលនិធិវិភាជន៍ខ្ពស់ជាងគេ គឺខេត្តព្រៃវែង ដែលមានចំនួនប្រមាណ២,០៥លានដុល្លារ និងខេត្តដែលទទួលបានមូលនិធិវិភាជន៍ទាបជាងគេ គឺខេត្តកំពង់ឆ្នាំង ដែលមានចំនួនប្រមាណ ៧១.៦០០ ដុល្លារ ។

ជាចុងក្រោយ គួរឱ្យកត់សម្គាល់ថា ធនធានទាំងនេះ គឺជាសមមាត្រនៃធនធានវិនិយោគដែលអាចមាននៅក្នុងខេត្ត ក្រុងនីមួយៗប៉ុណ្ណោះ។ ជាឧទាហរណ៍ នៅមានការងារ ដែលជាការវិភាគលើលទ្ធផលនៃសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក នឹងផ្តល់ព័ត៌មានបន្ថែមជាច្រើនជាងនេះទៅទៀត ក៏មានក្តីសង្ឃឹមផងដែរថា ការពង្រឹងក្របខ័ណ្ឌផែនការវិនិយោគ ដែលគាំទ្រដោយក្រសួងទាំងអស់ និងម្ចាស់ជំនួយនានា នឹងអាចធ្វើឱ្យមានភាពកាន់តែច្បាស់លាស់នៃសកម្មភាពវិនិយោគនាពេលអនាគត ។

## ៧.៥ ការគាំទ្រកម្មវិធីថ្នាក់ខេត្ត ក្រុង

### ៧.៥.១ រចនាសម្ព័ន្ធ និងមុខងារថ្នាក់ខេត្ត ក្រុង

ថវិកាគាំទ្រកម្មវិធីថ្នាក់ខេត្ត ក្រុង ផ្តល់នូវតម្រូវការធនធានចាំបាច់ដែលត្រូវការ ដោយរដ្ឋបាលខេត្ត ក្រុង ដើម្បីបំពេញតួនាទី និងការទទួលខុសត្រូវរបស់ខ្លួននៅក្នុងកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាលកម្ពុជា ។ ទាក់ទងទៅនឹងវិមជ្ឈការ គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហ-មជ្ឈការ (គ.ជ.វ.វ) អភិបាលខេត្ត-ក្រុងត្រូវបានទទួលនូវការធ្វើប្រតិភូកម្មការទទួលខុសត្រូវជាច្រើន ក្នុងការគ្រប់គ្រងលើការផ្តល់សេវាកម្មគាំទ្រនានាដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ក៏ដូចជាការមើលការខុសត្រូវ និងតាមដានជំនួសមុខឱ្យរដ្ឋាភិបាលថ្នាក់ជាតិ ។ ទាក់ទងទៅនឹងវិសហមជ្ឈការ កម្រិតធនធានថវិកាដែលបានបែងចែកទៅដល់ រដ្ឋបាលថ្នាក់ខេត្ត ក្រុងដោយ គ.ជ.វ.វ និងរដ្ឋាភិបាលនៃប្រទេសជាមិត្ត និងកម្មវិធីនានារបស់ដៃគូអភិវឌ្ឍន៍ តម្រូវឱ្យខេត្ត ក្រុងមានរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងច្បាស់លាស់ ព្រមទាំងធនធានបន្ថែម ។ ធៀបជាមួយនឹងផែនការ សកម្មភាព និងថវិការបស់ខេត្ត ក្រុងនិមួយៗ ដែលអនុម័តដោយគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត ក្រុង (គ.អ.ជ.ខ) និងនៅក្រោមអំណាចយុត្តាធិការរបស់អភិបាលខេត្ត ក្រុង គណៈកម្មាការប្រតិបត្តិនៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត ក្រុង (គ.ប្រ) បានបង្កើតឡើងនៅគ្រប់ខេត្ត ក្រុង ដើម្បីឱ្យការប្រតិបត្តិ និងការគាំទ្រចាំបាច់នានាមានលទ្ធភាពបន្តដំណើរការទៅបាននៅក្រោមកម្មវិធីកំណែទម្រង់ទាំងពីរ ហើយអាចគ្រប់គ្រងបានប្រកបដោយប្រសិទ្ធិភាពតាមរយៈការសម្របសម្រួលរវាងស្ថាប័ន និងវិស័យពាក់ព័ន្ធនានានៅថ្នាក់ខេត្ត ក្រុង ។

ជាការត្រៀមរៀបចំមុនដំណាក់កាលបន្ទាប់សម្រាប់ការកែទម្រង់នៅថ្នាក់ក្រោមជាតិ ផ្អែកទៅតាមការកែសម្រួលច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលខេត្ត ក្រុង ស្រុកខណ្ឌ គ.ជ.វ.វ បានសម្រេចបន្តអណត្តិរបស់គ.អ.ជ.ខ និងគ.ប្រ ដើម្បីធានានូវការបន្តកិច្ចប្រតិបត្តិការនៅក្នុងឆ្នាំ២០០៨ ។ ទោះជាយ៉ាងណាក៏ដោយ យើងទទួលស្គាល់ថា ការងារជាច្រើនទៀតត្រូវការរៀបចំដោយរាជរដ្ឋាភិបាល ដូចជាការរៀបចំឱ្យមានកិច្ចព្រមព្រៀងគ្នា និងការអនុម័តច្បាប់

ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងក្របខ័ណ្ឌបទបញ្ញត្តិនានា ដែលនឹងបង្កើតឡើងនូវប្រព័ន្ធគ្រប់គ្រងថ្នាក់ខេត្ត ក្រុងដែលនឹងច្របាច់បញ្ចូលគ្នានូវអំណាច និងមុខងារនានាដែលផ្តល់ឱ្យខេត្ត ក្រុង នៅក្រោមកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ។ ដោយហេតុនេះ វចនាសម្ព័ន្ធ និងមុខងារសង្ខេបខាងក្រោមនឹងបង្កលទ្ធភាពឱ្យការធ្វើកំណែទម្រង់ ព្រមទាំងការកសាងសមត្ថភាពរយៈពេលវែងនៅគ្រប់កម្រិតថ្នាក់ អាចអនុវត្តទៅបាន ហើយនៅក្នុងពេលជាមួយគ្នានេះដែរ បង្កើតនូវបទពិសោធន៍ និងមេរៀនគោលនយោបាយដ៏មានតម្លៃនានាសម្រាប់ធ្វើការពិចារណាកែលម្អឡើងវិញ ហើយជាបណ្តើរៗដាក់បញ្ចូលទៅក្នុងច្បាប់ និងបទបញ្ញត្តិទាំងឡាយ នាពេលអនាគត ។

**គណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត ក្រុង (គ.អ.ជ.ខ/ក្រ)** : នៅក្រោមការដឹកនាំរបស់អភិបាលខេត្ត ក្រុង ជាប្រធានគណៈកម្មាធិការ ដែលក្នុងនោះរួមមានសមាជិកជាប្រធានមន្ទីរមកពីគ្រប់មន្ទីរជំនាញ និងអភិបាលស្រុក ខណ្ឌ គ.អ.ជ.ខ/ក្រ តំណាងឱ្យវេទិការអភិបាលកិច្ច និងអភិវឌ្ឍន៍នៅថ្នាក់ក្រោមជាតិ សម្រាប់ការចែករំលែកផ្សព្វផ្សាយពីគោលនយោបាយ និងការសម្របសម្រួលទូទៅដល់ផែនការ និងការអភិវឌ្ឍន៍ខេត្ត ក្រុង ។

**គណៈកម្មាការប្រតិបត្តិនៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត ក្រុង (គ.ប្រ)** : នៅក្រោមការដឹកនាំរបស់អភិបាលខេត្ត ក្រុងជាប្រធាន ដែលរួមមានសមាជិកជាប្រធានមន្ទីរមកពីមន្ទីរជំនាញពាក់ព័ន្ធសំខាន់ៗចំនួន៦ ទៅ ៨មន្ទីរ គ.ប្រ ទទួលខុសត្រូវនូវក្នុងការសម្របសម្រួលប្រតិបត្តិការផែនការសកម្មភាព និងថវិកាដែលបានសម្រេចយល់ព្រម ដោយ គ.អ.ជ.ខ/ក្រ និងអនុម័តដោយ គ.ជ.វ.វ អាជ្ញាធរជាតិ និង/ឬ ដៃគូអភិវឌ្ឍន៍នានា ព្រមទាំងបទបញ្ញតិទាំង ឡាយដែលបានអនុម័តដោយ គ.ជ.វ.វ សម្រាប់ផ្តល់ការគាំទ្រដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ។

**អង្គភាពរដ្ឋបាលមូលដ្ឋាន** : ជាការិយាល័យមួយចំណុះឱ្យសាលាខេត្ត ក្រុង អង្គភាពនេះគ្រប់គ្រងមើលការខុត្រូវលើការផ្តល់ការកសាងសមត្ថភាព និងសម្របសម្រួលការផ្តល់សេវាកម្មដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ជាពិសេសតាមរយៈការបណ្តុះបណ្តាលដល់មន្ត្រីសម្របសម្រួលខេត្ត ក្រុង ស្រុក ខណ្ឌ និងទទួលខុសត្រូវលើប្រព័ន្ធតាមដាន វាយតម្លៃ និងរបាយការណ៍នៅមូលដ្ឋាន ។ ជាងនេះទៀត អង្គភាពនេះក៏ផ្តល់នូវសេវាកម្មជាក់លាក់ ដល់ការអនុវត្តគម្រោងមួយចំនួន រួមមានការបញ្ជ្រាបបញ្ហាអភិវឌ្ឍន៍នានាទាក់ទងទៅនឹងការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន និងសង្គមនៅថ្នាក់មូលដ្ឋាន ក៏ដូចជាទិដ្ឋភាពផ្សេងៗទៀតនៃកម្មវិធីគាំទ្រថ្នាក់ស្រុក ខណ្ឌ ។

**ផ្នែកគ្រប់គ្រងកិច្ចសន្យា** : នៅក្រោមការគ្រប់គ្រងដោយផ្ទាល់ពីមន្ទីរផែនការខេត្ត ក្រុង និងទទួលខុសត្រូវគ្រប់គ្រងលើគ្រប់កិច្ចសន្យាទាំងអស់ដែលចុះហត្ថលេខាដោយអភិបាលខេត្ត ក្រុងក្នុងនាមជាប្រធាន គ.ប្រ និងមើលការខុសត្រូវលើប្រព័ន្ធតាមដាន វាយតម្លៃ និងរបាយការណ៍នៅថ្នាក់ខេត្ត ក្រុង ទាក់ទងទៅនឹងកិច្ចសន្យាជាមួយមន្ទីរពាក់ព័ន្ធ ។

**ផ្នែកហិរញ្ញវត្ថុ** : ក្រោមការគ្រប់គ្រងដោយមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត ក្រុង ផ្នែកនេះរួមមានពីរផ្នែក : ផ្នែករតនាគារខេត្ត ក្រុង ទទួលខុសត្រូវលើការទទួល ការទូទាត់ចំណាយ គណនេយ្យ និងរាយការណ៍ពីមូល និធិឃុំ សង្កាត់ ក្នុងកិច្ចសហប្រតិបត្តិការជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ហើយផ្នែកហិរញ្ញវត្ថុខេត្ត ក្រុង ទទួលខុសត្រូវលើការទទួល ការទូទាត់ចំណាយ គណនេយ្យ និងរាយការណ៍ ពីធនធានហិរញ្ញវត្ថុដែលផ្ទេរចូលគណនីខេត្ត ក្រុង ផ្អែកតាមផែនការសកម្មភាព និងថវិកាដែលបានអនុម័ត និងការអនុវត្តកិច្ចសន្យាផ្សេងៗទៀត ។

**ផ្នែកគាំទ្របច្ចេកទេស** : នៅក្រោមការគ្រប់គ្រងដោយផ្ទាល់ពីមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ក្រុង អង្គភាពនេះផ្តល់នូវការគាំទ្រសេវាកម្មបច្ចេកទេសទៅដល់ក្រុមប្រឹក្សាឃុំ សង្កាត់ លើការរៀបចំប្លង់បច្ចេកទេសគម្រោង ការសិក្សាបច្ចេកទេស និងការចុះកិច្ចសន្យា ការតាមដានការអនុវត្តកិច្ចសន្យារបស់អ្នកម៉ៅការ ការធ្វើសាវនកម្មបច្ចេកទេសលើគម្រោងឃុំ សង្កាត់មួយចំនួន និងផ្តល់ការគាំទ្របច្ចេកទេសដល់គម្រោងហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានផ្សេងៗទៀតនៅក្រោមមូលនិធិវិនិយោគខេត្ត ក្រុង ស្រុក ខណ្ឌ ។

## ៧.៥.២ ការបែងចែកថវិកាគាំទ្រប្រតិបត្តិការកម្មវិធីខេត្ត ក្រុង

នៅក្នុងឆ្នាំ២០០៨នេះ ថវិកាសរុបចំនួន៤.៧ លានដុល្លា ត្រូវបានបែងចែកសម្រាប់គាំទ្រដល់ប្រតិបត្តិការកម្មវិធី ដែលក្នុងនោះ ៤.២ លានដុល្លា សម្រាប់គាំទ្រដល់សេវាកម្មនានា និងមុខងារគ្រប់គ្រងកម្មវិធី ដែលអនុវត្តដោយ គ.ប្រ ក្រោមការដឹកនាំដោយអភិបាលខេត្ត ក្រុង ដូចដែលបានពិពណ៌នាខាងលើ ហើយថវិកា ៥០០,០០០ដុល្លា សម្រាប់គាំទ្រដល់ក្រុមទីប្រឹក្សានៃគម្រោងគាំទ្រដល់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ តាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ (PSDD) ទូទាំង ២៤ ខេត្ត ក្រុង ។

ថវិកា ៤,២ លានដុល្លារសម្រាប់គាំទ្រដល់មុខងារសេវាកម្ម និងគ្រប់គ្រង បានបែងចែកទៅតាមរូបមន្ត និងតម្លៃស្តង់ដាររដ្ឋបាលទៅដល់២៤ខេត្ត ក្រុង ។ ការចំនាយផ្នែកនេះភាគច្រើនគឺទៅលើប្រាក់ឧបត្ថមដល់បុគ្គលិក គ.ប្រ បំពេញការងារពេញម៉ោង ដោយរយៈការចុះកិច្ចសន្យា និងការរៀបចំឱ្យមានផែនការសកម្មភាពប្រចាំឆ្នាំ ថ្លៃបណ្តុះបណ្តាលដល់ក្រុមប្រឹក្សាឃុំ សង្កាត់ និងមន្ត្រីសម្របសម្រួលខេត្ត ក្រុង ស្រុក ខណ្ឌ គ្រឿងបរិក្ខាការិយាល័យ និងមធ្យោបាយធ្វើដំណើរ សម្ភារៈការិយាល័យ និងប្រតិបត្តិការ ព្រមទាំងការថែទាំនានា ។ ជាមធ្យម ថវិកានេះមានចំនួនប្រហែល ១៧៥,០០០ ដុល្លារក្នុងមួយខេត្ត ក្រុង ឬ ៧%នៃធនធានសរុបផ្ទេរបែងចែកទៅឱ្យថ្នាក់ក្រោមជាតិ ។ ថវិកា ៥២០,០០០ដុល្លារ ទៀតគឺសម្រាប់គាំទ្រដល់ប្រតិបត្តិការរបស់ PSDD ដែលគ្រប់គ្រងដោយផ្ទាល់ដោយរដ្ឋបាលខេត្ត ក្រុង ដែលមានចំនួនជាមធ្យមប្រមាណ ២១,៧០០ដុល្លារក្នុងមួយខេត្ត ក្រុង សម្រាប់ការចំនាយលើសម្ភារៈ និងបរិក្ខាការិយាល័យ ការធ្វើដំណើរ ការងាររដ្ឋបាលសម្រាប់ទីប្រឹក្សា PSDD ខេត្ត ក្រុងចំនួន១៤៤ នាក់ ។

**តារាងទី ៣១ : ហិរញ្ញវត្ថុគាំទ្រដល់ប្រតិបត្តិការកម្មវិធីខេត្ត ក្រុង** ខាងក្រោមបង្ហាញពីធនធានហិរញ្ញវត្ថុសម្រាប់គាំទ្រដល់ប្រតិបត្តិការកម្មវិធីខេត្តក្រុងក្នុងឆ្នាំ២០០៨ ។ ដូចដែលមានបង្ហាញនៅក្នុងតារាងធនធាន PSDD

មានចំនួន ៧៦% នៃធនធានសរុប ហើយដោយឡែកធនធានរួមគ្នាពី IFAD, UNICEF, EC និង MDLF មានចំនួនសរុប ២០% ។ ធនធានចូលរួមចំណែកពីរាជរដ្ឋាភិបាល បង្ហាញនៅក្នុងតារាងនេះ មានតែថវិកាសម្រាប់គាំទ្រដល់ដៃគូការងារនៅក្រោមគម្រោង IFAD តែប៉ុណ្ណោះ ហើយមិនបានដាក់រួមបញ្ចូលនូវក្នុងជំពូកផ្សេងៗទៀតនៃការគាំទ្រទាំងនោះឡើយ ដែលក្នុងនោះមានដូចជា ប្រាក់ខែមន្ត្រីរាជការ និងការិយាល័យសម្រាប់បំពេញការងារ ។

**តារាងទី៣១ : ការវិភាជន៍មូលនិធិគាំទ្រកម្មវិធីខេត្ត ក្រុងឆ្នាំ២០០៨**

| ល.រ | ប្រភព | LAU | CAU | FU | TSU | សរុប | ភាគរយ |
|---|---|---|---|---|---|---|---|
| 1 | PSDD | 1,332,959 | 1,041,616 | 385,762 | 428,947 | **3,189,284** | 75.6% |
| 2 | UNICEF | 203,591 | 47,256 | 23,700 | 0 | **274,547** | 6.5% |
| 3 | IFAD/RPRP | 118,554 | 62,342 | 15,576 | 44,650 | **241,122** | 5.7% |
| 4 | IFAD/RULIP | 0 | 12,908 | 6,160 | 0 | **19,068** | 0.5% |
| 5 | EC-UNDP/DDLG | 105,987 | 26,429 | 7,125 | 15,044 | **154,585** | 3.7% |
| 6 | EC-UNDP/EFMP | 19,080 | 18,324 | 3,040 | 0 | **40,444** | 1.0% |
| 7 | MDLF/NRM in D&D | 102,000 | | | | **102,000** | 2.4% |
| 8 | WB/LASED* | | | | | **50,000** | 1.2% |
| 9 | WB/OWSO | 38,160 | | | | **38,160** | 0.9% |
| 10 | ADB/TSSL** | | | | | **40,000** | 0.9% |
| 11 | Canada/ADMAC | 0 | 16,578 | 6,864 | 0 | **23,442** | 0.6% |
| 12 | RGC | 3,722 | 9,580 | 1,836 | 1,338 | **16,476** | 0.4% |
| 13 | UNFPA | 12,940 | | | | **12,940** | 0.3% |
| 14 | GRET | 960 | 5,080 | 480 | 960 | **7,480** | 0.2% |
| 15 | UNCDF | 6,000 | | | | **6,000** | 0.1% |
| 16 | AUSAID/CCJAP | | 5,000 | | | **5,000** | 0.1% |
| សរុបរួម | | **1,943,953** | **1,245,113** | **450,543** | **490,939** | **$4,220,548** | **100%** |

* មិនបានធ្វើការវិភាជន៍មូលនិធិរហូតដល់ខែមីនា ឆ្នាំ២០០៨

** ផ្នែកគាំទ្រគម្រោងនៅខេត្ត ក្រុង

ផ្អែកទៅលើរូបមន្ត ស្តង់ដារប្រាក់ឧបត្ថមបុគ្គលិក និងឯកតាតម្លៃ ធនធាន PSDD ត្រូវបានរៀបចំគ្រោងដោយ PSDD សម្រាប់២៤ ខេត្ត ក្រុង ។ ធនធានពី IFAD, UNICEF និង EC/DDLG ទូទាត់តម្លៃទាំងនេះមួយចំនួននៅក្នុងខេត្តគោលដៅរបស់ពួកគេ ដោយឡែកធនធានពីដៃគូអភិវឌ្ឍន៍ផ្សេងទៀត ដាក់បូកបញ្ចូលបន្ថែមទៅក្នុងតម្លៃកម្មវិធីរួម ក៏ប៉ុន្តែសម្រាប់សកម្មភាពជាក់លាក់បម្រើឱ្យគោលបំណងរបស់ខ្លួន ។

**តារាងទី ៣២ : បុគ្គលិក គ.ប្រ និងការវិភាគ ឆ្នាំ២០០៨** ខាងក្រោមបង្ហាញពីចំនួនបុគ្គលិក គ.ប្រ សរុប នៅទូទាំង២៤ខេត្ត ក្រុង ក្នុងឆ្នាំ២០០៨ ដែលឆ្លុះបញ្ចាំងពីសូចនាករបន្ទុកការងារសម្រាប់បុគ្គលិកអង្គភាពនិមួយៗ ។ ពត៌មានបន្ថែមស្តីពីអង្គភាពនិមួយៗសូមមើលនៅខាងក្រោមនេះ ។

**តារាងទី៣២ ៖ ការបែងចែក និងការរៀបចំមន្ត្រីគណៈកម្មាធិការប្រតិបត្តិ**

| ផ្នែក | ស្ថាប័នដឹកនាំ | ចំនួនមន្ត្រី | សូចនាករបន្ទុកការងារ |
|---|---|---|---|
| LAU | សាលាខេត្ត ក្រុង | 1,012 | មន្ត្រីការិយាល័យ៣នាក់/ខេត្តក្រុង. អ្នកសម្របសម្រួល១នាក់/ក្រុមប្រឹក្សា២ឃុំ សង្កាត់ |
| CAU | ផែនការ | 205 | កិច្ចសន្យាខេត្ត ក្រុងចំនួន៤ និងទំហំទឹកប្រាក់ ១០០.០០០ដុល្លារ/មន្ត្រី CAU ម្នាក់ |
| FU | ហិរញ្ញវត្ថុ/រតនាគារ | 273 | ទំហំទឹកប្រាក់ជាមធ្យម ២១០.០០០ដុល្លារ/មន្ត្រី FU ម្នាក់ |
| TSU | អភិវឌ្ឍន៍ជនបទ | 251 | កិច្ចសន្យាចំនួន១៤ និងទំហំទឹកប្រាក់ ១១០.០០០ដុល្លារ/មន្ត្រី TSU ម្នាក់ |
| សមាជិកអចិន្ត្រៃយ៍ | | 24 | ទំហំទឹកប្រាក់ជាមធ្យម ២៣៥.០០០ដុល្លារ និងមន្ត្រីចំនួន៧៥នាក់/ខេត្ត ក្រុង |
| សវនករផ្ទៃក្នុង | | 24 | ទំហំទឹកប្រាក់ជាមធ្យម ២៣៥.០០០ដុល្លារ និងកិច្ចសន្យាចំនួន២០០/ខេត្ត ក្រុង |
| សរុប | | 1,789 | |

**អង្គភាពរដ្ឋបាលមូលដ្ឋាន ៖** នៅក្នុងឆ្នាំ២០០៤ អង្គភាពរដ្ឋបាលមូលដ្ឋានបានបង្កើតឡើងជាផ្លូវការ ជាអង្គភាពទី ៥ នៅក្នុងសាលាខេត្ត ក្រុង ជាមួយនឹងការកំនត់នូវអណ្តតិថ្មីនៅក្រោមអភិបាលខេត្ត ក្រុង ដើម្បីផ្តល់នូវការកសាងសមត្ថភាព សម្របសម្រួល តាមដាន និងរាយការណ៍ ដល់ក្រុមប្រឹក្សាឃុំ សង្កាត់ទាំង ១.៦២១ ឃុំ សង្កាត់ ។ នៅក្នុងឆ្នាំ២០០៨ បុគ្គលិកអង្គភាពរដ្ឋបាលមូលដ្ឋានមានចំនួនសរុប១.០១២នាក់នៅទូទាំង២៤ខេត្ត ក្រុង ដែលជាមធ្យមមានចំនួន៤២នាក់ក្នុងមួយខេត្ត ក្រុង ។ ក្នុងចំនោមចំនួនបុគ្គលិកសរុបទាំងនោះ បុគ្គលិកចំនួន៨៦ នាក់បំពេញការងារនៅក្នុងសាលាខេត្ត ក្រុង (ជាមធ្យម៣-៤នាក់) ២៣៨នាក់បម្រើការជាមន្ត្រីសម្របសម្រួលខេត្ត ក្រុង (ជាមធ្យម១០នាក់ក្នុងមួយខេត្ត ក្រុង) ផ្តល់ការគាំទ្រទៅដល់ថ្នាក់ស្រុក សម្របសម្រួលសកម្មភាពបណ្តុះបណ្តាលដោយឡែកនៅក្នុងខេត្តក្រុងចំនួនពាក់កណ្តាល គាំទ្របន្ថែមទៅដល់ការបញ្ជ្រាបបញ្ហានៃការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន និងស្ត្រី/កុមារ ហើយ ៦៨៨ នាក់ផ្សេងទៀត បំរើការងារការជាមន្ត្រីសម្របសម្រួលស្រុក ខណ្ឌ (ជាមធ្យម ២៨ នាក់ក្នុងមួយ ខេត្ត ក្រុង) សម្របសម្រួលដោយផ្ទាល់ជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ផ្តល់ការបណ្តុះបណ្តាល ហើយដោយឡែកនៅក្នុងខេត្ត ក្រុងចំនួនពាក់កណ្តាល គាំទ្របន្ថែមទៅដល់ការបញ្ជ្រាបបញ្ហានៃការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន និងស្ត្រី/កុមារ ។ ជាមធ្យម មន្ត្រីសម្របសម្រួលស្រុកម្នាក់គាំទ្រដល់ក្រុមប្រឹក្សា ឃុំ សង្កាត់ពីរឃុំ សង្កាត់ មន្ត្រីសម្របសម្រួលខេត្ត ក្រុងម្នាក់ផ្តល់ការគាំទ្រទៅដល់មន្ត្រីសម្របសម្រួលស្រុក ខណ្ឌ បីនាក់ ហើយបុគ្គលិកអង្គភាពរដ្ឋបាលមូលដ្ឋានបីនាក់ រួមទាំងប្រធានផង មានមូលដ្ឋាននៅក្នុងសាលាខេត្ត ក្រុង ។ ចំនួនបុគ្គលិកអង្គភាពរដ្ឋបាលមូលដ្ឋានមានការកើនឡើងចំនួន៧០នាក់បើប្រៀបធៀបទៅនឹងឆ្នាំ២០០៦ ដែលប្រការនេះអាចពន្យល់នូវមូលហេតុជាចំបងទាក់ទងទៅនឹងការថយចុះគួរឱ្យកត់សំគាល់នៅភាពជាដៃគូ និងធនធានដែលអាចមានសម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ ។ ប្រមាណជាពាក់កណ្តាលនៃចំនួនបុគ្គលិកសរុប គឺជាមន្ត្រីបម្រើការនៅក្នុងក្រសួងមហាផ្ទៃ ហើយមន្ត្រីផ្សេងទៀត គឺចុះកិច្ចសន្យាជួលពីមន្ទីរជំនាញពាក់ព័ន្ធនានាជុំវិញខេត្ត ក្រុង ។ ១៥% នៃបុគ្គលិកអង្គភាពរដ្ឋបាលមូលដ្ឋានសរុប គឺជាស្ត្រី ។

**ផ្នែកគ្រប់គ្រងកិច្ចសន្យា** : បុគ្គលិកនៃផ្នែកគ្រប់គ្រងកិច្ចសន្យាសរុបមានចំនួន ២០៥នាក់ នៅក្នុងផ្នែកគ្រប់គ្រងកិច្ចសន្យាទាំង២៤ខេត្ត ក្រុង ដែលក្នុងនោះជាមធ្យម ៨នាក់ ក្នុងមួយខេត្ត ក្រុង ។ បុគ្គលិកផ្នែកនេះសរុប ១២៦នាក់ បានចាត់តាំងឱ្យទទួលខុសត្រូវលើការងារគ្រប់គ្រងកិច្ចសន្យាខេត្ត ក្រុង (ជាមធ្យម៥នាក់ក្នុងមួយខេត្ត ក្រុង) ហើយ៧៩នាក់ទៀតទទួលខុសត្រូវការងារតាមដាន និងវាយតម្លៃ (ជាមធ្យម៣នាក់ក្នុងមួយខេត្ត ក្រុង) ។ ជាមួយនឹងអណ្ណតិរបស់ខ្លួននៅក្រោមយុត្តិការរបស់អភិបាលខេត្ត ក្រុង ដើម្បីគ្រប់គ្រង តាមដាន វាយតម្លៃ និងរាយការណ៍ពីកិច្ចសន្យាខេត្ត ក្រុង ព្រមទាំងការអនុវត្តកម្មវិធី ព្រមទាំងគ្រប់គ្រងលើការផ្តល់សេវាកម្មដល់ គ.ប្រ មន្ត្រីគ្រប់គ្រងកិច្ចសន្យាម្នាក់ទទួលខុសត្រូវគ្រប់គ្រងកិច្ចសន្យាក្នុងខេត្ត ក្រុង៤កិច្ចសន្យា ហើយមន្ត្រីគ្រប់គ្រងកិច្ចសន្យាម្នាក់ទទួលខុសត្រូវគ្រប់គ្រងថវិកាដែលបានបែងចែកឱ្យខេត្ត ក្រុងចំនួន១០០.០០០ ដុល្លា។ ប្រមាណជា ៦០%នៃមន្ត្រីក្រោមឱវាទផ្នែក គឺជាបុគ្គលិកមកពីក្រសួងផែនការ ហើយមន្ត្រីផ្សេងទៀតមកពីបណ្តាមន្ទីរជំនាញនានាជុំវិញខេត្ត ក្រុង ។ ២៥% នៃបុគ្គលិកផ្នែកគ្រប់គ្រងកិច្ចសន្យាសរុប គឺជាស្ត្រី ។

**ផ្នែកហិរញ្ញវត្ថុ** : បុគ្គលិកនៃផ្នែកហិរញ្ញវត្ថុសរុបមានចំនួន ២៧៣ នាក់ កំពុងបម្រើការងារនៅក្នុងផ្នែកហិរញ្ញវត្ថុទាំង២៤ខេត្ត ក្រុង ។ ផ្នែកនេះមានភារកិច្ចសំខាន់ៗចំនួនពីរដែលត្រូវផ្តល់ :

១). សេវាកម្មគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព និងការកសាងសមត្ថភាពដល់គ្រប់ធនធានទាំងអស់ដែលផ្ទេរតាមរយៈគណនីខេត្ត ក្រុងនៅក្នុងធនាគារពាណិជ្ជកម្ម ប្រតិបត្តិដោយមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅក្រោមអំណាចគ្រប់គ្រងដោយអភិបាលខេត្ត ក្រុង ក្នុងការផ្តល់ការគាំទ្រដល់អនុវត្តវិនិយោគ និងកម្មវិធីខេត្ត ក្រុង ។

២). បំពេញមុខងារពាក់ព័ន្ធនឹងការងារគណនេយ្យ ការទូទាត់ចំណាយ ការកសាងសមត្ថភាព និងរៀបចំរបាយការណ៍ហិរញ្ញវត្ថុ សម្រាប់ធនធានថវិកាឃុំ សង្កាត់ ដែលផ្ទេរតាមរយៈគណនីឃុំ សង្កាត់នៅក្នុងរតនាគារខេត្ត ក្រុង ។

ក្នុងចំណោមបុគ្គលិកទាំងអស់នៅក្រោមផ្នែកហិរញ្ញវត្ថុ មានបុគ្គលិក១០៥ នាក់ ទទួលខុសត្រូវលើការគ្រប់គ្រងហិរញ្ញវត្ថុនៃថវិកាបែងចែកសម្រាប់ខេត្ត ក្រុង ហើយ ១៦៨ នាក់ទៀត បំពេញការងារនៅក្រោមរតនាគារ ទាក់ទងទៅនឹងធនធានរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងគណនេយ្យ ។ មន្ត្រីផ្នែកហិរញ្ញវត្ថុប្រមាណ៩០% គឺជាមន្ត្រីមកពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលក្នុងនោះ ២៨%គឺជាស្ត្រី ។ នៅក្នុងឆ្នាំ២០០៨នេះ ជាមធ្យម មន្ត្រីផ្នែកហិរញ្ញវត្ថុម្នាក់គ្រប់គ្រងថវិកាចំនួន ២១០.០០០ ដុល្លារ ។

**ផ្នែកគាំទ្របច្ចេកទេស** : ផ្នែកនេះមានបុគ្គលិកសរុប ២៩១នាក់ នៅទូទាំង ២៤ ខេត្ត ក្រុង ដែលមានអាណត្តិផ្តល់សេវាកម្មបច្ចេកទេសដល់ក្រុមប្រឹក្សាឃុំ សង្កាត់ លើការរៀបចំប្លង់បច្ចេកទេសគម្រោង កិច្ចលទ្ធកម្ម ការអនុវត្តការពិនិត្យបញ្ជាក់ និងការថែទាំ ការកសាងសមត្ថភាព ការតាមដាន និងការរៀបចំរបាយការណ៍លើកិច្ចសន្យាវិនិយោគគម្រោងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ។ ជាមធ្យមមន្ត្រីគាំទ្របច្ចេកទេសម្នាក់គ្រប់គ្រងកិច្ចសន្យាឃុំ សង្កាត់ចំនួន ១៤ កិច្ចសន្យា ដែលមានថវិកាសរុបចំនួន ១១០.០០០ដុល្លា ។ មន្ត្រីផ្នែកគាំទ្របច្ចេកទេសប្រមាណ៧០% គឺជាមន្ត្រី

មកពីក្រសួងអភិវឌ្ឍន៍ជនបទ ។ ដោយសារតែវិស្វករជាស្ត្រីមានចំនួនតិចនៅក្នុងប្រទេសកម្ពុជា ចំនួនស្ត្រីនៅក្នុងផ្នែកគាំទ្របច្ចេកទេសមានតែ ៦% តែប៉ុណ្ណោះ ។

**សមាជិកអចិន្ត្រៃយ៍ និងសវនករផ្ទៃក្នុង :** នៅក្នុងខេត្ត ក្រុងនីមួយៗ មន្ត្រីជាន់ខ្ពស់ខេត្ត ក្រុងម្នាក់បានតែងតាំងដោយអភិបាលខេត្ត ក្រុង ជាសមាជិកអចិន្ត្រៃយ៍នៃគ.ប្រ ដើម្បីជួយដល់ការសម្របសម្រួល និងការគ្រប់គ្រងកម្មវិធីទូទៅនៃមុខងាររបស់គ.ប្រ ។ ក្នុងចំនោមសមាជិកអចិន្ត្រៃយ៍ទាំង២៤ មានតែម្នាក់ប៉ុណ្ណោះជាស្ត្រី ។ លើសពីនេះទៀត មន្ត្រីខេត្ត ក្រុងម្នាក់ផ្សេងទៀតក៏ត្រូវបានតែងតាំងជាសវនករផ្ទៃក្នុង ដើម្បីតាមដាន ស្រាវជ្រាវ និងរាយការណ៍ជូនអភិបាលខេត្ត ក្រុងលើបញ្ហាគណនេយ្យភាព ។ ចាប់តាំងពីពាក់កណ្តាលឆ្នាំ២០០៥មក សវនករផ្ទៃក្នុងក៏បានបំពេញតួនាទីជាលេខាធិការឱ្យក្រុមការងារគណនេយ្យភាពខេត្ត ក្រុងផងដែរ ។ ក្នុងចំនោមមន្ត្រីសវនករទាំង២៤ មានស្ត្រីតែ ០៤ នាក់ប៉ុណ្ណោះ ។

## ៧.៦ សេវាកម្មក្រសួង ស្ថាប័នថ្នាក់ជាតិ

ក្រសួង និងស្ថាប័ននានានៅថ្នាក់ជាតិ មានតួនាទីនៅក្នុងការបន្តការរៀបចំ និងកែលម្អក្របខ័ណ្ឌបទបញ្ញត្តិវិមជ្ឈការ ការរៀបចំ និងមើលការខុសត្រូវលើកម្មវិធីបណ្តុះបណ្តាលជាតិ ដើម្បីកសាងសមត្ថភាពនៅគ្រប់កម្រិតតាមដាន និងវាយតម្លៃការប្រព្រឹត្តទៅ និងការគ្រប់គ្រងអាជ្ញាធរថ្នាក់ក្រោមជាតិ គ្រប់គ្រងការអនុវត្តគម្រោងជាក់លាក់មួយចំនួននៅក្រោមក្របខ័ណ្ឌវិមជ្ឈការ និងវិសហមជ្ឈការ ព្រមទាំងរៀបចំបង្កើត និងអនុវត្តន៍សាកល្បងនូវយុទ្ធសាស្ត្រថ្មីៗនៅក្នុងក្របខ័ណ្ឌវិមជ្ឈការ និងវិសហមជ្ឈការ មានសារៈសំខាន់បំផុតនៅក្នុងដំណើរការកំណែទម្រង់របស់រាជរដ្ឋាភិបាល ។ នៅក្នុងឆ្នាំ២០០៨នេះ ថវិកាសរុបចំនួន ៤.៧លាន ដុល្លារ បានធ្វើការបែងចែកទៅដល់ក្រសួង និងស្ថាប័នថ្នាក់ជាតិចំនួន ១២ នៅក្រោមគម្រោងការនានា គាំទ្រទៅដល់ការអនុវត្តក្របខ័ណ្ឌផែនការសកម្មភាព និងថវិកា គ.ជ.វ.វ ។

### ៧.៦.១ ការបែងចែកថវិកាដល់អនុគណៈកម្មាធិការ គ.ជ.វ.វ

នៅក្រោមគម្រោង PSDD ថវិកាសរុបចំនួន២០០,០០០ដុល្លារ បានបែងចែកទៅដល់អនុគណៈកម្មាធិការ គ.ជ.វ.វ ទាំងប្រាំ ដូចដែលបានបង្ហាញនៅក្នុងតារាងទី ៣៣ ខាងក្រោម ។ ថវិកានេះបានគ្រោងដោយក្រសួង ដែលដឹកនាំអនុគណៈកម្មាធិការនិមួយៗ ដែលមានតួនាទីទទួលខុសត្រូវក្នុងការអនុវត្តភារៈកិច្ចទៅតាមអាណត្តិជាក់លាក់របស់ខ្លួនទៅតាមការបង្កើតឡើងនូវអនុគណៈកម្មាធិការ គ.ជ.វ.វពាក់ព័ន្ធ ។

**តារាងទី៣៣ ៖ ការទិតាដន័មូលនិធិសម្រាប់អនុគណៈកម្មការនៃ គ.ជ.ថ.ថ ឆ្នាំ២០០៨**

| អនុគណៈកម្មការរបស់ គ.ជ.វ.វ | ចំនួន |
|---|---|
| អនុគណៈកម្មការមុខងារ និងស្ថាប័ន | 100,000 |
| អនុគណៈកម្មការសារពើពន្ធ និងហិរញ្ញវត្ថុ | 30,000 |
| អនុគណៈកម្មការផែនការ | 35,000 |
| អនុគណៈកម្មការគ្រប់គ្រងអភិវឌ្ឍន៍ធនធានមនុស្ស | 25,000 |
| អនុគណៈកម្មការនត្យូបនីយកម្ម និងព្រំប្រទល់ | 10,000 |
| សរុប | **$200,000** |

## ៧.៦.២ ការបែងចែកថវិកាដល់ក្រសួង/ស្ថាប័ន

ដូចដែលបានបង្ហាញនៅក្នុងតារាងទី ៣៤ ខាងក្រោម គម្រោងចំនួនបួនបានទទួលការបែងចែកថវិកា ដែលមានចំនួនសរុប១,៦លានដុល្លា ទៅដល់ក្រសួង/ស្ថាប័នពាក់ព័ន្ធ ដើម្បីគាំទ្រដល់ការអនុវត្តសកម្មភាពជាក់លាក់នានាស្របទៅតាមអណ្ណត្តិរបស់ខ្លួន ហើយដែលទាក់ទងទៅនឹងការរៀបចំប្រព័ន្ធគោលនយោបាយ និងការផ្តួចផ្តើមវិស័យនានា ការកសាងសមត្ថភាព និងការគ្រប់គ្រង/តាមដានដោយថ្នាក់ជាតិ ។

**តារាងទី៣៤ ៖ ការទិតាដន័មូលនិធិសម្រាប់បណ្តាក្រសួង/ស្ថាប័ន**

| ក្រសួង/ស្ថាប័ន | PSDD | UNICEF | UNFPA | UNCDF | សរុប |
|---|---|---|---|---|---|
| មហាផ្ទៃ | 75,000 | 60,000 | 32,464 | | 167,464 |
| សេដ្ឋកិច្ច និងហិរញ្ញវត្ថុ | 10,000 | | | 87,000 | 97,000 |
| ផែនការ | 35,000 | 20,000 | | | 55,000 |
| អភិវឌ្ឍន៍ជនបទ | 50,000 | 1,070,000 | | | 1,120,000 |
| កិច្ចការនារី | 50,000 | 40,000 | | | 90,000 |
| ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល | 25,000 | | | | 25,000 |
| កសិកម្ម | 20,000 | | | | 20,000 |
| សង្គមកិច្ច | 20,000 | | | | 20,000 |
| អាជ្ញាធរសវនកម្មជាតិ | 15,000 | | | | 15,000 |
| សរុបរួម | **300,000** | **1,190,000** | **32,464** | **87,000** | **$1,609,464** |

ដោយឡែកធនធានថវិកាពី PSDD និងUNICEF ការបែងចែកថវិកាប្រចាំឆ្នាំទៅដល់ក្រសួងស្ថាប័នចំនួន ៩ ត្រូវបានធ្វើការពិភាក្សាចរចារវាងក្រុមដឹកនាំការងារកម្មវិធី គ.ជ.វ.វ នាខែមករា ២០០៨ ហើយបានក៏បានប្រែ

ក្លាយលទ្ធផលនៃការចរចារនេះទៅជាផែនការសកម្មភាព និងថវិការបស់ក្រសួងនិមួយៗ ។ ការបែងចែកថវិកានេះផ្អែកជាសំខាន់ទៅលើតួនាទី និងមុខងារ ដែលនឹងអនុវត្តដោយក្រសួងពាក់ព័ន្ធស្នូលទៅនឹងកំណែទម្រង់កម្មវិធីឱកាសនានា ព្រមទាំងការអនុវត្តកន្លងមក និងការប៉ាន់ប្រមាណតម្លៃលើសកម្មភាពទាំងឡាយដែលត្រូវធ្វើ ។ នៅក្នុងឆ្នាំ២០០៨នេះ UNICEF បានបែងចែកថវិកាដល់ក្រសួងមហាផ្ទៃ ផែនការ និងកិច្ចការនារីសម្រាប់គាំទ្រសកម្មភាពនានាទាក់ទងទៅនឹងការពង្រឹងការអភិវឌ្ឍន៍សង្គម នៅក្រោមក្របខណ្ឌបទបញ្ញត្តិវិមជ្ឈការ ។ បន្ថែមលើនេះទៀត UNICEF ក៏បានបែងចែកថវិកាមួយភាគធំទៅដល់ក្រសួងអភិវឌ្ឍន៍ជនបទ សម្រាប់គាំទ្រសកម្មភាពនានាទាក់ទងទៅនឹងទឹកស្អាត និងអនាម័យជនបទ និងយុទ្ធនាការអាសេនិកផងដែរ ។

UNFPA ក៏បានបែងចែកថវិកាទៅដល់ក្រសួងមហាផ្ទៃ នាយកដ្ឋានរដ្ឋបាលមូលដ្ឋានផងដែរ សម្រាប់ការតាមដាន និងចាត់ចែងមើលការខុសត្រូវ ការបណ្តុះបណ្តាល និងគ្រប់គ្រងលើអន្តរាគមន៍នានាគាំទ្រដោយ UNFPA នៅថ្នាក់ក្រោមជាតិ ទាក់ទងទៅនឹងវិស័យប្រជាសាស្ត្រ ។ UNFPAបានបែងចែកថវិកាទៅដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់គាំទ្រដល់សកម្មភាពនានាទាក់ទងទៅនឹងវិមជ្ឈការសារពើពន្ធផងដែរ ។

## ៧.៦.៣ ការវិភាជន៍ឱ្យអង្គភាពគាំទ្រកម្មវិធីរបស់ក្រសួង ស្ថាប័ន

គម្រោងចំនួន ៩ បានវិភាជន៍ថវិកាសរុបចំនួន ៣.៩ លានដុល្លារឱ្យដល់ក្រសួង ស្ថាប័ន ដែលទទួលខុសត្រូវក្នុងការអនុវត្តគម្រោង ឬសមាភាគជាក់លាក់នានា ។

**តារាងទី៣៥ : ការវិភាជន៍មូលនិធិឆ្នាំ២០០៨ សម្រាប់ផ្នែកគាំទ្រគម្រោងនៅបណ្តាក្រសួង**

| ក្រសួង/ស្ថាប័ន | ADB | | EC-UNDP | MDLF | JICA | IFAD | | CANADA | សរុប |
|---|---|---|---|---|---|---|---|---|---|
| | CCDP2 | TSSL | DDLG | NRML | PILAC | RPRP | RULIP | ADMAC | |
| មហាផ្ទៃ | 1,004,800 | 486,000 | 387,910 | | 500,000 | | | | 2,378,710 |
| សេដ្ឋកិច្ច-ហិរញ្ញវត្ថុ/រតនាគារ | | | | | | 13,940 | 9,140 | | 23,080 |
| កិច្ចការនារី | | | | | | 38,400 | 20,240 | | 58,640 |
| ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល | | | | | | | | | 0 |
| កសិកម្ម | | | | | | 98,518 | 200,800 | 23,096 | 322,414 |
| ដែនដី | | | | 690,000 | | | | | 690,000 |
| អាជ្ញាធរដោះមីនកម្ពុជា | | | | | | | | 5,000 | 5,000 |
| **សរុបរួម** | **1,004,800** | **486,000** | **387,910** | **690,000** | **500,000** | **150,858** | **230,180** | **28,096** | **$3,477,844** |

នៅក្នុងគម្រោងដែលទទួលបានហិរញ្ញប្បទានពី ADB តាមរយៈគម្រោង CCDP ២ និង គម្រោង TSSL បានរៀបចំជាកម្មវិធីដើម្បីគាំទ្រដល់អង្គភាពគាំទ្រគម្រោងចំនួន ២ នៅក្នុងក្រសួងមហាផ្ទៃ ដែលជាអ្នកទទួលខុសត្រូវក្នុងការប្រតិបត្តិគម្រោង ។ នៅក្នុងគម្រោង CCDP ២ ការផ្តល់ហិរញ្ញប្បទានរួមមាន ការតាមដានត្រួតពិនិត្យ និងមុខងារគ្រប់គ្រងទូទៅលើការសាងសង់ការិយាល័យសាលាឃុំ សង្កាត់ ការធ្វើយុទ្ធនាការផ្សព្វផ្សាយព័ត៌មាននៅថ្នាក់ជាតិ ការផ្តល់ឧបករណ៍នានា ដើម្បីរៀបចំបញ្ចូលក្នុងប្រព័ន្ធកុំព្យូទ័រនៃការចុះបញ្ជីអត្រានុកូលដ្ឋាន និងចូលរួមបដិភាគ

មួយផ្នែកជាមួយផែនការកសាងបណ្តុះបណ្តាលឆ្នាំ២០០៨ របស់ គ.ជ.វ.វ ។ នៅក្នុងគម្រោង TSSL ការផ្តល់ហិរញ្ញប្បទាន រួមបញ្ចូលការផ្តល់រថយន្ត និងឧបករណ៍នានា ការតាមដានត្រួតពិនិត្យ និងការគ្រប់គ្រងគម្រោង TSSL និង សកម្មភាពសម្របសម្រួលនានារបស់គម្រោង ។

នៅក្នុងកម្មវិធី NRML, ពហុដៃគូអភិវឌ្ឍន៍ MDLF បានវិភាជន៍មូលនិធិឱ្យដល់ក្រសួងរៀបចំដែនដី នគរូប នីយកម្ម និងសំណង់ ដែលជាអ្នកទទួលខុសត្រូវក្នុងការប្រតិបត្តិសមាសភាគការគ្រប់គ្រងដីធ្លីនៃកម្មវិធី NRML ។ ថវិកាទាំងអស់នេះ ត្រូវបានការវិភាជន៍សម្រាប់ប្រាក់លើកទឹកចិត្តដល់មន្ត្រីបំពេញការងារ កិច្ចលទ្ធកម្ម ការរៀបចំ សិក្ខាសាលា និងការបណ្តុះបណ្តាល និងថ្លៃប្រតិបត្តិការនានា ដែលពាក់ព័ន្ធនឹងការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន ការបង្កើតទំនាក់ទំនងឱ្យគ្នានៃគោលនយោបាយវិស័យ និងអន្តរវិស័យអំពីការគ្រប់គ្រងដីធ្លី ការរៀបចំក្របខ័ណ្ឌនៃ បទបញ្ញត្តិ និងច្បាប់សម្រាប់ការកសាងផែនការប្រើប្រាស់ដីធ្លី និងការគ្រប់គ្រងដីធ្លី ការផ្តល់កម្មសិទ្ធិដីធ្លីជាដុំ និងការ រៀបចំសេចក្តីណែនាំស្តីពីការគ្រប់គ្រងធនធានធម្មជាតិ ការរៀបចំឧបការណ៍នានា និងគំរូនៃការផ្តល់សេវាកម្ម ។

នៅក្នុងគម្រោង PILAC គាំទ្រដោយ JICA ជប៉ុន ក្នុងកិច្ចព្រមព្រៀងជាមួយក្រសួងមហាផ្ទៃមានទឹកប្រាក់ ប្រហែលជា ៥០០.០០០ ដុល្លារត្រូវបានរៀបចំជាកម្មវិធីដើម្បីផ្តល់ហិរញ្ញប្បទានដល់សកម្មភាពទាំងឡាយ ដែលពាក់ ព័ន្ធនឹងកម្មវិធីបណ្តុះបណ្តាលផ្សេងៗស្តីពី រដ្ឋបាលមូលដ្ឋានក៏ដូចជា ការធ្វើទស្សនកិច្ចសិក្សាទៅប្រទេសជប៉ុន ។

គម្រោង DDLG ដែលគាំទ្រដោយ EC/UNDP បានរៀបចំជាកម្មវិធីដើម្បីគាំទ្រអង្គភាពគាំទ្រគម្រោង នៅក្នុងក្រសួងមហាផ្ទៃ ដែលទទួលខុសត្រូវក្នុងការប្រតិបត្តិគម្រោង ដែលការគាំទ្រនេះរួមមាន កិច្ចលទ្ធនៃឧបករណ៍ នានា សកម្មភាពបណ្តុះបណ្តាលផ្សេងៗ និងការគាំទ្រដល់សម្ព័ន្ធភាព និងសមាគមក្រុមប្រឹក្សាឃុំ សង្កាត់នៅថ្នាក់ជាតិ និងថ្នាក់ខេត្ត ក្រុង ការតាមដានត្រួតពិនិត្យ ការគ្រប់គ្រងការអនុវត្តគម្រោង និងសកម្មភាពសម្របសម្រួលនានានៅ ថ្នាក់ជាតិ ។

គម្រោង RPRP និងគម្រោង RULIP ដែលគាំទ្រដោយ IFAD និងរដ្ឋាភិបាលកាណាដា បានគាំទ្រអង្គភាព គាំទ្រកម្មវិធីរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលជាអ្នកទទួលខុសត្រូវក្នុងការប្រតិបត្តិគម្រោងទាំងពីរ នេះ ក៏ដូចជាគម្រោង ADMAC ។ ថវិកាដែលគាំទ្រដោយគម្រោងទាំងនេះ រួមបញ្ចូលប្រាក់លើកទឹកចិត្តបុគ្គលិក កិច្ចលទ្ធកម្ម ថ្លៃប្រតិបត្តិការនានា ការរៀបចំសិក្ខាសាលា និងកិច្ចប្រជុំ ដែលពាក់ព័ន្ធនឹងបញ្ហាសម្របសម្រួលគម្រោង និងការងារបច្ចេកទេស ។ លើសពីនេះទៀត IFAD បានធ្វើការវិភាជន៍ឱ្យដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង កិច្ចការនារី ហើយកាណាដាបានវិភាជន៍ឱ្យអាជ្ញាធរសកម្មភាពមីននៅកម្ពុជា សម្រាប់សកម្មភាពប្រតិបត្តិការនានា ដែលពាក់ព័ន្ធនឹងការបំពេញមុខងាររបស់ដៃគូនៃគម្រោងនីមួយៗ ។

នៅទំព័របន្ទាប់ តារាងទី ៣៥ : សេវាកម្មគាំទ្រក្រសួងថ្នាក់ជាតិឆ្នាំ ២០០៨ ឆ្លុះបញ្ចាំងបីថវិកាវិភាជន៍ និង ការសង្ខេបអំពីសកម្មភាពសំខាន់ៗដែលរំពឹងថានឹងអនុវត្តនៅក្នុងឆ្នាំ២០០៨ ដោយក្រសួង ស្ថាប័នថ្នាក់ជាតិចំនួន ១៤ ។

## តារាងទី៣៦ ៖ សេវាកម្មនានាគាំទ្រដល់ក្រសួងថ្នាក់ជាតិឆ្នាំ២០០៨

| ល.រ | ក្រសួង/ស្ថាប័ន | សង្ខេបសកម្មភាព | ថវិកាឆ្នាំ២០០៨ |
|---|---|---|---|
| 1 | មហាផ្ទៃ | **1.1. Japan-JICA/PILAC:** ការសិក្សាវាយតម្លៃ ការរៀបចំគ្រោងការ និងការអនុវត្ត ការកសាងសមត្ថភាពអំពីរដ្ឋបាលមូលដ្ឋាន ។ | 500,000 |
| | | **1.2. ADB/TSSL:** ផ្នែកគាំទ្រគម្រោងគាំទ្រដល់ការប្រតិបត្តិមូលនិធិសម្រាប់ជីវភាពរស់នៅនៅឃុំ លទ្ធកម្មសម្ភារៈបរិក្ខារ ការបណ្តុះបណ្តាល/ការត្រួតពិនិត្យរចនាសម្ព័ន្ធគ្រប់គ្រងថ្នាក់ក្រោមជាតិ ការតាមដានត្រួតពិនិត្យ ។ | 486,000 |
| | | **1.3. ADB/CCDP:** ផ្នែកគាំទ្រគម្រោងគាំទ្រដល់ការតាមដានត្រួតពិនិត្យការសាងសង់សាលាឃុំសង្កាត់ ការបញ្ចូលទៅក្នុងប្រព័ន្ធកុំព្យូទ័រនូវទិន្នន័យអគ្រានុកូលដ្ឋាន សម្ភារៈបរិក្ខារ យុទ្ធនាការផ្សព្វផ្សាយ ការបណ្តុះបណ្តាល ។ | 476,335 |
| | | **1.4. EC-UNDP/DDLG:** ផ្នែកគាំទ្រគម្រោងគាំទ្រដល់សមាគមក្រុមប្រឹក្សាឃុំសង្កាត់ថ្នាក់ជាតិ និងខេត្តក្រុង កិច្ចសហប្រតិបត្តិការអន្តរឃុំសង្កាត់ ការរៀបចំគោលនយោបាយ ការតាមដាន/ការត្រួតពិនិត្យ ។ | 387,910 |
| | | **1.5. PSDD:** គាំទ្រដល់អនុគណៈកម្មការរបស់ គ.ជ.វ.វ អំពីរចនាសម្ព័ន្ធ/មុខងារ និងដល់ក្រសួងមហាផ្ទៃសម្រាប់ការកសាងសមត្ថភាពឃុំ សង្កាត់ ប្រតិបត្តិមូលនិធិឃុំសង្កាត់ មូលដ្ឋានទិន្នន័យថ្នាក់ជាតិ គណនេយ្យភាព តាមដាន/ត្រួតពិនិត្យ ។ | 175,000 |
| | | **1.6. UNICEF/Seth Koma:** គាំទ្រដល់នាយកដ្ឋានរដ្ឋបាលមូលដ្ឋានក្រសួងមហាផ្ទៃដើម្បីបញ្ជ្រាបបញ្ហាស្ត្រី/កុមារនៅថ្នាក់ឃុំ សង្កាត់ ។ | 60,000 |
| | | **1.7. UNFPA:** គាំទ្រដល់នាយកដ្ឋានរដ្ឋបាលមូលដ្ឋានក្រសួងមហាផ្ទៃក្នុងការរៀបចំឯកសារ/បណ្តុះបណ្តាលដល់ក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីបង្កើនការយល់ដឹងអំពីមេរោគអេដស៍/ជំងឺអេដស៍ និងកិច្ចការពារ ។ | 32,464 |
| | | **សរុបរង** | **2,117,709** |
| 2 | ហិរញ្ញវត្ថុ/រតនាគារ | **2.1. UNCDF:** គាំទ្រដល់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសម្រាប់វិមជ្ឈការសារពើពន្ធ សាកល្បងប្រព័ន្ធហិរញ្ញវត្ថុពីរថ្នាក់នៅកម្រិតថ្នាក់ស្រុកខណ្ឌ/ឃុំសង្កាត់ ។ | 87,000 |
| | | **2.2. PSDD:** គាំទ្រដល់អនុគណៈកម្មការរបស់ គ.ជ.វ.វ អំពីកិច្ចការហិរញ្ញវត្ថុ/សារពើពន្ធ ដល់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសម្រាប់ការពង្រឹង/ពិនិត្យលិខិតបទដ្ឋានមូលនិធិ និងដល់រតនាគារជាតិសម្រាប់ត្រួតពិនិត្យទៅលើមូលនិធិឃុំសង្កាត់ ។ | 40,000 |
| | | **2.3. IFAD:** ការរៀបចំ/ការចុះបញ្ជីការគម្រោងនៅថ្នាក់ជាតិអំពីគម្រោង IFAD RPRP និង RULIP ។ | 23,080 |
| | | **សរុបរង** | **150,080** |

| ល.រ | ក្រសួង/ស្ថាប័ន | សង្ខេបសកម្មភាព | ថវិកាឆ្នាំ២០០៨ |
|---|---|---|---|
| 3 | ផែនការ | **3.1. PSDD:** គាំទ្រដល់អនុគណៈកម្មការរបស់ គ.ជ.វ.វ អំពីផែនការ និងក្រសួងសម្រាប់ប្រព័ន្ធព័ត៌មានទិន្នន័យមូលដ្ឋានឃុំ សង្កាត់ ពិនិត្យឡើងវិញនូវប្រព័ន្ធកសាងផែនការ និងការបណ្តុះបណ្តាល/ការត្រួតពិនិត្យមន្ទីរផែនការខេត្ត ក្រុង ។ | 70,000 |
| | | **3.2. UNICEF/Seth Koma:** គាំទ្រដល់ការប្រមូល និងវិភាគទិន្នន័យនៅក្នុងខេត្តគោលដៅសិទ្ធិកុមារ ដែលផ្តោតទៅលើបញ្ហាស្ត្រី/កុមារ ។ | 20,000 |
| | | ***សរុបរង*** | **90,000** |
| 4 | អភិវឌ្ឍន៍ជនបទ | **4.1. UNICEF/Seth Koma:** ទឹកស្អាត/អនាម័យ : គោលនយោបាយ/គោលការណ៍ណែនាំ ការបង្កើតលទ្ធភាពបរិស្ថាន ការអង្កេត/ការបន្ធូរបន្ថយជាតិអាសេនិក និងការសម្របសម្រួលផ្តោតទៅលើសេវាកម្ម ។ | 1,062,508 |
| | | **4.2. PSDD:** ការបណ្តុះបណ្តាលស្តីពីការអនុវត្តគោលការណ៍ណែនាំ រៀបចំគំនូសប្លង់ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន និងការពិនិត្យ/វាយតម្លៃទៅលើការថែទាំ សវនកម្មបច្ចេកទេស ការត្រួតពិពិនិត្យពីថ្នាក់ជាតិ ។ | 50,000 |
| | | ***សរុបរង*** | **1,112,508** |
| 5 | ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល | **5.1. PSDD:** ការរៀបចំមេរៀនបទពិសោធគោលនយោបាយអំពីការផ្តល់សេវាកម្មសាធារណៈ ការចុះកិច្ចសន្យា និងប្រព័ន្ធផ្តល់ប្រាក់ឧបត្ថម្ភតាមលទ្ធផលការងារនៅកម្រិតខេត្ត ក្រុង ។ | **25,000** |
| 6 | កិច្ចការ នារី | **6.1. IFAD:** គាំទ្រដល់ការបញ្ជ្រាបយេនឌ័រនៅក្នុងការអភិវឌ្ឍកសិកម្មនៅគម្រោង IFAD RPRP និង RULIP ។ | 58,640 |
| | | **6.2. PSDD:** ការបញ្ជ្រាបយេនឌ័រនៅថ្នាក់ខេត្តក្រុង និងឃុំសង្កាត់ ការបណ្តុះបណ្តាល/ការសម្របសម្រួលសម្រាប់ការអនុវត្តក្របខ័ណ្ឌការងារតាមដានយេនឌ័រ គាំទ្រដល់គណៈកម្មាធិការទទួលកិច្ចការនារីនិងកុមារ និងការត្រួតពិនិត្យពីថ្នាក់ជាតិ ។ | 50,000 |
| | | **6.3. UNICEF/Seth Koma:** ការពង្រឹងការអភិវឌ្ឍផ្អែកសង្គមនៅមូលដ្ឋាន ដោយផ្តោតទៅលើបញ្ហាស្ត្រី និងកុមារ ។ | 40,000 |
| | | ***សរុបរង*** | **148,640** |

| ល.រ | ក្រសួង/ស្ថាប័ន | សង្ខេបសកម្មភាព | ថវិកាឆ្នាំ២០០៨ |
|---|---|---|---|
| 7 | កសិកម្ម | **7.1. IFAD/RULIP:** គាំទ្រដល់ផ្នែកគាំទ្រគម្រោងនៅក្រសួងកសិកម្ម សម្រាប់រៀបចំកម្មវិធី លទ្ធកម្ម ការគ្រប់គ្រងហិរញ្ញវត្ថុ ការតាមដាន ការប្រឹក្សាយោបល់ ការរៀបចំរបាយការណ៍ និងការសម្របសម្រួលបច្ចេកទេសគម្រោង RULIP ។ | 200,800 |
| | | **7.2. IFAD/RPRP:** គាំទ្រដល់ផ្នែកគាំទ្រគម្រោងនៅក្រសួងកសិកម្ម សម្រាប់រៀបចំកម្មវិធី លទ្ធកម្ម ការគ្រប់គ្រងហិរញ្ញវត្ថុ ការតាមដាន ការប្រឹក្សាយោបល់ ការរៀបចំរបាយការណ៍ និងការសម្របសម្រួលបច្ចេកទេសគម្រោង RPRP ។ | 98,518 |
| | | **7.3. Canada/ADMAC:** គាំទ្រដល់ផ្នែកគាំទ្រគម្រោងនៅក្រសួងកសិកម្ម សម្រាប់រៀបចំកម្មវិធី លទ្ធកម្ម ការគ្រប់គ្រងហិរញ្ញវត្ថុ ការតាមដាន ការរៀបចំរបាយការណ៍ និង និងការសម្របសម្រួលបច្ចេកទេសមីក្រូឥណទាន សម្រាប់គម្រោង ADMAC ។ | 38,707 |
| | | **7.4. PSDD:** គាំទ្រដល់ក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការរបស់ក្រសួងកសិកម្ម សម្រាប់រៀបចំយុទ្ធសាស្ត្រវិមជ្ឈការ និងវិសហមជ្ឈការកសិកម្ម ផ្អែកលើបទពិសោធដែលបានបង្កើតឡើងនៅក្រោមគម្រោង IFAD និងគម្រោងដទៃទៀត នៅកម្រិតថ្នាក់ក្រោមជាតិ ។ | 20,000 |
| | | **សរុបរង** | **358,025** |
| 8 | ការគ្រប់គ្រងដីធ្លី | **8.1. MDLF:** គោលនយោបាយវិស័យ/ពហុវិស័យទាក់ទងនឹងការគ្រប់គ្រងដីធ្លី ក្របខ័ណ្ឌលិខិតបទដ្ឋាន/ច្បាប់សម្រាប់ការគ្រប់គ្រង និងផែនការប្រើប្រាស់ដីធ្លី ការអភិវឌ្ឍសមត្ថភាពស្ថាប័ន ការចុះបញ្ជីដីធ្លីដាច់ដាក់ៗ សង្គមស៊ីវិលទទួលបានព័ត៌មានអំពីការគ្រប់គ្រងដីធ្លី ។ | 690,000 |
| | | **8.2. PSDD:** គាំទ្រដល់អនុគណៈកម្មការនគរូបនីយកម្មនិងព្រំប្រទល់របស់ គ.ជ.វ.វ សម្រាប់កែសម្រួលព្រំប្រទល់រដ្ឋបាល ដោយភ្ជាប់ជាមួយច្បាប់អង្គការ និងការរៀបចំផ្តួចផ្តើមគោលនយោបាយនគរូបនីយកម្ម ។ | 10,000 |
| | | **សរុបរង** | **700,000** |
| 9 | រដ្ឋលេខាធិការមុខងារសាធារណៈ | **9.1. PSDD:** គាំទ្រដល់អនុគណៈកម្មការគ្រប់គ្រងអភិវឌ្ឍន៍ធនធានមនុស្សរបស់ គ.ជ.វ.វ សម្រាប់ការពិនិត្យ និងរៀបចំគោលនយោបាយបុគ្គលិក ស្ថិតក្រោមក្រុមប្រឹក្សាថ្នាក់ក្រោមជាតិយោងតាមច្បាប់អង្គការ ។ | **25,000** |
| 10 | សង្គមកិច្ច | **10.1. PSDD:** គាំទ្រសម្រាប់ពិនិត្យគោលការណ៍ណែនាំស្តីពីការអភិវឌ្ឍសង្គមដែលបានអនុវត្តសាកល្បងនៅឃុំ សង្កាត់ និងរៀបចំយុទ្ធសាស្ត្រវិមជ្ឈការ និងវិសហមជ្ឈការអនាគត ។ | **20,000** |
| 11 | អាជ្ញាធរសវនកម្មជាតិ | **11.1. PSDD:** គាំទ្រសម្រាប់ការធ្វើសវនកម្មគណនីឃុំ សង្កាត់មួយចំនួន ។ | **15,000** |
| 12 | អាជ្ញាធរដោះមីនកម្ពុជា | **12.1. Canada/ADMAC:** គាំទ្រសម្រាប់ការសម្របសម្រួល/ត្រួតពិនិត្យរបស់ថ្នាក់ជាតិនៃផ្នែកផែនការដោះមីនកម្ពុជា នៅ៦ខេត្ត ។ | **5,000** |
| | | **សរុបរួម** | **$4,766,962** |

## ៧.៧ ការគាំទ្រកម្មវិធីនៅថ្នាក់ជាតិ : លេខាធិការដ្ឋាន គ.ជ.អ.ប និងក្រុមគាំទ្រកម្មវិធី

នៅក្នុងរចនាសម្ព័ន្ធរបស់ គ.ជ.វ.រ ក្រុមគាំទ្រកម្មវិធីត (PST) ត្រូវបានបង្កើតឡើងនៅខែ មករា ឆ្នាំ ២០០៧ មានទីតាំងនៅក្នុងក្រសួងមហាផ្ទៃ ដែលមានអាណត្តិ : ១) គ្រប់គ្រងការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ គ.ជ.វ.រ និង ២) បំពេញតួនាទីជាទីភ្នាក់ងារទីប្រតិបត្តិនៃគម្រោងជាក់លាក់ទាំងឡាយដែលបានចុះហត្ថលេខា ជាមួយ គ.ជ.វ.រ ។ នៅក្នុងឆ្នាំ ២០០៨ មានគម្រោងជាច្រើនដែលស្ថិតក្រោមការទទួលខុសត្រូវរបស់ PST រួមមានគម្រោង UNDP/DfID/Sida PSDD, គម្រោង RILG គាំទ្រដោយធនាគារពិភពលោក គម្រោងការិយាល័យច្រកចេញចូលតែមួយ DfGG/OWSO និងគម្រោងបែងចែងដីធ្លីសម្រាប់អភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច LASED, សមាសភាគ វិមជ្ឈការ និងវិសហមជ្ឈការគាំទ្រដោយកម្មវិធី NRML Danida/DfID និងគម្រោងនវានុវត្តន៍ដើម្បីវិមជ្ឈការ និងកិច្ចអភិវឌ្ឍន៍មូលដ្ឋាន IDLD គាំទ្រដោយ UNCDF ដែលថវិកាសរុបទាំងអស់នៃគម្រោងទាំងនេះមានចំនួន ៣០ លានដុល្លារ ឬស្មើនឹង ៥០% នៃជំនួយសរុបពីខាងក្រៅដល់ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ គ.ជ.វ.រ ។ មួយភាគធំនៃជំនួយបច្ចេកទេស និងការគាំទ្រថវិកានៅថ្នាក់ក្រោមជាតិ គឺគ្រប់គ្រងដោយក្រុមគាំទ្រកម្មវិធី ដូច្នេះទំនាក់ទំនងនានានៃគម្រោងទាំងអស់ ដែលគាំទ្រដោយដៃគូអភិវឌ្ឍន៍នានានៅក្នុងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ ២០០៨របស់ គ.ជ.វ.រ គឺពឹងផ្អែកដោយផ្ទាល់ និងដោយប្រយោលលើការគាំទ្រទាំងអស់នេះ ។

ដូចមានបង្ហាញនៅក្នុងដ្យាក្រាមខាងក្រោម ក្រុមគាំទ្រកម្មវិធីរបស់ គ.ជ.វ.រ បានបង្កើតជាផ្នែកចំនួន ៤ សម្រាប់ការងារគ្រប់គ្រង : ផ្នែកហិរញ្ញវត្ថុ ផ្នែកសម្រាបសម្រួលគម្រោង/រដ្ឋបាលកិច្ចសន្យា ផ្នែកត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មាន និងផ្នែករដ្ឋបាល ។

ក្នុងគោលបំណងនៃការសម្រាបសម្រួល និងប្រតិបត្តិផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ គ.ជ.វ.រ ក្រុមគាំទ្រកម្មវិធីជាអ្នករក្សាទំនាក់ទំនងយ៉ាងជិតស្និទជាមួយអភិបាលខេត្ត ក្រុង គ.អ.ជ.ខ ខេត្ត ក្រុង និង គ.ប្រ នៅក្នុងខេត្ត ក្រុងទាំង ២៤ ។

**ក្រុមគាំទ្រកម្មវិធីរបស់ គ.ជ.អ.ប**



នៅក្នុងអាណត្តិរបស់ គ.ជ.វ.វ ក្រុមគាំទ្រកម្មវិធីមិនមែនជាអ្នកអនុវត្តសកម្មភាព ដែលពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នឡើយ ប៉ុន្តែក្រុមគាំទ្រកម្មវិធីផ្តល់ជាវេទិកាសម្រាប់ការពិភាក្សា និងសម្របសម្រួលអន្តរក្រសួង ដែលទាក់ទងសកម្មភាពទាំងឡាយដែលគាំទ្រថវិកាពីខាងក្រៅ អភិបាលកិច្ច និងកិច្ចអភិវឌ្ឍន៍ និងលើកំពស់ភាពជាដៃគូនៅក្នុងរដ្ឋាភិបាល និងរវាងរដ្ឋាភិបាលជាមួយនឹងដៃគូអភិវឌ្ឍន៍ដែលចូលរួមចំណែកក្នុងការពិភាក្សាអំពីទិសដៅអនាគតនៃកំណែទម្រង់អភិបាលកិច្ចមូលដ្ឋាន ។

